ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការសម្រាប់អនុវត្ត
# ការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី
# តាមបណ្តាខេត្ត និងរាជធានី
# ឆ្នាំ ២០១៥-២០២០

ក្រសួងរ៉ែ និងថាមពល

អាជ្ញាធរអគ្គិសនីកម្ពុជា

និងក្រុមហ៊ុនអគ្គិសនីកម្ពុជា

ខែ កក្កដា ឆ្នាំ ២០១៥

## កំណត់សំគាល់

ផែនការនេះ សិក្សានិងរៀបចំ ដោយក្រុមការងារបច្ចេកទេសរបស់អាជ្ញាធរអគ្គិសនីកម្ពុជា សហការជាមួយក្រុមការងារជំនាញរបស់អគ្គិសនីកម្ពុជា ក្រោមការដឹកនាំរបស់ **ឯកឧត្តម បណ្ឌិត ទី នរិន្ទ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ។

ផែនការនេះ ត្រូវបានពិនិត្យ និងអនុម័តដោយ សិក្ខាសាលាស្តីពី "ការពិនិត្យ និងសម្រេចផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្តាខេត្ត និងរាជធានី" នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ក្រោមអធិបតីភាព និងការដឹកនាំកិច្ចប្រជុំរបស់ **ឯកឧត្តម ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីសំខាន់ៗ របស់ក្រសួងរ៉ែ និងថាមពលចំនួន១៧ នាក់ អាជ្ញាធរអគ្គិសនីកម្ពុជា ចំនួន ២៩ នាក់ អគ្គិសនីកម្ពុជា ចំនួន ១៥ នាក់ តំណាងគណៈអភិបាលគ្រប់រាជធានី/ខេត្តចំនួន ចំនួន ២៥ នាក់ និងតំណាងមន្ទីររ៉ែ និងថាមពលមកពីរាជធានី/ខេត្តទាំង ២៥ ចំនួន៣០ នាក់។

# មាតិកា


| ផ្នែក | ខ្លឹមសារ | ទំព័រ |
|---|---|---|
| **ផ្នែកទី១** | លិខិតរបស់ក្រសួងរ៉ែ និងថាមពល ស្នើសុំរាជរដ្ឋាភិបាលពិនិត្យលើ "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ ២០១៥-២០២០" និងចំណារយល់ព្រមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** | I |
| **ផ្នែកទី២** | ប្រកាសស្តីពីការកំណត់ផែនការយុទ្ធសាស្ត្រ ដើម្បីបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥-២០២០ | VIII |
| **ផ្នែកទី៣** | កំណត់ហេតុស្តីពី ការពិនិត្យ និងសម្រេច "ផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្តាខេត្ត និងរាជធានី" | XIX |
| **ផ្នែកទី៤** | សេចក្តីផ្តើម និងសេចក្តីសន្និដ្ឋានទូទាំងប្រទេស អំពីការអនុវត្តការបន្ថយអត្រានិងគម្លាតថ្លៃលក់តាម ផែនការរបស់រាជរដ្ឋាភិបាល | ១ |
| **ផ្នែកទី៥** | តារាងសង្ខេបលទ្ធផលនៃការសិក្សា ការផ្គត់ផ្គង់ និងផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្តារាជធានី/ខេត្ត ទាំង ២៥ | ១១ |
| **ផ្នែកទី៦** | ការសិក្សាអំពីការអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅតាមបណ្តារាជធានី/ខេត្ត នីមួយៗ | ១៩ |
| • | ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅរាជធានីភ្នំពេញ សម្រាប់ឆ្នាំ ២០១៥-២០២០ | ២០ |
| • | ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកណ្តាល សម្រាប់ឆ្នាំ ២០១៥-២០២០ | ៣០ |
| • | ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ស្ពឺ សម្រាប់ឆ្នាំ ២០១៥-២០២០ | ៣៨ |

- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តតាកែវ សម្រាប់ឆ្នាំ ២០១៥-២០២០ ៤៣
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពត សម្រាប់ឆ្នាំ២០១៥-២០២០ ៥០
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកែប សម្រាប់ឆ្នាំ ២០១៥-២០២០ ៥៧
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តព្រះសីហនុ សម្រាប់ឆ្នាំ ២០១៥-២០២០ ៦១
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ឆ្នាំង សម្រាប់ឆ្នាំ ២០១៥-២០២០ ៦៧
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តពោធិ៍សាត់ សម្រាប់ឆ្នាំ ២០១៥-២០២០ ៧២
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តបាត់ដំបង សម្រាប់ឆ្នាំ ២០១៥-២០២០ ៧៦
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គត់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ ២០១៥-២០២០ ៨២
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តសៀមរាប សម្រាប់ឆ្នាំ ២០១៥-២០២០ ៨៨
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ចាម សម្រាប់ឆ្នាំ ២០១៥-២០២០ ៩៦
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកោះកុង សម្រាប់ឆ្នាំ ២០១៥-២០២០ ១០៤
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តព្រៃវែង សម្រាប់ឆ្នាំ ២០១៥-២០២០ ១១០

- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តត្បូងឃ្មុំ សម្រាប់ឆ្នាំ ២០១៥-២០២០ ១២០
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តស្វាយរៀង សម្រាប់ឆ្នាំ ២០១៥-២០២០ ១២៨
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តក្រចេះ សម្រាប់ឆ្នាំ ២០១៥-២០២០ ១៣៤
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តស្ទឹងត្រែង សម្រាប់ឆ្នាំ ២០១៥-២០២០ ១៤៣
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ធំ សម្រាប់ឆ្នាំ ២០១៥-២០២០ ១៥០
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តរតនគិរី សម្រាប់ឆ្នាំ ២០១៥-២០២០ ១៥៩
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តមណ្ឌលគិរី សម្រាប់ឆ្នាំ ២០១៥-២០២០ ១៦៥
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តព្រះវិហារ សម្រាប់ឆ្នាំ ២០១៥-២០២០ ១៦៩
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តឧត្តរមានជ័យ សម្រាប់ឆ្នាំ ២០១៥-២០២០ ១៧៦
- ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភព អគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តប៉ៃលិន សម្រាប់ឆ្នាំ ២០១៥-២០២០ ១៨២

# លិខិតរបស់ក្រសួងរ៉ែ និងថាមពល ស្នើសុំរាជរដ្ឋាភិបាលពិនិត្យលើ "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥-២០២០"

# និង

# ចំណារយល់ព្រមរបស់សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ១៥៤៨.រថ.លស

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៤

**សូមគោរពជូន**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**ជាទីគោរពដ៏ខ្ពង់ខ្ពស់**

**កម្មវត្ថុ** ៖ សំណើសុំពិនិត្យ និងណែនាំលើ "ផែនការយុទ្ធសាស្ត្រ បន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥-២០២០" ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រោមការដឹកនាំនិងគាំទ្រ ប្រកបដោយទស្សនៈវិស័យជាយុទ្ធសាស្ត្រច្បាស់លាស់របស់**សម្តេច** វិស័យអគ្គិសនីរបស់កម្ពុជាបានរីកចម្រើន និងអភិវឌ្ឍទៅមុខយ៉ាងឆាប់រហ័ស ។ ក្នុងនោះ ចំពោះប្រភពអគ្គិសនី រាជរដ្ឋាភិបាលបានជំរុញការអភិវឌ្ឍប្រភពអគ្គិសនីនានាក្នុងស្រុក រួមជាមួយការនាំចូលប្រភពអគ្គិសនីខ្លះពីប្រទេសជិតខាង ដែលធ្វើឲ្យពីពេលនេះរហូតដល់ឆ្នាំ ២០១៨ កម្ពុជាអាចមានប្រភពអគ្គិសនីគ្រប់គ្រាន់ មិនមានការខ្វះខាតទេ ។ ចំពោះ"បណ្តាញជាតិ" ដែលជាមូលដ្ឋានគ្រឹះនៃការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា រាជរដ្ឋាភិបាលបានជំរុញការអភិវឌ្ឍអនុស្ថានីយ ខ្សែបញ្ជូន និងខ្សែបញ្ជូនរងដែលបច្ចុប្បន្នបានគ្របដណ្តប់ផ្ទាល់លើរាជធានី/ខេត្តចំនួន ១៣ រួចហើយ ព្រមទាំងបានជំរុញការអភិវឌ្ឍខ្សែបញ្ជូនរងខ្លះ បញ្ជូនប្រភពអគ្គិសនីបន្តជាបណ្តោះអាសន្នទៅឲ្យផ្នែកខ្លះនៃខេត្តចំនួន ៤ ទៀត ដែលនៅក្បែរគ្នា ។ ចំពោះការចែកចាយអគ្គិសនីសម្រាប់ការប្រើប្រាស់ធម្មតាវិញ រាជរដ្ឋាភិបាលបានជំរុញការអភិវឌ្ឍត្រង់ស្វូ និងខ្សែបណ្តាញចែកចាយតាមភូមិនានា ដែលបច្ចុប្បន្នបានគ្របដណ្តប់ ៦០.៣២% នៃភូមិទាំងអស់របស់កម្ពុជារួចហើយ ។ ក្នុងគោលដៅ "**ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលមួយគ្រប់គ្រាន់ ប្រកបដោយចីរភាព ស្ថិរភាព គុណភាព និងថ្លៃកាន់តែទាបទូទាំងព្រះរាជាណាចក្រកម្ពុជា**" ដែលជាចក្ខុវិស័យ នៃ វិស័យថាមពលកម្ពុជា សម្រាប់អាណត្តិ ២០១៣-២០១៨ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា បានរួមគ្នាធ្វើការសិក្សា និងរៀបចំ "**ផែនការយុទ្ធសាស្ត្រ បន្ថយអត្រានិងតម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥-២០២០**" ។

បច្ចុប្បន្ន ការសិក្សានិងរៀបចំផែនការយុទ្ធសាស្ត្រនេះបានធ្វើរួចរាល់ហើយ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងក្រុមហ៊ុនអគ្គិសនីកម្ពុជា ដែលជាអ្នកអនុវត្តផែនការនេះផ្ទាល់ ក៏បានធ្វើការពិភាក្សា និងឯកភាពគ្នាលើយុទ្ធសាស្ត្រ និងផែនការសកម្មភាព នៃផែនការនេះ រួចហើយដែរ ។ ដើម្បីឈានទៅដាក់ឲ្យអនុវត្ត



លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

ផែនការយុទ្ធសាស្ត្រនេះ ខ្ញុំបាទសូមគោរពស្នើសុំ **សម្តេចតេជោនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងផ្តល់មតិណែនាំដ៏ខ្ពង់ខ្ពស់ លើចំណុចគោលសំខាន់ៗនៃផែនការ ដូចខាងក្រោម ៖

## ១.ការបន្ថយអត្រាថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា

ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រឹះនៃការផ្គត់ផ្គង់អគ្គិសនីរបស់កម្ពុជា ដែលរាជរដ្ឋាភិបាលបានខិតខំជំរុញច្រើនឆ្នាំកន្លងមកនេះ បានចាប់ផ្តើមផ្តល់ផ្លែផ្កាជាបណ្តើរៗដល់កម្ពុជាហើយ ដោយផ្តល់លទ្ធភាពឲ្យកម្ពុជាអាចផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីធំៗប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម កាន់តែច្រើនតំបន់ទៅ និងអាចបន្ថយអត្រាថ្លៃលក់អគ្គិសនីឲ្យថយចុះ ទាំងការផ្គត់ផ្គង់របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងទាំងការផ្គត់ផ្គង់របស់អ្នកផ្គត់ផ្គង់ឯកជន ឲ្យតែការផ្គត់ផ្គង់នោះបានភ្ជាប់ប្រភពអគ្គិសនី ជាមួយហេដ្ឋារចនាសម្ព័ន្ធគ្រឹះដែលបានអភិវឌ្ឍន៍ខាងលើ គឺ"បណ្តាញជាតិ"។ ក្នុងនោះ ចំពោះការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីធំៗប្រភេទឧស្សាហកម្ម ពាណិជ្ជកម្ម ដែលមានអត្រាថ្លៃលក់ស្មើនឹង ០.២១ ដុល្លាអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង (គវ៉ម) នៅឆ្នាំ ២០១២ បានថយចុះជាបន្តបន្ទាប់មកស្មើនឹង ០.១៨ ដុល្លាអាមេរិក ក្នុង១គវ៉ម នៅឆ្នាំ ២០១៤ នេះ។ ចំពោះការផ្គត់ផ្គង់អគ្គិសនីវាយឲ្យប្រជាពលរដ្ឋតាមភូមិ ដែលពីមុននេះបន្តិចមានថ្លៃខ្ពស់គឺពីជាង ២០០០ រៀល ទៅជាង ៣០០០ រៀល ក្នុង១គវ៉ម ក៏បានថយចុះជាបន្តបន្ទាប់មកក្នុងរង្វង់ ១០៥០ រៀល ទៅ ១១០០ រៀល ក្នុង១គវ៉ម នៅឆ្នាំ ២០១៤ ក្នុងតំបន់ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយ "បណ្តាញជាតិ" ដែរ។ សម្រាប់ឆ្នាំ ២០១៥-២០២០ យើងខ្ញុំស្នើសុំធ្វើការបន្ថយអត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយ "បណ្តាញជាតិ" ជាបន្តទៀត ក្នុងកម្រិតមួយដែលអាច ៖

- រក្សាបាននូវស្ថិរភាព និងនិរន្តរភាព នៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនី ទាំងអាជីវកម្មផ្គត់ផ្គង់អគ្គិសនីរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងទាំងអាជីវកម្មផ្គត់ផ្គង់អគ្គិសនីរបស់អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន
- រក្សាបានការទាក់ទាញការចូលរួមរបស់ផ្នែកឯកជន ក្នុងវិស័យអគ្គិសនីបន្តទៀត និង
- រក្សាបាននូវការអនុវត្តការកំណត់បញ្ជីថ្លៃលក់អគ្គិសនី តាមគោលការណ៍របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងបទប្បញ្ញត្តិ ដែលត្រូវធ្វើយ៉ាងណាឲ្យថ្លៃលក់អគ្គិសនីអាចរំលោះចំណាយផ្គត់ផ្គង់ និងមានចំណេញសមស្របសម្រាប់ការធ្វើអាជីវកម្មអគ្គិសនី។

## ២.ការបន្ថយគម្លាតថ្លៃលក់អគ្គិសនីដែលខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀត

ដោយសារសក្តានុពលនៃអាជីវកម្មអគ្គិសនីនៅតំបន់ផ្គត់ផ្គង់នីមួយៗមិនដូចគ្នា ដូច្នេះ ការថយចុះនៃថ្លៃអគ្គិសនីនៅតំបន់នានា ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយ "បណ្តាញជាតិ" មានល្បឿនមិនដូចគ្នាទេ គឺកន្លែងខ្លះថយចុះខ្លាំង ដូចជារាជធានីភ្នំពេញ និងក្រុងធំៗ ដែលជាតំបន់ផ្គត់ផ្គង់របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា ឯកន្លែងខ្លះទៀតថយចុះតិច ដូចជាតំបន់ជនបទដែលជាតំបន់ផ្គត់ផ្គង់របស់សេវាករអគ្គិសនីឯកជន។ ដូច្នេះ ដើម្បីកុំឲ្យថ្លៃលក់អគ្គិសនីពីតំបន់មួយទៅតំបន់មួយទៀត មានអត្រាខុសគ្នាច្រើនពេក និងដើម្បីជំរុញឲ្យមានសមធម៌រវាងតំបន់ទីក្រុង និងតំបន់ជនបទ យើងខ្ញុំស្នើសុំប្រើយន្តការកំណត់ឲ្យតំបន់ដែលមានថ្លៃថយចុះខ្លាំង ជួយទទួលបន្ទុកថ្លៃខ្លះរបស់តំបន់ដែលមានថ្លៃថយចុះតិច មានន័យថាឲ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាជួយទទួលបន្ទុកថ្លៃខ្លះរបស់អ្នកផ្គត់ផ្គង់អគ្គិសនីឯកជន ប៉ុន្តែរក្សាលទ្ធភាពឲ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាអាចបន្ថយអត្រាថ្លៃលក់របស់ខ្លួនខ្លះ។ តាមយន្តការនេះ យើងខ្ញុំស្នើសុំអនុញ្ញាតឲ្យក្រុមហ៊ុនអគ្គិសនីកម្ពុជាធ្វើការបង្វែរកញ្ចប់ថវិកា ដែលនឹងគ្រោងនៅក្នុងបញ្ជីថ្លៃលក់អគ្គិសនីប្រចាំឆ្នាំ ទៅឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ(ម.អ.ជ)របស់ក្រុមហ៊ុនអគ្គិស-

នីកម្ពុជា ដើម្បី ម.អ.ជ ប្រើប្រាស់សម្រាប់ជួយបន្ថយគម្លាតថ្លៃលក់អគ្គិសនីផង និងសម្រាប់គោលដៅសមធម៌ដ៏ទៃទៀតដែលបានគ្រោងផង ។

ដោយសារថា ដើម្បីអនុវត្តយន្តការខាងលើបាន ចាំបាច់ត្រូវការរៀបចំគោលការណ៍ និងនីតិវិធីនានាឲ្យបានច្បាស់លាស់ ដូច្នេះ ក្រសួងស្នើសុំចាប់ផ្តើមអនុវត្តការបន្ថយគម្លាតថ្លៃលក់អគ្គិសនី ចាប់ពីខែ មិនា ឆ្នាំ ២០១៦ តទៅ ។

ក្នុងការបន្ថយគម្លាតថ្លៃលក់ក្នុងតំបន់ភ្ជាប់ជាមួយ"បណ្តាញជាតិ" យើងខ្ញុំស្នើសុំអនុវត្តដូចខាងក្រោម ៖

- ចំពោះអត្រាថ្លៃលក់អគ្គិសនីចេញពីអនុស្ថានីយ អត្រាថ្លៃលក់ដុំឲ្យអ្នកចែកចាយបន្ត និងអត្រាថ្លៃលក់សម្រាប់អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ដែលប្រើលើតង់ស្យុងមធ្យម ទាំងអគ្គិសនីកម្ពុជា និងទាំងសេវាករអគ្គិសនីឯកជន កំណត់ឲ្យមានការថយចុះផង និងឲ្យមានអត្រាដូចគ្នាទូទាំងប្រទេសផង លើកលែងតែក្នុងប្រព័ន្ធចែកចាយរាជធានីភ្នំពេញ ដែលអនុញ្ញាតឲ្យខុសគ្នាបន្តិច ក្នុង ២-៣ ឆ្នាំដំបូង។
- ចំពោះអត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធម្មតានិងគេហដ្ឋាននៅតំបន់ជនបទ របស់សេវាករឯកជន កំណត់ឲ្យមានការថយចុះជាបន្តបន្ទាប់តាមអត្រាថ្លៃមួយដូចគ្នា សម្រាប់ទូទាំងប្រទេស ប៉ុន្តែអនុញ្ញាតឲ្យមានគម្លាតខុសគ្នាបន្តិច(២០៛/១គីឡូវ៉ាត់ម៉ោង) ជាមួយអត្រាថ្លៃលក់អគ្គិសនីនៅរាជធានីភ្នំពេញ ។
- យន្តការជួយទទួលបន្ទុកថ្លៃខ្លះរបស់អគ្គិសនីកម្ពុជាខាងលើនេះ ស្នើសុំមិនគ្របដណ្តប់លើតំបន់សេដ្ឋកិច្ចពិសេសឬតំបន់ឧស្សាហកម្ម ដែលម្ចាស់តំបន់ធ្វើការផ្គត់ផ្គង់អគ្គិសនីដោយផ្ទាល់ ដោយប្រើរោងចក្រអគ្គិសនីផ្ទាល់ខ្លួនបន្ថែម ពីលើការយកប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជានោះទេ ។

## ៣.លទ្ធផលរំពឹងទុកនៃការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី

តាមការគណនា ប្រសិនបើពុំមានអ្វីប្រែប្រួលធំដុំទេ ការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅតំបន់ទាំងអស់ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយ"បណ្តាញជាតិ" អាចនឹងទទួលបាន ដូចតារាងខាងក្រោម៖

| | ឯកតា | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|
| **ការទិញពីអនុស្ថានីយផ្ទាល់** | | | | | | | |
| ទិញពី ឡានចន្ត MV របស់អនុស្ថានីយ | ដុល្លារ/១គវម៉ | 0.1290 | 0.1260 | 0.1260 | 0.1260 | 0.1260 | 0.1260 |
| **ចំពោះប្រព័ន្ធភ្នំពេញ កណ្តាល របស់ EDC** | | | | | | | |
| ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវម៉ | 0.1770 | 0.1720 | 0.1670 | 0.1650 | 0.1630 | 0.1620 |
| ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ >200kWh/ខែ | រៀល/១គវម៉ | 820 | 780 | 770 | 750 | 740 | 730 |
| ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ 51-200kWh/ខែ | រៀល/១គវម៉ | 720 | 720 | 720 | 720 | 720 | 720 |
| ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ ≤50kWh/m | រៀល/១គវម៉ | 610 | 610 | 610 | 610 | 610 | 610 |
| **ចំពោះបណ្តាតំបន់ទីរួមខេត្តនិងតំបន់ផ្សេងទៀតដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា** | | | | | | | |
| ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវម៉ | 0.1700 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| ថ្លៃលក់ LV ឲ្យអតិថិជនធម្មតានិងគេហដ្ឋាន | រៀល/១គវម៉ | 820-1000 | 780 | 770 | 750 | 740 | 730 |
| **ចំពោះការលក់ដុំចេញពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា** | | | | | | | |
| ថ្លៃលក់ដុំ MV ឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ | ដុល្លារ/១គវម៉ | 0.138-0.153 | 0.1470 | 0.1450 | 0.1440 | 0.1430 | 0.1420 |
| ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវម៉ | 0.1700 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| **ចំពោះការលក់ដុំចេញពីបណ្តាញបញ្ជូនរបស់សេវាករឯកជន** | | | | | | | |
| ថ្លៃលក់ដុំ MV ឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ | ដុល្លារ/១គវម៉ | 0.1510 | 0.1470 | 0.1450 | 0.1440 | 0.1430 | 0.1420 |
| ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវម៉ | 0.1725 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| **ចំពោះតំបន់ផ្គត់ផ្គង់របស់សេវាករឯកជនដែលភ្ជាប់ផ្ទាល់ឬប្រយោលពីបណ្តាញជាតិ** | | | | | | | |
| ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវម៉ | 0.1725 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| ថ្លៃលក់ LV ឲ្យអតិថិជនធម្មតានិងគេហដ្ឋាន | រៀល/១គវម៉ | 1000-1050 | 800 | 790 | 770 | 760 | 750 |

លទ្ធផលនៃការបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីខាងលើនេះ បានបង្ហាញថាអត្រាថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទឧស្សាហកម្ម ពាណិជ្ជកម្មនៅភ្នំពេញ នឹងថយចុះពី ០.១៨១៨ ដុល្លាអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៤ នេះមក ០.១៧២ ដុល្លាអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៦ និងស្មើនឹង ០.១៦៥ដុល្លាអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៨។ ដោយឡែកចំពោះលំនៅដ្ឋានប្រជាពលរដ្ឋនៅតំបន់ជនបទ ដែលតាមស្ថិតិបច្ចុប្បន្ននេះ មានលំនៅដ្ឋានចំនួនជាង ៧៥០,០០០ ខ្នងផ្ទះ កំពុងភ្ជាប់ចរន្តអគ្គិសនីពីបណ្តាញអគ្គិសនីរបស់សេវាករអគ្គិសនីឯកជន ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយ"បណ្តាញជាតិ" អត្រាថ្លៃលក់អគ្គិសនីក៏នឹងថយចុះពី ១០៥០រៀល-១១០០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង បច្ចុប្បន្ន មក ៨០០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៦ និងស្មើនឹង ៧៧០រៀលក្នុង១គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៨។ តួលេខនៃការបន្ថយអត្រាថ្លៃលក់អគ្គិសនីខាងលើ បានបង្ហាញថា អត្រាថ្លៃលក់អគ្គិសនីនៅប្រទេសកម្ពុជា (២០១៦-២០២០) ពិតជានៅខ្ពស់ជាងប្រទេសជិតខាង ប៉ុន្តែគម្លាតថ្លៃនេះជាមួយប្រទេសជិតខាងនឹងមិនច្រើនដូចមុនទេ ដោយសារថ្លៃនៅកម្ពុជាថយចុះច្រើន ឯថ្លៃអគ្គិសនីរបស់ប្រទេសជិតខាងអាចនឹងឡើងថ្លៃខ្លះក្នុងរង្វង់ឆ្នាំខាងលើនេះ។

## ៤.ការពង្រីកលទ្ធភាពបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីឲ្យបានទូទាំងប្រទេស

### ក.យុទ្ធសាស្ត្រ

តាមការសិក្សា និងវិភាគ *លទ្ធភាពបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅកម្ពុជា គឺអាចធ្វើបានតែក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពបណ្តាញជាតិប៉ុណ្ណោះ* ។ ដូច្នេះដើម្បីពង្រីកលទ្ធភាពបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីឲ្យបានទូទាំងប្រទេស រាជរដ្ឋាភិបាលត្រូវជំរុញការពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពនៃបណ្តាញជាតិ ឲ្យគ្របដណ្តប់តំបន់ដែលនៅសល់ឲ្យអស់ដោយ ៖ ទី១.ត្រូវជំរុញការអភិវឌ្ឍន៍បណ្តាញបញ្ជូនតង់ស្យុងខ្ពស់និងអនុស្ថានីយ ទៅខេត្តណាដែលបណ្តាញជាតិមិនទាន់ទៅដល់ ទី២.ត្រូវជំរុញការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ទៅកាន់តំបន់ណាដែលពុំទាន់មានប្រភពអគ្គិសនីពីបណ្តាញជាតិ និងទី៣.ត្រូវជំរុញឲ្យសេវាករឯកជនធ្វើការអភិវឌ្ឍន៍បណ្តាញចែកចាយអគ្គិសនី ទៅគ្របដណ្តប់ភូមិទាំងឡាយ ដែលពុំទាន់មានបណ្តាញចែកចាយ។

### ខ.ដំណោះស្រាយកន្លងមក

ដើម្បី*ពង្រីកលទ្ធភាពបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី* ក្រសួងរ៉ែ និងថាមពលបានធ្វើលិខិតលេខ ០៥១រថ.អថ.របាចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៤ ស្នើសុំ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** សុំឲ្យរាជរដ្ឋាភិបាលជួយដោះស្រាយបញ្ហាទុនសម្រាប់ធ្វើការវិនិយោគពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី តាមគម្រោងយុទ្ធសាស្ត្រខាងលើ។ អនុវត្តតាមចំណាររបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ បានដឹកនាំកិច្ចប្រជុំចង្អៀតនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីដោះស្រាយបញ្ហាទុនដែលបានស្នើសុំនេះ កាលពីថ្ងៃទី ០៩ ខែ តុលា កន្លងទៅ។ បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបង្កើបនូវដំណោះស្រាយមួយចំនួនរួចហើយ ប៉ុន្តែពុំទាន់បានកំណត់ជាផ្លូវការនៅឡើយទេ ដូច្នេះយើងខ្ញុំស្នើសុំ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតឲ្យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ បន្តកិច្ចប្រជុំជួយដោះស្រាយបញ្ហាស្នើសុំទុនខាងលើបន្តទៀត ដើម្បីអាចពង្រីកលទ្ធភាពបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីឲ្យបានទូទាំងប្រទេសនៅឆ្នាំ ២០២០ ឬមុនឆ្នាំនេះ តាមផែនការដែលបានគ្រោង។

## ៥.ការជួយដល់ការប្រើប្រាស់អគ្គិសនីរបស់គ្រួសារក្រីក្រនៅតំបន់ជនបទ

ដើម្បីជួយដល់គ្រួសារក្រីក្រនៅជនបទក្នុងការប្រើប្រាស់អគ្គិសនី យើងខ្ញុំស្នើសុំអនុវត្តដូចខាងក្រោម ៖

- ត្រៀមកញ្ចប់ថវិកានៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ សម្រាប់ឲ្យគ្រួសារក្រីក្រនៅតំបន់ជនបទ អាចខ្ចីដោយឥតមានការប្រាក់ ក្នុងរយៈពេលយូរ សម្រាប់ចំណាយលើការភ្ជាប់ចរន្តអគ្គិសនីដំបូង
- ត្រៀមកញ្ចប់ថវិកានៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ) សម្រាប់ជួយទទួលបន្ទុកបន្ថយអត្រាថ្លៃលក់អគ្គិសនីបន្ថែម ឲ្យគ្រួសារដែលក្រីក្រខ្លាំង (កំណត់និយមន័យគ្រួសារក្រីក្រខ្លាំង គឺគ្រួសារដែលប្រើអគ្គិសនីតិច ឧទាហរណ៍ប្រើមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ដែលបច្ចុប្បន្នអ្នកប្រើប្រាស់អគ្គិសនីត្រឹមកម្រិតនេះ មានចំនួនប្រហែល ៣០% នៃចំនួនគ្រួសារដែលកំពុងភ្ជាប់ចរន្តប្រើប្រាស់អគ្គិសនីនៅតំបន់ជនបទ)
- តាមការគណនាចំណូលចំណាយរបស់អគ្គិសនីកម្ពុជា ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ លទ្ធភាពកញ្ចប់ថវិកាដែលក្រុមហ៊ុនអគ្គិសនីកម្ពុជាមាននៅ ម.អ.ជ អាចទទួលបន្ទុកបន្ថយអត្រាថ្លៃលក់អគ្គិសនីបន្ថែម ឲ្យគ្រួសារក្រីក្រដែលប្រើតិចខាងលើក្នុងរង្វង់ពី ៣០% ទៅ ៤០% បន្ថែមទៀត ពីអត្រាថ្លៃលក់អគ្គិសនីដែលបានបន្ថយជារួមរួចហើយ នៅក្នុងតារាងខាងលើ។ ឧទាហរណ៍ នៅឆ្នាំ ២០១៦ អត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទនឹងត្រូវបានកាត់បន្ថយជារួមនៅត្រឹម ៨០០រៀលក្នុង១គវ៉ម ប្រសិនបើកញ្ចប់ថវិកានៅ ម.អ.ជ អាចទទួលបន្ទុកបន្ថយអត្រាថ្លៃលក់អគ្គិសនី ៤០% បន្ថែម ឲ្យគ្រួសារក្រីក្រ ពេលនោះ គ្រួសារក្រីក្រដែលប្រើអគ្គិសនីតិចត្រឹម ១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ នឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០រៀល ក្នុង១គវ៉ម ប៉ុណ្ណោះ។ តាមឧទាហរណ៍នេះ នៅឆ្នាំ ២០១៧ ដែលអត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទត្រូវបានកាត់បន្ថយ នៅត្រឹម ៧៩០ រៀលក្នុង១គវ៉ម នោះ គ្រួសារក្រីក្រទាំងនោះនឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៧៤ រៀលក្នុង១គវ៉ម ហើយនៅឆ្នាំ ២០១៨ ដែលអត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទត្រូវបានកាត់បន្ថយនៅត្រឹម ៧៧០រៀលក្នុង១គវ៉ម នោះ ដូច្នេះគ្រួសារក្រីក្រទាំងនោះនឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៦២រៀលក្នុង១គវ៉ម ប៉ុណ្ណោះ។

## ៦.ការជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទ

ដោយសារកសិកម្ម គឺជាមុខរបរមូលដ្ឋានរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ និងជាគន្លឹះនៃការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតំបន់ជនបទ ដូច្នេះបន្ថែមពីលើការជួយដល់គ្រួសារក្រីក្រនៅតំបន់ជនបទ យើងខ្ញុំស្នើសុំប្រើប្រាស់កញ្ចប់ថវិកាប្រចាំឆ្នាំ ដែលអគ្គិសនីកម្ពុជាផ្ទេរឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទមួយផ្នែកសម្រាប់អន្តរាគមន៍ជួយកាត់បន្ថយថ្លៃលក់អគ្គិសនី ដែលប្រើសម្រាប់ការបូមទឹកដាក់ស្រែ និងសម្រាប់ការបូមទឹកធ្វើកសិកម្មផ្សេងៗទៀត ដូចជាការដាំដំណាំ ឬបន្លែផ្សេងៗ នៅតំបន់ជនបទ ក្នុងរង្វង់ពី ៣០% ទៅ ៤០% បន្ថែមទៀតពីអត្រាថ្លៃដែលបានបន្ថយជារួមរួចហើយនៅតំបន់ជនបទ ឲ្យតែការប្រើប្រាស់នេះឋិតនៅក្នុងពេលម៉ោងដែលពុំមានបន្ទុកអតិបរិមា (ឧទាហរណ៍ពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក)។ ឧទាហរណ៍ នៅឆ្នាំ ២០១៦ អត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទនឹងត្រូវកាត់បន្ថយជារួមនៅត្រឹម ៨០០រៀលក្នុង១គវ៉ម ប្រសិនបើ ម.អ.ជ អាចអន្តរាគមន៍កាត់បន្ថយអត្រាថ្លៃលក់អគ្គិសនី ៤០% បន្ថែម ឲ្យការបូមទឹកសម្រាប់កសិកម្ម ពេលនោះ ការបូមទឹកធ្វើកសិកម្មដែលប្រើអគ្គិសនីពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក នឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៨០រៀលក្នុង១គវ៉ម ប៉ុណ្ណោះ។ តាមឧទាហរណ៍នេះ នៅឆ្នាំ ២០១៧ ដែលអត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទត្រូវបានកាត់បន្ថយ នៅ

ត្រឹម ៧៩០រៀលក្នុង១គីឡូវ៉ាត់ម៉ោង នោះ ការបូមទឹកធ្វើកសិកម្មដែលប្រើអគ្គិសនីពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក នឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៧៤រៀលក្នុង១គីឡូវ៉ាត់ម៉ោង ឯនៅឆ្នាំ ២០១៨ ដែលអត្រាថ្លៃអគ្គិសនីនៅតំបន់ជនបទត្រូវបានកាត់បន្ថយនៅត្រឹម ៧៧០រៀលក្នុង១គីឡូវ៉ាត់ម៉ោង នោះ ការបូមទឹកធ្វើកសិកម្មដែលប្រើអគ្គិសនីពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក នឹងបង់ថ្លៃអគ្គិសនីត្រឹមតែ ៤៦២រៀលក្នុង១គីឡូវ៉ាត់ម៉ោង ប៉ុណ្ណោះ ។ *ធ្វើដូច្នេះ សហគមន៍ ឬគ្រួសារ ដែលឧស្សាហ៍ និងព្យាយាមនៅតំបន់ជនបទ អាចនឹងមានឱកាសទទួលបានផលប្រយោជន៍ពីការបន្ថយថ្លៃលក់អគ្គិសនីនេះ ព្រមទាំងអាចជំរុញឲ្យមានការគិតគូរបង្កើនមុខរបរកសិកម្មនៅតំបន់ជនបទទៀតផង ។*

ដោយសារការជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងដំណាក់កាលដំបូងនេះ គឺជាអន្តរាគមន៍តាមចំនួនថវិកាដែលបានគ្រោងប្រចាំឆ្នាំ ដូច្នេះ យើងខ្ញុំស្នើសុំកំណត់លក្ខខណ្ឌនៃការជួយបន្ថយថ្លៃអគ្គិសនីបន្ថែមខាងលើនេះ ដូចខាងក្រោម ៖

- ផ្តល់ការអនុគ្រោះបន្ថយថ្លៃនេះ តាមការស្នើសុំជាក់ស្តែងពីអ្នកប្រើប្រាស់ ឬពីសហគមន៍ ដែលបានរៀបចំហេដ្ឋារចនាសម្ព័ន្ធប្រើប្រាស់អគ្គិសនីសម្រាប់ប្រភេទនេះ និងសម្រាប់ពេលម៉ោងដែលបានកំណត់
- ការស្នើសុំនេះត្រូវធ្វើតាមរយៈអាជ្ញាធរឃុំ និងមន្ទីររ៉ែ និងថាមពលខេត្ត ទៅមូលនិធិអគ្គិសនីការូបនីយកម្មជនបទ របស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា
- ក្នុងការជួយបន្ថយថ្លៃនេះ មូលនិធិអគ្គិសនីការូបនីយកម្មជនបទ ត្រូវផ្តល់ឲ្យតាមសំណើសុំនានា រហូតដល់អស់ថវិកាក្នុងកញ្ចប់ថវិកាដែលបានគ្រោងសម្រាប់ឆ្នាំនីមួយៗ ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាពិនិត្យសម្រេច និងណែនាំការអនុវត្តលើចំណុចគោលសំខាន់ៗខាងលើ ដោយអនុគ្រោះ។ បានទទួលការណែនាំដ៏ខ្ពង់ខ្ពស់នេះហើយ ក្រសួងរ៉ែ និងថាមពល នឹងរៀបចំកែសម្រួលខ្លឹមសារ និងរៀបចំសេចក្តីប្រកាសរបស់ក្រសួង ដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រខាងលើ។ ជូនភ្ជាប់មកជាមួយនូវសេចក្តីព្រាងខ្លឹមសារសង្ខេបនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ២០១៥-២០២០ ។

ជាមួយគ្នានេះដែរ ខ្ញុំបាទមានបំណងស្នើសុំ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មេត្តាប្រកាសជូនសាធារណៈជនអំពី "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ ២០១៥-២០២០" នៅក្នុងឱកាសដែល **សម្តេច** ធ្វើជាអធិបតី ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការស្ថានីយ៍វារីអគ្គិសនីឬស្សីជ្រុំក្រោម នៅថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៥ ខាងមុខ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មេត្តាទទួលនូវគារវកិច្ច និងការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

28.12.14

ស៊ុយ_សែម

# ប្រកាស
# ស្តីពីការកំណត់ ផែនការយុទ្ធសាស្ត្រ
# ដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី
# នៅព្រះរាជាណាចក្រកម្ពុជា
# សម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ០០៩៤.១៦.អវត.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៥

# ប្រកាស

## ស្តីពីការកំណត់ផែនការយុទ្ធសាស្ត្រ ដើម្បីបន្ថយអគ្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០

## រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួង រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៥៧៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួង រ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- យោងឯកសារសិក្សាស្តីពីផែនការយុទ្ធសាស្ត្របន្ថយអគ្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥-២០២០ ដែលបានសិក្សារួមគ្នាដោយក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា នៅឆ្នាំ ២០១៤
- យោងការសម្រេចរបស់កិច្ចប្រជុំរួម ដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល ដើម្បីពិនិត្យនិងសម្រេចលើឯកសារផែនការយុទ្ធសាស្ត្របន្ថយអគ្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ នៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០១៤
- យោងចំណារឯកភាពរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៤ លើសំណើសុំពិនិត្យ និងណែនាំលើផែនការយុទ្ធសាស្ត្របន្ថយអគ្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ របស់ក្រសួងរ៉ែ និងថាមពល លេខ ១៥៤៨.រថ.លស ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤ ។

## សម្រេច

**ប្រការ ១៖** ដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្របន្ថយអគ្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ដែលបានសិក្សារួមគ្នាដោយក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ក្នុង

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom PenhTel 1 (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh

គោលដៅចែករំលែកផ្លែផ្កាទទួលបានពីការអភិវឌ្ឍវិស័យអគ្គិសនីឲ្យបានសមធម៌ ដោយធ្វើឲ្យថ្លៃអគ្គិសនីនៅតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ មានថ្លៃកាន់តែទាប មានគម្លាតខុសគ្នាកាន់តែតិច និងជំរុញពង្រីកតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិនេះឲ្យគ្របដណ្តប់ទូទាំងប្រទេស ស្របតាមចក្ខុវិស័យនៃវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ ២៖** ផែនការយុទ្ធសាស្ត្រដែលដាក់ឲ្យអនុវត្តក្នុងប្រការ១ខាងលើនេះមានឈ្មោះថា "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៥-២០២០" ដែលមានខ្លឹមសារទាំងស្រុងដូចអត្ថបទភ្ជាប់ជាមួយ។

**ប្រការ ៣៖** អគ្គនាយកដ្ឋានថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា មន្ទីររ៉ែ និងថាមពលគ្រប់រាជធានី-ខេត្ត មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនិងអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនីគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរួមគ្នាអនុវត្ត "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០" ដែលបានកំណត់ក្នុងប្រការ ១ និងប្រការ ២ ខាងលើ ឲ្យបានសុក្រឹត និងមានប្រសិទ្ធភាព ដើម្បីឈានទៅសម្រេចគោលដៅនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ ៤៖** ប្រកាស និងសេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥៖** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**ស៊ុយ_សែម**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីររ៉ែ និងថាមពលរាជធានី-ខេត្ត
- ដូចប្រការ ៣ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ

# ខ្លឹមសារនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាត ថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ២០១៥-២០២០

## ១-សេចក្តីផ្តើម

នៅព្រះរាជាណាចក្រកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំមុននេះ ការធ្វើយ៉ាងណាជំរុញឲ្យមានការវិនិយោគបង្កើតការផ្គត់ផ្គង់អគ្គិសនីនៅតាមតំបន់នានាឲ្យបានលឿន ដើម្បីឲ្យប្រជាពលរដ្ឋធាប់មានអគ្គិសនីប្រើប្រាស់ជំនួសឲ្យការប្រើអាគុយ ប្រេងកាត ឬចន្លុះ គឺជាអាទិភាពសំខាន់បំផុតរបស់កម្ពុជានៅពេលនោះ។ ដូច្នេះ នយោបាយផែនការ និងយុទ្ធសាស្ត្រក្នុងវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាលកន្លងមក ភាគច្រើនគឺមានទិសដៅជំរុញការវិនិយោគអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ដើម្បីផ្តល់សេវាផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់នានាទូទាំងព្រះរាជាណាចក្រកម្ពុជា ទាំងទីក្រុង ទីប្រជុំជន និងទាំងតំបន់ជនបទ ទោះជាការអភិវឌ្ឍខ្លះត្រូវបានអនុញ្ញាតឲ្យធ្វើតាមរយៈការវិនិយោគរបស់ផ្នែកឯកជនតូចៗក៏ដោយ។ បច្ចុប្បន្ន ពេលដែលការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី បានគ្របដណ្តប់ជាងពាក់កណ្តាលនៃចំនួនភូមិទាំងអស់របស់កម្ពុជារួចហើយ ការបន្ថយអត្រាថ្លៃលក់អគ្គិសនីឲ្យទាបជាងថ្លៃបច្ចុប្បន្ន ការបន្ថយគម្លាតថ្លៃលក់អគ្គិសនីកុំឲ្យខុសគ្នាខ្លាំងពេកពីតំបន់មួយទៅតំបន់មួយទៀត ការធ្វើយ៉ាងណាឲ្យការផ្គត់ផ្គង់មានស្ថិរភាព មានគុណភាព និងមានសុវត្ថិភាព និងការជួយដោះស្រាយលទ្ធភាពប្រើប្រាស់អគ្គិសនីរបស់គ្រួសារក្រីក្រនៅតំបន់ជនបទ ព្រមទាំងការជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការធ្វើកសិកម្មរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទក៏បានក្លាយទៅជាបញ្ហាអាទិភាពក្នុងវិស័យអគ្គិសនីដែលរាជរដ្ឋាភិបាលត្រូវធ្វើការដោះស្រាយផងដែរ។ ដូច្នេះ ក្រសួងទទួលបន្ទុកវិស័យថាមពល បញ្ញត្តិករវិស័យអគ្គិសនី និងសហគ្រាសអគ្គិសនីរបស់រដ្ឋ ដែលមានក្រសួង រ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ទោះជាក្នុងពេលដែលកំពុងជំរុញការអភិវឌ្ឍពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់នានា ដែលពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីបន្តទៀតក៏ដោយក៏ត្រូវមានកាតព្វកិច្ចរួមគ្នាធ្វើការសិក្សា និងពិនិត្យស្ថានភាពនានា ក្នុងវិស័យអគ្គិសនីនៅកម្ពុជាបច្ចុប្បន្នកំណត់នូវផែនការយុទ្ធសាស្ត្រមួយដើម្បីដោះស្រាយបញ្ហាទាំងឡាយខាងលើផងដែរ។ ផែនការយុទ្ធសាស្ត្រដើម្បីដោះស្រាយបញ្ហាទាំងឡាយ ដូចបានរៀបរាប់ខាងលើនេះ មានឈ្មោះខ្លីហៅថា "**ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៥-២០២០**"។

## ២-មូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រ

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងអាណត្តិកន្លងមក វិស័យអគ្គិសនីត្រូវបានជំរុញឆ្លងកាត់ពីដំណាក់កាលនៃការស្តារឡើងវិញ ក្រោយការបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយសង្គ្រាម និងរបបប៉ុលពត មកដល់ដំណាក់កាលអភិវឌ្ឍន៍ថ្មីៗបន្ថែមជាច្រើន ទាំងផ្នែកប្រភពថាមពលអគ្គិសនី និងទាំងផ្នែកបណ្តាញបញ្ជូន និងចែកចាយអគ្គិសនី ដើម្បីបំពេញតាមតម្រូវការនៃកំណើនវឌ្ឍនភាពនៃជីវភាពរស់នៅ និងសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា។ សម្រាប់អាណត្តិ ២០១៣-២០១៨ នេះ គោលដៅនៃវិស័យអគ្គិសនីរបស់រាជរដ្ឋាភិបាលគឺ៖ "**ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលមួយគ្រប់គ្រាន់ ប្រកបដោយចីរភាព ស្ថិរភាព គុណភាព និងថ្លៃកាន់តែទាបទូទាំងព្រះរាជាណាចក្រកម្ពុជា**"។ ដើម្បីសម្រេចគោលដៅខាងលើនេះ ក្រសួងរ៉ែ និងថាមពលបានកំណត់ទិសដៅយុទ្ធសាស្ត្រសំខាន់ៗនៃវិស័យអគ្គិសនី ចំនួន ៥ ដូចខាងក្រោម៖

**១-ជំរុញរក្សាឲ្យបានតុល្យភាពនៃការផ្គត់ផ្គង់ និងតម្រូវការថាមពលអគ្គិសនី៖** ធ្វើយ៉ាងណាឲ្យប្រភពអគ្គិសនីមានគ្រប់គ្រាន់មិនមានការខ្វះខាត និងឲ្យទាន់តាមកំណើននៃសេចក្តីត្រូវការប្រើប្រាស់ទាំងសម្រាប់ជីវភាព និងទាំងសម្រាប់សេដ្ឋកិច្ចរបស់កម្ពុជា។

**២-ជំរុញពង្រីកទំហំវិសាលភាពនៃសេវាផ្គត់ផ្គង់អគ្គិសនី៖** ពន្លឿនការអភិវឌ្ឍពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ដែលរួមមានអនុស្ថានីយ៍ បណ្តាញបញ្ជូន បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយឲ្យគ្របដណ្តប់ទូទាំងប្រទេសឲ្យបានឆាប់រហ័ស។

**៣-ជំរុញលើកកំពស់សមធម៌ក្នុងការទទួលសេវាផ្គត់ផ្គង់អគ្គិសនីរបស់ប្រជាពលរដ្ឋនៅតំបន់ជនបទ៖** ជួយឲ្យតំបន់ជនបទមានអគ្គិសនីប្រើប្រាស់ដូចទីក្រុង ជួយដល់ការប្រើប្រាស់អគ្គិសនីរបស់គ្រួសារក្រីក្រនៅតំបន់ជនបទ និងជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់ការប្រកបរបរកសិកម្មនៅតំបន់ជនបទ។

**៤-ពង្រឹងស្ថេរភាព និងគុណភាពនៃសេវាផ្គត់ផ្គង់អគ្គិសនី៖** ធ្វើយ៉ាងណាឲ្យការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា កាន់តែមានគុណភាព មានស្ថិរភាព មានសុវត្ថិភាព មានតម្លាភាព។

**៥-ជំរុញកាត់បន្ថយអត្រានិងគម្លាតថ្លៃអគ្គិសនី៖** បន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅកម្ពុជាឲ្យនៅក្នុងកំរិតមួយសមស្របដោយរក្សានិរន្តរភាពនៃការផ្គត់ផ្គង់ និងការចូលរួមរបស់ឯកជនបន្តទៀត។

តាមទិសដៅយុទ្ធសាស្ត្រទាំង៥ខាងលើ ការដោះស្រាយបន្ថយអត្រាថ្លៃលក់អគ្គិសនី ការដោះស្រាយបន្ថយគម្លាតថ្លៃលក់អគ្គិសនីពីតំបន់មួយទៅតំបន់មួយទៀត ការធ្វើយ៉ាងណាឲ្យការផ្គត់ផ្គង់អគ្គិសនីមានស្ថិរភាព មានគុណភាព និងមានសុវត្ថិភាព ការពង្រីកការផ្គត់ផ្គង់ទៅតំបន់ពុំទាន់មានការផ្គត់ផ្គង់ និងការជួយដោះស្រាយបញ្ហាលទ្ធភាពប្រើប្រាស់អគ្គិសនីរបស់គ្រួសារក្រីក្រ ព្រមទាំងការជួយដោះស្រាយការប្រើប្រាស់អគ្គិសនីសម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទ ដែលជាកម្មវត្ថុនៃផែនការយុទ្ធសាស្ត្រ *"បន្ថយអត្រាថ្លៃលក់អគ្គិសនី និងបន្ថយគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០"* គឺសុទ្ធតែជាបេសកម្មសំខាន់ៗដែលបានកំណត់នៅក្នុងទិសដៅជាយុទ្ធសាស្ត្ររបស់វិស័យអគ្គិសនីនៅកម្ពុជា។ ដូច្នេះ ផែនការយុទ្ធសាស្ត្រ *"បន្ថយអត្រាថ្លៃលក់អគ្គិសនី និងបន្ថយគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រ កម្ពុជាឆ្នាំ ២០១៥-២០២០"* គឺជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្ររួមរបស់វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

# ៣-គោលដៅនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៥-២០២០

គោលដៅនៃ"ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១៥-២០២០" មាន ៥ ចំណុចសំខាន់ៗ ដូចខាងក្រោម៖

**ទី១**- បន្ថយអត្រាថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ឲ្យថយចុះជាបន្តបន្ទាប់ដោយរក្សាបាននូវស្ថិរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនី និងរក្សាបាននូវការអនុវត្តគោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនី ដែលកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។

**ទី២**- បន្ថយគម្លាតថ្លៃលក់អគ្គិសនី ដែលខុសគ្នាពីតំបន់មួយទៅតំបន់មួយទៀតនៅកម្ពុជាបច្ចុប្បន្ន ឲ្យកាន់តែថយចុះបន្តិចម្តងៗ រហូតទាល់តែដូចគ្នាទូទាំងប្រទេសតាមប្រភេទអតិថិជនប្រើប្រាស់អគ្គិសនី។

**ទី៣**- ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់អគ្គិសនីចេញពីប្រព័ន្ធផ្គត់ផ្គង់បណ្តាញជាតិ ដែលជាប្រព័ន្ធផ្គត់ផ្គង់មួយមានលទ្ធភាពធ្វើឲ្យការផ្គត់ផ្គង់ មានស្ថិរភាព មានគុណភាព មាននិរន្តរភាព និងធ្វើឲ្យអត្រាថ្លៃ និងគម្លាតថ្លៃថយចុះ ដើម្បីពង្រីកលទ្ធភាពទាំងនេះឲ្យគ្របដណ្តប់ទៅគ្រប់តំបន់ទូទាំងប្រទេស ។

**ទី៤**- រៀបចំថ្លៃលក់អគ្គិសនីមួយអនុគ្រោះសម្រាប់គ្រួសារក្រីក្រនៅតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអាចឲ្យគ្រួសារក្រីក្រនៅតំបន់ជនបទនេះ មានលទ្ធភាពប្រើប្រាស់អគ្គិសនីយ៉ាងហោចណាស់ក៏សម្រាប់ជីវភាពជាមូលដ្ឋានដែរ។

**ទី៥**- រៀបចំថ្លៃលក់អគ្គិសនីមួយអនុគ្រោះសម្រាប់ការបូមទឹកធ្វើកសិកម្មនៅតំបន់ជនបទ ដែលកសិករអាចភ្ជាប់ចរន្តប្រើប្រាស់ពីខ្សែបណ្តាញតង់ស្យុងមធ្យម និងពីខ្សែបណ្តាញតង់ស្យុងទាបគ្រប់ប្រភេទ ទាំងក្នុងក្របខណ្ឌខ្សែបណ្តាញរបស់អគ្គិសនីកម្ពុជា និងទាំងក្នុងក្របខណ្ឌខ្សែបណ្តាញរបស់សេវាករអគ្គិសនីឯកជន ដើម្បីឲ្យប្រជាកសិករនៅតំបន់ជនបទអាចធ្វើកសិកម្មបានងាយស្រួល និងមានប្រសិទ្ធភាព។

យោងតាមការសិក្សា និងគណនាលំអិតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ ២០២០ គោលដៅទាំង៥នៃ"ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០" អាចកំណត់ជាតួលេខថ្លៃតាមឆ្នាំ ដូចតារាងខាងក្រោម ៖

## គោលដៅនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីឆ្នាំ ២០១៥-២០២០

| | ប្រភេទនៃការផ្គត់ផ្គង់ | ឯកតា | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|
| ១ | **ការទិញពីអនុស្ថានីយផ្ទាល់** | | | | | | | |
| | ទិញពីទ្វារចេញ MV របស់អនុស្ថានីយ | ដុល្លារ/១គវ៉ែ | 0.1290 | 0.1260 | 0.1260 | 0.1260 | 0.1260 | 0.1260 |
| ២ | **ចំពោះប្រព័ន្ធភ្នំពេញ កណ្តាល របស់** EDC | | | | | | | |
| 1 | ការកំណត់ថ្លៃល្បាយប្រភពអគ្គិសនីតាមឆ្នាំ | USD/kWh | 0.1570 | 0.1520 | 0.1470 | 0.1450 | 0.1430 | 0.1420 |
| 2 | ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវ៉ែ | 0.1770 | 0.1720 | 0.1670 | 0.1650 | 0.1630 | 0.1620 |
| 3 | ថ្លៃលក់ LV ធុនធំ ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | USD/kWh | 0.1810 | 0.1760 | 0.1710 | 0.1690 | 0.1670 | 0.1660 |
| 4 | ថ្លៃលក់ LV ធុនមធ្យម ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | USD/kWh | 0.1850 | 0.1800 | 0.1750 | 0.1730 | 0.1710 | 0.1700 |
| 5 | ថ្លៃលក់ LV ធុនតូច ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | USD/kWh | 0.1930 | 0.1880 | 0.1830 | 0.1810 | 0.1790 | 0.1780 |
| 6 | ថ្លៃលក់ LV ធុនតូច ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | រៀល/kWh | 791 | 771 | 750 | 742 | 734 | 730 |
| 7 | ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ >200kWh/ខែ | រៀល/១គវ៉ែ | 820 | 780 | 770 | 750 | 740 | 730 |
| | ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ 51-200kWh/ខែ | រៀល/១គវ៉ែ | 720 | 720 | 720 | 720 | 720 | 720 |
| | ថ្លៃលក់ LV ឲ្យគេហដ្ឋានដែលប្រើ ≤50kWh/m | រៀល/១គវ៉ែ | 610 | 610 | 610 | 610 | 610 | 610 |

| | ប្រភេទនៃការផ្គត់ផ្គង់ | ឯកតា | 2015 | 2016 | 2017 | 2018 | 2019 | 2020 |
|---|---|---|---|---|---|---|---|---|
| ៣ | ចំពោះបណ្តាតំបន់ទីរួមខេត្តនិងតំបន់ផ្សេងទៀតដែលផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជា | | | | | | | |
| 1 | ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវ៉ៃម៉ | 0.1700 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| 2 | ថ្លៃលក់ LV ឲ្យអតិថិជនធម្មតានិងគេហដ្ឋាន | រៀល/១គវ៉ៃម៉ | 820-1000 | 780 | 770 | 750 | 740 | 730 |
| 1 | គ្រួសារដែលប្រើអគ្គិសនីមិនលើសពី ១០គវ៉ៃម៉/១ខែ | រៀល/kWh | | 480 | 474 | 462 | 456 | 450 |
| ៤ | ចំពោះការលក់ដុំចេញពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា | | | | | | | |
| 1 | ថ្លៃលក់ដុំ MV ឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ | ដុល្លារ/១គវ៉ៃម៉ | 0.138-0.153 | 0.1470 | 0.1450 | 0.1440 | 0.1430 | 0.1420 |
| 2 | ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវ៉ៃម៉ | 0.1700 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| ៥ | ចំពោះការលក់ដុំចេញពីបណ្តាញបញ្ជូនរបស់សេវាករឯកជន | | | | | | | |
| 1 | ថ្លៃលក់ដុំ MV ឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ | ដុល្លារ/១គវ៉ៃម៉ | 0.1510 | 0.1470 | 0.1450 | 0.1440 | 0.1430 | 0.1420 |
| 2 | ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវ៉ៃម៉ | 0.1725 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| ៦ | ចំពោះតំបន់ផ្គត់ផ្គង់របស់សេវាករឯកជនដែលភ្ជាប់ផ្ទាល់ឬប្រយោលពីបណ្តាញជាតិ | | | | | | | |
| 1 | ថ្លៃលក់ MV ឲ្យឧស្សាហកម្ម ពាណិជ្ជកម្ម | ដុល្លារ/១គវ៉ៃម៉ | 0.1725 | 0.1675 | 0.1650 | 0.1640 | 0.1630 | 0.1620 |
| 2 | ថ្លៃលក់ LV ឲ្យអតិថិជនធម្មតានិងគេហដ្ឋាន | រៀល/១គវ៉ៃម៉ | 1000-1050 | 800 | 790 | 770 | 760 | 750 |
| 1 | គ្រួសារដែលប្រើអគ្គិសនីមិនលើសពី ១០គវ៉ៃម៉/១ខែ | រៀល/kWh | | 480 | 474 | 462 | 456 | 450 |
| ៧ | ការជួយដល់ការប្រើប្រាស់អគ្គិសនីសម្រាប់បូមទឹកកសិកម្មនៅជនបទ | | | | | | | |
| 1 | អ្នកដែលបានសុំ និងឋិតនៅក្នុងលទ្ធភាពកញ្ចប់ថវិកា | រៀល/kWh | | 480 | 474 | 462 | 456 | 450 |

**កំណត់សំគាល់៖**

១. សម្រាប់ឆ្នាំ ២០១៥ ចំពោះតំបន់ទាំងឡាយដែលទើបនឹងធ្វើការអភិវឌ្ឍរួច ឬតំបន់ទាំងឡាយដែលនៅឆ្ងាយពីអនុស្ថានីយបណ្តាញជាតិ ដែលត្រូវដោះស្រាយការផ្គត់ផ្គង់ដោយរបៀបបណ្ដោះអាសន្ន និងកំពុងឋិតនៅក្នុងផែនការអនុញ្ញាតឲ្យវិនិយោគ ដោយបន្ថយថ្លៃលក់អគ្គិសនីបន្តិចម្តងតាមកម្មវិធី ឬឋិតនៅក្នុងថ្លៃបណ្តោះអាសន្នតំបន់ទាំងនោះ ត្រូវអនុវត្តតាមផែនការបន្ថយថ្លៃលក់អគ្គិសនីបន្តិចម្តងតាមកម្មវិធី ឬតាមថ្លៃបណ្តោះអាសន្នរហូតដល់ខែ មិនា ឆ្នាំ ២០១៦ ទើបចាប់ផ្តើមអនុវត្តផែនការដែលបានគ្រោងក្នុងតារាងខាងលើ។

២. អត្រាថ្លៃដែលកំណត់ក្នុងផែនការខាងលើ មិនគ្របដណ្តប់លើតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្មដែលម្ចាស់តំបន់ធ្វើការផ្គត់ផ្គង់អគ្គិសនីដោយផ្ទាល់ ដោយប្រើរោងចក្រអគ្គិសនីផ្ទាល់ខ្លួនបន្ថែមពីលើការយកប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជាឡើយ។

# ៤-គោលការណ៍ និងការកិច្ចកំណត់បញ្ជីថ្លៃលក់អគ្គិសនី

នយោបាយ គោលការណ៍ និងនីតិវិធីកំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់កម្ពុជា គឺត្រូវបានកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា។ គោលការណ៍កំណត់បញ្ជីថ្លៃលក់អគ្គិសនី ដែលកំណត់ដោយច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវធ្វើយ៉ាងណាឲ្យថ្លៃលក់អគ្គិសនីអាចរំលោះចំណាយផ្គត់ផ្គង់ និងមានចំណេញសមស្របសម្រាប់ការធ្វើអាជីវកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីរក្សានិរន្តរភាពនៃដំណើរការអាជីវកម្មផ្គត់ផ្គង់អគ្គិសនីដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា គឺជាស្ថាប័នឯករាជទទួលបន្ទុកកំណត់បញ្ជីថ្លៃលក់អគ្គិសនី។ ដូច្នេះ នយោបាយ គោលការណ៍ នីតិវិធី និងការកិច្ចកំណត់បញ្ជីថ្លៃលក់អគ្គិសនីខាងលើនេះពុំមានការកែប្រែទេ។

## ៥-តំបន់អនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងតម្លៃថ្លៃ

តាមការសិក្សា និងគណនារួមគ្នារបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា *លទ្ធភាពនៃការបន្ថយអត្រា និងតម្លៃថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា គឺអាចធ្វើបានតែក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិទេ*។ ដូច្នេះ ដើម្បីបន្ថយអត្រា និងតម្លៃថ្លៃលក់អគ្គិសនី នៅតំបន់ទាំងឡាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល និងនៅតំបន់ទាំងឡាយដែលនាំចូលប្រភពអគ្គិសនីតាមរូបភាពតូចៗពីប្រទេសជិតខាង ត្រូវពង្រីកបណ្តាញបញ្ជូនវេងចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិឲ្យទៅគ្របដណ្តប់តំបន់ទាំងនោះ។ តំបន់ដែលអាចបន្ថយថ្លៃ និងតម្លៃថ្លៃតាមផែនការយុទ្ធសាស្ត្រខាងលើក្នុងពេលបច្ចុប្បន្ន និងតំបន់ដែលអាចបន្ថយអត្រា និងតម្លៃថ្លៃលក់អគ្គិសនីតាមផែនការពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ប្រភពអគ្គិសនីពីបណ្តាញជាតិជាបន្តបន្ទាប់ ចាប់ពីឆ្នាំ ២០១៥ តទៅ មានកំណត់នៅក្នុងផែនទីបង្ហាញតំបន់ខាងក្រោម៖



១.តំបន់ដែលគ្របដោយពណ៌លឿងគឺតំបន់កំពុងផ្គត់ផ្គង់
២.តំបន់ដែលគ្របដោយពណ៌ក្រហមគឺតំបន់អាចពង្រីកក្នុងដំណាក់កាលបន្ទាប់
៣.តំបន់ដែលគ្របដោយពណ៌បៃតងគឺតំបន់ដែលត្រូវបង្កើតអនុស្ថានីយសិនទើបអាចពង្រីកបាន

ផែននៃតំបន់ដែលត្រូវអនុវត្តការបន្ថយថ្លៃ និងតម្លៃថ្លៃតាមផែនការយុទ្ធសាស្ត្រខាងលើត្រូវកំណត់ដោយមានការឯកភាពគ្នារវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា។ ក្នុងករណីចាំបាច់ក្នុងគោលបំណងផ្តល់នូវផលប្រយោជន៍បណ្តោះអាសន្នឲ្យតំបន់ណាមួយ ដែលនៅក្បែរតំបន់គ្របដណ្តប់របស់បណ្តាញជាតិ ប៉ុន្តែពុំទាន់អាចពង្រីកបណ្តាញបញ្ជូនវេងឲ្យទៅគ្របដណ្តប់តំបន់នោះតាមបទដ្ឋានបច្ចេកទេសបាន អាជ្ញាធរ-អគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា អាចឯកភាពគ្នាអនុញ្ញាតឲ្យមានការផ្តល់ប្រភពបន្តគ្នាជាបណ្តោះអាសន្ន ដោយកំណត់ថ្លៃលក់អគ្គិសនី ដោយឡែកណាមួយខុសពីផែនការរួមក្នុងរយៈពេលបណ្តោះអាសន្នរហូតដល់តំបន់នោះត្រូវបានគ្របដណ្តប់ត្រឹមត្រូវដោយបណ្តាញបញ្ជូនវេងតាមបទដ្ឋានបច្ចេកទេស។

## ៦-ផែនការសកម្មភាពដែលត្រូវអនុវត្ត

### ក-ការរៀបចំប្រព័ន្ធថវិកា

តាមការសិក្សា និងការគណនាចំណាយផ្គត់ផ្គង់បានឲ្យដឹងថា ដើម្បីអាចបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីចេញពីប្រភពបណ្តាញជាតិ បានត្រូវប្រើគោលការណ៍ផ្ទេរបន្ទុកថ្លៃពីកន្លែងថ្លៃខ្ពស់ទៅកន្លែងថ្លៃទាប (Cross-subsidy) នៅក្នុងការកំណត់ថ្លៃលក់អគ្គិសនី ដែលមានន័យថា ផ្ទេរបន្ទុកថ្លៃដែលខ្ពស់នៅតំបន់ជនបទខ្លះឲ្យទៅអាជីវកម្មរបស់អគ្គិសនីកម្ពុជាជាអ្នកទទួលបន្ទុក ព្រោះ អគ្គិសនីកម្ពុជា គឺជាអ្នកធ្វើអាជីវកម្មអគ្គិសនីនៅលើបណ្តាញបញ្ជូន និងធ្វើអាជីវកម្មចែកចាយនៅរាជធានីភ្នំពេញ និងទីរួមខេត្តសំខាន់ៗ ដែលជាតំបន់មានសក្តានុពលអាជីវកម្មខ្ពស់ និងមានថ្លៃទាប។ ដោយសារសកម្មភាពនៃការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីមាន ២ ទិសដៅ គឺ ទី១-ការបន្ថយអត្រាថ្លៃលក់ផ្ទាល់ និងទី២-ការពង្រីកវិសាលភាពនៃតំបន់ដែលអាចមានលទ្ធភាពបន្ថយអត្រាថ្លៃលក់បាន ដូច្នេះ កញ្ចប់ថវិកាដែលអគ្គិសនីកម្ពុជាត្រូវទទួលបន្ទុកត្រូវមាន ២ ប្រភេទ គឺទី១-កញ្ចប់ថវិកាទទួលបន្ទុកកាត់បន្ថយអត្រាថ្លៃលក់អគ្គិសនីដែលខ្ពស់នៅតំបន់ជនបទ និងទី២-កញ្ចប់ថវិកាជួយជំរុញការពង្រីកបណ្តាញនៅតំបន់ជនបទដែលនៅសល់។ ដើម្បីអាចឈានទៅសម្រេចគោលដៅទាំង ២ នេះបាន ផែនការសកម្មភាពដែលត្រូវអនុវត្តនៅក្នុងការកំណត់បញ្ជីថ្លៃលក់អគ្គិសនីត្រូវរៀបចំដូចខាងក្រោម៖

1. អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការកំណត់បញ្ជីថ្លៃលក់អគ្គិសនីឲ្យអគ្គិសនីកម្ពុជា ក្នុងអត្រាមួយដែលអាចឲ្យអគ្គិសនីកម្ពុជាមានចំណូលគ្រប់គ្រាន់សម្រាប់ការទទួលបន្ទុកកាត់បន្ថយថ្លៃអគ្គិសនីនៅតំបន់ណាដែលខ្ពស់ជាងថ្លៃលក់អគ្គិសនីរបស់ខ្លួន ឲ្យតែតំបន់នោះបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិរបស់ខ្លួន។
2. អនុញ្ញាតឲ្យអគ្គិសនីកម្ពុជាធ្វើការបង្វែរកញ្ចប់ថវិកាក្នុងរង្វង់ ៤០-៤៥% នៃថវិកាចំណូលកាត់ចំណាយរួចរបស់ខ្លួនទៅឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ដើម្បីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទប្រើប្រាស់សម្រាប់ជួយកាត់បន្ថយគម្លាតថ្លៃលក់អគ្គិសនីនៅតំបន់ជនបទ និងជួយជំរុញការពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទដែលនៅសល់។
3. កំណត់ឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទប្រើប្រាស់កញ្ចប់ថវិកានេះ អាទិភាពទី១-សម្រាប់ជួយកាត់បន្ថយគម្លាតថ្លៃលក់អគ្គិសនីនៅតំបន់ជនបទ អាទិភាពទី២-ជួយដោះស្រាយបញ្ហាប្រើប្រាស់អគ្គិសនីរបស់គ្រួសារប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ អាទិភាពទី៣-ជួយបន្ថយថ្លៃអគ្គិសនីដល់ការបូមទឹកកសិកម្ម និងអាទិភាពទី៤-ជួយជំរុញការពង្រីកបណ្តាញ។
4. រៀងរាល់ដំណាច់ឆ្នាំនីមួយៗ អគ្គិសនីកម្ពុជាត្រូវរៀបចំផែនការបញ្ជីថ្លៃលក់ថ្មី ផែនការថវិកាចំណូល ចំណាយ និងផែនការបង្វែរថវិកាទៅមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងដាក់ទៅអាជ្ញាធរអគ្គិសនីកម្ពុជាដើម្បីធ្វើការអនុម័ត ស្របតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនី។

## ខ-ពេលវេលាអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី

ក្នុងឆ្នាំ ២០១៥ អាជ្ញាធរអគ្គិសនីកម្ពុជា បន្តពិនិត្យបន្ថយអត្រាថ្លៃលក់អគ្គិសនីតាមកំណើនបរិមាណប្រើប្រាស់អគ្គិសនីបន្តទៀត។ ស្របជាមួយគ្នានេះដែរ នៅឆ្នាំ ២០១៥ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជាត្រូវរៀបចំនីតិវិធី និងគោលការណ៍នានា ដើម្បីត្រៀមសម្រាប់អនុវត្តផែនការកាត់បន្ថយគម្លាតថ្លៃលក់អគ្គិសនី ដែលនឹងត្រូវចាប់ផ្តើមនៅខែ មិនា ឆ្នាំ ២០១៦។

## គ-គោលដៅពាក់ព័ន្ធជាមួយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី

ពាក់ព័ន្ធជាមួយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ គោលដៅនៃការអនុវត្តន៍ត្រូវបានចែកជា ២ គោលដៅ ដូចខាងក្រោម៖

**គោលដៅទី១៖** ចំពោះអត្រាថ្លៃ ៣ ប្រភេទ គឺ១-អត្រាថ្លៃលក់ចេញពីអនុស្ថានីយ ២-អត្រាថ្លៃលក់ដុំឲ្យអ្នកចែកចាយ និង៣-អត្រាថ្លៃលក់សម្រាប់អ្នកប្រើលើតង់ស្យុងមធ្យមចេញពីបណ្តាញបញ្ជូនរងទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជន ត្រូវកំណត់ឲ្យមានអត្រា និងទម្រង់នៃបញ្ជីថ្លៃលក់អគ្គិសនីដូចគ្នាទូទាំងតំបន់ដែលផ្គត់ផ្គង់របស់បណ្តាញជាតិ លើកលែងតែក្នុងប្រព័ន្ធចែកចាយរាជធានី-ភ្នំពេញ និងកណ្តាលរបស់អគ្គិសនីកម្ពុជា ដែលអាចខុសពីនេះបន្តិចក្នុងរង្វង់ ២-៣ ឆ្នាំដំបូងនៃការចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ។

**គោលដៅទី២៖** ចំពោះអត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធម្មតា និងគេហដ្ឋាន នៅតំបន់ជនបទអាចរក្សាទុកឲ្យមានគម្លាតតិចតួច ដើម្បីផ្តល់សញ្ញាឲ្យប្រជាពលរដ្ឋនៅជនបទដឹងថា នៅទីនោះមានថ្លៃដើមខ្ពស់ជាង។ អ្នកប្រើប្រាស់ធម្មតា និងគេហដ្ឋាន មានន័យថាអ្នកប្រើប្រាស់គ្រប់ប្រភេទដែលប្រើប្រាស់អគ្គិសនីពីខ្សែបណ្តាញអគ្គិសនីតង់ស្យុងទាបដាក់តាមផ្លូវសាធារណៈ។

## ឃ-ផែនការសកម្មភាពក្នុងការធ្វើឯកភាពថ្លៃប្រភពអគ្គិសនីសម្រាប់ផ្តល់ឲ្យសេវាករចែក-ចាយ និងអ្នកប្រើប្រាស់អគ្គិសនីប្រភេទតង់ស្យុងមធ្យម

ដើម្បីឲ្យសេវាករចែកចាយអគ្គិសនី និងអ្នកប្រើប្រាស់ប្រភេទតង់ស្យុងមធ្យមទទួលបាននូវអគ្គិសនីមួយដែលមានអត្រាថ្លៃដូចគ្នា ក្នុងប្រព័ន្ធផ្គត់ផ្គង់ទាំងឡាយដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ អាជ្ញាធរអគ្គិសនី-កម្ពុជា ត្រូវកំណត់គោលការណ៍ចំពោះអាជីវកម្មបញ្ជូនរងនៅព្រះរាជាណាចក្រកម្ពុជា ដូចខាងក្រោម៖

1. គ្រប់បណ្តាញបញ្ជូនរងទាំងអគ្គិសនីកម្ពុជា និងទាំងឯកជន ត្រូវលក់អគ្គិសនីឲ្យសេវាករចែកចាយអគ្គិសនី និងអ្នកប្រើប្រាស់តង់ស្យុងមធ្យមតាមអត្រាថ្លៃដែលបានកំណត់ទូទាំងប្រព័ន្ធផ្គត់ផ្គង់របស់បណ្តាញជាតិ។
2. ចំពោះសេវាករបញ្ជូនរងឯកជនណាដែលអាចធ្វើអាជីវកម្មបញ្ជូនរងអគ្គិសនី តាមអត្រាថ្លៃកំណត់ខាងលើនេះបាន សេវាករឯកជននោះអាចបន្តអាជីវកម្មផ្ទាល់ខ្លួនបន្តទៀតជាធម្មតា ដូចពេលបច្ចុប្បន្ន។
3. ចំពោះសេវាករបញ្ជូនរងឯកជនណា ដែលពុំអាចធ្វើអាជីវកម្មបញ្ជូនរងជាមួយអត្រាថ្លៃកំណត់ខាងលើបាន សេវាករនោះអាចធ្វើសំណើមកអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីពិនិត្យគណនាចំណូលចំណាយឡើងវិញ ប្រសិនបើពិនិត្យទៅឃើញថា មានលទ្ធផលខាតហួសពីអត្រាចំណេញដែលត្រូវផ្តល់ឲ្យ ពេលនោះអាជ្ញាធរ-អគ្គិសនីកម្ពុជា អាចអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាជួយទទួលលក់អគ្គិសនី តាមអត្រាថ្លៃខាងលើលើហេដ្ឋា-រចនាសម្ព័ន្ធរបស់សេវាករនោះ រួចទូទាត់ជូនសេវាករឯកជននូវថ្លៃឈ្នួលបណ្តាញបញ្ជូនរង តាមចំនួនដែលគណនាឃើញ ដោយផ្តល់នូវប្រាក់ចំណេញសមស្របលើតម្លៃអចលនទ្រព្យសល់តាមឆ្នាំនីមួយៗ។ ក្នុងករណីនេះ ការធ្វើអាជីវកម្មជំនួស គឺធ្វើដោយផ្នែកអាជីវកម្មរបស់អគ្គិសនីកម្ពុជា ឯការបំពេញខាត គឺត្រូវធ្វើដោយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទដោយយកចេញពីកញ្ចប់ថវិកាដែលបានគ្រោងសម្រាប់បន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ជនបទ។ ក្នុងករណីដែលអគ្គិសនីកម្ពុជាពុំទាន់មានលទ្ធភាពអភិវឌ្ឍន៍បណ្តាញបញ្ជូនរង និងអនុស្ថានីយ៍នៅខេត្តណាមួយ រួចតម្រូវឲ្យបណ្តាញបញ្ជូនរងរបស់ឯកជនធ្វើការបញ្ជូនប្រភពអគ្គិសនីទៅឲ្យអ្នកចែកចាយ និងអ្នកប្រើប្រាស់តង់ស្យុងមធ្យមនៅខេត្តនោះលើសពីប្រវែងស្តង់ដារបញ្ជូនរង ២២ គីឡូវ៉ុល ធម្មតាកំណត់ដោយអគ្គិសនីកម្ពុជា ពេលនោះអគ្គិសនីកម្ពុជា អាចសម្រេចឲ្យអ្នកបញ្ជូនរងឯកជនធ្វើការបញ្ជូនរងជាបណ្តោះអាសន្ន ទម្រាំដល់ពេលដែលអគ្គិសនីកម្ពុជាធ្វើការអភិវឌ្ឍន៍អនុស្ថានីយ៍នៅខេត្តនោះ តាមអត្រាថ្លៃកំណត់ទូទាំងប្រទេសខាងលើ ដោយអគ្គិសនីកម្ពុជាឯកភាពឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទធ្វើការប៉ះប៉ូវការចំណាយបាត់បង់ថាមពលលើខ្សែបណ្តាញបញ្ជូនរង ដែលលើសពីអត្រាបាត់-

បង់ធម្មតា ដោយសារប្រវែងបញ្ជូនជាក់ស្តែងឆ្ងាយជាងប្រវែងបញ្ជូនស្តង់ដារ ជាបណ្តោះអាសន្ន។

4. អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ត្រូវរៀបចំគោលការណ៍ និងនីតិវិធីនានា ដែលចាំបាច់សម្រាប់ការអនុម័ត និងការអនុវត្តករណីដែលអាជ្ញាធរអគ្គិសនីកម្ពុជាអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាជួយទទួលលក់អគ្គិសនីលើហេដ្ឋារចនាសម្ព័ន្ធរបស់សេវាករ និងករណីដែលអគ្គិសនីកម្ពុជាឯកភាពអ្នកបញ្ជូនរងឯកជនធ្វើការបញ្ជូនរងទៅខេត្តណាដែលពុំទាន់មានអនុស្ថានីយ ជាបណ្តោះអាសន្ន។

## ខ-នីតិវិធីសម្រាប់អនុវត្តក្នុងការប៉ះប៉ូវថ្លៃអគ្គិសនី ដែលតម្រូវឲ្យបន្ថយអត្រានៅតំបន់របស់សេវាករឯកជន

ដើម្បីអនុវត្តការប៉ះប៉ូវថ្លៃអគ្គិសនីដែលតម្រូវឲ្យបន្ថយទាំងថ្លៃទូទៅ ទាំងថ្លៃអនុគ្រោះសម្រាប់គ្រួសារក្រីក្រ និងទាំងថ្លៃអនុគ្រោះសម្រាប់ការបូមទឹកធ្វើកសិកម្ម នៅតំបន់ចែកចាយរបស់សេវាករឯកជន ឲ្យបានរលូន មានតម្លាភាព និងមានប្រសិទ្ធភាព ការប៉ះប៉ូវនេះ ត្រូវអនុវត្តតាមនីតិវិធី ដូចខាងក្រោម៖

1. មុនដំណាច់ឆ្នាំនីមួយៗ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធ្វើការគណនាអត្រាថ្លៃលក់អគ្គិសនីសមស្របប្រចាំឆ្នាំ សម្រាប់អតិថិជនប្រភេទធម្មតា និងលំនៅដ្ឋាន អតិថិជនជាគ្រួសារក្រីក្រ អតិថិជនជាអ្នកបូមទឹកធ្វើកសិកម្ម នៅតំបន់ចែកចាយរបស់សេវាករឯកជននីមួយៗទៅតាមបទប្បញ្ញត្តិ និងនីតិវិធី ដែលមានជាធរមាន។
2. មូលនិធិអគ្គិសនីការូបនីយកម្មជនបទ ត្រូវគណនា និងផ្ទៀងផ្ទាត់ឡើងវិញការគណនាថ្លៃលក់អគ្គិសនី សម្រាប់អតិថិជនប្រភេទធម្មតា និងលំនៅដ្ឋាន អតិថិជនជាគ្រួសារក្រីក្រ អតិថិជនជាអ្នកបូមទឹកធ្វើកសិកម្ម នៅតំបន់ចែកចាយរបស់សេវាករឯកជននីមួយៗនេះ ទៅតាមបទប្បញ្ញត្តិនិងនីតិវិធី ដែលមានជាធរមាន។
3. បន្ទាប់ពីមានការឯកភាពគ្នារវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទលើអត្រាថ្លៃលក់អគ្គិសនីប្រចាំឆ្នាំសម្រាប់អតិថិជនប្រភេទធម្មតា និងលំនៅដ្ឋាន អតិថិជនជាគ្រួសារក្រីក្រ អតិថិជនជាអ្នកបូមទឹកធ្វើកសិកម្ម នៅតំបន់ចែកចាយរបស់សេវាករឯកជននីមួយៗរួចហើយ ទើបអាជ្ញាធរអគ្គិសនីកម្ពុជា អាចធ្វើការអនុម័តបញ្ជីថ្លៃលក់អគ្គិសនី ឲ្យសេវាករឯកជនសម្រាប់ឆ្នាំនោះបាន។
4. ក្រោយដំណាច់ខែនីមួយៗ សេវាករចែកចាយឯកជនទាំងអស់ត្រូវផ្ញើរព័ត៌មានអំពីបរិមាណថាមពល ដែលខ្លួនបានលក់ទៅឲ្យអតិថិជនធម្មតា និងលំនៅដ្ឋាន អតិថិជនជាគ្រួសារក្រីក្រ អតិថិជនជាអ្នកបូមទឹកធ្វើកសិកម្ម នៅតំបន់របស់ខ្លួនឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា និងមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទ។
5. អាជ្ញាធរអគ្គិសនីកម្ពុជា និងមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់តួលេខនេះ រហូតទាល់តែអាចទទួលយកបានទាំងអស់គ្នា ទើបមូលនីធិអគ្គិសនីភាវូបនីយកម្មជនបទធ្វើការប៉ះប៉ូវថវិកានៃគម្លាតថ្លៃលក់សម្រាប់អតិថិជនប្រភេទធម្មតា និងលំនៅដ្ឋានឲ្យទៅសេវាករឯកជន។
6. ក្នុងរយៈពេលមិនលើសពី ១២ ខែ មូលនីធិអគ្គិសនីភាវូបនីយកម្មជនបទអាចមានសិទ្ធធ្វើការត្រួតពិនិត្យតួលេខបរិមាណថាមពលប្រចាំខែ ដែលបានអនុវត្តកន្លងទៅឡើងវិញ។ ក្នុងករណីប្រសិនបើរកឃើញមានការខុសឆ្គងក្នុងការផ្តល់ ឬក៏បំប៉ោងតួលេខណាមួយ មូលនីធិអគ្គិសនីភាវូបនីយកម្មជនបទអាចធ្វើការកាត់កងលើថវិកាដែលត្រូវផ្ទេរឲ្យសេវាករឯកជន ដើម្បីប៉ះប៉ូវគម្លាតថ្លៃដែលខុសគ្នាបាន។

* * * * * * * * * *

# កំណត់ហេតុសិក្ខាសាលាស្តីពី
# ការពិនិត្យ និងសម្រេច "ផែនការសម្រាប់អនុវត្ត
# ការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី
# តាមបណ្តាខេត្ត និងរាជធានី"

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់ហេតុសិក្ខាសាលាស្ដីពី
# ការពិនិត្យ និងសម្រេច "ផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្ដាខេត្ត និងរាជធានី"

ឆ្នាំពីរពាន់ដប់ប្រាំ ខែមិថុនា ថ្ងៃទីម្ភៃប្រាំ ម៉ោងប្រាំបី ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានរៀបចំបើកសិក្ខាសាលាស្ដីពីការពិនិត្យ និងសម្រេច "ផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្ដាខេត្ត និងរាជធានី" នៅអាជ្ញាធរអគ្គិសនីកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្ដម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល។ សមាសភាពអញ្ជើញចូលរួមមានថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិក របស់ក្រសួងរ៉ែ និងថាមពល ១៧ នាក់ អាជ្ញាធរអគ្គិសនីកម្ពុជា ២៩ នាក់ អគ្គិសនីកម្ពុជា ១៥ នាក់ តំណាងសាលាខេត្ត ២៥ នាក់ និងតំណាងមន្ទីររ៉ែ និងថាមពល ៣០ នាក់ មកពីខេត្ត និងរាជធានីទាំង ២៥ ។ ជូនភ្ជាប់មកជាមួយបញ្ជីឈ្មោះសមាសភាពអញ្ជើញចូលរួមសរុប ១១៦ នាក់ ។

កម្មវិធីសិក្ខាសាលា មានដូចខាងក្រោម ៖

១.សុន្ទរកថាបើកសិក្ខាសាលាដោយឯកឧត្ដម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងជាប្រធានដឹកនាំអង្គសិក្ខាសាលា ។

២.បទបង្ហាញដោយឯកឧត្ដម **ទី នរិន្ទ** ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ស្ដីពីសេចក្ដីព្រាង "ផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្ដាខេត្ត និងរាជធានី" ។

៣.សេចក្ដីណែនាំបែងចែកក្រុមពិភាក្សា និងណែនាំអំពីការពិភាក្សា ដោយឯកឧត្ដម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងជាប្រធានដឹកនាំអង្គសិក្ខាសាលា ។

៤.ការពិភាក្សាតាមក្រុមពិភាក្សា ដែលក្នុងនោះមាន ៖

- ក្រុមពិភាក្សាទី ១ ដឹកនាំដោយលោក យឹម វិសិដ្ឋ ពិភាក្សាអំពីផែនការនៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តកំពង់ស្ពឺ ខេត្តតាកែវ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកំពង់ឆ្នាំង ។
- ក្រុមពិភាក្សាទី ២ ដឹកនាំដោយលោក ថេង ម៉ារិទ្ធ ពិភាក្សាអំពីផែនការនៅខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម ខេត្តកោះកុង ខេត្តព្រៃវែង និងខេត្តត្បូងឃ្មុំ ។
- ក្រុមពិភាក្សាទី ៣ ដឹកនាំដោយលោក តេង សុខុមាល ពិភាក្សាអំពីផែនការនៅខេត្តស្វាយរៀង, ខេត្តក្រចេះ, ខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តប៉ៃលិន។

៥.របាយការណ៍ និងសំណូមពររបស់ក្រុមពិភាក្សានីមួយៗ ការពិភាក្សារួម និងការបូកសរុបចុងក្រោយរបស់អង្គសិក្ខាសាលាដឹកនាំដោយឯកឧត្ដម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងជាប្រធានដឹកនាំអង្គសិក្ខាសាលា។

សំណូមពររបស់ក្រុមពិភាក្សា និងការសម្រេចរបស់អង្គសិក្ខាសាលា មានដូចខាងក្រោម ៖

**សំណូមពររបស់ក្រុមពិភាក្សាទី ១ និងសេចក្ដីសម្រេចរបស់អង្គសិក្ខាសាលា**

1. ក្រុមពិភាក្សាទី ១ ស្នើសុំកែសម្រួលខ្លឹមសារក្នុងផែនការ ត្រង់ចំណុចថា "កំណត់ឲ្យក្រុមហ៊ុន អូ.អេស.វី.អគ្រេឌីង វិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីបណ្ដាញជាតិទៅ

ជំនួសការផលិតអគ្គិសនីប្រើម៉ាស៊ីនដ្យេសែល ២ តំបន់ គឺទី១ របស់សេវាករ ហុង សេងគ្រី និងទី២ របស់សេវាករ កែ សារឿន នៅស្រុកជលគិរី ខេត្តកំពង់ឆ្នាំង" មកជា "ជម្រុញឲ្យក្រុមហ៊ុន អូ.អេស.វី.អ និងអគ្គិសនីកម្ពុជា វិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនវ៉ុល ២២ គីឡូវ៉ុល ទៅតំបន់នោះ ទៅតាមលទ្ធភាពជាក់ស្តែង តំបន់ណាគួរឲ្យក្រុមហ៊ុន អូ.អេស.វី.អ ធ្វើ និងតំបន់ណាគួរឲ្យអគ្គិសនីកម្ពុជា ធ្វើ" ។ **ចំពោះសំណើនេះ អង្គសិក្ខាសាលា ឯកភាពកែសម្រួលផែនការ តាមសំណើរបស់ក្រុមពិភាក្សា ។**

2. **ក្រុមពិភាក្សាទី ១** ស្នើសុំបន្ថែមនៅក្នុងផែនការ អំពីផែនការដោះស្រាយការផ្គត់ផ្គង់អគ្គិសនីតំបន់នៅស្រុកកំពង់លែង ដែលបច្ចុប្បន្នអ្នកស្នើសុំធ្វើការវិនិយោគ កំពុងមានវិវាទផ្ទៃក្នុងជាមួយគ្នា ដោយស្នើសុំបញ្ចូលក្នុងផែនការ ឲ្យក្រសួងរ៉ែ និងថាមពល ជួយដោះស្រាយបញ្ហាវិវាទនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នេះ ឲ្យបានលឿន និងអាចចេញអាជ្ញាប័ណ្ណធ្វើសេវាកម្មបាន ព្រមទាំងស្នើសុំឲ្យអគ្គិសនីកម្ពុជា ធ្វើការសាងសង់ខ្សែបញ្ជូនទៅកាន់តំបន់ស្រុកកំពង់លែង ដើម្បីដោះស្រាយការផ្គត់ផ្គង់ និងថ្លៃអគ្គិសនី នៅតំបន់នេះ។ **ចំពោះសំណើនេះ អង្គសិក្ខាសាលាឯកភាពបន្ថែមនៅក្នុងផែនការ តាមសំណើ។**
3. **ក្រុមពិភាក្សាទី ១** ស្នើសុំរំកិលពេលវេលាដោះស្រាយការបន្ថយថ្លៃនៅក្នុងតំបន់ចែកចាយទាំង ៨ តំបន់ នៅស្រុកទ្រាំង ស្រុកបូរីជលសារ ស្រុកកោះអណ្តែត ខេត្តតាកែវ ដែលទិញប្រភពអគ្គិសនីបន្តពីលោក ម៉ាក់ ខុម ដែលគ្រោងនឹងអនុវត្តឲ្យបាននៅចុងឆ្នាំ២០១៦ មកអនុវត្តឲ្យបាននៅខែមីនា ឆ្នាំ២០១៦ វិញ ។ សំណើនេះ **អង្គសិក្ខាសាលាបានឯកភាពកែសម្រួលនៅក្នុងផែនការ** ។
4. **ក្រុមពិភាក្សាទី ១** ស្នើសុំរំកិលពេលវេលាដោះស្រាយការការបន្ថយថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយទាំង ៣ នៅស្រុកអង្គជ័យ និងស្រុកជងទង់ ខេត្តកំពត ដែលគ្រោងភ្ជាប់ប្រភពបណ្តាញជាតិមកបន្ថែមលើប្រភពនាំចូលពីប្រទេសវៀតណាម ដែលគ្រោងអនុវត្តឲ្យបាននៅចុងឆ្នាំ២០១៦ មកអនុវត្តឲ្យបាននៅខែមីនា ឆ្នាំ ២០១៦ វិញ ។ **សំណើនេះ អង្គសិក្ខាសាលាបានឯកភាពកែសម្រួលនៅក្នុងផែនការឡើងវិញ** ។
5. **ក្រុមពិភាក្សាទី ១** ស្នើសុំកុំឲ្យប្រើពាក្យនៅក្នុងផែនការថា "លក្ខណៈភូមិសាស្ត្រខេត្តកែប ប្រៀបដូចជាស្រុកមួយនៅក្នុងខេត្តកំពត" ពីព្រោះភូមិសាស្ត្រខេត្តកែប ពិតមែនតែតូច ប៉ុន្តែមានឋានៈជាខេត្តមួយដូចគេដែរ។ **សំណើនេះ អង្គសិក្ខាសាលាបានឯកភាពកែសម្រួលឡើងវិញ** ។

**សំណូមពររបស់ក្រុមពិភាក្សាទី ២ និងសេចក្តីសម្រេចរបស់អង្គសិក្ខាសាលា**

6. នៅខេត្តពោធិ៍សាត់ ស្រុកវាលវែង មានតំបន់ចែកចាយចំនួន ៣ នៅប្រើម៉ាស៊ីនដ្យេសែលផលិតអគ្គិសនី តាមផែនការ កំណត់ឲ្យអគ្គិសនីកម្ពុជា វិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនវ៉ុល ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីទៅតំបន់ទាំង ៣ ឲ្យហើយនៅឆ្នាំ២០១៧ ។ **ក្រុមពិភាក្សាទី ២** ឯកភាពតាមផែនការខាងលើ ប៉ុន្តែស្នើសុំថែងថា ឲ្យអគ្គិសនីកម្ពុជាខិតខំធ្វើឲ្យបានមុនផែនការដែលបានកំណត់ គឺឲ្យបាននៅឆ្នាំ២០១៦។ **អង្គសិក្ខាសាលាសម្រេចឯកភាពតាមសំណើ ដោយដាក់បញ្ចូលក្នុងផែនការថា "ឲ្យអគ្គិសនីកម្ពុជា ខិតខំជម្រុញការងារនេះ ឲ្យបានមុនផែនការ"** ។
7. **ក្រុមពិភាក្សាទី ២** ស្នើសុំជួយដោះស្រាយឲ្យមានប្រភពអគ្គិសនីពីបណ្តាញជាតិចូលទៅដល់កោះជីវ៉ាំង នៅស្រុកឯកភ្នំ ខេត្តបាត់ដំបង ផង ដោយបច្ចុប្បន្ន នៅលើកោះនេះមានសេវាករម្នាក់កំពុងធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីដោយគ្មានអាជ្ញាប័ណ្ណ និងប្រើម៉ាស៊ីនដ្យេសែល។ ដោយតំបន់នេះជាតំបន់ក្នុងដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា **ដូច្នេះអង្គសិក្ខាសាលាសម្រេចឲ្យអគ្គិសនីកម្ពុជា ពិនិត្យដោះស្រាយបញ្ហានេះ តាមសំណើឲ្យបានឆាប់** ។
8. **ក្រុមពិភាក្សាទី ២** ស្នើសុំឲ្យអង្គសិក្ខាសាលាពិនិត្យ ជម្រុញឲ្យសេវាករឈ្មោះ សំណាង សត្យា ធ្វើសេវាកម្មនៅស្រុកសង្កែ ខេត្តបាត់ដំបង ធ្វើការពង្រីកខ្សែបណ្តាញទៅចូលទៅភូមិដែលនៅសល់ឲ្យបានលឿន។ **អង្គសិក្ខាសាលាសម្រេចឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ចុះពិនិត្យ និងជម្រុញតាមសំណើ។**

សំណូមពររបស់ក្រុមពិភាក្សាទី ៣ និងសេចក្តីសម្រេចរបស់អង្គសិក្ខាសាលា

៦. ក្រុមពិភាក្សាទី ៣ បានឯកភាពតាមសេចក្តីព្រាងផែនការបន្ថយថ្លៃ គ្រាន់តែមានចម្ងល់ និងសំណូមពរមួយចំនួន ក្រៅផែនការបន្ថយថ្លៃលក់អគ្គិសនី ។ **អង្គសិក្ខាសាលាបានទទួលយកសំណូមពរទាំងនេះ និងសម្រេចឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណ ពិភាក្សាគ្នា និងពិនិត្យដោះស្រាយជូនតាមសំណើ។**

ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងជាប្រធានដឹកនាំអង្គសិក្ខាសាលាបានធ្វើការបូកសរុប អំពីការពិភាក្សារួមលើមតិរបស់ក្រុមពិភាក្សានីមួយៗ ដោយឯកភាពធ្វើការកែសម្រួល "ផែនការសម្រាប់អនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីតាមបណ្តាខេត្ត និងរាជធានី" តាមអ្វីដែលអង្គសិក្ខាសាលបានសម្រេចដូចរៀបរាប់ខាងលើ ក្រៅពីនោះ គឺរក្សាទុកខ្លឹមសារ តាមសេចក្តីព្រាងដដែល។

ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល និងជាប្រធានដឹកនាំអង្គសិក្ខាសាលា បានមានមតិប្រកាសបិទអង្គប្រជុំ និងបានថ្លែងអំណរគុណដល់ឯកឧត្តម លោក លោកស្រីទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងអង្គសិក្ខាសាលាថ្ងៃនេះ មានដំណើរការប្រកបដោយជោគជ័យ និងមានអត្ថន័យយ៉ាងជ្រាលជ្រៅបំផុត។

អង្គសិក្ខាសាលាបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំពីរ និងដប់ប្រាំនាទី នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសស្និទស្នាលបំផុត ។

**អ្នករៀបចំកំណត់ហេតុ**

**គេង សុខុមាល**

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**
**និងជាសមាជិកអង្គប្រជុំ**

**បណ្ឌិត.ធី នរិន្ទ**

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុក**
**អគ្គនាយកក្រុមហ៊ុនអគ្គិសនីកម្ពុជា**
**និងជាសមាជិកអង្គប្រជុំ**

**កែវ រតនៈ**

**បានឃើញ និង ឯកភាព**
**រដ្ឋមន្ត្រី ក្រសួងរ៉ែ និងថាមពល**
**និងជាប្រធានដឹកនាំអង្គសិក្ខាសាលា**

**ស៊ុយ សែម**

# សេចក្តីផ្តើម និងសេចក្តីសន្និដ្ឋានទូទាំងប្រទេស
# អំពីការអនុវត្ត ការបន្ថយអត្រា និងគម្លាតថ្លៃលក់
# តាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា

# សេចក្តីផ្តើម

យោងតាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់ "ផែនការយុទ្ធសាស្ត្រដើម្បីបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០" បានកំណត់ថា ៖ **លទ្ធភាពនៃការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី នៅព្រះរាជាណាចក្រកម្ពុជា នៅតាមតារាងបន្ថយអត្រាថ្លៃលក់ដែលបានគ្រោងនៅក្នុងប្រកាសក្រសួង គឺអាចធ្វើបានតែក្នុងប្រព័ន្ធផ្គត់ផ្គង់ប្រភពអគ្គិសនីផ្ទាល់របស់បណ្តាញជាតិ ប៉ុណ្ណោះ ពុំទាន់អាចអនុវត្តចំពោះតំបន់នៅឆ្ងាយ ដែលត្រូវផ្តល់ប្រភពបន្តគ្នាជាបណ្តោះអាសន្ន តំបន់ប្រើប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង និងតំបន់ផលិតប្រភពអគ្គិសនីដោយខ្លួនឯងឡើយ** ។ ដែននៃតំបន់ដែលត្រូវអនុវត្តការបន្ថយថ្លៃ និងគម្លាតថ្លៃតាមផែនការយុទ្ធសាស្ត្រខាងលើ ត្រូវកំណត់ដោយមានការឯកភាពគ្នារវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ដើម្បីធ្វើយ៉ាងណាឲ្យបានសមស្របតាមទំហំថវិកាដែលអគ្គិសនីកម្ពុជាមាន ដើម្បីផ្ទេរទៅឲ្យមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ សម្រាប់ជួយប៉ះប៉ូវលំអៀងថ្លៃដែលខុសគ្នា រវាងថ្លៃទទួលបានពីការគណនាតាមគោលការណ៍អាជីវកម្មត្រឹមត្រូវ និងថ្លៃដែលបានកំណត់តាមផែនការ ។ ក្នុងករណីចាំបាច់ ក្នុងគោលបំណងផ្តល់នូវផលប្រយោជន៍បណ្តោះអាសន្នឲ្យតំបន់ចែកចាយណាមួយ ដែលនៅក្បែរតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិ ប៉ុន្តែពុំទាន់អាចធ្វើការវិនិយោគបង្កើតអនុស្ថានីយ និងពង្រីកបណ្តាញបញ្ជូនរងឲ្យទៅគ្របដណ្តប់តំបន់ចែកចាយនោះ តាមបទដ្ឋានបច្ចេកទេសបាន អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា អាចឯកភាពគ្នាអនុញ្ញាតឲ្យមានការផ្តល់ប្រភពបន្តគ្នាជាបណ្តោះអាសន្នសិន ដោយកំណត់ថ្លៃលក់អគ្គិសនីដោយឡែកណាមួយ ខុសពីថ្លៃក្នុងផែនការរួមខាងលើ ក្នុងរយៈពេលបណ្តោះអាសន្ន រហូតដល់តំបន់នោះ ត្រូវបានគ្របដណ្តប់ត្រឹមត្រូវដោយមានអនុស្ថានីយ និងបណ្តាញបញ្ជូនរងតាមបទដ្ឋានបច្ចេកទេស។ ចំពោះតំបន់ចែកចាយទាំងឡាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល និងនៅតំបន់ទាំងឡាយដែលនាំចូលប្រភពអគ្គិសនីតាមរូបភាពតូចៗ ពីប្រទេសជិតខាង ដើម្បីបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីនៅទីនោះ ឲ្យដូចផែនការយុទ្ធសាស្ត្រខាងលើ គេត្រូវពង្រីកបណ្តាញបញ្ជូនរងចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ ឲ្យទៅគ្របដណ្តប់តំបន់ទាំងនោះសិន ។

តាមខ្លឹមសារដូចបានជំរាបខាងលើ ការអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីខាងលើ តាមបណ្តារាជធានី/ខេត្ត ទាំង ២៥ ក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈ និងពេលវេលាអនុវត្តមិនដូចគ្នាទេ ហើយកន្លែងខ្លះ ដើម្បីអនុវត្តបាន គេត្រូវធ្វើការអភិវឌ្ឍន៍ពង្រីកបណ្តាញបញ្ជូនទៅគ្របដណ្តប់តំបន់នោះផ្ទាល់ ទើបអាចអនុវត្តបាន ដូច្នេះដើម្បីអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាលកម្ពុជាឲ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព ព្រមទាំងបង្ហាញឲ្យមានតម្លាភាពផង គេត្រូវធ្វើការសិក្សាលម្អិតអំពីភាពគ្របដណ្តប់របស់ប្រភពអគ្គិសនីបណ្តាញជាតិ ស្ថានភាពផ្គត់ផ្គង់អគ្គិសនី និងស្ថានភាពថ្លៃអគ្គិសនី តាមតំបន់នីមួយៗ ដើម្បីកំណត់ថា តើតំបន់នោះ អាចអនុវត្តថ្លៃអគ្គិសនីតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលឬទេ ? ។ នៅពេលធ្វើការសិក្សាលម្អិតអំពីបញ្ហាទាំងនេះ តាមបណ្តាខេត្ត/ក្រុងនីមួយៗ គេមិនត្រឹមតែមើលឃើញបញ្ហាផ្គត់ផ្គង់អគ្គិសនី និងបញ្ហាថ្លៃអគ្គិសនីប៉ុណ្ណោះទេ តែគេក៏បានមើលឃើញនូវតម្រូវការនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់បន្ថែម នៅក្នុងខេត្ត/រាជធានីនោះ ផងដែរ ដើម្បីកែសម្រួលឲ្យតំបន់ចែកចាយដែលមិនទាន់

មានលទ្ធភាពអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីបាន អាចប្រែក្លាយទៅជាតំបន់ចែកចាយដែលអាចអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល ខាងលើ។

ក្នុងការសិក្សាផែនការ ដើម្បីអនុវត្តថ្លៃអគ្គិសនីតាមផែនការបន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរាជធានី/ខេត្តនីមួយៗ យើងបែងចែកការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជា ៣ ប្រភេទ ដោយប្រើពាក្យគន្លឹះបច្ចេកទេសចំនួន ៣ គឺ ៖ ទី១.**ការផ្គត់ផ្គង់ដុំ** ទី២.**ការផ្គត់ផ្គង់ធំ** និងទី៣.**ការផ្គត់ផ្គង់រាយ** ។ **ការផ្គត់ផ្គង់ដុំ** សំដៅការផ្គត់ផ្គង់ដុលចេញពីអនុស្ថានីយបណ្តាញជាតិផ្ទាល់ ដែលមានអានុភាពចាប់ពី ១០ មេហ្គាវ៉ាត់ឡើងទៅក្នុងអតិថិជន១ ។ **ការផ្គត់ផ្គង់ធំ** សំដៅការផ្គត់ផ្គង់ឲ្យអតិថិជនធំៗ តាមតង់ស្យុងមធ្យមចេញពីបណ្តាញបញ្ជូនរង ដែលជាធម្មតាត្រូវមានអានុភាពចាប់ពី ២៧៥ កាវ៉េអា រហូតដល់ ១០ មេហ្គាវ៉ាត់ ក្នុងអតិថិជន ១ ។ **ការផ្គត់ផ្គង់រាយ** សំដៅការផ្គត់ផ្គង់អានុភាពតូច និងមធ្យមឲ្យអតិថិជនតាមរយៈបណ្តាញចែកចាយរបស់អ្នកចែកចាយអគ្គិសនីនៅតំបន់ចែកចាយនីមួយៗ ។ ដោយសារតែអ្នកចែកចាយអគ្គិសនី ជាធម្មតាមានបណ្តាញ ២ ប្រភេទ គឺបណ្តាញតង់ស្យុងមធ្យម និងបណ្តាញតង់ស្យុងទាប ដូច្នេះការផ្គត់ផ្គង់រាយមាន ២ ប្រភេទ គឺទី១ **ការផ្គត់ផ្គង់មធ្យម** ដែលជាការផ្គត់ផ្គង់តាមបណ្តាញតង់ស្យុងមធ្យមរបស់អ្នកចែកចាយ ចំពោះអានុភាពចាប់ពី ៥០ កាវ៉េអា រហូតដល់ ៥ មេហ្គាវ៉ាត់ និងទី២ **ការផ្គត់ផ្គង់តូច** ដែលជាការផ្គត់ផ្គង់តាមខ្សែបណ្តាញតង់ស្យុងទាបរបស់អ្នកចែកចាយ ចំពោះអ្នកប្រើប្រាស់តូចៗដែលមានកម្លាំងប្រើប្រាស់ចាប់ពី ៥ អំពែរ រហូតដល់ ១៥០ អាំពែរ ១ ហ្វា ឬ ៣ ហ្វា ។

ដើម្បីបង្ហាញដោយសង្ខេបអំពីលទ្ធផលនៃការសិក្សា តាមបណ្តារាជធានី/ខេត្ត ទាំង ២៥ អំពីលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនី និងលទ្ធភាពនៃការអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា តំបូងយើងពិនិត្យមើលលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនីដុំ និងលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនីធំរបស់រាជធានី/ខេត្តនីមួយៗ សិន មានន័យថា ពិនិត្យមើលអំពីហេដ្ឋារចនាសម្ព័ន្ធធំរបស់បណ្តាញជាតិ គឺអនុស្ថានីយ និងបណ្តាញបញ្ជូនរងនៅរាជធានី/ខេត្តនោះ តើមានឬទេ ? ។ បន្ទាប់ពីពិនិត្យមើលលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនីដុំ និងលទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនីធំរួច ទើបយើងពិនិត្យអំពីការផ្គត់ផ្គង់អគ្គិសនីរាយ តាមតំបន់ចែកចាយអគ្គិសនីនីមួយៗ ដែលរាជធានី/ខេត្តនីមួយៗ នោះមាន។ ក្នុងការពិនិត្យអំពីការផ្គត់ផ្គង់អគ្គិសនីរាយ តំបន់ចែកចាយរបស់រាជធានី/ខេត្ត ត្រូវបានចែកជា ៤ ប្រភេទគឺ ទី១.**តំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីអនុស្ថានីយ ឬពីបណ្តាញបញ្ជូនរងរបស់បណ្តាញជាតិផ្ទាល់** ទី២.**តំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីបណ្តាញជាតិដែរ ប៉ុន្តែតាមរយៈការបញ្ជូនបន្តគ្នាជាបណ្តោះអាសន្ន** ទី៣.**តំបន់ចែកចាយដែលប្រើប្រភពអគ្គិសនីនាំចូល ដើម្បីធ្វើការផ្គត់ផ្គង់** និងទី៤.**តំបន់ចែកចាយដែលនៅប្រើម៉ាស៊ីនម៉ាស៊ូតសេល ដើម្បីផលិតអគ្គិសនី** ។ ដូច្នេះនៅក្នុងតារាងសង្ខេបបង្ហាញអំពីលទ្ធផលនៃការសិក្សា តាមបណ្តារាជធានី/ខេត្ត ទាំង ២៥ ស្តីអំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងលទ្ធភាពនៃការអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី យើងចែកការពិនិត្យជា ៥ ចំណុច ដូចខាងក្រោម ៖

១. **ការផ្គត់ផ្គង់ផ្ទាល់តាមអនុស្ថានីយ និងបណ្តាញបញ្ជូនរង៖** ចំណុចនេះ យើងពិនិត្យអំពីលទ្ធភាពនៃការផ្គត់ផ្គង់ដុំ និងលទ្ធភាពនៃការផ្គត់ផ្គង់ធំ នៅក្នុងរាជធានី/ខេត្តនោះ ទៅតាមស្ថានភាព

ដែលរាជធានី/ខេត្តនោះ មានអនុស្ថានីយ និង/ឬ បណ្តាញបញ្ជូនរង ឬគ្មាន ។ ខេត្តខ្លះ ដែលមានអនុស្ថានីយ និងមានបណ្តាញបញ្ជូនរង យើងបានប្រើពាក្យ **អាចផ្គត់ផ្គង់ជុំ និងធំតាមថ្លៃផែនការ** មានន័យថា អាចមានលទ្ធភាពផ្គត់ផ្គង់ជុំផង និងធំផង តាមអត្រាថ្លៃដែលកំណត់ក្នុងផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ខេត្តខ្លះមិនមានអនុស្ថានីយទេ តែមានបណ្តាញបញ្ជូនរង ដូច្នេះយើងបានប្រើពាក្យ **អាចផ្គត់ផ្គង់ធំតាមថ្លៃផែនការ** មានន័យថា អាចផ្គត់ផ្គង់ត្រឹមរូបភាពធំ តាមអត្រាថ្លៃដែលកំណត់ក្នុងផែនការរបស់រាជរដ្ឋាភិបាល ។ ខេត្តខ្លះមិនទាន់មានអនុស្ថានីយ និងបណ្តាញបញ្ជូនរងទេ តែគ្រោងមានអនុស្ថានីយ និង/ឬ បណ្តាញបញ្ជូនរង នៅឆ្នាំបន្ទាប់ណាមួយ ដូច្នេះយើងបានប្រើពាក្យ **នឹងផ្គត់ផ្គង់ជុំ (ឬធំ) តាមថ្លៃផែនការ** មានន័យថា នឹងអាចផ្គត់ផ្គង់តាមរូបភាពជុំ និង/ឬ ធំតាមអត្រាថ្លៃដែលកំណត់ក្នុងផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា នៅឆ្នាំណាមួយខាងមុខ ។

២. **តំបន់ចែកចាយដែលភ្ជាប់ប្រភពដោយផ្ទាល់ជាមួយបណ្តាញជាតិ** ៖ ចំណុចនេះ យើងពិនិត្យអំពីការផ្គត់ផ្គង់រាយ នៅតំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីអនុស្ថានីយ ឬពីខ្សែបណ្តាញបញ្ជូនរងដែលចេញពីអនុស្ថានីយដោយផ្ទាល់ ។ តំបន់ចែកចាយប្រភេទនេះ អាចផ្គត់ផ្គង់អគ្គិសនីជារូបភាពតូច និងមធ្យម តាមការបន្ថយថ្លៃដែលកំណត់ក្នុងផែនការរាជរដ្ឋាភិបាលទាំងស្រុង ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ដែលក្នុងតារាងសង្ខេបយើងប្រើពាក្យថា "**អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ**" សំដៅលទ្ធភាពនៃការផ្គត់ផ្គង់រាយ តាមការបន្ថយអត្រា និងគម្លាតថ្លៃ នៃផែនការរបស់រាជរដ្ឋាភិបាលចាប់ពីខែមីនា ឆ្នាំ ២០១៦ ។

៣. **តំបន់ចែកចាយដែលភ្ជាប់ប្រភពបណ្តាញជាតិ ដោយការបញ្ជូនបន្ត ឬការបញ្ជូនក្នុងចម្ងាយឆ្ងាយ** ៖ ចំណុចនេះ យើងពិនិត្យអំពីការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយដែលទទួលបានប្រភពអគ្គិសនីពីបណ្តាញជាតិ ដោយសារការបញ្ជូនបន្ត ឬការទិញបន្តគ្នា ក្នុងពេលដែលបណ្តាញបញ្ជូនរងនៅក្នុងខេត្តនោះ ពុំទាន់ពង្រីកខ្លួនទៅគ្របដណ្តប់តំបន់នោះ ដោយផ្ទាល់នៅឡើយ ។ តំបន់ចែកចាយប្រភេទនេះ កំពុងឋិតនៅក្នុងដំណាក់កាលបណ្តោះអាសន្ន ដែលមិនទាន់អាចអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល បាននៅឡើយ ពីព្រោះនៅមានការចំណាយច្រើនលើការបញ្ជូនបន្តគ្នា និងលើការបាត់បង់ថាមពលដែលមានចំនួនច្រើន ដោយសារតែខ្សែបណ្តាញមានចម្ងាយឆ្ងាយ ។ ចំពោះតំបន់ចែកចាយប្រភេទនេះ គេត្រូវធ្វើការអភិវឌ្ឍន៍ពង្រីកបណ្តាញបញ្ជូនរង បញ្ជូនប្រភពអគ្គិសនីរបស់បណ្តាញជាតិទៅគ្របដណ្តប់តំបន់ចែកចាយទាំងនេះ ដោយផ្ទាល់សិន ទើបអាចអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃបាន ដូច្នេះក្នុងតារាងសង្ខេបយើងប្រើពាក្យថា "**ដើម្បីអនុវត្តថ្លៃតាមផែនការ**" សំដៅការអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាលនៅពេលដែលតំបន់ចែកចាយទាំងនោះ បានភ្ជាប់ជាមួយបណ្តាញបញ្ជូនរងរបស់បណ្តាញជាតិដោយផ្ទាល់។

៤. **តំបន់ចែកចាយដែលភ្ជាប់ប្រភពអគ្គិសនី ដោយការនាំចូល (ផ្ទាល់ ឬដោយការបញ្ជូនបន្ត)** ៖ ចំណុចនេះ យើងពិនិត្យអំពីការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយដែលទទួលបានប្រភពអគ្គិសនីពីការនាំចូលពីប្រទេសជិតខាង ដូចជាពីប្រទេសវៀតណាម ប្រទេសថៃ និងប្រទេសឡាវ ដែលតំបន់ខ្លះ គឺបាននាំចូលដោយផ្ទាល់ តំបន់ខ្លះទៀត ទិញបន្តពីតំបន់នាំចូលដោយផ្ទាល់ និងតំបន់ខ្លះ

ទៀត ទិញពីបណ្តាញបញ្ជូនរងដែលយកប្រភពអគ្គិសនីពីការនាំចូលខាងលើ ។ តំបន់ចែកចាយប្រភេទនេះ ពីមុនមក គឺមានថ្លៃអគ្គិសនីទាបជាងតំបន់ដ៏ទៃទៀត ដោយថ្លៃអគ្គិសនីនាំចូលពីប្រទេសជិតខាងមានថ្លៃទាបជាងប្រភពអគ្គិសនីដែលមានក្នុងស្រុក ប៉ុន្តែបច្ចុប្បន្ន ដោយសារអត្រាថ្លៃនាំចូលអគ្គិសនីពីប្រទេសជិតខាងកាន់តែឡើងថ្លៃ ធ្វើឲ្យថ្លៃដើមនៃអគ្គិសនីនៅតំបន់ចែកចាយទាំងនោះ កាន់តែកើនឡើង ដែលទាមទារត្រូវធ្វើការកែសម្រួលថ្លៃអគ្គិសនីឡើងវិញ ជាបន្តបន្ទាប់ ។ ទោះបីជាយ៉ាងណាក៏ដោយ ដោយសារតែតំបន់ចែកចាយប្រភេទនេះ ជាតំបន់ដែលទទួលបាននូវផលប្រយោជន៍ ពីថ្លៃអគ្គិសនីទាបជាងគេយូរមកហើយ និងម្យ៉ាងទៀតថ្លៃអគ្គិសនីបច្ចុប្បន្នក៏មិនខ្ពស់ខ្លាំងដែរ ដូច្នេះយើងអាចរក្សាថ្លៃទាំងនេះឲ្យនៅដដែលជាបណ្តោះអាសន្នសិន ទម្រាំដល់ពេលវេលា ដែលតំបន់ទាំងនោះត្រូវប្តូរមកយកប្រភពអគ្គិសនីពីបណ្តាញជាតិវិញ ។ ក្នុងតារាងសង្ខេប យើងប្រើពាក្យថា "**ដើម្បីអនុវត្តថ្លៃតាមផែនការ**" សំដៅការអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាល នៅពេលដែលតំបន់ចែកចាយទាំងនោះ បានប្តូរមកយកប្រភពអគ្គិសនីពីបណ្តាញជាតិវិញ ។

៥. **តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដៀសែល** ៖ ចំណុចនេះ យើងពិនិត្យអំពីការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយ ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ។ តំបន់ចែកចាយប្រភេទនេះ គឺជាតំបន់ដែលមានថ្លៃអគ្គិសនីខ្ពស់ ការផ្គត់ផ្គង់មិនមានគុណភាព និងស្ថេរភាព ដូច្នេះចាំបាច់ត្រូវពង្រីកបណ្តាញជាតិ និងបណ្តាញបញ្ជូនរងទៅគ្របដណ្តប់ ដើម្បីឲ្យតំបន់ចែកចាយទាំងនេះ អាចក្លាយទៅជាតំបន់ភ្ជាប់ប្រភពអគ្គិសនីផ្ទាល់របស់បណ្តាញជាតិ ដែលអាចបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមផែនការរបស់រាជរដ្ឋាភិបាលបាន ។ ក្នុងតារាងសង្ខេបយើងប្រើពាក្យថា "**ដើម្បីអនុវត្តថ្លៃតាមផែនការ**" សំដៅការអនុវត្តការបន្ថយអត្រា និងគម្លាតថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាល នៅពេលដែលយើងពង្រីកបណ្តាញជាតិ និងបណ្តាញបញ្ជូនរង ដើម្បីឲ្យតំបន់ចែកចាយទាំងនោះ អាចប្តូរពីការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល មកយកប្រភពអគ្គិសនីពីបណ្តាញជាតិវិញ ។

ក្រោយពីការសិក្សាលម្អិតអំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងលទ្ធភាពបន្ថយថ្លៃអគ្គិសនីតាមតំបន់នានាក្នុងរាជធានី/ខេត្តនីមួយៗ យើងបានរៀបចំជារបាយការណ៍ ៣ គឺ ទី១.សេចក្តីសន្និដ្ឋានទូទាំងប្រទេសអំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងការអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល និងទី២.តារាងសង្ខេបលទ្ធផលនៃការសិក្សាតាមរាជធានី/ខេត្តនីមួយៗ និងទី៣.បាយការលម្អិតនៃការសិក្សាលទ្ធភាពនៃការផ្គត់ផ្គង់ និងលទ្ធភាពនៃការអនុវត្តថ្លៃតាមផែនការបន្ថយអត្រា និងគម្លាតថ្លៃ របស់រាជរដ្ឋាភិបាល តាមរាជធានី/ខេត្តនីមួយៗ ។

# សេចក្តីសន្និដ្ឋានទូទាំងប្រទេស អំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងការអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល

ក្រោយពីការសិក្សាលម្អិតអំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងលទ្ធភាពបន្ថយថ្លៃអគ្គិសនីតាមតំបន់នានាក្នុងរាជធានី/ខេត្តនីមួយៗ យើងអាចធ្វើការសន្និដ្ឋានទូទាំងប្រទេស អំពីលទ្ធភាពផ្គត់ផ្គង់អគ្គិសនី និងលទ្ធភាពអនុវត្តផែនការបន្ថយអត្រា និងគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល ចំនួន ៦ ចំណុច ដូចខាងក្រោម ៖

១. **ចំពោះការផ្គត់ផ្គង់អគ្គិសនីដុំ និងការអនុវត្តថ្លៃលក់អគ្គិសនីដុំ តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល** ៖ ជាគោលការណ៍បច្ចេកទេស រាជធានី/ខេត្ត ដែលអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីដុំជូនអ្នកប្រើប្រាស់អគ្គិសនី តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលបាន គឺរាជធានី/ខេត្ត ដែលមានខ្សែបណ្តាញជាតិទៅដល់ និងមានអនុស្ថានីយបណ្តាញជាតិ ។ នៅខែ មីនា ឆ្នាំ ២០១៦ នឹងមានរាជធានី/ខេត្ត ចំនួន ១៤ មានអនុស្ថានីយបណ្តាញជាតិរបស់ខ្លួនផ្ទាល់ ដែលអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីដុំជូនអ្នកប្រើប្រាស់អគ្គិសនីបាន គឺ ៖ រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ, ខេត្តតាកែវ, ខេត្តកំពត, ខេត្តកែប, ខេត្តព្រះសីហនុ, ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប, ខេត្តកំពង់ចាម និងខេត្តកោះកុង ។ នៅឆ្នាំ ២០១៧ នឹងមានខេត្ត ២ ទៀត គឺខេត្តព្រៃវែង និងខេត្តស្វាយរៀង នឹងមានអនុស្ថានីយបណ្តាញជាតិ ដែលអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីដុំ ជូនអ្នកប្រើប្រាស់អគ្គិសនីបានដែរ ។ នៅឆ្នាំ ២០១៨ នឹងមានខេត្ត ៣ បន្ថែមទៀត គឺខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តកំពង់ធំ ដែលអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីដុំ ជូនអ្នកប្រើប្រាស់អគ្គិសនីបានដែរ ។ ដូច្នេះរហូតដល់ឆ្នាំ ២០១៨ នៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងមានរាជធានី/ខេត្ត ចំនួន ១៩ ដែលអាចអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីដុំ ជូនអ្នកប្រើប្រាស់អគ្គិសនី តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល បាន ។

២. **ចំពោះការផ្គត់ផ្គង់អគ្គិសនីធំ និងការអនុវត្តថ្លៃលក់អគ្គិសនីធំ តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល** ៖ ជាគោលការណ៍បច្ចេកទេស រាជធានី/ខេត្ត ដែលអាចមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីធំ ជូនអ្នកប្រើប្រាស់អគ្គិសនីតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល គឺរាជធានី/ខេត្តណាដែលមានខ្សែបណ្តាញបញ្ជូនរង ចេញពីអនុស្ថានីយបណ្តាញជាតិ ក្នុងចម្ងាយសមស្របតាមបទដ្ឋានបច្ចេកទេស ។ តាមគោលការណ៍ខាងលើនេះ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ មាន រាជធានី/ខេត្តចំនួន ១៨ មានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីធំឲ្យអ្នកប្រើប្រាស់អគ្គិសនី តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលបាន ដែលក្នុងនោះ ទី១.មានរាជធានី/ខេត្ត ដែលមានអនុស្ថានីយផ្ទាល់ចំនួន ១៤ គឺ ៖ រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ, ខេត្តតាកែវ, ខេត្តកំពត, ខេត្តកែប, ខេត្តព្រះសីហនុ, ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប, ខេត្តកំពង់ចាម និងខេត្តកោះកុង និង ទី២.រាជធានី/ខេត្តចំនួន ៤ ដែលឋិតនៅជិតរាជធានី/ខេត្ត មានអនុស្ថានីយ ក្នុងចម្ងាយសមស្របតាមគោលការណ៍បច្ចេកទេស ដែលអាចពង្រីកបណ្តាញបញ្ជូនរងទៅគ្របដណ្តប់ផ្នែកណាមួយគឺ ៖ ខេត្តត្បូង

ឃុំ ខេត្តព្រៃវែង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ។ នៅឆ្នាំ ២០១៧ និង ២០១៨ ដោយសារមានរាជធានី/ខេត្ត ចំនួន ៥ ខេត្ត គឺខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តក្រចេះ ខេត្តស្ទឹងត្រែង និងខេត្តកំពង់ធំ នឹងមានអនុស្ថានីយផ្ទាល់របស់ខ្លួនដែរ (ខេត្តព្រៃវែង មាននៅក្នុងខេត្តទាំង ១៩ ពីមុនរួចហើយ) ដូច្នេះ នៅឆ្នាំ ២០១៨ នឹងមានរាជធានី/ខេត្ត សរុបចំនួន ២២ ដែលមានលទ្ធភាពផ្គត់ផ្គង់អគ្គិសនីធំ តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលបាន ដែលក្នុងនោះ មានរាជធានី/ខេត្ត ដែលមានអនុស្ថានីយផ្ទាល់ខ្លួនចំនួន ១៩ និងរាជធានី/ខេត្តចំនួន ៣ ដែលអាចពង្រីកខ្សែបណ្តាញបញ្ជូនរងទៅគ្របដណ្តប់ការផ្គត់ផ្គង់បាន។ ជាសរុបចំពោះការផ្គត់ផ្គង់អគ្គិសនីក្នុងរូបភាពធំ នៅឆ្នាំ ២០១៨ នៅសល់តែខេត្ត ៣ ប៉ុណ្ណោះ ដែលត្រូវគិតគូរដោះស្រាយ គឺខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តព្រះវិហារ ។ ការផ្គត់ផ្គង់អគ្គិសនីធំតាមបណ្តាញបញ្ជូនរង ចេញពីអនុស្ថានីយបណ្តាញជាតិទៅកាន់រាជធានី/ខេត្ត ទាំងនេះ នឹងត្រូវអនុវត្តថ្លៃតាមផែនការបន្ថយអត្រាថ្លៃផ្គត់ផ្គង់ធំទូទាំងប្រទេសរបស់រាជរដ្ឋាភិបាល ក្នុងនោះ តំបន់ចែកចាយណាដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញបញ្ជូនរងនេះ **នឹងអាចអនុវត្តថ្លៃតាមផែនការបាន** ។

៣. **ចំពោះការផ្គត់ផ្គង់អគ្គិសនីរាយនៅតាមតំបន់ចែកចាយ ដែលភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្ទាល់ និងអាចអនុវត្តថ្លៃលក់អគ្គិសនី តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលបាន** ៖ តាមស្ថិតិ **នៅខែ ឧសភា ឆ្នាំ ២០១៥** ក្នុងចំណោមតំបន់ចែកចាយដែលកម្ពុជា មានចំនួន ៣៥៨ តំបន់ទូទាំងប្រទេស (គិតតំបន់ចែកចាយរបស់ EDC ដាច់ដោយឡែកពីគ្នាតាមតំបន់នីមួយៗ) **មានតំបន់ចែកចាយចំនួន ២២៨ តំបន់** កំពុងទទួលប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ និង/ឬពី បណ្តាញបញ្ជូនរង ចេញពីបណ្តាញជាតិដោយផ្ទាល់ ដែលអាចអនុញ្ញាតឲ្យយើងធ្វើការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាលភ្លាមៗ បាន ។ យោងតាមគម្រោងនៃការអភិវឌ្ឍន៍បន្តទៀត រហូតដល់**ខែ មីនា ឆ្នាំ ២០១៦** នឹងមានតំបន់ចែកចាយចំនួន ២៧ ទៀត នឹងបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិដោយផ្ទាល់បាន ដែលអាចធ្វើឲ្យតំបន់ដែលអនុញ្ញាតឲ្យយើងធ្វើការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាលកើនឡើងដល់ **២៥៥ តំបន់** ក្នុងចំណោមតំបន់ចែកចាយទូទាំងប្រទេសចំនួន ៣៥៨ តំបន់ ។ តំបន់ចែកចាយដែលអាចអនុវត្តថ្លៃលក់អគ្គិសនី តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលទាំង ២៥៥ តំបន់នេះ ឋិតនៅក្នុងរាជធានី/ខេត្ត ចំនួន ១៨ ក្នុងព្រះរាជាណាចក្រកម្ពុជា គឺ ៖ រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តកំពង់ស្ពឺ, ខេត្តតាកែវ, ខេត្តកំពត, ខេត្តកែប, ខេត្តព្រះសីហនុ, ខេត្តកំពង់ឆ្នាំង, ខេត្តពោធិ៍សាត់, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តសៀមរាប, ខេត្តកំពង់ចាម, ខេត្តកោះកុង, ខេត្តត្បូងឃ្មុំ, ខេត្តព្រៃវែង, ខេត្តកំពង់ធំ និងខេត្តឧត្តរមានជ័យ ។ យោងតាមគម្រោងនៃការអភិវឌ្ឍន៍បន្តទៀត រហូតដល់ **ឆ្នាំ ២០១៧** នឹងមានតំបន់ចែកចាយចំនួន ២៨ (ក្នុងនោះ មានតំបន់នាំចូលអគ្គិសនី ១៥ តំបន់ និងតំបន់ផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ១៣) ទៀត នឹងបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិដោយផ្ទាល់បាន ដែលអាចធ្វើឲ្យតំបន់ដែលអនុញ្ញាតឲ្យយើងធ្វើការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ

តាមផែនការរបស់រាជរដ្ឋាភិបាល កើនឡើងដល់ **២៨៣ តំបន់** ក្នុងចំណោមតំបន់ចែកចាយទូទាំងប្រទេសចំនួន ៣៥៨ តំបន់ ។ បន្ទាប់មក យោងតាមគម្រោងនៃការអភិវឌ្ឍន៍បន្តទៀត រហូតដល់ **ឆ្នាំ ២០១៨** នឹងមានតំបន់ចែកចាយចំនួន ៥៤ (ក្នុងនោះ មានតំបន់ទិញបន្តគ្នាចំនួន ៩ តំបន់, តំបន់នាំចូលអគ្គិសនី ១៦ តំបន់ និងតំបន់ផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ២៩) ទៀត នឹងបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិដោយផ្ទាល់បាន ដែលអាចធ្វើឲ្យតំបន់ដែលអនុញ្ញាតឲ្យយើងធ្វើការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាល កើនឡើងដល់ **៣៣៧ តំបន់** ក្នុងចំណោមតំបន់ចែកចាយទូទាំងប្រទេសចំនួន ៣៥៨ តំបន់ ។

៤. **ចំពោះការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ចែកចាយ ដែលភ្ជាប់ប្រភពពីបណ្តាញជាតិ ប៉ុន្តែ ពុំទាន់អាចអនុវត្តថ្លៃ តាមផែនការរបស់រាជរដ្ឋាភិបាលនៅឡើយ ៖** នៅខែឧសភា ឆ្នាំ ២០១៥ មានតំបន់ចែកចាយចំនួន ២៧ តំបន់ ដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិដែរ ប៉ុន្តែ ពុំទាន់អាចអនុវត្តតាមផែនការរបស់រាជរដ្ឋាភិបាលបាននៅឡើយ ដែលក្នុងនោះមាន ៖ តំបន់ឧស្សាហកម្មចំនួន ៣ តំបន់ ដែលត្រូវអនុវត្តថ្លៃតាមគោលការណ៍ដោយឡែក និងតំបន់ទិញពីបណ្តាញបញ្ជូនរងឆ្ងាយ ឬទិញបន្តគ្នាចំនួន ២៤ តំបន់ ដែលមានចំណាយនៅខ្ពស់ ពុំទាន់អាចបន្ថយថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាលបាន ក្នុងនោះ នៅខេត្តកណ្តាល មាន ២ តំបន់, ខេត្តបាត់ដំបង មាន ៤ តំបន់, ខេត្តសៀមរាប មាន ៣ តំបន់, ខេត្តកំពង់ចាម មាន ២ តំបន់, ខេត្តព្រៃវែង មាន ៤ តំបន់, ខេត្តត្បូងឃ្មុំ មាន ៧ តំបន់ និងខេត្តកំពង់ធំ មាន ២ តំបន់ ។ តំបន់ចែកចាយទាំង ២៤ តំបន់នេះ ត្រូវបានកំណត់ថ្លៃមួយដោយឡែកជាបណ្តោះអាសន្នសិន ដើម្បីរក្សាអាជីវកម្មឲ្យមាននិរន្តរភាព និងក្នុងពេលជាមួយគ្នានេះ កំពុងខិតខំជម្រុញការពង្រីកបណ្តាញបញ្ជូនរង ឲ្យទៅគ្របដណ្តប់តំបន់ទាំងនេះ ដើម្បីកែសម្រួលថ្លៃអគ្គិសនី មកអនុវត្តតាមអត្រាក្នុងផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលវិញ ។ ដោយឡែកចំពោះតំបន់ឧស្សាហកម្ម ៣ តំបន់ ក្នុងនោះ ២ តំបន់នៅក្នុងរាជធានីភ្នំពេញ និង ១ តំបន់នៅក្រុងព្រះសីហនុ ត្រូវបានកំណត់ឲ្យអនុវត្តថ្លៃតាមគោលការណ៍ដោយឡែក ដោយបញ្ចូលថ្លៃរោងចក្រអគ្គិសនីប្រើប្រេងបន្ថែម សង្ឃឹមថា នៅឆ្នាំបន្តបន្ទាប់ទំហំទីផ្សារនៅតំបន់ឧស្សាហកម្មទាំងនេះ នឹងកើនឡើង ធ្វើឲ្យថ្លៃលក់អគ្គិសនីថយចុះជាបន្តបន្ទាប់ ។ ក្នុងចំណោមតំបន់ចែកចាយទាំង ២៤ នេះ មានតំបន់ចែកចាយចំនួន ១៥ ត្រូវបានគ្រោងអភិវឌ្ឍន៍ភ្ជាប់ជាមួយប្រភពបណ្តាញជាតិ ដើម្បីរៀបចំថ្លៃនៅតំបន់ទាំងនេះឲ្យអនុវត្តតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលដែរ ដែលក្នុងនោះមាន ៖ ខេត្តកណ្តាល ២ តំបន់, ខេត្តបាត់ដំបង ៤ តំបន់, ខេត្តសៀមរាប ៣ តំបន់, ខេត្តកំពង់ចាម ២ តំបន់ និងខេត្តព្រៃវែង ៤ តំបន់ ។ ដូច្នេះចាប់ពីខែ មីនា ឆ្នាំ ២០១៦ នៅសល់តែតំបន់ចែកចាយតែ ៩ តំបន់ទេ ដែលមិនទាន់អាចអនុវត្តថ្លៃតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលបាន ។ តំបន់ចែកចាយទាំង ៩ តំបន់នេះ គ្រោងអភិវឌ្ឍន៍ភ្ជាប់ជាមួយប្រភពបណ្តាញជាតិ ដើម្បីរៀបចំថ្លៃនៅតំបន់ទាំងនេះ ឲ្យអនុវត្តតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល នៅឆ្នាំ ២០១៨ ។

៥. **ចំពោះការផ្គត់ផ្គង់អគ្គិសនី នៅតំបន់ចែកចាយ ប្រើប្រភពអគ្គិសនីដែលនាំចូលពីប្រទេសជិតខាង ៖** ក្នុងចំណោមតំបន់ចែកចាយ ៣៥៦ តំបន់ ទូទាំងប្រទេស មានតំបន់ចែកចាយចំនួន ៥៩ តំបន់ កំពុងប្រើប្រាស់ប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម ថៃ និងឡាវ ក្នុងនោះមានតំបន់របស់ EDC ចំនួន ៩ តំបន់ និងងតំបន់របស់សេវាករចែកចាយឯកជនចំនួន ៥០ តំបន់ ។ តំបន់ចែកចាយទាំង ៥៩ តំបន់នេះ មានតំបន់ចែកចាយចំនួន ២៨ តំបន់ ជាតំបន់ដែលនាំចូលប្រភពអគ្គិសនីដោយផ្ទាល់ រួចតំបន់ចែកចាយចំនួន ៣១ តំបន់ ជាតំបន់ដែលទិញបន្តពីតំបន់នាំចូលផ្ទាល់ទាំងនេះ ។ តំបន់ចែកចាយដែលនាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសជិតខាងទាំង ២៨ តំបន់នេះ មានតំបន់ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ចំនួន ២០ តំបន់ (EDC ៩ តំបន់) តំបន់ដែលនាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសថៃ ចំនួន ៦ តំបន់ និងតំបន់ដែលនាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសឡាវ ចំនួន ២ តំបន់ (EDC ២ តំបន់) ។ ជាអាទិភាព រាជរដ្ឋាភិបាលនឹងខិតខំពង្រីកបណ្ដាញបញ្ជូនវងចេញពីអនុស្ថានីយបណ្ដាញជាតិ ឲ្យទៅគ្របដណ្ដប់តំបន់ចែកចាយ ៣១ តំបន់ ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ដែលនាំចូលផ្ទាល់សិន ដើម្បីបង្កើនស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនីផង និងអនុវត្តថ្លៃតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលផង ។ ចំពោះតំបន់ចែកចាយដែលនាំចូលប្រភពអគ្គិសនីផ្ទាល់ចំនួន ២៨ តំបន់វិញ ដោយសារថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយទាំងនេះក៏មានថ្លៃទាបដែរ យើងនឹងខិតខំរក្សាអត្រាថ្លៃតាមស្ថានភាពជាក់ស្ដែងជាបណ្ដោះអាសន្នសិន រហូតដល់ពេលវេលាចាំបាច់មួយ ដែលប្រជាពលរដ្ឋភាគច្រើនគាំទ្រឲ្យមានការផ្លាស់ប្ដូរ មកប្រើពីប្រភពបណ្ដាញជាតិវិញ ទើបយើងកែសម្រួលឲ្យបែរមកយកប្រភពអគ្គិសនីពីប្រភពបណ្ដាញជាតិ និងអនុវត្តអត្រាថ្លៃតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលវិញ ។

តាមផែនការដែលបានគ្រោង តំបន់ប្រើប្រភពអគ្គិសនី ដែលនាំចូលពីប្រទេសជិតខាងចំនួន **១០ តំបន់** នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្ដាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល នៅខែ មីនា ឆ្នាំ២០១៦ ដែលក្នុងនោះមាន ៖ ១ តំបន់នៅខេត្តកណ្ដាល និង ៩ តំបន់នៅខេត្តតាកែវ។ នៅចុងឆ្នាំ ២០១៦ មានតំបន់ចែកចាយប្រើប្រភពអគ្គិសនី ដែលនាំចូលពីប្រទេសជិតខាងចំនួន **៤ តំបន់**ទៀត នៅខេត្តកំពត នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្ដាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល ។ នៅឆ្នាំ ២០១៧ នឹងមានតំបន់ចែកចាយប្រើប្រភពអគ្គិសនី ដែលនាំចូលពីប្រទេសជិតខាងចំនួន **១៥ តំបន់** នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្ដាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាលដែលក្នុងនោះមាន ៖ ១ តំបន់នៅខេត្តកែប, ១ តំបន់នៅខេត្តបាត់ដំបង, ២ តំបន់នៅខេត្តបន្ទាយមានជ័យ, ១ តំបន់នៅខេត្តកោះកុង, ៣ តំបន់នៅខេត្តព្រៃវែង, ១ តំបន់ នៅខេត្តត្បូងឃ្មុំ, ៤ តំបន់នៅខេត្តស្វាយរៀង និង ២ តំបន់នៅខេត្តប៉ៃលិន ។ នៅឆ្នាំ ២០១៨ នឹងមានតំបន់ចែកចាយប្រើប្រភពអគ្គិសនីដែលនាំចូលពីប្រទេសជិតខាងចំនួន **១៦ តំបន់** នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្ដាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាលដែលក្នុងនោះមាន ៖ ៦តំបន់នៅខេត្តក្រចេះ, ២ តំបន់នៅខេត្តស្ទឹងត្រែង, ៣ តំបន់នៅខេត្តរតនគិរី, ២ តំបន់នៅខេត្តព្រះវិហារ, ២ តំបន់នៅខេត្តមណ្ឌលគិរី និង ១ តំបន់នៅខេត្តឧត្តរមានជ័យ ។ ដូច្នេះ មានន័យថា រហូតដល់ឆ្នាំ

២០១៨ ក្នុងចំណោមតំបន់ចែកចាយទាំង ៥៩ តំបន់ ដែលកំពុងតែប្រើប្រាស់ប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម ថៃ និងឡាវ នឹងមានតំបន់ចែកចាយចំនួន ៤៥ តំបន់ នឹងត្រូវបានផ្ទេរមកភ្ជាប់ជាមួយប្រភពបណ្តាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាលវិញ ។

៦. **ចំពោះការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយ ដែលនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី ៖** នៅខែ ឧសភា ឆ្នាំ ២០១៥ មានតំបន់ចែកចាយចំនួន ៤៤ តំបន់ ដែលនៅរាយប៉ាយក្នុងរាជធានី/ខេត្ត ចំនួន ១២ កំពុងនៅប្រើម៉ាស៊ីនដៀសែល ដើម្បីផលិតអគ្គិសនីសម្រាប់ផ្គត់ផ្គង់ឲ្យអ្នកប្រើប្រាស់នៅឡើយ ។ តំបន់ចែកចាយទាំង ៤៤ តំបន់នេះ គឺជាតំបន់ចែកចាយដែលមានថ្លៃអគ្គិសនីខ្ពស់ ការផ្គត់ផ្គង់មិនទាន់មានគុណភាព និងស្ថេរភាព ដូច្នេះ រាជរដ្ឋាភិបាលកំពុងចាត់ទុកតំបន់ទាំងនេះជាតំបន់អាទិភាព ដែលចាំបាច់ត្រូវពង្រីកបណ្តាញជាតិ និងបណ្តាញបញ្ជូនរងទៅគ្របដណ្តប់ឲ្យបានឆាប់ ដើម្បីឲ្យតំបន់ចែកចាយទាំង ៤៤ តំបន់នេះ អាចក្លាយទៅជាតំបន់ភ្ជាប់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិដែលអាចបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមផែនការរបស់រាជរដ្ឋាភិបាលបាន ។ នៅក្នុងរយៈពេលបណ្តោះអាសន្ន ដែលប្រភពអគ្គិសនីពីបណ្តាញជាតិ ពុំទាន់អាចគ្របដណ្តប់លើតំបន់នេះ ដើម្បីឲ្យមានយុត្តិធម៌រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ក្នុងតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែល អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

តាមផែនការដែលបានគ្រោង តំបន់ប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីចំនួន **២ តំបន់** នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្តាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល នៅខែ មីនា ឆ្នាំ ២០១៦ ដែលក្នុងនោះមាន ៖ ១ តំបន់នៅរាជធានីភ្នំពេញ និង ១ តំបន់ទៀត នៅខេត្តកណ្តាល ។ នៅឆ្នាំ ២០១៧ នឹងមានតំបន់ចែកចាយដែលប្រ់ម៉ាស៊ីនដៀសែលផលិតអគ្គិសនីចំនួន **១៣ តំបន់** នឹងត្រូវបានភ្ជាប់ជាមួយប្រភពបណ្តាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមាន ៖ ២ តំបន់នៅខេត្តកំពង់ឆ្នាំង, ៣ តំបន់នៅខេត្តពោធិ៍សាត់, ៤ តំបន់នៅខេត្តសៀមរាប, ៣ តំបន់នៅខេត្តកំពង់ចាម និង ១ តំបន់នៅខេត្តកោះកុង ។ នៅឆ្នាំ ២០១៨ នឹងមានតំបន់ចែកចាយដែលប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីចំនួន **២៩ តំបន់** នឹងត្រូវភ្ជាប់ជាមួយប្រភពបណ្តាញជាតិ រួចអនុវត្តថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមាន ៖ ៤ តំបន់នៅខេត្តក្រចេះ, ១ តំបន់នៅខេត្តស្ទឹងត្រែង, ៥ តំបន់នៅខេត្តកំពង់ធំ, ២ តំបន់នៅខេត្តរតនគិរី, ១២ តំបន់នៅខេត្តព្រះវិហារ, ៣ តំបន់នៅខេត្តឧត្តរមានជ័យ និង ២ តំបន់ទៀត នៅខេត្តកោះកុង ។

# តារាងសង្ខេបលទ្ធផលនៃការសិក្សាការផ្គត់ផ្គង់ និងផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី តាមបណ្ដារាជធានី/ខេត្ត ទាំង ២៥

# តារាងសង្ខេបលទ្ធផលទូទាំងប្រទេស នៃការសិក្សាលម្អិតអំពីការផ្គត់ផ្គង់អគ្គិសនីដុំ និងធំ ចេញពីអនុស្ថានីយ និងចេញពីបណ្ដាញបញ្ជូនវងនានា របស់ប្រព័ន្ធបណ្ដាញជាតិ និងផែនការបន្ថយអត្រា និងគម្លាតថ្លៃនៃការផ្គត់ផ្គង់ដុំ និងធំនេះ

**ការផ្គត់ផ្គង់ដុំ**-សំដៅការផ្គត់ផ្គង់អគ្គិសនីដុល ចេញពីអនុស្ថានីយផ្ទាល់ដែលមានអានុភាពចាប់ពី ១០MW ឡើង ក្នុងអតិថិជន ១ កន្លែង

**ការផ្គត់ផ្គង់ធំ**-សំដៅការផ្គត់ផ្គង់ទំហំធំ តាម MV ចេញពីបណ្ដាញបញ្ជូនវង ចាប់ពី ២៧៥ ការ៉េអា រហូតដល់ ១០ មេហ្គាវ៉ាត់ ក្នុងអតិថិជន ១ កន្លែង

| ប្រភេទផ្គត់ផ្គង់ | ស្ថានភាពឆ្នាំ ២០១៥ | ស្ថានភាពឆ្នាំ ២០១៦ | ស្ថានភាពឆ្នាំ ២០១៧ | ស្ថានភាពឆ្នាំ ២០១៨ | ស្ថានភាពឆ្នាំ ២០១៩ | ស្ថានភាពឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| **ការផ្គត់ផ្គង់ដុំ** (>10MW) | **ខេត្តអាចផ្គត់ផ្គង់បាន** ៖ ភ្នំពេញ, កណ្ដាល, កំពង់ស្ពឺ, តាកែវ, កំពត, កែប, ព្រះសីហនុ, កំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប, កំពង់ចាម (**សរុប ១៣ ខេត្ត**)<br>**អត្រាថ្លៃ៖** HV=0.127$/kWh<br>MV=0.129$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** បន្ថែមខេត្តកោះកុង មួយទៀត (**សរុប ១៤ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>HV=0.124$/kWh<br>MV=0.126$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** បន្ថែមខេត្តព្រៃវែង និងខេត្តស្វាយរៀង ២ ទៀត (**សរុប ១៦ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>HV=0.124$/kWh<br>MV=0.126$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** បន្ថែមខេត្តក្រចេះ, ស្ទឹងត្រែង និងខេត្តកំពង់ធំ ៣ ទៀត (**សរុប ១៩ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>HV=0.124$/kWh<br>MV=0.126$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** បន្ថែមខេត្តព្រះវិហារ, ខេត្តរតនគិរី ២ ទៀត (**សរុប ២១ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>HV=0.124$/kWh<br>MV=0.126$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** បន្ថែមខេត្តត្បូងឃ្មុំ,ឧត្ដរមានជ័យ,មណ្ឌលគិរី និងប៉ៃលិន ៤ទៀត (**សរុប២៥ខេត្ត**)<br>**អត្រាថ្លៃ៖**<br>HV=0.124$/kWh<br>MV=0.126$/kWh |
| **ការផ្គត់ផ្គង់ធំ** (275kVA-10MW) | **ខេត្តអាចផ្គត់ផ្គង់បាន៖**ទី១.ខេត្តមានអនុស្ថានីយ ១៣ គឺ ភ្នំពេញ, កណ្ដាល, កំពង់ស្ពឺ, តាកែវ, កំពត, កែប, ព្រះសីហនុ, កំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងកំពង់ចាម និងទី២.ខេត្ត ២ ដែលនៅក្បែរគឺ ៖ ខេត្តត្បូងឃ្មុំ និងខេត្តព្រៃវែង (**សរុប ១៥ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.177$/kWh<br>EDC MV=0.170$/kWh<br>REE MV=0.1725$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** ពង្រីកបណ្ដាញបញ្ជូនវងថែម ៣ខេត្តទៀត គឺខេត្តកោះកុង (មានអនុស្ថានីយ), ខេត្តប៉ៃលិន និងខេត្តឧត្ដរមានជ័យ (១ផ្នែកតូច) (**សរុប ១៨ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.172$/kWh<br>EDC MV=0.1675$/kWh<br>REE MV=0.1675$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** ថែមខេត្តមានអនុស្ថានីយ ២ ខេត្តទៀត, ពង្រីកបណ្ដាញបញ្ជូនវងពីបណ្ដាញជាតិថ្មី ១ខេត្តទៀតគឺខេត្តស្វាយរៀង (**សរុប ១៩ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.167$/kWh<br>EDC MV=0.165$/kWh<br>REE MV=0.165$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** ថែមខេត្តមានអនុស្ថានីយ ៣ ខេត្តទៀត, ពង្រីកបណ្ដាញបញ្ជូនវងពីបណ្ដាញជាតិថ្មី៣ខេត្តទៀតគឺខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង (**សរុប ២២ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.165$/kWh<br>EDC MV=0.164$/kWh<br>REE MV=0.164$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** ពង្រីកបណ្ដាញបញ្ជូនវងពីបណ្ដាញជាតិ ផ្ទាល់ ២ខេត្តទៀត គឺខេត្តព្រះវិហារ និងខេត្តរតនគិរី (**សរុប ២៤ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.163$/kWh<br>EDCMV=0.163$/kWh<br>REE MV=0.163$/kWh | **ខេត្តអាចផ្គត់ផ្គង់បាន៖** ពង្រីកបណ្ដាញបញ្ជូនវងបន្តទៅខេត្តមណ្ឌលគិរី ១ ទៀត (**សរុប ២៥ ខេត្ត**)<br>**អត្រាថ្លៃ៖**<br>PP MV=0.162$/kWh<br>EDC MV=0.162$/kWh<br>REE MV=0.162$/kWh |

# តារាងសង្ខេបលទ្ធផលទូទាំងប្រទេសនៃការសិក្សា អំពីការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ និងផែនការបន្ថយអត្រា និងគម្លាតថ្លៃនៃការផ្គត់ផ្គង់អគ្គិសនីរាយ

**ការផ្គត់ផ្គង់រាយ**-សំដៅការផ្គត់ផ្គង់អានុភាពតូច (LV) និងអានុភាពមធ្យម (MV) ឲ្យអតិថិជនតាមរយៈបណ្តាញចែកចាយរបស់អ្នកចែកចាយអគ្គិសនី នៅតំបន់ចែកចាយនីមួយៗ

| **ប្រភេទតំបន់** | **ស្ថានភាពឆ្នាំ ២០១៥** | **ស្ថានភាពឆ្នាំ ២០១៦** | **ស្ថានភាពឆ្នាំ ២០១៧** | **ស្ថានភាពឆ្នាំ ២០១៨** | **ស្ថានភាពឆ្នាំ ២០១៩** | **ស្ថានភាពឆ្នាំ ២០២០** |
|---|---|---|---|---|---|---|
| **តំបន់ចែកចាយ-ភ្ជាប់ប្រភពផ្ទាល់ពីបណ្តាញជាតិ** (**អាចអនុវត្តការបន្ថយថ្លៃតាមផែនការ**) | **ចំនួនតំបន់៖** ក្នុងចំណោម ៣៥៨ តំបន់ មានតំបន់ប្រភេទនេះ ចំនួន ២២៨ កំពុងទទួលប្រភពអគ្គិសនីពីអនុស្ថានីយ ឬពីបណ្តាញបញ្ជូនរងផ្ទាល់<br>**<u>អត្រាថ្លៃ៖</u>**<br>MVEDC =0.177 & 0.170$/kWh<br>MV REEs=0.1725$/kWh<br>LV=1,100៛; 1,050៛; 1,000៛; 820៛; 720៛; 610៛/kWh | **ចំនួនតំបន់៖** កើនឡើង ២៧ បន្ថែមទៀត ធ្វើឲ្យចំនួនសរុបស្មើនឹង ២៥៥/៣៥៨ តំបន់ មិនគិតតំបន់ឲ្យវិនិយោគថ្មីៗ<br>**<u>អត្រាថ្លៃ៖</u>**<br>MV=0.172$; 0.1675$/kWh<br>LVធម្មតា=780; 800 ៛/kWh<br>ថ្លៃអនុគ្រោះ PP=610៛/kWh<br>ថ្លៃអនុគ្រោះ RR=480៛/kWh<br>ថ្លៃបូមទឹកយប់=480៛/kWh | **ចំនួនតំបន់៖**កើនឡើង២៨ បន្ថែមទៀត ធ្វើឲ្យចំនួនសរុបស្មើនឹង ២៨៣/៣៥៨ តំបន់ មិនគិតតំបន់ឲ្យវិនិយោគថ្មីៗ<br>**<u>អត្រាថ្លៃ៖</u>**<br>MV=0.167; 0.165$/kWh<br>LVធម្មតា=770; 790 ៛/kWh<br>ថ្លៃអនុគ្រោះ PP=610៛/kWh<br>ថ្លៃអនុគ្រោះ RR=474៛/kWh<br>ថ្លៃបូមទឹកយប់=474៛/kWh | **ចំនួនតំបន់៖**កើនឡើង៥៤ ទៀត ធ្វើឲ្យចំនួនសរុបស្មើនឹង ៣៣៧/៣៥៨ តំបន់ មិនគិតតំបន់ឲ្យវិនិយោគថ្មីៗ<br>**<u>អត្រាថ្លៃ៖</u>**<br>MV=0.165; 0.164$/kWh<br>LVធម្មតា=750; 770 ៛/kWh<br>ថ្លៃអនុគ្រោះ PP=610៛/kWh<br>ថ្លៃអនុគ្រោះRR=462៛/kWh<br>ថ្លៃបូមទឹកយប់=462៛/kWh | **ចំនួនតំបន់៖**កើនឡើង១៣ បន្ថែមទៀតធ្វើឲ្យចំនួនសរុប ៣៥០/៣៥៨ មិនគិតតំបន់ឲ្យវិនិយោគថ្មីៗ<br>**<u>អត្រាថ្លៃ៖</u>**<br>MV= 0.163$/kWh<br>LVធម្មតា=740;760 ៛/kWh<br>ថ្លៃអនុគ្រោះPP=610៛/kWh<br>ថ្លៃអនុគ្រោះRR=456៛/kWh<br>ថ្លៃបូមទឹកយប់=456៛/kWh | **ចំនួនតំបន់៖**កើនឡើង៥ បន្ថែមទៀតធ្វើឲ្យចំនួនសរុប ៣៥៥/៣៥៨ មិនគិតតំបន់ឲ្យវិនិយោគថ្មីៗ<br>**<u>អត្រាថ្លៃ៖</u>**<br>MV= 0.162$/kWh<br>LVធម្មតា=730;750 ៛/kWh<br>ថ្លៃអនុគ្រោះPP=610៛/kWh<br>ថ្លៃអនុគ្រោះRR=450៛/kWh<br>ថ្លៃបូមទឹកយប់=450៛/kWh |
| **តំបន់ចែកចាយ-ប្រភពបញ្ជូនបន្ត ឬបញ្ជូនឆ្ងាយ** (**ត្រូវធ្វើការអភិវឌ្ឍន៍**) | **ចំនួនតំបន់៖** ក្នុងចំណោម ៣៥៨ តំបន់មានតំបន់ប្រភេទនេះចំនួន២៧ ក្នុងនៅតំបន់ឧស្សាហកម្ម ៣ តំបន់ដែលត្រូវកំណត់ថ្លៃដោយឡែក<br>**<u>អត្រាថ្លៃ៖</u>**<br>កំណត់តាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗជាបណ្តោះអាសន្ន ។ | **ចំនួនតំបន់៖** តំបន់ប្រភេទនេះនៅសល់តែ ៩ ប៉ុណ្ណោះ មិនគិតពីតំបន់ឧស្សាហកម្មដែលអាចមានថែមទៀត<br>**<u>អត្រាថ្លៃ៖</u>**<br>កំណត់តាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ សិន ។ | **ចំនួនតំបន់៖** តំបន់ប្រភេទនេះនៅសល់តែ ៥ ប៉ុណ្ណោះ មិនគិតពីតំបន់ឧស្សាហកម្មដែលអាចមានថែមទៀត<br>**<u>អត្រាថ្លៃ៖</u>**<br>កំណត់តាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ សិន ។ | **ចំនួនតំបន់៖** ភ្ជាប់តំបន់ចាស់អស់ បើមាន គឺមានតែតំបន់ឧស្សាហកម្មដែលត្រូវកំណត់ថ្លៃដោយឡែក<br>**<u>អត្រាថ្លៃ៖</u>**<br>កំណត់តាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗសិន ។ | គ្មាន | គ្មាន |
| **តំបន់ចែកចាយ-ប្រភពនាំចូលអគ្គិសនី** (**ត្រូវធ្វើការអភិវឌ្ឍន៍**) | **ចំនួនតំបន់៖** ក្នុងចំណោម ៣៥៨ មានតំបន់ប្រភេទនេះ ៥៩ (២៨នាំចូលផ្ទាល់ និង ៣១ ទិញបន្ត)<br>**<u>អត្រាថ្លៃ៖</u>**<br>តំបន់នាំចូលផ្ទាល់ថ្លៃ=600-800 ៛/kWh; តំបន់ទិញបន្ត=940-1200៛ | **ចំនួនតំបន់៖** តំបន់ប្រភេទនេះនឹងនៅសល់តែ ៤៩ (១០តំបន់ភ្ជាប់ជាមួយបណ្តាញជាតិ)<br>**<u>អត្រាថ្លៃ៖</u>**<br>តំបន់នាំចូលផ្ទាល់រក្សាថ្លៃដដែល; ខិតខំបន្ថយថ្លៃតំបន់បញ្ជូនបន្ត | **ចំនួនតំបន់៖**តំបន់ប្រភេទនេះនឹងសល់តែ៣០(១៩តំបន់នឹងភ្ជាប់បណ្តាញជាតិ)<br>**<u>អត្រាថ្លៃ៖</u>**<br>តំបន់នាំចូលផ្ទាល់រក្សាដដែល; ខិតខំបន្ថយតំបន់បញ្ជូនបន្ត | **ចំនួនតំបន់៖**តំបន់ប្រភេទនេះនឹងសល់តែ១៤(១៦តំបន់នឹងភ្ជាប់បណ្តាញជាតិ)<br>**<u>អត្រាថ្លៃ៖</u>**<br>ខិតខំរក្សាថ្លៃដែលប្រហាក់ប្រហែលតំបន់បណ្តាញជាតិ | **ចំនួនតំបន់៖**រក្សាតែតំបន់ដែលមានថ្លៃទាបក្រៅពីនោះភ្ជាប់ជាមួយបណ្តាញជាតិវិញ<br>**<u>អត្រាថ្លៃ៖</u>**<br>ខិតខំរក្សាថ្លៃឲ្យប្រហាក់ប្រហែលតំបន់បណ្តាញជាតិ | **ចំនួនតំបន់៖**រក្សាតែតំបន់ដែលមានថ្លៃទាប ក្រៅពីនោះភ្ជាប់ជាមួយបណ្តាញជាតិវិញ<br>**<u>អត្រាថ្លៃ៖</u>**<br>ខិតខំរក្សាថ្លៃឲ្យប្រហាក់ប្រហែលតំបន់បណ្តាញជាតិ |

| | | | | | | |
|---|---|---|---|---|---|---|
| **តំបន់ចែកចាយ-ប្រភពម៉ាស៊ីនដ្យេសែល** (**ត្រូវធ្វើការអភិវឌ្ឍន៍**) | **ចំនួនតំបន់៖** ក្នុងចំណោម ៣៥៨ មានតំបន់ប្រភេទនេះ ៤៤ (ឋិតនៅក្នុងខេត្តចំនួន ១២)<br>**អត្រាថ្លៃ៖**<br>យន្តការកំណត់ថ្លៃ = តារាងថ្លៃប្រែប្រួលតាមថ្លៃប្រេងក្នុងខែនីមួយៗ;<br>អត្រាថ្លៃនៃតំបន់នីមួយ ឋិតនៅចន្លោះ=1600-3200៛/kWh; | **ចំនួនតំបន់៖** តំបន់ប្រភេទនេះនឹងនៅសល់ ៤២ (មិនគិតការផ្តល់សម្បទានថ្មីៗ)<br>**អត្រាថ្លៃ៖**<br>យន្តការកំណត់ថ្លៃ=តារាងថ្លៃប្រែប្រួលតាមថ្លៃប្រេងក្នុងខែនីមួយៗ;<br>អត្រាថ្លៃនៃតំបន់នីមួយៗ ឋិតនៅចន្លោះ=1600-3200៛/kWh; | **ចំនួនតំបន់៖** តំបន់ប្រភេទនេះ នឹងនៅសល់ ២៩ (មិនគិតការផ្តល់សម្បទានថ្មីៗ)<br>**អត្រាថ្លៃ៖**<br>យន្តការកំណត់ថ្លៃ=តារាងថ្លៃប្រែប្រួលតាមថ្លៃប្រេងនៃខែនីមួយៗ; អត្រាថ្លៃនៃតំបន់នីមួយៗឋិតនៅចន្លោះ=1600-3200៛/kWh; | **ចំនួនតំបន់៖** តំបន់ប្រភេទនេះ នឹងនៅសល់ ០ (មិនគិតការផ្តល់សម្បទានថ្មីៗ)<br>**អត្រាថ្លៃ៖**<br>ប្រសិនបើមានតំបន់ថ្មីកំណត់ថ្លៃតាមយន្តការតារាងថ្លៃប្រែប្រួលតាមថ្លៃប្រេងនៃខែនីមួយៗ | គ្មាន | គ្មាន |

# តារាងសង្ខេបលទ្ធផលនៃការសិក្សាលម្អិតតាមបណ្តារាជធានី/ខេត្ត ទាំង ២៥ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការអនុវត្តបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនី តាមផែនការយុទ្ធសាស្ត្រ របស់រាជរដ្ឋាភិបាល

| **ខេត្ត/រាជធានី** | **ការផ្គត់ផ្គង់ផ្ទាល់ពីអនុស្ថានីយនិងបណ្តាញបញ្ជូនខ** | **តំបន់ចែកចាយ-ភ្ជាប់ប្រភពផ្ទាល់ពីបណ្តាញជាតិ** | **តំបន់ចែកចាយ-ប្រភពបញ្ជូនបន្ត ឬបញ្ជូនឆ្ងាយ** | **តំបន់ចែកចាយ-ប្រភពនាំចូលអគ្គិសនី** | **តំបន់ចែកចាយ-ប្រភពម៉ាស៊ីនម៉ាស៊ីនសៀសែល** |
|---|---|---|---|---|---|
| ១.រាជធានីភ្នំពេញ | មានអនុស្ថានីយចំនួន ៤, បញ្ជូនរង ៣ (EDC, Transco និងTPLCហូលឌីង) **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការបាន** | មាន ១៤ តំបន់ ៖ ១ តំបន់ចែកចាយរបស់ EDC, ៤ ជាតំបន់ផ្សារ និង ៩ ជាតំបន់ចែកចាយឯកជន **អាចផ្គត់ផ្គង់រាយ តាមថ្លៃផែនការ** | មានតំបន់ឧស្សាហកម្ម ២ ដែលតាមការកំណត់**ត្រូវអនុវត្តថ្លៃ តាមគោលការណ៍ដោយឡែក** | គ្មាន | មាន១នៅកោះដាច់ គ្រោងរុញប្រភពទៅឲ្យ **ដើម្បីអនុវត្តថ្លៃឲ្យបានតាមផែនការ** នៅឆ្នាំ ២០១៦ ដែរ |
| ២.ខេត្តកណ្តាល | មានអនុស្ថានីយចំនួន ២, បញ្ជូនរង ៣ (EDC, LMK និង TPLC Holding) **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការបាន** | មាន ៤៨ តំបន់ ៖ ១ ជាតំបន់ចែកចាយរបស់ EDC និង ៤៨ ទៀត ជាតំបន់សេវាករឯកជន, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | មាន ២ តំបន់ នឹងរៀបចំភ្ជាប់ ដើម្បីឲ្យ**អនុវត្តថ្លៃតាមផែនការ ចាប់ពីឆ្នាំ ២០១៦ ដែរ** | មាន ១ តំបន់ (នាំចូលពី VN) បច្ចុប្បន្នភ្ជាប់ពីអនុស្ថានីយរួចហើយ **គ្រោងអនុវត្តថ្លៃតាមផែនការនៅឆ្នាំ ២០១៦ ដែរ** | មាន ១ នៅកោះឧកញ៉ាតី គ្រោងរុញប្រភពទៅឲ្យ **ដើម្បីអនុវត្តថ្លៃឲ្យបាននៅឆ្នាំ ២០១៦ ដែរ** |
| ៣.ខេត្តកំពង់ស្ពឺ | មានអនុស្ថានីយ២, បញ្ជូនរង២ (EDC និងសុខាអេឡិកទ្រីស៊ីធី), **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ១៩ តំបន់ ៖ ១ ជាតំបន់ EDC និង១៨ទៀតជាតំបន់សេវាករឯកជន **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | គ្មាន | គ្មាន |
| ៤.ខេត្តតាកែវ | មានអនុស្ថានីយចំនួន ១, បញ្ជូនរងពីបណ្តាញជាតិ ២ (EDC និង LMK), **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ២១ តំបន់ ៖ ១ (របស់EDC) និង២០ទៀត ជាតំបន់សេវាករឯកជន **អាចផ្គត់ផ្គង់រាយ តាមថ្លៃផែនការ បាន** | គ្មាន | មាន ១២តំបន់ (VN) ៖ ៣ នាំចូលផ្ទាល់ថ្លៃទាបទុកថ្លៃដដែល និង៩ទិញបន្ត**គ្រោងភ្ជាប់ដើម្បីបន្ថយថ្លៃនៅចុងឆ្នាំ ២០១៦** | គ្មាន |
| ៥.ខេត្តកំពត | មានអនុស្ថានីយចំនួន ១ កន្លែង, មានបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ៥ តំបន់ ៖ ១ជាតំបន់ EDC និង ៤ ទៀត ជាតំបន់ចែកចាយរបស់ឯកជន, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | មាន៥ (VN) ៖ ២ នាំចូលផ្ទាល់,តំបន់EDCទុកថ្លៃដដែល, **៤តំបន់ទៀតគ្រោងភ្ជាប់ដើម្បីបន្ថយថ្លៃនៅចុង ២០១៦** | គ្មាន |

| | | | | | |
|---|---|---|---|---|---|
| ៦.ខេត្តកែប | អាចផ្គត់ផ្គង់ជុំពីអនុស្ថានីយកំពត,មានបណ្តាញបញ្ជូនរងរបស់EDC, **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | គ្មាន | គ្មាន | មាន ១ (VN) រក្សាថ្លៃដដែលសិន **គ្រោងភ្ជាប់បណ្តាញជាតិ នៅឆ្នាំ ២០១៧** | គ្មាន |
| ៧.ខេត្តព្រះសីហនុ | មានអនុស្ថានីយ ២ កន្លែង, មានបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន១១តំបន់ ៖ ១ជាតំបន់EDC និង ១០ ទៀតជាតំបន់សេវាករឯកជន, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | មានតំបន់ឧស្សាហកម្ម ១ **ត្រូវអនុវត្តថ្លៃតាមគោលការណ៍ដោយឡែក។** | គ្មាន | គ្មាន |
| ៨.ខេត្តកំពង់ឆ្នាំង | មានអនុស្ថានីយ ១ នៅស្រុកទឹកផុស, មានបណ្តាញបញ្ជូនរងរបស់ OSVR Trading, **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ៨ តំបន់ឯកជន ទិញប្រភពពីបញ្ជូនរងរបស់ OSVR Trading, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការបាន** | គ្មាន | គ្មាន | មាន២តំបន់ជាតំបន់កោះ គ្រោងកំណត់ឲ្យពង្រីកខ្សែបញ្ជូនរងឲ្យ**ដើម្បីអនុវត្តថ្លៃផែនការនៅឆ្នាំ ២០១៧** |
| ៩.ខេត្តពោធិ៍សាត់ | មានអនុស្ថានីយ ២ កន្លែង, មានបណ្តាញបញ្ជូនរងរបស់EDC, **អាចផ្គត់ផ្គង់ជុំនិងធំតាមថ្លៃផែនការ** | មាន ១២ តំបន់ឯកជន ទិញប្រភពពីបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | គ្មាន | មាន៣តំបន់ គ្រោងពង្រីកខ្សែបញ្ជូនរង **ដើម្បីអនុវត្តថ្លៃផែនការនៅចុង ២០១៧** |
| ១០.ខេត្តបាត់ដំបង | មានអនុស្ថានីយចំនួន ២ កន្លែង, មានបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់ជុំនិងធំតាមថ្លៃផែនការ** | មាន ២៥ តំបន់៖ ១ ជាតំបន់ EDC និង ២៤ ជាតំបន់ចែកចាយឯកជន, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | មាន ៤ តំបន់ គ្រោងពង្រីកខ្សែបញ្ជូនរង EDC ទៅឲ្យ **ដើម្បីអនុវត្តថ្លៃតាមផែនការ នៅឆ្នាំ ២០១៦ ដែរ** | មាន ១ (Thai) រក្សាថ្លៃដដែល **គ្រោងពង្រីកខ្សែបញ្ជូនរង ដើម្បីអនុវត្តថ្លៃតាមផែនការ នៅឆ្នាំ ២០១៧** | គ្មាន |
| ១១.ខេត្តបន្ទាយមានជ័យ | មានអនុស្ថានីយ ១ កន្លែង និងមានបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់ជុំនិងធំតាមថ្លៃផែនការ** | មាន ២១ តំបន់ ៖ ១ របស់EDC និង ២០ ជាតំបន់សេវាករឯកជន, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | មាន ២ (Thai)រក្សាថ្លៃដដែល **គ្រោងពង្រីកខ្សែបញ្ជូនរង ដើម្បីអនុវត្តថ្លៃតាមផែនការ នៅឆ្នាំ ២០១៧** | គ្មាន |
| ១២.ខេត្តសៀមរាប | មានអនុស្ថានីយចំនួន២,មានបណ្តាញបញ្ជូនរង២ (EDC និង KTC), **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ១៣ តំបន់៖ ១ជាតំបន់EDC និង ១២ ជាតំបន់ចែកចាយឯកជន, **អាចអនុវត្តថ្លៃតាមផែនការ** | មាន ៣ តំបន់បានពង្រីកខ្សែបញ្ជូនរង**នឹងអនុវត្តថ្លៃតាមផែនការនៅឆ្នាំ ២០១៦ ដែរ** | គ្មាន | មាន៤ តំបន់,**គ្រោងពង្រីកខ្សែបញ្ជូនរងដើម្បីអនុវត្តថ្លៃផែនការនៅចុង ២០១៧** |
| ១៣.ខេត្តកំពង់ចាម | មានអនុស្ថានីយ១,បញ្ជូនរង៤៖ EDC, ស្គន់-ចំការលើ, BVC, TPLC, **អាចផ្គត់ផ្គង់ជុំ និងធំ តាមថ្លៃផែនការ** | មាន ៣៥ តំបន់៖ ១ជាតំបន់ EDC និង ៣៤ ជាតំបន់ចែកចាយឯកជន **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | មាន២តំបន់ កំពុងពង្រីកប្រភពទៅឲ្យ **ដើម្បីអនុវត្តថ្លៃផែនការ នៅឆ្នាំ ២០១៦ ដែរ** | គ្មាន | មាន៣តំបន់,**គ្រោងពង្រីកខ្សែបញ្ជូនរងដើម្បីអនុវត្តថ្លៃផែនការនៅចុង ២០១៧** |

| | | | | | |
|---|---|---|---|---|---|
| ១៤.ខេត្តកោះកុង | ចុងឆ្នាំ ២០១៥ នឹងមានអនុស្ថានីយ ១ កន្លែង, មានបណ្ដាញបញ្ជូនរងរបស់ EDC, **នឹងអាចផ្គត់ផ្គង់ដុំនិងធំតាមថ្លៃផែនការ** | មាន ៥ តំបន់ ជារបស់សេវាករឯកជន ដែលទិញប្រភពពីបញ្ជូនរង EDC, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | មាន ១ តំបន់ (Thai-LYP), រក្សាថ្លៃដដែលសិន **គ្រោងរៀបចំឲ្យអនុវត្តថ្លៃផែនការនៅឆ្នាំ ២០១៧** | មានពតំបន់,១គ្រោងរុញប្រភពទៅឲ្យ **ដើម្បីអនុវត្តថ្លៃផែនការនៅឆ្នាំ ២០១៧** លើកលែងតំបន់កោះ ២ |
| ១៥.ខេត្តព្រៃវែង | នឹងមានអនុស្ថានីយ ១ (២០១៧), មានបណ្ដាញបញ្ជូនរង៥ក្រុមហ៊ុន**នឹងអាចផ្គត់ផ្គង់ដុំ និងធំ តាមថ្លៃផែនការ** | មាន ១៩ តំបន់៖ ១ ជាតំបន់ EDC និង ១៨ តំបន់សេវាករឯកជន **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | មាន ៤ តំបន់ប៉ុន្តែនឹងរៀបចំឲ្យ**អនុវត្តថ្លៃផែនការ** នៅខែ មីនា ឆ្នាំ ២០១៦ ដែរ | មាន ៣ តំបន់ (ផ្ទាល់ពីVN), រក្សាថ្លៃដដែលសិន, **គ្រោងអនុវត្តថ្លៃផែនការនៅឆ្នាំ ២០១៧** | គ្មាន |
| ១៦.ខេត្តត្បូងឃ្មុំ | គ្មានអនុស្ថានីយទេ មានតែបណ្ដាញបញ្ជូនរង៣ (EDC, អេឡិកទ្រីស៊ីធីត្បូងឃ្មុំ និង EDCon), **អាចផ្គត់ផ្គង់ធំតាមថ្លៃផែនការ** | មាន ៧ តំបន់៖ ២តំបន់ជារបស់ EDC និង ៥ តំបន់ទៀតជារបស់ឯកជន **អាចផ្គត់ផ្គង់រាយ តាមថ្លៃផែនការ** | មាន ៧ តំបន់ យកប្រភពពីខ្សែEDC ចេញពីខេត្តក្រចេះ នឹងរៀបចំឲ្យ**អនុវត្តថ្លៃតាមផែនការ**នៅឆ្នាំ២០១៨ | មាន៥(VN)៖ EDC ២និងឯកជន២នាំចូលផ្ទាល់រក្សាថ្លៃសិន, ឯកជន១ទិញបន្តពីEDC**គ្រោងអនុវត្តថ្លៃផែនការឆ្នាំ ២០១៧** | គ្មាន |
| ១៧.ខេត្តស្វាយរៀង | នឹងមានអនុស្ថានីយ១ នៅឆ្នាំ២០១៧, មានបញ្ជូនរងរបស់ EDC, **នឹងអាចផ្គត់ផ្គង់ដុំនិងធំតាមថ្លៃផែនការ។** | គ្មាន | គ្មាន | មាន៤៖១(EDC) និង ៣ ឯកជនទិញពី EDC **គ្រោងអនុវត្តថ្លៃផែនការនៅឆ្នាំ ២០១៧** | គ្មាន |
| ១៨.ខេត្តក្រចេះ | នឹងមានអនុស្ថានីយ១នៅឆ្នាំ២០១៨, មានបញ្ជូនរងរបស់ EDC, **នឹងអាចផ្គត់ផ្គង់ដុំ និងធំតាមថ្លៃផែនការ** | គ្មាន | គ្មាន | មាន៦(VN)៖EDC ២ នាំចូលផ្ទាល់ និងឯកជន៤ទិញបន្ត, **អនុវត្តថ្លៃផែនការ ២០១៨** | មាន៤តំបន់ **គ្រោងពង្រីកបណ្ដាញបញ្ជូនរងនៅគ្រប់ដណ្ដប់នៅឆ្នាំ ២០១៨** |
| ១៩.ខេត្តស្ទឹងត្រែង | នឹងមានអនុស្ថានីយ១នៅឆ្នាំ២០១៨, មានបញ្ជូនរងរបស់ EDC, **នឹងអាចផ្គត់ផ្គង់ដុំ និងធំតាមថ្លៃផែនការ** | គ្មាន | គ្មាន | មាន២(Lao)៖EDC១ នាំចូលផ្ទាល់ និងឯកជន១ទិញបន្ត, **អនុវត្តថ្លៃផែនការ ២០១៨** | មាន១ តំបន់ **គ្រោងពង្រីកបណ្ដាញបញ្ជូនរងនៅគ្រប់ដណ្ដប់នៅឆ្នាំ ២០១៨** |
| ២០.ខេត្តកំពង់ធំ | នឹងមានអនុស្ថានីយ១នៅឆ្នាំ២០១៨, មានបញ្ជូនរង២(EDCនិងBVC), **នឹងអាចផ្គត់ផ្គង់ដុំ និងធំតាមថ្លៃផែនការ** | ១២ តំបន់ឯកជន ទិញពីបញ្ជូនរងរបស់ BVC, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការនៅឆ្នាំ ២០១៦** | មាន ២ តំបន់ **គ្រោងពង្រីកបណ្ដាញបញ្ជូនរងនៅគ្រប់ដណ្ដប់នៅឆ្នាំ ២០១៨** | គ្មាន | មាន៥តំបន់ **គ្រោងពង្រីកបណ្ដាញបញ្ជូនរងនៅគ្រប់ដណ្ដប់នៅឆ្នាំ ២០១៨** |
| ២១.ខេត្តរតនគិរី | គ្មានអនុស្ថានីយផ្ទាល់ទេ, បច្ចុប្បន្ននាំចូលពី VN **គ្រោងពង្រីកបណ្ដាញបញ្ជូនរងពីអនុស្ថានីយសេសាន២ ទៅផ្ដល់ឲ្យនៅឆ្នាំ ២០១៨** | គ្មាន | គ្មាន | មាន៣ តំបន់ ៖ ១(EDC) និង ២ តំបន់ឯកជនទិញពី EDC **គ្រោងអនុវត្តថ្លៃផែនការនៅតំបន់ឯកជន នៅឆ្នាំ ២០១៨** | មាន ២ តំបន់, **គ្រោងពង្រីកបណ្ដាញបញ្ជូនរងនៅគ្រប់ដណ្ដប់នៅឆ្នាំ ២០១៨** |

| | | | | | |
|---|---|---|---|---|---|
| ២២.ខេត្តមណ្ឌលគិរី | គ្មានអនុស្ថានីយផ្ទាល់ទេ, **គ្រោងនឹងពិនិត្យលទ្ធភាព ពង្រីកបណ្តាញបញ្ជូននិងអនុស្ថានីយរបស់** EDC **នៅខេត្តនេះ** | គ្មាន | គ្មាន | មាន២តំបន់ ជាតំបន់ EDC នាំចូលពី VN បូកនឹងវារីអគ្គិសនី **គ្រោងនឹងពិនិត្យលទ្ធភាពពង្រីកបណ្តាញបញ្ជូនរង** | គ្មាន |
| ២៣.ខេត្តព្រះវិហារ | គ្មានអនុស្ថានីយផ្ទាល់ទេ, **គ្រោងនឹងពិនិត្យលទ្ធភាព ពង្រីកបណ្តាញបញ្ជូននិងអនុស្ថានីយរបស់** EDC **នៅខេត្តនេះ** | គ្មាន | គ្មាន | សរុប ២ តំបន់ ៖ EDC១ និង ឯកជន១ទិញពី EDC, **គ្រោងពង្រីកបណ្តាញបញ្ជូនរងនៅគ្របដណ្តប់នៅឆ្នាំ ២០១៨ ពេលកំពង់ធំ មានអនុស្ថានីយ** | មាន១២តំបន់, **គ្រោងពង្រីកបណ្តាញបញ្ជូនរងនៅគ្របដណ្តប់នៅឆ្នាំ ២០១៨ ពេលកំពង់ធំមានអនុស្ថានីយ** |
| ២៤.ខេត្តឧត្តរមានជ័យ | គ្មានអនុស្ថានីយផ្ទាល់ទេ,មានបញ្ជូនរង EDC ចូលខ្លះ, **គ្រោងពិនិត្យលទ្ធភាពពង្រីកបណ្តាញបញ្ជូនរងរបស់** EDC **នៅឲ្យ** | មានតំបន់ឯកជន ២ តំបន់ ទិញប្រកពពីបណ្តាញបញ្ជូនរងរបស់ EDC, **អាចផ្គត់ផ្គង់រាយតាមថ្លៃផែនការ** | គ្មាន | មាន ១ តំបន់(LYP) នាំចូលពីថៃ, **គ្រោងពង្រីកបណ្តាញបញ្ជូនរងនៅគ្របដណ្តប់នៅឆ្នាំ ២០១៨** | មាន ៣ តំបន់, **គ្រោងពង្រីកបណ្តាញបញ្ជូនរងនៅគ្របដណ្តប់នៅឆ្នាំ ២០១៨** |
| ២៥.ខេត្តប៉ៃលិន | គ្មានអនុស្ថានីយផ្ទាល់ទេ, មានបញ្ជូនរង EDC ចូលខ្លះ, **គ្រោងពិនិត្យលទ្ធភាពពង្រីកបណ្តាញបញ្ជូនរងរបស់** EDC **នៅឲ្យពេញលេញ** | គ្មាន | គ្មាន | មាន ២ ឯកជន៖១នាំចូលពីថៃផ្ទាល់និង១ទៀតទិញបន្ត, រក្សាថ្លៃដដែល, **គ្រោងពង្រីកបណ្តាញបញ្ជូនរងនៅគ្របដណ្តប់ពេញលេញនៅឆ្នាំ ២០១៧** | គ្មាន |

# ការសិក្សាអំពីការអនុវត្តការបន្ថយអត្រា
# និងគម្លាតថ្លៃលក់អគ្គិសនី
# នៅតាមបណ្តារាជធានី/ខេត្ត នីមួយៗ

## ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅរាជធានីភ្នំពេញ សម្រាប់ឆ្នាំ ២០១៥-២០២០

### ១.លទ្ធភាពផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ

#### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ចាប់តាំងពីឆ្នាំ ២០០២ មក ប្រភពអគ្គិសនីសម្រាប់រាជធានីភ្នំពេញ ទទួលបានមកពីរោងចក្រអគ្គិសនីប្រើប្រេងឥន្ធនៈមួយចំនួននៅក្នុងរាជធានីភ្នំពេញ និងស្ថានីយវារីអគ្គិសនីតូចមួយនៅខេត្តកំពង់ស្ពឺ គឺវារីអគ្គិសនីគិរីរម្យទី ១ ទំហំ ១២ មេហ្គាវ៉ាត់ ។ នៅពេលនោះ រាជធានីភ្នំពេញ ចាប់ផ្តើមមានប្រព័ន្ធបណ្តាញបញ្ជូនព័ទ្ធជុំវិញក្រុង និងមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីចំនួន ៣ កន្លែង ដែលអាច**ផ្គត់ផ្គង់អគ្គិសនីដុំ**បាន ។ ដោយសារកំណើននៃសេចក្តីត្រូវការប្រើប្រាស់អគ្គិសនីរបស់រាជធានីភ្នំពេញ កើនឡើងជារៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលមានផែនការធ្វើការអភិវឌ្ឍន៍ប្រព័ន្ធបណ្តាញបញ្ជូនអគ្គិសនីបន្ថែមជាបន្តបន្ទាប់ ដើម្បីអាចនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្តល់ឲ្យរាជធានីភ្នំពេញ បន្ថែមជាបណ្តោះអាសន្ន និងអាចឈានទៅធ្វើការអភិវឌ្ឍន៍វារីអគ្គិសនីធំៗ រោងចក្រអគ្គិសនីដុតធ្យូងថ្មនាំចូល និងរោងចក្រអគ្គិសនីប្រភេទដ៏ទៃទៀត នៅក្នុងប្រទេស ដើម្បីផ្តល់ប្រភពអគ្គិសនីឲ្យបានគ្រប់គ្រាន់សម្រាប់កម្ពុជា ។ ចាប់ពីឆ្នាំ ២០០៩ គម្រោងអភិវឌ្ឍន៍ប្រព័ន្ធបញ្ជូនត្រូវបានដាក់ឲ្យដំណើរការ រួមជាមួយការដាក់ឲ្យដំណើរការគម្រោងប្រភពអគ្គិសនីដែលបានអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។ បច្ចុប្បន្នប្រព័ន្ធបញ្ជូនដែលបានអភិវឌ្ឍន៍នេះ បានក្លាយទៅជាប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីដោយភ្ជាប់ភ្នំពេញ ជាមួយបណ្តាខេត្តនានា មានខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តកំពង់ចាម និងភ្ជាប់ជាមួយប្រភពអគ្គិសនីធំៗ ២ ប្រភេទ គឺទី ១ ប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម និងប្រទេសថៃ និងទី ២ ប្រភពអគ្គិសនីដែលបានអភិវឌ្ឍន៍ក្នុងស្រុកជាបន្តបន្ទាប់ ក្នុងនោះមានវារីអគ្គិសនីរោងចក្រដុតធ្យូងថ្ម និងរោងចក្រអគ្គិសនីប្រភេទដ៏ទៃទៀត ដែលរាជរដ្ឋាភិបាលបានធ្វើការអភិវឌ្ឍន៍ ។ នៅរាជធានីភ្នំពេញ ក្រៅពីអនុស្ថានីយចំនួន ៣ ដែលបានសាងសង់រួចយូរហើយនោះ បច្ចុប្បន្នអគ្គិសនីកម្ពុជាបានធ្វើការសាងសង់អនុស្ថានីយបណ្តាញជាតិជាច្រើនកន្លែងបន្ថែមទៀត ដើម្បីសម្រួលដល់ការ**ផ្គត់ផ្គង់អគ្គិសនីដុំ** ដល់អ្នកប្រើប្រាស់ និងអាចផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិទៅឲ្យតំបន់ចែកចាយនានា ដែលឋិតនៅក្នុង និងនៅជុំវិញរាជធានីភ្នំពេញ ។ ការផ្តល់ប្រភពអគ្គិសនីពីអនុស្ថានីយនានា ទៅឲ្យតំបន់ចែកចាយនានានៅក្នុងទឹកដីនៃរាជធានីភ្នំពេញ គឺធ្វើតាមបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុនចំនួន ៣ គឺទី ១ បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ទី ២ បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន គ្រេនស្កូ អេនើជី ខេមបូឌា និងទី ៣ បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ជី.ភី.អិល.ស៊ី ហូលឌីង ។ បច្ចុប្បន្នលទ្ធភាពនៃការផ្គត់ផ្គង់ដុំ និងការផ្គត់ផ្គង់ធំ អាចមានទូទាំងរាជធានីភ្នំពេញ លើកលែងតែតំបន់កោះមួយ គឺតំបន់កោះដាច់ ដែលយើងកំពុងតែពង្រីកបណ្តាញបញ្ជូនរង ដើម្បីផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិទៅឲ្យ ។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្ររាជធានីភ្នំពេញ មានខណ្ឌចំនួន ១២ គឺៈ ១.ខណ្ឌដូនពេញ ២.ខណ្ឌ៧មករា ៣.ខណ្ឌចំការមន ៤. ខណ្ឌទួលគោក ៥.ខណ្ឌមានជ័យ ៦.ខណ្ឌច្បារអំពៅ ៧.ខណ្ឌដង្កោ ៨.ខណ្ឌសែនសុខ ៩.ខណ្ឌពោធិ៍សែនជ័យ ១០.ខណ្ឌព្រែកព្នៅ ១១.ខណ្ឌជ្រោយចង្វារ និង ១២.ខណ្ឌឫស្សីកែវ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងរាជធានីភ្នំពេញ ត្រូវបានដោះស្រាយដោយរបៀប ៣ យ៉ាងគឺ ៖ ទី១. **ការផ្គត់ផ្គង់អគ្គិសនីជុំ** ពីអនុស្ថានីយនានា ដែលឋិតនៅក្នុងរាជធានីភ្នំពេញ ទី២.**ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងនានា ដែលមានក្នុងទឹកដីនៃរាជធានីភ្នំពេញ និងទី៣.**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនី ដើម្បី**ផ្គត់ផ្គង់អគ្គិសនីរាយ** ឲ្យអ្នកប្រើប្រាស់នៅតាមតំបន់ចែកចាយនានាក្នុងទឹកដីនៃរាជធានីភ្នំពេញ ត្រូវបានដោះស្រាយដោយការវិនិយោគរបស់អគ្គិសនីកម្ពុជា លើតំបន់សំខាន់ៗ ដែលជាទីក្រុងចាស់ឋិតនៅកណ្តាលក្រុង ដោយឡែកចំពោះតំបន់ជាយក្រុង ដែលពីមុនពុំដែលមានអគ្គិសនីប្រើប្រាស់ បានអនុញ្ញាតឲ្យអ្នកវិនិយោគឯកជនក្នុងស្រុកធ្វើការវិនិយោគ ។ ដោយសារតែភ្នំពេញ គឺជារាជធានីរបស់កម្ពុជា បញ្ហាអនុញ្ញាតឲ្យឯកជនធ្វើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងធ្វើការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់មួយចំនួនក្នុងទឹកដីរាជធានីភ្នំពេញនេះ បានក្លាយទៅជាបញ្ហាមួយដែលសាធារណជនតែងតែសួរថា ហេតុអ្វី បានជារាជរដ្ឋាភិបាលអនុញ្ញាតឲ្យឯកជនធ្វើការផ្គត់ផ្គង់អគ្គិសនីនៅតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញ ដែរ? ។ ខាងក្រោមនេះ គឺជាខ្លឹមសារបំភ្លឺនូវសំណួរនេះ ។

## ហេតុអ្វី បានជាអនុញ្ញាតឲ្យឯកជនធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនី នៅតំបន់មួយចំនួនក្នុងរាជធានីភ្នំពេញ ដែរ?

ក្នុងរង្វង់ឆ្នាំ ១៩៩៦ នៅពេលដែលធនាគារពិភពលោកចូលមកជួយស្តារការផ្គត់ផ្គង់អគ្គិសនី និងជួយរៀបចំសេចក្តីព្រាងច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដោយសាររាជរដ្ឋាភិបាលពុំមានទុនសាងសង់បណ្តាញបញ្ជូន និងអនុស្ថានីយ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា ត្រូវបានដោះស្រាយតាមមធ្យោបាយបង្កើតឲ្យមានការផ្គត់ផ្គង់តាមតំបន់ចែកចាយដាច់ដោយឡែកនីមួយៗ។ ក្នុងកំឡុងពេលនោះ ថវិកាដែលរាជរដ្ឋាភិបាលអាចកៀរគរបានគឺត្រូវបានប្រើប្រាស់សម្រាប់តែការស្តារការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ដែលធ្លាប់មានអគ្គិសនីពីមុនមកប៉ុណ្ណោះ ។ ចំពោះតំបន់ទាំងឡាយដែលអគ្គិសនីកម្ពុជា មិនមានលទ្ធភាពវិនិយោគ ក្នុងនោះមានទាំងតំបន់មួយចំនួននៅក្នុងរាជធានីភ្នំពេញ ផងដែរ (ពីព្រោះតាំងពីជំនាន់មុនៗ មក តំបន់ទាំងនេះជាតំបន់ពុំធ្លាប់មានអគ្គិសនីទេ)យើងពុំមានជម្រើសអ្វីផ្សេង ក្រៅពីអនុញ្ញាតឲ្យឯកជនធ្វើការវិនិយោគបង្កើតការផ្គត់ផ្គង់អគ្គិសនីដាច់ដោយឡែកពីអគ្គិសនីកម្ពុជា ឡើយ ។ ការសម្រេចដូច្នេះ ពីព្រោះថា ប្រសិនបើនៅរង់ចាំលទ្ធភាពវិនិយោគរបស់អគ្គិសនីកម្ពុជា វិញ មិនដឹងថាពេលណាដែលអគ្គិសនីកម្ពុជាមានលទ្ធភាពទេ ពីព្រោះរហូតដល់ពេលបច្ចុប្បន្ននេះ អាទិភាពវិនិយោគរបស់អគ្គិសនីកម្ពុជា កំពុងសំដៅទៅការអភិវឌ្ឍន៍មូលដ្ឋានគ្រឹះនៃការផ្គត់ផ្គង់នៅឡើយ មិនទាន់អាចដកយកមករៀបចំបណ្តាញចែកចាយតាមតំបន់ឡើយ ។ម្យ៉ាងទៀត ការអនុញ្ញាតឲ្យឯកជនធ្វើការផ្គត់ផ្គង់អគ្គិសនីដោយប្រើម៉ាស៊ីនដ្យេសែលតំបូង ទោះបីជាការផ្គត់ផ្គង់មួយដែលមានថ្លៃខ្ពស់ ប៉ុន្តែវាជាដំណោះស្រាយតំបូងដែលចៀសពុំរួច ចំពោះតំបន់ទាំងឡាយដែលអគ្គិសនីកម្ពុជា ពុំមានលទ្ធភាពវិនិយោគ ពីព្រោះថា ៖

➢ ល្អជាងការទុកឲ្យប្រជាពលរដ្ឋនៅតំបន់នោះប្រើអាគុយ និងចង្កៀងប្រេងកាត (ការចំណាយលើការប្រើប្រាស់ថាមពលផ្គត់ផ្គង់ចេញពីម៉ាស៊ីនដ្យេសែល យ៉ាងហោចណាស់ក៏ថោកជាង ស្ថេរភាពជាង និងប្រសិទ្ធភាពជាង ការប្រើអាគុយ និងចង្កៀងប្រេងកាតដែរ)
➢ បើកឱកាសបង្កើតឲ្យមានការវិនិយោគសាងសង់បណ្ដាញចែកចាយអគ្គិសនីជាបណ្ដើរៗ ដែលបណ្ដាញនេះ នឹងក្លាយទៅជាមូលដ្ឋានមួយ សម្រាប់ធ្វើការចែកចាយអគ្គិសនីឲ្យតំបន់ទាំងនោះភ្លាម នៅពេលដែលប្រភពអគ្គិសនីថោកពីបណ្ដាញជាតិរបស់អគ្គិសនីកម្ពុជា បានពង្រីកទៅដល់ ប្រសិនបើមិនដូច្នេះទេ ទោះជានៅពេលនោះ រដ្ឋាភិបាលមានទុនក៏ដោយ ក៏គេត្រូវចំណាយពេលវេលាពី ២ ទៅ ៣ ឆ្នាំបន្ថែមទៀត ដើម្បីធ្វើការសាងសង់បណ្ដាញចែកចាយនៅតាមបណ្ដាភូមិទាំងនេះដែរ ។

ដូច្នេះ សេវាករឯកជនមិនមែនជាឈ្មួញកណ្ដាល ឬគ្រាន់តែជាអ្នកលក់បន្តទេ ប៉ុន្តែគឺជាដៃគូវិនិយោគដ៏សំខាន់របស់រាជរដ្ឋាភិបាល ដែលបានធ្វើការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធបណ្ដាញចែកចាយអគ្គិសនី ត្រង់ស្វូ និងបរិក្ខារភ្ជាប់ចរន្តនៅតាមខណ្ឌសង្កាត់នានា ដែលរាជរដ្ឋាភិបាល និងអគ្គិសនីកម្ពុជាពុំមានលទ្ធភាពវិនិយោគ។ ដោយសារការចូលរួមវិនិយោគរបស់សេវាករឯកជនទូទាំងប្រទេសនេះហើយ ទើបធ្វើឲ្យភូមិចំនួនជាង ៦០% (នៅខែ ធ្នូ ឆ្នាំ ២០១៤) នៃភូមិទាំងអស់នៅកម្ពុជា មានបណ្ដាញផ្គត់ផ្គង់អគ្គិសនី រួចការចូលរួមវិនិយោគរបស់សេវាករឯកជនទូទាំងប្រទេសនេះហើយ ទើបរាជរដ្ឋាភិបាល និងអគ្គិសនីមានឱកាសប្រមូលនូវហិរញ្ញប្បទានដែលរាជរដ្ឋាភិបាលអាចកៀរគរបាន និងទុនផ្ទាល់ខ្លួន មកធ្វើការវិនិយោគសាងសង់បណ្ដាញបញ្ជូនតង់ស្យុងខ្ពស់អនុស្ថានីយ និងបណ្ដាញបញ្ជូនរង ដែលជាឆ្អឹងខ្នង និងជាមូលដ្ឋានគ្រឹះនៃការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា ដែលធ្វើឱ្យប្រព័ន្ធនេះ អាចភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីរបស់ប្រទេសជិតខាង អាចភ្ជាប់ជាមួយប្រភពវារីអគ្គិសនី និងរោងចក្រអគ្គិសនីធំៗ ដែលរាជរដ្ឋាភិបាលបានអភិវឌ្ឍន៍ អាចគ្របដណ្ដប់ផ្ដល់ប្រភពអគ្គិសនីដែលមានស្ថេរភាពគុណភាព និងថ្លៃទាបដល់បណ្ដាខេត្តនានា ព្រមទាំងអាចបញ្ចុះថ្លៃអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានជាបណ្ដើរៗ ដូចពេលបច្ចុប្បន្ននេះបាន ។ ប្រសិនបើពុំបើកឲ្យសេវាករឯកជនក្នុងស្រុកជួយចូលរួមវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនេះទេ តំបន់មួយចំនួនធំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រហែលជានឹងត្រូវរង់ចាំការវិនិយោគពីរដ្ឋ ឬពីអគ្គិសនីកម្ពុជា ក្នុងរយៈពេលពី ២០ ទៅ ៣០ ឆ្នាំ ទើបអាចមានការវិនិយោគ និងមានការផ្គត់ផ្គង់អគ្គិសនីត្រឹមត្រូវ ។

បច្ចុប្បន្ននៅរាជធានីភ្នំពេញ មានតំបន់ផ្គត់ផ្គង់អគ្គិសនីចំនួន ១៩ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដែលគ្របដណ្ដប់តំបន់សំខាន់ៗ ដែលជាទីកដីចាស់របស់រាជធានីភ្នំពេញ និង១៨ តំបន់ទៀត ជាតំបន់ចែកចាយដែលវិនិយោគ និងផ្គត់ផ្គង់អគ្គិសនីដោយសេវាករអគ្គិសនីឯកជន។ ក្នុងចំណោមតំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជនទាំង ១៨ តំបន់នោះ មានតំបន់ចែកចាយប្រភេទខុសៗគ្នា ដូចខាងក្រោម ៖

➢ ៤ តំបន់ ជាតំបន់ផ្សារលក់ដូរនៅក្នុងដែនអាជ្ញាប័ណ្ណចែកចាយរបស់អគ្គិសនីកម្ពុជា ដែលបានអនុញ្ញាតឲ្យសេវាករឯកជនធ្វើការវិនិយោគរៀបចំខ្សែបណ្ដាញដោយឡែក និងធ្វើការលក់រាយឲ្យអ្នកប្រើប្រាស់ដែលជាតូបលក់ដូរក្នុងផ្សារនោះ

- ២ តំបន់ ជាតំបន់សេដ្ឋកិច្ចពិសេស/តំបន់ឧស្សាហកម្ម ដែលបានអនុញ្ញាតឲ្យម្ចាស់តំបន់ ឬក៏សេវាករឯកជនធ្វើការវិនិយោគរៀបចំខ្សែបណ្តាញចែកចាយដោយឡែក និងធ្វើការលក់អគ្គិសនីឲ្យរោងចក្រ ឧស្សាហកម្ម និងអ្នកប្រើប្រាស់ក្នុងតំបន់នោះ ជាធម្មតា តំបន់សេដ្ឋកិច្ចពិសេស/តំបន់ឧស្សាហកម្មនេះ មានរោងចក្រអគ្គិសនីប្រើប្រេងរបស់ខ្លួនផ្ទាល់ និងបានទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយរបស់អគ្គិសនីកម្ពុជាបន្ថែម
- ១១ តំបន់ ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទិញប្រភពអគ្គិសនីរបស់បណ្តាញជាតិតាមរយៈបណ្តាញបញ្ជូនវងនានា និង
- ១ តំបន់ទៀត គឺជាតំបន់កោះ ដែលផ្គត់ផ្គង់អគ្គិសនីដោយសេវាករឯកជន រួចនៅផលិតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ ជាបណ្តោះអាសន្ន (កោះដាច់) ។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅរាជធានីភ្នំពេញ




## បញ្ជីឈ្មោះតំបន់ចែកចាយ និងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងរាជធានីភ្នំពេញ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា ភ្នំពេញ | 001 L | បណ្តាញជាតិ | ភ្នំពេញ និងតាខ្មៅ |
| 2 | ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប | 014 L | EDC | ខណ្ឌជ្រោយចង្វារ |
| 3 | ក្រុមហ៊ុន វីកូ | 050 L | EDC | ខណ្ឌច្បារអំពៅ |
| 4 | សហគ្រាស ពាន អ ធី ថេកណឡជី | 066 L | EDC – TPLC | ខណ្ឌជ្រោយចង្វារ |
| 5 | ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ | 090 L | EDC – TPLC | ខណ្ឌជ្រោយចង្វារ |
| 6 | សហគ្រាស អិនធី អេឡិកទ្រី សឹបប្លាយ | 103 L | EDC – TPLC | ខណ្ឌជ្រោយចង្វារ |
| 7 | ក្រុមហ៊ុន ហ្គោល វ៉ាន់ឡុង | 138 L | EDC | ផ្សារអូរឬស្សី |
| 8 | សេវាករ លាង ឈុននី | 143 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ខណ្ឌជ្រោយចង្វារ |

| | | | | |
|---|---|---|---|---|
| 9 | សហគ្រាស មូល ទិត្យ អគ្គិសនី | 176 L | EDC | ខ័ណ្ឌព្រែកព្នៅ |
| 10 | ក្រុមហ៊ុន ខូលបឹន អេនើជី (ខេមបូឌា) | 215 L | EDC-Transco | ខ័ណ្ឌដង្កោ |
| 11 | ក្រុមហ៊ុន អគ្គិសនី ដង្កោ | 222 L | EDC | ខ័ណ្ឌដង្កោ |
| 12 | ក្រុមហ៊ុន អិល.អិម.ខេ | 223 L | EDC | ខ័ណ្ឌដង្កោ |
| 13 | ក្រុមហ៊ុន អេស.វី.ស៊ី ផៅវ៉េ ឌីវើឡុបមេន | 243 L | EDC-MSL | ខ័ណ្ឌសែនសុខ |
| 14 | ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង | 252 L | EDC | ខ័ណ្ឌជ្រោយចង្វារ |
| 15 | សហគ្រាស អភិវឌ្ឍន៍ អគ្គិសនី ជនបទ | 261 L | EDC | ខ័ណ្ឌពោធិ៍សែនជ័យ |
| 16 | ក្រុមហ៊ុន វឌ្ឍនៈ ប្របភើធី អិលធីឌី | 325 L | EDC | ខ័ណ្ឌដង្កោ |
| 17 | សេវាករ គួច ចំណាន | 377 L | EDC –LV | ផ្សារច្បារអំពៅ២ |
| 18 | សេវាករ ទា ហាំងសេង | 378 L | EDC –MV | ផ្សារ CITY MALL |
| 19 | សេវាករ ជុង សុខលឹម | 390 L | EDC –LV | ផ្សារកណ្តាលទី១ |

## លទ្ធផលនៃការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ដល់ឆ្នាំ ២០១៥

| ស្រុក/ខណ្ឌ | ចំនួនភូមិ | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិសល់ |
|---|---|---|---|---|---|---|
| | សរុប | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ចំការមន | 95 | 95 | 100% | 95 | 100% | - |
| ដូនពេញ | 134 | 134 | 100% | 134 | 100% | - |
| 7មករា | 66 | 66 | 100% | 66 | 100% | - |
| ទួលគោក | 143 | 143 | 100% | 143 | 100% | - |
| ដង្កោ | 87 | 87 | 100% | 87 | 100% | - |
| មានជ័យ | 46 | 46 | 100% | 16 | 34.79% | 30 |
| ឫស្សីកែវ | 21 | 21 | 100% | 21 | 100% | - |
| សែនសុខ | 32 | 32 | 100% | 32 | 100% | - |
| ពោធិ៍សែនជ័យ | 158 | 158 | 100% | 153 | 96.84% | 5 |
| ជ្រោយចង្វារ | 22 | 22 | 100% | 22 | 100% | - |
| ព្រែកព្នៅ | 59 | 59 | 100% | 59 | 100% | - |
| ច្បារអំពៅ | 49 | 49 | 100% | 30 | 61.22% | 19 |
| **សរុប** | **900** | **900** | **100%** | **858** | **95.33%** | **54** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្តបច្ចុប្បន្ន និងផែនការបន្ថយថ្លៃអគ្គិសនីនៅរាជធានីភ្នំពេញ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងរាជធានីភ្នំពេញ អាចបែងចែកជាផែនការដោយឡែកចំនួន ៥ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយនានា ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញមេរាជធានីភ្នំពេញ របស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងនានា ដែលមិនពាក់ព័ន្ធជាមួយប្រភពអគ្គិសនីប្រើប្រេងរបស់រាជធានីភ្នំពេញ ៤.ការផ្គត់ផ្គង់អគ្គិសនី នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និង៥.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅរាជធានីភ្នំពេញ ទាំង ៥ នេះ មានខ្លឹមសារ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

តាមស្ថានភាពជាក់ស្តែងនៃប្រភពអគ្គិសនីនៅរាជធានីភ្នំពេញ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយនៅរាជធានីភ្នំពេញ ត្រូវចែកចេញជា ២ ប្រភេទ គឺ ទី១.ការទិញជុំពីអនុស្ថានីយកណ្តាលក្រុងភ្នំពេញ ដែលបានចូលរួម

ប្រើប្រភពអគ្គិសនីរបស់រោងចក្រអគ្គិសនីប្រើប្រេង ដែលមានក្នុងក្រុងភ្នំពេញ និងទី២.ការទិញដុំពីអនុស្ថានីយ នៅជាយក្រុងភ្នំពេញ ដែលប្រើប្រភពអគ្គិសនីរបស់បណ្តាញជាតិ មិនពាក់ព័ន្ធជាមួយរោងចក្រអគ្គិសនីប្រើប្រេង ដែលមានក្នុងក្រុងភ្នំពេញ ។ ដូច្នេះ ការទិញអគ្គិសនីដុំពីអនុស្ថានីយនៅជាយក្រុងភ្នំពេញ គឺជាការទិញដុំផ្ទាល់ពីបណ្តាញជាតិ ដែលត្រូវអនុវត្តតាមផែនការថ្លៃរបស់បណ្តាញជាតិ ដោយឡែកការទិញអគ្គិសនីដុំ ពីអនុស្ថានីយកណ្តាលក្រុងភ្នំពេញ គឺជាការទិញដុំពីប្រព័ន្ធមួយដែលមានការចូលរួមជួយជានាស្ថេរភាពរបស់រោងចក្រប្រើប្រេងឥន្ធនៈនានា ដែលមាននៅក្នុងរាជធានីភ្នំពេញ ទាំងរបស់ EDC និងទាំងរបស់អ្នកវិនិយោគឯកជន (IPP) ដូច្នេះ ក្នុងករណីនេះ អ្នកទិញដុំត្រូវមានកាតព្វកិច្ចជួយចេញថ្លៃចំណាយខ្លះលើរោងចក្រប្រើប្រេងឥន្ធនៈទាំងនេះ ទាំងរបស់ EDC និងទាំងរបស់អ្នកវិនិយោគឯកជន (IPP) ដែលបានត្រៀមបម្រុងប្រភពអគ្គិសនីសម្រាប់បញ្ចេញប្រភពថាមពល នៅពេលមានតម្រូវការជានានូវស្ថេរភាពនៃការផ្គត់ផ្គង់ បន្ថែមពីលើថ្លៃរបស់បណ្តាញជាតិ ។

- **ទិញពីអនុស្ថានីយនៅជាយរាជធានីភ្នំពេញ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ |
|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.129$/kWh | 0.126$/kWh |

- **ទិញពីអនុស្ថានីយនៅកណ្តាលក្រុងភ្នំពេញ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ |
|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.129$/kWh + ថ្លៃសេវាមធ្យមនៃ IPP | 0.126$/kWh+ ថ្លៃសេវាមធ្យមនៃ IPP |

<u>**កំណត់សំគាល់**</u>៖ ថ្លៃសេវាមធ្យមនេះ ត្រូវកំណត់ ១ ឆ្នាំម្តង ទៅតាមកំណើននៃបរិមាណប្រភពអគ្គិសនីដែលក្រុងភ្នំពេញ ត្រូវការ ដែលនឹងថយចុះបន្តិចម្តងៗ រហូតដល់ចំនួនមួយដែលអាចលុបចេញបាន ។

## ២.២ ការផ្គត់ផ្គង់អគ្គិសនីនៅក្រៅតំបន់របស់អគ្គិសនីកម្ពុជា ចេញពីបណ្តាញមេរបស់រាជធានីភ្នំពេញ (ជួយចេញថ្លៃ IPP បន្ថែមឲ្យភ្នំពេញ)

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែចេញពីPP | 0.177$/kWh | 0.172$/kWh | 0.167$/kWh | 0.165$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញបញ្ជូនរង ដែលមិនពាក់ព័ន្ធនឹងការប្រើប្រភពរបស់ផ្នែកក្នុងរបស់ប្រព័ន្ធភ្នំពេញ

ចំពោះការផ្គត់ផ្គង់អគ្គិសនីដុំ ចេញពីបណ្តាញបញ្ជូនរងនានា ក្រៅក្រុងភ្នំពេញ ដែលមិនពាក់ព័ន្ធដល់ការប្រើប្រាស់ប្រភពអគ្គិសនីផ្នែកក្នុង របស់ប្រព័ន្ធចែកចាយរាជធានីភ្នំពេញ មិនមានការតម្រូវឲ្យបង់ថ្លៃសេវាបន្ថែមសម្រាប់រោងចក្រអគ្គិសនី ដែលត្រៀមបម្រុងនៅក្នុងរាជធានីភ្នំពេញ ឡើយ ដូច្នេះផែនការបន្ថយថ្លៃលក់អគ្គិសនី MV ដែលទិញពីបណ្តាញបញ្ជូនរងទាំងនេះ មានដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់ ៖** លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅខាងលើបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋានសម្រាប់គណនា ។

## ២.៤ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅកណ្តាលក្រុងភ្នំពេញ

ស្ថានភាពថ្លៃអគ្គិសនី នៅឆ្នាំ ២០១៥ និងផែនការបន្ថយថ្លៃទៅអនាគត ក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅរាជធានីភ្នំពេញ មានស្ថានភាពដូចខាងក្រោម ៖

### (១).ស្ថានភាពថ្លៃនៅឆ្នាំ ២០១៥

| ប្រភេទអតិថិជន | | អត្រាថ្លៃលក់ |
|---|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា** | | |
| ដែលប្រើមិនលើស ៥០ kWh ក្នុង១ខែ | | ៦១០ រៀល ក្នុង ១ kWh |
| ដែលប្រើពី ៥១ ដល់ ២០ 0kWh ក្នុង១ខែ | | ៧២០ រៀល ក្នុង ១ kWh |
| ដែលប្រើលើសពី ២០០ kWh ក្នុង១ខែ | | ៨២០ រៀល ក្នុង ១ kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ** | | |
| គ្រប់ទំហំប្រើប្រាស់ | | ៨២០ រៀល ក្នុង ១ kWh |
| **៣.អតិថិជនស្ថានទូត ផ្ទះ និងស្ថាប័ននានារបស់ជនបរទេស** | | |
| គ្រប់ទំហំប្រើប្រាស់ | | ៨២០ រៀល ក្នុង ១ kWh |
| **៤.អតិថិជនរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្ម ទាំងអស់** | | |
| ធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US) ក្នុង ១ kWh | |
| ធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US) ក្នុង ១ kWh | |
| ធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US) ក្នុង ១ kWh | |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US) ក្នុង ១ kWh | |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US) ក្នុង ១ kWh | |

**កំណត់សំគាល់៖** ល្បាយប្រភពអគ្គិសនីដែលអគ្គិសនីកម្ពុជាបានប្រើខាងលើ គឺជាល្បាយនៃប្រភពអគ្គិសនីដែលចេញពីប្រភពបណ្តាញជាតិ ដែលមានថ្លៃថោក និងចេញពីប្រភពរោងចក្រប្រើប្រេងនៅក្នុងរាជធានីភ្នំពេញ ។ ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី ដែល EDC បានគណនាសម្រាប់ឆ្នាំ ២០១៥ ឃើញស្មើនឹង 0.157$/kWh ។ ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនីនេះ ត្រូវបាន EAC អនុម័តយល់ព្រម ធ្វើឲ្យថ្លៃទិញអគ្គិសនីរបស់អតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញ MV របស់ EDC សម្រាប់ឆ្នាំ ២០១៥ មានអត្រាស្មើ 0.177$/kWh ពីព្រោះត្រូវបូកនឹងថ្លៃសេវាបណ្តាញចែកចាយ 0.020$US ក្នុង១kWh បន្ថែមទៀត។

### (២).ផែនការបន្ថយថ្លៃដែលត្រូវអនុវត្តពីខែ មីនា ឆ្នាំ ២០១៦

ការបន្ថយថ្លៃអគ្គិសនី ចាប់ពីខែ មីនា ឆ្នាំ ២០១៦ នឹងត្រូវអនុវត្តតាមផែនការដូចខាងក្រោម ៖

- **សម្រាប់អ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម**

ចំពោះអ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម ថ្លៃអគ្គិសនីសម្រាប់ឆ្នាំ ២០១៦ ដល់ ២០២០ នៅរក្សាអនុវត្តយន្តការគណនាដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | ថ្លៃអគ្គិសនី |
|---|---|
| ធុនតូច | = ( ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US ) ក្នុង ១ kWh |
| ធុនមធ្យម | = ( ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US ) ក្នុង ១ kWh |
| ធុនធំ | = ( ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US ) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = ( ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US ) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ | = ( ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US ) ក្នុង ១ kWh |

ប៉ុន្តែថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី ក្នុងតារាងគណនា មានផែនការបន្ថយថ្លៃ ដូចខាងក្រោម ៖

| | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ថ្លៃល្បាយប្រភពអគ្គិសនី | 0.157$/kWh | 0.152$/kWh | 0.147$/kWh | 0.145$/kWh | 0.143$/kWh | 0.142$/kWh |

ដូច្នេះផែនការថ្លៃអគ្គិសនីទិញលើតង់ស្យុងមធ្យម ក្នុងប្រព័ន្ធរាជធានីភ្នំពេញ របស់អគ្គិសនីកម្ពុជា មានអត្រាតាមឆ្នាំ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែចេញពីPP | 0.177$/kWh | 0.172$/kWh | 0.167$/kWh | 0.165$/kWh | 0.163$/kWh | 0.162$/kWh |

- **សម្រាប់លំនៅដ្ឋាន** ( **ថ្លៃធម្មតានិងថ្លៃអនុគ្រោះដល់លំនៅដ្ឋានក្រីក្រ** )

| ទំហំប្រើប្រាស់ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| លើសពី ២០០kWh/m | ៨២០៛/kWh | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |
| ពី៥១ដល់២០០kWh/m | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh |
| មិនលើសពី៥០ kWh/m | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh |

- **សម្រាប់អតិថិជនរាយដ៏ទៃទៀតក្រៅពីលំនៅដ្ឋាន**

| ទំហំប្រើប្រាស់ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| គ្រប់ទំហំប្រើប្រាស់ | ៨២០៛/kWh | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

## ២.៥ ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់លក់រាយ ក្នុងដែនអាជ្ញាប័ណ្ណអគ្គិសនីកម្ពុជា

ដូចបានជំរាបជូនខាងលើ ក្នុងដែនអាជ្ញាប័ណ្ណចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា មានតំបន់លក់រាយចំនួន ៤ តំបន់ ដែលជាតំបន់ផ្សារលក់ដូរសាធារណៈ ។ តំបន់ទាំង ៤ នេះមាន ផ្សារអូរឫស្សី, ផ្សារកណ្តាល, ផ្សារ City Mall, និងផ្សារច្បារអំពៅ ។ បច្ចុប្បន្នការកំណត់ថ្លៃអគ្គិសនីសម្រាប់តំបន់ផ្សារទាំង ៤ នេះគឺធ្វើតាមការគណនាថ្លៃប្រភពអគ្គិសនីដែលអគ្គិសនីកម្ពុជាលក់ដុំឲ្យអ្នកលក់រាយ និងការចំណាយជាក់ស្តែងនៃតំបន់លក់រាយនីមួយៗ ។ ដោយសារតែតំបន់នេះ គឺជាផ្សារលក់ដូរដែលអ្នកប្រើប្រាស់អគ្គិសនីនីមួយៗ ទិញអគ្គិសនីយកទៅប្រើប្រាស់ ដើម្បីបម្រើអាជីវកម្មលក់ដូររបស់ខ្លួន ដូច្នេះថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនប្រភេទនេះ ពុំមានការផ្តល់លក្ខខណ្ឌអនុគ្រោះដូចលំនៅដ្ឋានទេ គឺត្រូវលក់តាមថ្លៃអាជីវកម្មធម្មតា ។ ដោយសារតែតំបន់ទាំងនេះ គឺជាតំបន់ក្នុងដែនអាជ្ញាប័ណ្ណចែកចាយរបស់អគ្គិសនីកម្ពុជា ដូច្នេះអគ្គិសនីកម្ពុជា មានកាតព្វកិច្ចត្រូវធ្វើយ៉ាងណាឲ្យថ្លៃលក់អគ្គិសនីនៅក្នុងតំបន់លក់រាយនេះ ដូចគ្នានឹងអត្រាថ្លៃអគ្គិសនីនៅក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន ។ ដូច្នេះ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទៅ ផែនការថ្លៃលក់អគ្គិសនីនៅតំបន់លក់រាយក្នុងដែនអាជ្ញាប័ណ្ណអគ្គិសនីកម្ពុជានេះ ត្រូវអនុវត្តតាមការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដែលពុំមានលក្ខខណ្ឌអនុគ្រោះ ដូចខាងក្រោម ៖

| ការប្រើប្រាស់ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ប្រើប្រាស់ធម្មតាតាមតូប | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

**កំណត់សំគាល់**៖ អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជាត្រូវរៀបចំកំណត់ថ្លៃលក់ដុំឲ្យសេវាករលក់រាយ ព្រមទាំងយន្តការ និងនីតិវិធី គណនាថ្លៃ ដើម្បីឲ្យសេវាករលក់រាយនៅតំបន់លក់រាយទាំងនេះ អាចលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់តាមអត្រាថ្លៃកំណត់តាមផែនការរបស់រាជរដ្ឋាភិបាលខាងលើ ដោយរក្សាបាននូវនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីរបស់អ្នកលក់រាយក្នុងតំបន់របស់ខ្លួនបន្តទៀត ។

## ២.៦ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលបានទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិ

ដូចបានជំរាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជននៅរាជធានីភ្នំពេញទាំង ១៤ តំបន់ មានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម និង ១២ តំបន់ជាតំបន់ចែកចាយឲ្យប្រជាពលរដ្ឋធម្មតា ។ ម្យ៉ាងទៀត ក្នុងនោះតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្មទាំង ២ តំបន់ទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិ បន្ថែមពីលើរោងចក្រអគ្គិសនីប្រើប្រេងផ្ទៃក្នុងរបស់ខ្លួន និងតំបន់ចែកចាយ ១១ តំបន់ជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិ រួច ១ តំបន់ទៀត ជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលជាបណ្ដោះអាសន្ន ។ ដូច្នេះយើងពិនិត្យមើលផែនការបន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ៣ ប្រភេទខាងលើនេះ ដូចខាងក្រោម ៖

### (១).ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម

តាមខ្លឹមសារនៃផែនការយុទ្ធសាស្ត្រ បន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១៥-២០២០ បានកំណត់ថា "អត្រាថ្លៃដែលកំណត់ក្នុងផែនការយុទ្ធសាស្ត្រ នឹងមិនគ្របដណ្ដប់លើតំបន់សេដ្ឋកិច្ចពិសេស ឬតំបន់ឧស្សាហកម្ម ដែលម្ចាស់តំបន់នីមួយៗ ធ្វើការផ្គត់ផ្គង់អគ្គិសនីដោយផ្ទាល់ ដោយប្រើរោងចក្រអគ្គិសនីផ្ទាល់ខ្លួនបន្ថែម ពីលើការយកប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជាឡើយ" ។ ការកំណត់ដូច្នេះគឺដោយសារស្ថាប័នជំនាញផ្ដល់លទ្ធភាពឲ្យម្ចាស់តំបន់សេដ្ឋកិច្ច ឬតំបន់ឧស្សាហកម្ម អាចធ្វើការរំលោះទុនវិនិយោគដែលខ្លួនបានវិនិយោគលើរោងចក្រអគ្គិសនីបម្រុង ដើម្បីបង្កើនកម្រិតស្ថេរភាពនៅក្នុងតំបន់របស់ខ្លួន ។ ដូច្នេះ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្មទាំង ២ តំបន់នៅក្នុងទឹកដីនៃរាជធានីភ្នំពេញនេះ នឹងត្រូវកំណត់ថ្លៃដោយឡែក តាមថ្លៃប្រភពអគ្គិសនីដែលទទួលបានពីបណ្ដាញជាតិ បូកបន្ថែមនឹងថ្លៃរោងចក្រអគ្គិសនីប្រើប្រេងដែលគេបានវិនិយោគក្នុងតំបន់របស់គេ ។

### (២).ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយដែលទទួលប្រភពពីបណ្ដាញជាតិ

ចំពោះតំបន់ចែកចាយ ដែលទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិទាំង ១១ តំបន់ ថ្លៃអគ្គិសនីត្រូវអនុវត្តតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,000៛/kWh | ៨00៛/kWh | ៧៩0៛/kWh | ៧៧0៛/kWh | ៧៦0៛/kWh | ៧៥0៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១0kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨0៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥0៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨0៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥0៛/kWh |

### (៣).**ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយឯកជន ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម្ស៊ីនដៀសែលនៅកោះដាច់**

នៅលើកោះដាច់ ឃុំកោះដាច់ ខណ្ឌជ្រោយចង្វារ ដោយសារមានទន្លេឃាំងជុំវិញ ធ្វើឲ្យពិបាកក្នុងការបញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្គត់ផ្គង់ឲ្យដូច្នេះការផ្គត់ផ្គង់អគ្គិសនីឲ្យកោះនេះ ត្រូវបានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជនផលិតអគ្គិសនីដោយប្រើម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ប្រែប្រួលទៅតាមថ្លៃប្រេងឥន្ធនៈ។ដើម្បីដោះស្រាយការផ្គត់ផ្គង់អគ្គិសនីប្រកបដោយគុណភាពស្ថេរភាព និងថ្លៃថោកដល់ប្រជាពលរដ្ឋដែលនៅលើកោះនេះ អគ្គិសនីកម្ពុជាមានគម្រោងដាក់ទុនវិនិយោគកប់ខ្សែកាបតង់ស្យុងមធ្យម ២២ គីឡូវ៉ុល នៅបាតទន្លេ ដើម្បីបញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្គត់ផ្គង់ឲ្យសេវាករចែកចាយអគ្គិសនីនៅលើកោះនេះ ។ បញ្ហាថ្លៃអគ្គិសនីសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់អគ្គិសនីនៅលើកោះដាច់ ឃុំកោះដាច់ ខណ្ឌជ្រោយចង្វារ ត្រូវបានបែងចែកជា ២ ដំណាក់កាលគឺ ៖ ទី១.ដំណាក់កាលនៅប្រើម៉ាស៊ីនដៀសែល ថ្លៃអគ្គិសនីកំណត់ទៅតាមថ្លៃប្រេងឥន្ធនៈ និងទី២.ដំណាក់កាលក្រោយពេលទទួលបានប្រភពអគ្គិសនីពីបណ្តាញជាតិ ពេលនោះថ្លៃអគ្គិសនីនឹងចាប់អនុវត្តដូចថ្លៃអគ្គិសនីរបស់តំបន់ដ៏ទៃទៀត ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិដែរ (ផែនការថ្លៃមានបង្ហាញនៅចំណុចខាងលើរួចហើយ) ។ ដូច្នេះពេលវេលាបន្ថយថ្លៃអគ្គិសនីនៅលើកោះដាច់ ខាងលើនេះអាស្រ័យនឹងការដោះស្រាយទុនវិនិយោគ និងការសាងសង់ខ្សែកាបកប់បាតទន្លេ របស់អគ្គិសនីកម្ពុជា ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តកណ្តាល សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកណ្តាល

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តកណ្តាល និងរាជធានីភ្នំពេញ ត្រូវបានចាត់ទុកជាតំបន់មួយដែលមានបន្ទុកអគ្គិសនីធំនៅកម្ពុជា ធៀបទៅនឹងខេត្តដ៏ទៃទៀត និងមានអនុស្ថានីយបណ្តាញជាតិច្រើន (ប្រើប្រាស់រួមគ្នាជាមួយរាជធានីភ្នំពេញ) នៅរាយប៉ាយក្នុងតំបន់នេះទៅតាមស្ថានភាពនៃភូមិសាស្ត្រ និងស្ថានភាពនៃបន្ទុក ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិទាំងនេះ ទៅឲ្យតំបន់ចែកចាយនានានៅក្នុងខេត្តកណ្តាល គឺធ្វើតាមបណ្តាញបញ្ជូនរងដែលបច្ចុប្បន្នមានបណ្តាញបញ្ជូនរង ៣ គឺ ៖ ១.បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ២.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អិល.អិម.ខេ និង៣.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង ។ ក្រៅពីការបញ្ជូនអគ្គិសនីតាមរយៈបណ្តាញបញ្ជូនរងទាំង ៣ នេះ ក៏នៅមានការបញ្ជូនបន្តគ្នាជាបណ្តោះអាសន្នរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ក្នុងពេលដែលអ្នកបញ្ជូនរងទាំង ៣ ពុំទាន់អាចពង្រីកបឲ្យរាយពាសពេញទូទាំងខេត្តកណ្តាលបាន ។ ក្រៅពីនេះនៅខេត្តកណ្តាល ក៏មានការនាំចូលអគ្គិសនីពីប្រទេសវៀតណាម និងការបញ្ជូនបន្តគ្នាជាបណ្តោះអាសន្ន របស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយដែលបាននាំចូលអគ្គិសនីពីប្រទេសវៀតណាមផងដែរ ដែលបច្ចុប្បន្ន កំពុងតែដោះស្រាយរៀបចំឲ្យភ្ជាប់ប្រភពអគ្គិសនីពីបណ្តាញជាតិវិញ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តកណ្តាល មានក្រុង ១ ឈ្មោះក្រុងតាខ្មៅ និងស្រុកចំនួន ១០ គឺ ៖ ១.ស្រុកល្វាឯម ២.ស្រុកកៀនស្វាយ ៣.ស្រុកលើកដែក ៤.ស្រុកកណ្តាលស្ទឹង ៥.ស្រុកពញាឮ ៦.ស្រុកខ្សាច់កណ្តាល ៧.ស្រុកអង្គស្នួល ៨.ស្រុកមុខកំពូល ៩.ស្រុកកោះធំ និង១០.ស្រុកស្អាង ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកណ្តាល ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយ **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរង និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ត្រូវបានចែកជា ៥ ប្រភេទ ទៅតាមតំបន់ចែកចាយគឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ទី២.តំបន់ចែកចាយរបស់សេវាករឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងនានា, ទី៣.តំបន់ចែកចាយនៅជាប់ព្រំដែនវៀតណាម ដែលប្រើប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល ទី៤.តំបន់នៅឆ្ងាយពីប្រភពទាំង ២ ខាងលើ ដែលដោះស្រាយដោយការបញ្ជូនបន្តគ្នា ជាបណ្តោះអាសន្ន និងទី៥.តំបន់កោះឧញ៉ាតី ខណ្ឌដោយទន្លេធំៗ ជុំវិញ ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ បច្ចុប្បន្ននៅខេត្តកណ្តាល មានតំបន់ចែកចាយអគ្គិសនីរាយចំនួន ៥៣ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងតាខ្មៅ និង ៥២

តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន។ តំបន់ចែកចាយរបស់សេវាករឯកជនទាំង ៥២ ចែកចេញជា ៣ ប្រភេទគឺ ទី១.តំបន់ចែកចាយដែលទិញអគ្គិសនីពីប្រភពបណ្តាញជាតិ មាន ៥០ តំបន់ ទី២. តំបន់ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មាន ១ តំបន់ និងទី៣.តំបន់ដែលនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី មាន ១ តំបន់ ។ តំបន់ចែកចាយរបស់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពបណ្តាញជាតិទាំង ៥០ តំបន់នោះមាន ៖ ៨ តំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយរបស់អគ្គិសនីកម្ពុជា, ១១ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ៧ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អិល.អិម.ខេ, ១៣ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង, ៣ តំបន់ទិញប្រភពអគ្គិសនីពីក្រុមហ៊ុន ម៉េងសុខឡេង ខនស្រ្តាក់សិន អេឡិកទ្រីក ដែលចាត់ទុកដូចជាបណ្តាញបញ្ជូនរងដែរ, ៦ តំបន់ទិញប្រភពអគ្គិសនីពីអគ្គិសនីកៀនស្វាយ ដែលបានចាត់ទុកដូចជាបណ្តាញបញ្ជូនរងដែរ និង ២ តំបន់ទិញបន្តគ្នាមួយជាន់ទៀតក្នុងលក្ខណៈបណ្តោះអាសន្នរង់ចាំទិញផ្ទាល់ពីខ្សែបញ្ជូនរងណាមួយដែលពង្រីកទៅដល់ ។ តំបន់ផ្គត់ផ្គង់ដោយការនាំចូលអគ្គិសនីពីប្រទេសវៀតណាម មាន ១ តំបន់ ហើយតំបន់នេះ ក៏បានទិញអគ្គិសនីផ្ទាល់ពីអនុស្ថានីយយកទៅបន្ថែមផងដែរ ។ នៅខេត្តកណ្តាល នេះមានតំបន់ ១ នៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ គឺតំបន់ចែកចាយនៅលើកោះឧញ៉ាតី ដែលខណ្ឌដោយទន្លេជុំវិញ ។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកណ្តាល

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (កណ្តាល) | 001 L | GS | ក្រុងតាខ្មៅ |
| 2 | សហគ្រាស ធី.អិន.ឌី.អិន អេឡិកទ្រីធី | 071 L | GS | ស្រុកស្អាង |
| 3 | សហគ្រាស អេឡិចទ្រីស៊ីធី ស្អាង | 086 L | GS | ស្រុកស្អាង |
| 4 | សេវាករ ឡេង ម៉ូវ | 099 L | GS | ស្រុកឧត្តុង្គ |
| 5 | ក្រុមហ៊ុន ម៉េងសុខឡេង ខនស្រ្តាក់សិន អេឡិកទ្រីក | 137 L | GS | ស្រុកអង្គស្នួល |
| 6 | ក្រុមហ៊ុន អគ្គិសនី កៀនស្វាយ | 150 L | GS | ស្រុកកៀនស្វាយ |
| 7 | ក្រុមហ៊ុន ខ្មែរ អេឡិកទ្រីស៊ីធី សឺវីស | 151 L | GS | ស្រុកស្អាង |
| 8 | ក្រុមហ៊ុន អិល.អិម.ខេ | 223 L | GS | ស្រុកកណ្តាលស្ទឹង |
| 9 | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី | 224 L | GS | ស្រុកកណ្តាលស្ទឹង |
| 10 | ក្រុមហ៊ុន អានកូ អាហារ៍ណៃ នីហាវ៉ណៃ | 011 L | GS & VN | ស្រុកកោះធំ |
| 11 | ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប | 014 L | GS-EDC | ស្រុកអង្គស្នួល |
| 12 | សេវាករ នៅ ស្រីពេជ្រ | 021 L | GS-EDC | ស្រុកកៀនស្វាយ |
| 13 | សេវាករ ង៉ែត ហុង | 053 L | GS-EDC | ស្រុកអង្គស្នួល |
| 14 | សហគ្រាស អេឡិចទ្រីស៊ីធី អង្គស្នួល | 061 L | GS-EDC | ស្រុកអង្គស្នួល |
| 15 | ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ | 090 L | GS-EDC | ស្រុកមុខកំពូល |
| 16 | សហគ្រាស មូល ទិត្យ អគ្គិសនី | 176 L | GS-EDC | ស្រុកពញាឮ |
| 17 | អគ្គិសនី សំពោងធំ | 226 L | GS-EDC | ស្រុកកៀនស្វាយ |
| 18 | សេវាករ អៃ ហេងហួត | 264 L | GS-EDC | ស្រុកពញាឮ |
| 19 | សេវាករ ឈរ វ៉េងងួន | 355 L | GS-EDC | ស្រុកខ្សាច់កណ្តាល |
| 20 | សួនឧស្សាហកម្ម ឈុន ហុង | 381 L | GS-EDC | ស្រុកអង្គស្នួល |
| 21 | សួនឧស្សាហកម្ម សំពោងធំ អេស.អ៊ី.ហ្សេត | 398 L | GS-EDC | ស្រុកកៀនស្វាយ |
| 22 | សេវាករ ឈុន លី | 170 L | GS-EDC-SRTH | ស្រុកកៀនស្វាយ |

| | | | | |
|---|---|---|---|---|
| 23 | សហគ្រាស ក្អមសំណរ ឌីវេឡុបមេន | 316 L | GS-EDC-SRTH-NSP | ស្រុកលើកដែក |
| 24 | សហគ្រាស អ៊ិសធើន ផៅវ័រ សឹបផ្លាយ | 049 L | GS-KSV | ស្រុកស្អាង |
| 25 | សេវាករ ប៊ុន ហ៊ុយ | 169 L | GS-KSV | ស្រុកកៀនស្វាយ |
| 26 | សេវាករ ភួង សោភា | 171 L | GS-KSV | ស្រុកល្វាឯម |
| 27 | សេវាករ អ៊ីវ ម៉ាឡា | 211 L | GS-KSV | ស្រុកស្អាង |
| 28 | សេវាករ វាន់ រ៉ាមុន | 249 L | GS-KSV | ស្រុកល្វាឯម |
| 29 | សេវាករ អ៊ុក សុរិដ្ឋា | 350 L | GS-KSV | ស្រុកល្វាឯម |
| 30 | សហគ្រាស អគ្គិសនី កន្ទួត | 058 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 31 | ក្រុមហ៊ុន ខេម អិនជីននីរីង & ឌីវេឡុបមេន | 144 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 32 | សហគ្រាស អេឡិកទ្រីស៊ីធី បឹងខ្យាង | 153 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 33 | សហគ្រាស អេឡិកទ្រីស៊ីធី ពត់សរ | 174 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 34 | សហគ្រាស អគ្គិសនី ញ៉ឹក ម៉ី | 179 L | GS-LMK | ស្រុកស្អាង |
| 35 | សេវាករ ភឿន សារឿន | 219 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 36 | សេវាករ សោ សាអ៊ុន | 266 L | GS-LMK | ស្រុកកណ្ដាលស្ទឹង |
| 37 | សហគ្រាស ឧដុង្គ ផៅវ័រ សឹបផ្លាយ | 076 L | GS-MSL | ស្រុកពញាឮ |
| 38 | ក្រុមហ៊ុន អេស.វី.ស៊ី ផៅវ័រ ឌីវើឡុបមេន | 243 L | GS-MSL | ស្រុកពញាឮ |
| 39 | សេវាករ អ៊ូ ប៊ុនលី | 278 L | GS-MSL | ស្រុកពញាឮ |
| 40 | សេវាករ អៀង សេងហ៊ី | 037 L | GS-TPLC | ស្រុកមុខកំពូល |
| 41 | សេវាករ ឯ ឡុង | 062 L | GS-TPLC | ស្រុកពញាឮ |
| 42 | សហគ្រាស ពាន អ ធី ថេកណឡជី | 066 L | GS-TPLC | ស្រុកមុខកំពូល |
| 43 | សេវាករ ទ្រី ឡេង | 130 L | GS-TPLC | ស្រុកមុខកំពូល |
| 44 | សេវាករ ស៊ុន អូន | 186 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 45 | សេវាករ ឆាយ ចាន់សុភា | 204 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 46 | សេវាករ សុខ ពីន | 209 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 47 | សេវាករ ថូយ វ៉ុន | 230 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 48 | សហគ្រាស សូហ្វ ថេក | 234 L | GS-TPLC | ស្រុកមុខកំពូល |
| 49 | សេវាករ ចេង សុផល | 235 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 50 | សហគ្រាស អគ្គិសនី កំពង់ចម្លង | 272 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 51 | សេវាករ ឃុន ណៃគាង | 335 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 52 | ក្រុមហ៊ុន សីវេន អេនជី | 347 L | GS-TPLC | ស្រុកខ្សាច់កណ្ដាល |
| 53 | សេវាករ ស៊ុយ ចំណាន | 250 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកខ្សាច់កណ្ដាល |

# ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកណ្ដាល

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្ដល់ | | បានសាងសង់បណ្ដាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្ដាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| កណ្ដាលស្ទឹង | 127 | 125 | 98.43% | 123 | 96.85% | 2 |
| កៀនស្វាយ | 30 | 29 | 96.67% | 29 | 96.67% | - |
| ខ្សាច់កណ្ដាល | 93 | 93 | 100.00% | 93 | 100.00% | - |
| កោះធំ | 93 | 93 | 100.00% | 89 | 95.70% | 4 |
| លើកដែក | 24 | 24 | 100.00% | 23 | 95.83% | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| ល្វាឯម | 43 | 43 | 100.00% | 37 | 86.05% | 6 |
| មុខកំពូល | 39 | 35 | 89.74% | 39 | 100.00% | -4 |
| អង្គស្នួល | 200 | 197 | 98.50% | 176 | 88.00% | 21 |
| ពញាឮ | 124 | 122 | 98.39% | 115 | 92.74% | 7 |
| ស្អាង | 119 | 115 | 96.64% | 113 | 94.96% | 2 |
| តាខ្មៅ | 20 | 20 | 100.00% | 20 | 100.00% | - |
| សរុប | 912 | 896 | 98.25% | 857 | 93.97% | 39 |

### ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តកណ្ដាល




## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកណ្ដាល

ផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកណ្ដាល អាចបែងចែកជាផែនការលើការផ្គត់ផ្គង់ដោយឡែកចំនួន ៨ ប្រភេទ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយនានា ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្ដាញបញ្ជូនរងដែលចេញពីប្រព័ន្ធរបស់រាជធានីភ្នំពេញ (ថ្លៃខ្ពស់បន្តិចដោយត្រូវជួយចេញសេវា IPP បន្ថែមឲ្យភ្នំពេញ) ៣.ការផ្គត់ផ្គង់អគ្គិសនីជុំពីបណ្ដាញបញ្ជូនរងទាំងឡាយ ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជន ដែលមិនពាក់ព័ន្ធជាមួយប្រព័ន្ធភ្នំពេញ ៤.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ៥.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់ឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្ដាញជាតិ ៦.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់ឯកជនដែលយកប្រភពអគ្គិសនីពីបណ្ដាញជាតិដែរប៉ុន្តែបន្តពីតំបន់ចែកចាយ ១ ទៀត ៧.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់ឯកជនដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម និង៨.ការផ្គត់

ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលផលិតអគ្គិសនីពីម៉ាស៊ីនដ្យាសែល ។ ដូច្នេះផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកណ្ដាល ត្រូវបានបែងចែកលម្អិតជាផែនការ ទៅតាមការផ្គត់ផ្គង់អគ្គិសនីចំនួន ៨ ប្រភេទ ដូចខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្ដាញបញ្ជូនរងដែលចេញពីប្រព័ន្ធអគ្គិសនីរបស់រាជធានីភ្នំពេញ ( ជួយចេញសេវា IPP បន្ថែមឲ្យភ្នំពេញ )

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែចេញពីPP | 0.177$/kWh | 0.172$/kWh | 0.167$/kWh | 0.165$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្ដាញបញ្ជូនរងទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជន ដែលមិនពាក់ព័ន្ធជាមួយប្រព័ន្ធភ្នំពេញ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៤ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា

ចំពោះតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដែលគ្របដណ្ដប់ក្រុងតាខ្មៅ រាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ ថ្លៃអគ្គិសនីកំពុងអនុវត្ត និងការបន្ថយថ្លៃអគ្គិសនី នឹងអនុវត្តតាមផែនការដូចខាងក្រោម ៖

<u>**ថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលកំពុងអនុវត្តនៅឆ្នាំ២០១៥**</u>

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា នៅក្នុងតំបន់ចែកចាយក្រុងតាខ្មៅ ខេត្តកណ្ដាល** | |
| ដែលប្រើមិនលើស ៥០ kWh ក្នុង ១ ខែ | ៦១០ រៀល ក្នុង១kWh |
| ដែលប្រើមិនលើស ២០០ kWh ក្នុង ១ ខែ | ៧២០ រៀល ក្នុង១kWh |
| ដែលប្រើលើសពី ២០០ kWh ក្នុង ១ ខែ | ៨២០ រៀល ក្នុង១kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ** | |
| គ្រប់ទំហំប្រើប្រាស់ | ៨២០ រៀល ក្នុង១kWh |
| **៣.អតិថិជនស្ថានទូត ផ្ទះ និងស្ថាប័ននានារបស់ជនបរទេស** | |
| គ្រប់ទំហំប្រើប្រាស់ | ៨២០ រៀល ក្នុង១kWh |

| ៤.អតិថិជនរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្ម ទាំងអស់ | |
|---|---|
| ធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US) ក្នុង១kWh |
| ធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US) ក្នុង១kWh |
| ធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US) ក្នុង១kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US) ក្នុង១kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US)ក្នុង១kWh |

**កំណត់សំគាល់៖** ល្បាយប្រភពអគ្គិសនីដែលបានប្រើខាងលើ គឺជាល្បាយនៃប្រភពអគ្គិសនីពីបណ្តាញជាតិ និងប្រភពអគ្គិសនីចេញពីរោងចក្រប្រើប្រេងនៅជានីភ្នំពេញ ដោយសារក្រុងតាខ្មៅ ខេត្តកណ្តាល និងក្រុងច្បារមន ខេត្តកំពង់ស្ពឺ បានប្រើប្រព័ន្ធចែកចាយអគ្គិសនីជាប់ជាមួយប្រភពអគ្គិសនីរបស់ភ្នំពេញ ដូច្នេះថ្លៃប្រភពអគ្គិសនីត្រូវបានគិតដូចភ្នំពេញដែរ ។ ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី សម្រាប់ឆ្នាំ ២០១៥ គឺស្មើនឹង 0.157$/kWh។

ការបន្ថយថ្លៃអគ្គិសនី ចាប់ពីខែ មីនា ឆ្នាំ ២០១៦ នឹងត្រូវអនុវត្តតាមផែនការ ដូចខាងក្រោម ៖

**(១).សម្រាប់អ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម**

ចំពោះអ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម ថ្លៃអគ្គិសនីសម្រាប់ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ នៅរក្សាអនុវត្តយន្តការគណនាដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | ថ្លៃអគ្គិសនី |
|---|---|
| ធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US) ក្នុង១kWh |
| ធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US) ក្នុង១kWh |
| ធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US) ក្នុង១kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US) ក្នុង១kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US)ក្នុង១kWh |

ប៉ុន្តែថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី ក្នុងតារាងគណនា មានផែនការបន្ថយថ្លៃ ដូចខាងក្រោម ៖

| | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ថ្លៃល្បាយប្រភពអគ្គិសនី | 0.157$/kWh | 0.152$/kWh | 0.147$/kWh | 0.145$/kWh | 0.143$/kWh | 0.142$/kWh |

**(២).សម្រាប់លំនៅដ្ឋានទូទៅ (ថ្លៃធម្មតានិងថ្លៃអនុគ្រោះដល់លំនៅដ្ឋានក្រីក្រ)**

| ទំហំប្រើប្រាស់ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| លើសពី ២០០kWh/m | ៨២០៛/kWh | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |
| ពី៥១ដល់២០០kWh/m | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh |
| មិនលើសពី៥០ kWh/m | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh | ៦១០៛/kWh |

## ២.៥ តំបន់ចែកចាយរបស់ឯកជនដែលយកប្រភពអគ្គិសនី ពីបណ្តាញជាតិផ្ទាល់

ក្នុងចំណោមតំបន់ចែកចាយដែលគ្រប់គ្រងដោយសេវាករឯកជនទាំង ៥២ តំបន់ មាន ៤៨ តំបន់ គឺជាតំបន់ដែលត្រូវបានចាត់ទុកថា ដូចបានយកប្រភពអគ្គិសនីពីបណ្តាញជាតិផ្ទាល់ (ពីអនុស្ថានីយ ឬពីបណ្តាញបញ្ជូនរង) ដែលក្នុងនោះមាន ៖ ៨ តំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយរបស់អគ្គិសនីកម្ពុជា, ១១ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ៧ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អិល.អិម.ខេ,

១៣ តំបន់ទិញពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង, ៣ តំបន់ទិញប្រភពអគ្គិសនីពីក្រុមហ៊ុន ម៉េងសុខឡេង ខនស្រ្តាក់សិន អេឡិកទ្រីក ដែលចាត់ទុកដូចជាបណ្តាញបញ្ជូនរងដែរ, ៦ តំបន់ទិញប្រភពអគ្គិសនីពីក្រុមហ៊ុន អគ្គិសនី កៀនស្វាយ ដែលបានចាត់ទុកដូចជាបណ្តាញបញ្ជូនរងដែរ ។ ចំពោះតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលត្រូវបានចាត់ទុកថា យកអគ្គិសនីពីប្រភពបណ្តាញជាតិផ្ទាល់ ទាំង ៤៨ តំបន់នេះ ថ្លៃអគ្គិសនីកំពុងអនុវត្ត និងការបន្ថយថ្លៃអគ្គិសនី នឹងត្រូវអនុវត្តតាមផែនការ ដូចខាងក្រោម ៖

**សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៦ តំបន់ចែកចាយរបស់ឯកជន ដែលអគ្គិសនីពីបណ្តាញជាតិបន្តពីតំបន់មួយទៀត

ក្នុងចំណោមតំបន់ចែកចាយ ដែលគ្រប់គ្រងដោយសេវាករឯកជនទាំង ៥២ តំបន់ មាន ២ តំបន់ ក៏យកប្រភពអគ្គិសនីពីបណ្តាញជាតិដែរ ប៉ុន្តែពុំបានយកផ្ទាល់ពីបណ្តាញជាតិទេ គឺបានយកបន្តពីតំបន់ចែកចាយមួយទៀតដែលភ្ជាប់ជាមួយបណ្តាញជាតិក្នុងនោះមាន ៖ ទី ១ តំបន់របស់សេវាករ ឈុន លី នៅក្នុងស្រុកកៀនស្វាយ ដែលយកប្រភពអគ្គិសនីពីតំបន់ចែកចាយរបស់សហគ្រាស អគ្គិសនី សំរោងធំ ទី ២ តំបន់របស់សេវាករ នៅ ស្រីពេជ្រ យកប្រភពអគ្គិសនីពីតំបន់ចែកចាយរបស់សហគ្រាស អគ្គិសនី សំរោងធំ និងទី៣ សហគ្រាស ក្អមសំណរ ឌីវេឡុបមេន យកប្រភពអគ្គិសនីពីតំបន់ចែកចាយរបស់សេវាករ នៅ ស្រីពេជ្រ ។ នៅឆ្នាំ ២០១៥ ដើម្បីឲ្យមានថ្លៃទិញប្រភពដូចគេ និងមានថ្លៃលក់រាយស្មើនឹង ១,០០០ រៀល/គីឡូវ៉ាត់ម៉ោង ដូចគេ តំបន់ទាំង ៣ នេះ ត្រូវបានអគ្គិសនីកម្ពុជាជួយប៉ះប៉ូវចេញថ្លៃសេវាបញ្ជូនបន្ត ។ ក្នុងទិសដៅបន្តទៀត តំបន់ចែកចាយទាំង ២ ខាងលើនេះ ត្រូវបានចាត់ទុកថាឋិតនៅក្នុងកាតព្វកិច្ចរបស់អគ្គិសនីកម្ពុជា ដែលជាម្ចាស់ប្រភពអគ្គិសនីរបស់បណ្តាញជាតិ ដែលត្រូវធ្វើយ៉ាងណាឲ្យតំបន់ទាំង ៣ នេះ អាចអនុវត្តថ្លៃអគ្គិសនីតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាលចាប់ពីខែ មីនា ឆ្នាំ ២០១៦ ដែរ ។ ដូច្នេះបន្តទៀត អគ្គិសនីកម្ពុជាអាចបន្តប៉ះប៉ូវបន្ថែមទៀតសម្រាប់តំបន់ទាំង ៣ ឬក៏សម្រេចចិត្តសាងសង់ខ្សែបណ្តាញ ២២ គីឡូវ៉ុល និងតម្លើងត្រង់ស្វូផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់ទាំង ៣ នេះ ផ្ទាល់តែម្តង ។

## ២.៧ តំបន់ចែកចាយរបស់ឯកជន ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម

ក្រុមហ៊ុន អានកូ អាហរ័ណ នីហរ័ណ (ជ្រៃធំ) ត្រូវបានអនុញ្ញាតឲ្យនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ។ កន្លងមក ក្រៅពីធ្វើការចែកចាយអគ្គិសនីក្នុងដែនអាជ្ញាប័ណ្ណរបស់ខ្លួន ក្រុមហ៊ុននេះ ក៏ត្រូវបានអនុញ្ញាតឲ្យលក់ប្រភពអគ្គិសនីបន្តឲ្យសេវាករចែកចាយឯកជន ២ ទៀត នៅក្នុងស្រុកស្អាងដែរ ។ ដោយសារថ្មីៗ នេះ ការផ្គត់ផ្គង់អគ្គិសនីរបស់ប្រទេសវៀតណាម ឲ្យតំបន់នេះមានការរអាក់រអួលញឹកញាប់ ប្រជាពលរដ្ឋនៅតំបន់នេះ បានស្នើសុំឲ្យមានការដោះស្រាយការផ្គត់ផ្គង់ពីបណ្តាញជាតិវិញ ទោះជាថ្លៃលក់អគ្គិសនីត្រូវឡើងខ្ពស់ជាងពេលយកអគ្គិសនីពីប្រទេសវៀតណាម ក៏ដោយ ។ ដូច្នេះនៅឆ្នាំ ២០១៥ នេះ តំបន់ឯកជន ២ ដែលទិញប្រភពអគ្គិសនីបន្តពីក្រុមហ៊ុន អានកូ អាហរ័ណ នីហរ័ណ (ជ្រៃធំ) ត្រូវបានអនុញ្ញាតឲ្យយកប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិផ្ទាល់វិញ រួចផែនការបន្ថយថ្លៃអគ្គិសនីនៃតំបន់ទាំង ២ នេះ នឹងអនុវត្តដូចផែនការរួមខាងលើ ដោយតំបន់ចែកចាយទាំង ២ នេះ បានបញ្ចូលទៅក្នុងតំបន់ដែលត្រូវយកប្រភពអគ្គិសនីពីបណ្តាញជាតិទាំង ៥០ ខាងលើ ។ ចំពោះតំបន់ចែកចាយរបស់ក្រុមហ៊ុន អានកូ អាហរ័ណ នីហរ័ណ (ជ្រៃធំ) បច្ចុប្បន្នក្រៅពីការនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ក៏បានអនុញ្ញាតឲ្យភ្ជាប់ប្រភពអគ្គិសនីពីអនុស្ថានីយផ្ទាល់ដែរ ដូច្នេះអាចអនុវត្តថ្លៃអគ្គិសនីតាមផែនការរបស់រាជរដ្ឋាភិបាលពេលណាក៏បាន ។ សម្រាប់ឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនឹងត្រូវកំណត់ទៅតាមគោលការណ៍អាជីវកម្មផ្ទាល់នៃតំបន់នេះ ដែលអាចមានថ្លៃទាបជាងផែនការ ។ ប៉ុន្តែចាប់ពីខែ មីនា ឆ្នាំ ២០១៦ តទៅ ថ្លៃអគ្គិសនីនៅតំបន់ខាងលើ អាចកំណត់ទៅតាមផែនការរួមទូទាំងប្រទេសរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានទាំងថ្លៃធម្មតា និងថ្លៃអនុគ្រោះ ដូចតំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិផ្ទាល់ដែរ ។

## ២.៨ តំបន់ចែកចាយរបស់ឯកជន ដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល

នៅលើកោះឧកញ៉ាតី នៃស្រុកខ្សាច់កណ្តាល ដោយសារមានទន្លេឃាំងជុំវិញ ធ្វើឲ្យពិបាកក្នុងការបញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្តល់ឲ្យ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីឲ្យកោះនេះ ត្រូវបានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជនផលិតអគ្គិសនីដោយប្រើម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ប្រែប្រួលទៅតាមថ្លៃប្រេងឥន្ធនៈ ។ ដើម្បីដោះស្រាយការផ្គត់ផ្គង់អគ្គិសនីប្រកបដោយគុណភាព ស្ថេរភាព និងថ្លៃសមរម្យដល់ប្រជាពលរដ្ឋដែលនៅលើកោះនេះ អគ្គិសនីកម្ពុជាមានគម្រោងដាក់ទុនវិនិយោគកប់ខ្សែកាបតង់ស្យុងមធ្យម ២២ គីឡូវ៉ុល នៅបាតទន្លេ ដើម្បីបញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្តល់ឲ្យសេវាករចែកចាយអគ្គិសនីនៅលើកោះនេះ ឲ្យបានមុនដំណាច់ឆ្នាំ ២០១៥ នេះ ។ បញ្ហាថ្លៃអគ្គិសនីសម្រាប់ប្រជាពលរដ្ឋប្រើប្រាស់អគ្គិសនីនៅលើកោះឧកញ៉ាតី ត្រូវបានបែងចែកជា ២ ដំណាក់កាល គឺ ៖ ទី១.ដំណាក់កាលនៅប្រើម៉ាស៊ីនដៀសែល ថ្លៃអគ្គិសនីកំណត់ទៅតាមថ្លៃប្រេងឥន្ធនៈ និងទី ២.ដំណាក់កាលក្រោយពេលទទួលបានប្រភពអគ្គិសនីពីបណ្តាញជាតិ ពេលនោះថ្លៃអគ្គិសនីនឹងចាប់អនុវត្តដូចថ្លៃអគ្គិសនីរបស់តំបន់ដ៏ទៃទៀត ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិដែរ ។ ដូច្នេះពេលវេលាបន្ថយថ្លៃអគ្គិសនីនៅលើកោះឧកញ៉ាតី ខាងលើនេះ អាស្រ័យនឹងការដោះស្រាយទុនវិនិយោគ និងការសាងសង់ខ្សែកាបកប់បាតទន្លេរបស់អគ្គិសនីកម្ពុជា ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ស្ពឺ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពង់ស្ពឺ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តកំពង់ស្ពឺ ជាខេត្តមួយដែលមានទីតាំងនៅជិតរាជធានីភ្នំពេញ និងបានតភ្ជាប់ជាមួយប្រព័ន្ធបណ្តាញអគ្គិសនីរាជធានីភ្នំពេញ ១ ផ្នែកតាមរយៈខ្សែបណ្តាញមេ ២២ គីឡូវ៉ុល ជាច្រើនខ្សែ ដែលភ្ជាប់ពីចុងខ្សែមេ ២២ គីឡូវ៉ុល របស់រាជធានីភ្នំពេញ មកដល់ក្រុងច្បារមន ខេត្តកំពង់ស្ពឺ និង ១ ផ្នែកទៀត តាមរយៈខ្សែបណ្តាញតង់ស្យុងខ្ពស់ ១១៥ គីឡូវ៉ុល ១ ខ្សែ ដែលភ្ជាប់ពីអនុស្ថានីយនៅភ្នំពេញ កាត់តាមកំពង់ស្ពឺ ទៅភ្ជាប់ជាមួយស្ថានីយវារីអគ្គិសនីគិរីរម្យទី ១ និងស្ថានីយវារីអគ្គិសនីគិរីរម្យទី ៣ ។ ក្រៅពីមានអនុស្ថានីយរបស់បណ្តាញជាតិ ១ កន្លែង ឋិតនៅក្រុងច្បារមនដែលជាទីរួមខេត្ត ខេត្តកំពង់ស្ពឺ ក៏បានទទួលប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ មួយចំនួនទៀត ដែលឋិតនៅជាយរាជធានីភ្នំពេញផងដែរ ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិទៅឲ្យតំបន់ចែកចាយនានានៅក្នុងខេត្តកំពង់ស្ពឺ គឺធ្វើឡើងតាមបណ្តាញបញ្ជូនរង ដែលបច្ចុប្បន្នមាន បណ្តាញបញ្ជូនរងចំនួន ២ គឺ ៖ ទី ១.បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី២.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តកំពង់ស្ពឺ មានក្រុង ១ ឈ្មោះក្រុងច្បារមន និងមានស្រុកចំនួន ៧ គឺ៖ ១.ស្រុកគងពិសី ២.ស្រុកបរសេដ្ឋ ៣.ស្រុកសំរោងទង ៤.ស្រុកភ្នំស្រួច ៥.ស្រុកថ្ពង ៦.ស្រុកឧដុង្គ និង៧.ស្រុកឱរ៉ាល់។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកំពង់ស្ពឺ ត្រូវបានដោះស្រាយដោយការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ការផ្គត់ផ្គង់អគ្គិសនីដុំពីបណ្តាញបញ្ជូនរងនានា និងការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ចែកជា ២ ប្រភេទ គឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងច្បាមន និងទី២.តំបន់ចែកចាយរបស់សេវាករឯកជន។ បច្ចុប្បន្ននៅខេត្តកំពង់ស្ពឺមានតំបន់ចែកចាយអគ្គិសនីចំនួន ១៩ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ ជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និង ១៨ តំបន់ ទៀត ជាតំបន់ចែកចាយរបស់សេវាករឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជន ១៨ តំបន់ មាន ៖ ៤ តំបន់ទិញអគ្គិសនីផ្ទាល់ពីអនុស្ថានីយ ១២ តំបន់ ទិញអគ្គិសនីផ្ទាល់ពីខ្សែបញ្ជូនរង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា និង ៣ តំបន់ ទិញអគ្គិសនីផ្ទាល់ពីខ្សែបញ្ជូនរង ២២ គីឡូវ៉ុល របស់ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី ។

### បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកំពង់ស្ពឺ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (កំពង់ស្ពឺ) | 001 L | GS | កំពង់ស្ពឺ |
| 2 | សេវាករ ង៉ែត ហុង | 053 L | GS-EDC | ស្រុកសំរោងទង |

| | | | | |
|---|---|---|---|---|
| 3 | សេវាករ សុខ ហ៊ុយ | 067 L | GS-EDC | ស្រុកភ្នំស្រួច |
| 4 | សហគ្រាស ឧដុង្គ ផៅវ៉ៃ សឹបផ្លាយ | 076 L | EDC - MSL | ស្រុកឧត្តុង្គ |
| 5 | សហគ្រាស អគ្គិសនី ពេជ្រនីល អិល.អេស.ខេ | 082 L | GS-EDC | ស្រុកភ្នំស្រួច |
| 6 | សេវាករ ឡេង ម៉ូវ | 099 L | GS | ស្រុកឧត្តុង្គ |
| 7 | សហគ្រាស អេឡិកទ្រីស៊ីធី ផ្សារថ្នល់បត់ | 101 L | GS-EDC | ស្រុកបសេដ្ឋ |
| 8 | សេវាករ ម៉ែន គន្ធា | 136 L | GS-EDC | ស្រុកភ្នំស្រួច |
| 9 | ក្រុមហ៊ុន ម៉េងសុខឡេង ឧនស្ត្រាក់សិន អេឡិកទ្រីក | 137 L | GS | ស្រុកសំរោងទង |
| 10 | សេវាករ អ៊ុយ សុផាត | 154 L | GS-EDC | ស្រុកគងពិសី |
| 11 | សហគ្រាស អភិវឌ្ឍន៍ អគ្គិសនី សំរិទ្ធ គីរី | 155 L | GS-EDC | ស្រុកឧត្តុង្គ |
| 12 | សេវាករ ម៉ែន សម្បត្តិ | 156 L | GS-EDC | ស្រុកសំរោងទង |
| 13 | សេវាករ កឿន សារឿន | 219 L | EDC - LMK | ស្រុកគងពិសី |
| 14 | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី | 224 L | GS | ស្រុកសំរោងទង |
| 15 | សេវាករ លី ជិនឡុង | 237 L | GS-EDC | ស្រុកភ្នំស្រួច |
| 19 | សេវាករ អ៊ូ ប៊ុនលី | 278 L | EDC - MSL | ស្រុកឧត្តុង្គ |
| 20 | ក្រុមហ៊ុន ភ្នំពេញ ស៊ូហ្គើរ អេឡិកទ្រីស៊ីធី | 338 L | GS-EDC | ស្រុកឱរ៉ាល់ |
| 21 | សេវាករ ចាន់ គឹមអេង | 385 L | GS-EDC | ស្រុកភ្នំស្រួច |
| 22 | សេវាករ អ៊ឹង យុនវឌ្ឍនៈ | 386 L | GS-EDC | ស្រុកបសេដ្ឋ |

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តកំពង់ស្ពឺ



## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកំពង់ស្ពឺ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បរសេដ្ឋ | 218 | 102 | 46.79% | 55 | 25.23% | 47 |
| ច្បារមន | 56 | 55 | 98.21% | 51 | 91.07% | 4 |
| គងពិសី | 250 | 250 | 100.00% | 201 | 80.40% | 49 |
| ឱរ៉ាល់ | 69 | 38 | 55.07% | - | - | 38 |
| ឧដុង្គ | 251 | 239 | 95.22% | 134 | 53.39% | 105 |
| ភ្នំស្រួច | 145 | 120 | 82.76% | 94 | 64.83% | 26 |
| សំរោងទង | 295 | 287 | 97.29% | 159 | 53.90% | 128 |
| ថ្ពង | 74 | 74 | 100.00% | 13 | 17.57% | 61 |
| **សរុប** | **1,358** | **1,165** | **85.79%** | **707** | **52.06%** | **458** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ស្ពឺ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ស្ពឺ អាចធ្វើលើការផ្គត់ផ្គង់ដោយឡែកចំនួន ៥ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងដែលចេញពីប្រព័ន្ធអគ្គិសនីរបស់រាជធានីភ្នំពេញ (ថ្លៃខ្ពស់បន្តិច ដោយត្រូវជួយចេញសេវា IPP បន្ថែមឲ្យភ្នំពេញ) ៣.ការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញបញ្ជូនរង ដែលមិនពាក់ព័ន្ធជាមួយប្រព័ន្ធរាជធានីភ្នំពេញ ៤.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និង៥.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ស្ពឺ ត្រូវបានបែងចែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ទាំង ៥ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញខ្សែអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងដែលចេញពីប្រព័ន្ធរាជធានីភ្នំពេញ (ជួយចេញសេវា IPP បន្ថែមឲ្យភ្នំពេញ)

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែចេញពីPP | 0.177$/kWh | 0.172$/kWh | 0.167$/kWh | 0.165$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងដែលមិនពាក់ព័ន្ធជាមួយប្រព័ន្ធរាជធានីភ្នំពេញ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៤ ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងច្បារមន

ចំពោះតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងច្បារមន ថ្លៃអគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលកំពុងអនុវត្តនៅឆ្នាំ ២០១៥ នេះ មានដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា នៅក្នុងតំបន់ចែកចាយក្រុងច្បារមន ខេត្តកំពង់ស្ពឺ** | |
| ដែលប្រើមិនលើសពី ២០០ kWh ក្នុង១ខែ | ៧២០ រៀល ក្នុង ១ kWh |
| ដែលប្រើលើសពី ២០០ kWh ក្នុង១ខែ | ៨២០ រៀល ក្នុង ១ kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ** | |
| គ្រប់ទំហំប្រើប្រាស់ | ៨២០ រៀល ក្នុង ១ kWh |
| **៣.អតិថិជនស្ថានទូត ផ្ទះ និងស្ថាប័ននានារបស់ជនបរទេស** | |
| គ្រប់ទំហំប្រើប្រាស់ | ៨២០ រៀល ក្នុង ១ kWh |
| **៤.អតិថិជនរដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្ម ទាំងអស់** | |
| ធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US) ក្នុង ១ kWh |
| ធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US) ក្នុង ១ kWh |
| ធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ៍ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US)ក្នុង ១ kWh |

**កំណត់សំគាល់៖** ល្បាយប្រភពអគ្គិសនីដែលបានប្រើខាងលើ គឺជាល្បាយនៃប្រភពអគ្គិសនីពីបណ្តាញជាតិ និងប្រភពអគ្គិសនីចេញពីរោងចក្រប្រើប្រេងនៅរាជធានីភ្នំពេញ ដោយសារក្រុងតាខ្មៅខេត្តកណ្តាលនិងក្រុងច្បារមនខេត្តកំពង់ស្ពឺ បានប្រើប្រព័ន្ធចែកចាយអគ្គិសនីជាប់ជាមួយប្រភពអគ្គិសនីរបស់ភ្នំពេញ ដូច្នេះ ថ្លៃប្រភពអគ្គិសនីត្រូវបានគិតដូចភ្នំពេញដែរ។ ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី សម្រាប់ឆ្នាំ២០១៥ គឺស្មើនឹង 0.157 $/kWh។

ការបន្ថយថ្លៃអគ្គិសនី ចាប់ពីខែមិនា ឆ្នាំ២០១៦ នឹងត្រូវអនុវត្តតាមផែនការដូចខាងក្រោម ៖

<u>(១).សម្រាប់អ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម</u>

ចំពោះអ្នកប្រើប្រាស់ជារដ្ឋបាល ឧស្សាហកម្ម និងពាណិជ្ជកម្ម នៅក្រុងច្បារមន ថ្លៃអគ្គិសនីសម្រាប់ឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ នៅរក្សាអនុវត្តយន្តការគណនាដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | ថ្លៃអគ្គិសនី |
|---|---|
| ធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.036$US) ក្នុង ១ kWh |

| | |
|---|---|
| ធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.028$US) ក្នុង ១ kWh |
| ធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.024$US) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ពីបណ្តាញMV របស់EDC | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.020$US) ក្នុង ១ kWh |
| ប្រភេទតង់ស្យុងមធ្យមភ្ជាប់ផ្ទាល់ពីអនុស្ថានីយ៍ | = (ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី+0.0025$US) ក្នុង ១kWh |

ប៉ុន្តែថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនី ក្នុងតារាងគណនា មានផែនការបន្ថយថ្លៃ ដូចខាងក្រោម ៖

| | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ថ្លៃល្បាយប្រភពអគ្គិសនី | 0.157$/kWh | 0.152$/kWh | 0.147$/kWh | 0.145$/kWh | 0.143$/kWh | 0.142$/kWh |

(២).សម្រាប់លំនៅដ្ឋានទូទៅ (ថ្លៃធម្មតា និងថ្លៃអនុគ្រោះដល់លំនៅដ្ឋានក្រីក្រ)

| ទំហំប្រើប្រាស់ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| លើសពី ២០០kWh/ខែ | ៨២០៛/kWh | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |
| មិនលើសពី២០០kWh/ខែ | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh | ៧២០៛/kWh |

(៣).ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

(៤).ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន

ចំពោះតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន នៅក្នុងខេត្តកំពង់ស្ពឺ ថ្លៃអគ្គិសនីចាប់ពីឆ្នាំ ២០១៥ ទៅ នឹងមានផែនការ ដូចខាងក្រោម ៖

សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

កំណត់សំគាល់ ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម ១០ kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តតាកែវ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តតាកែវ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តតាកែវ គឺជាខេត្តមួយឋិតនៅចំកន្លងនៃខ្សែបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ដែលតភ្ជាប់ភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ វៀតណាម ខេត្តកំពត និងខេត្តព្រះសីហនុ ។ បណ្តាញជាតិបញ្ជូនអគ្គិសនីខាងលើនេះមានអនុស្ថានីយមួយឋិតនៅក្រុងដូនកែវ ដែលផ្តល់ប្រភពអគ្គិសនីដុំពីបណ្តាញជាតិ ផ្គត់ផ្គង់ឲ្យតំបន់ចែកចាយមួយចំនួនធំរបស់ខេត្តតាកែវ ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅឲ្យតំបន់ចែកចាយនានាគឺធ្វើតាមរបៀប ២ យ៉ាងគឺ ៖ ទី១ ចេញពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី២ តាមរយៈបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អិល.អិម.ខេ ។ ក្រៅពីការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិទៅឲ្យតំបន់ចែកចាយ ដោយបណ្តាញបញ្ជូនរងទាំង ២ ខាងលើ ក៏នៅមានការបញ្ជូនបន្តគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយមួយចំនួនជាបណ្តោះអាសន្ន ក្នុងពេលដែលបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អិល អិម ខេ ពុំទាន់អាចពង្រីកឲ្យគ្របដណ្តប់ទូទាំងខេត្តតាកែវបាន ។ ក្រៅពីប្រភពអគ្គិសនីពីបណ្តាញជាតិ តំបន់មួយចំនួននៅជាប់ព្រំដែនប្រទេសវៀតណាម ក៏បានទទួលប្រភពអគ្គិសនីដោយការនាំចូលពីប្រទេសវៀតណាមផងដែរ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល រួចធ្វើការបញ្ជូនបន្តគ្នាក្នុងចំណោមតំបន់មួយចំនួនក្បែរព្រំដែនជាបណ្តោះអាសន្ន ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តតាកែវ មានក្រុង ១ ឈ្មោះក្រុងដូនកែវ និងស្រុកចំនួន ៩ គឺ៖ ១.ស្រុកបាទី ២.ស្រុកសំរោង ៣.ស្រុកព្រៃកប្បាស ៤.ស្រុកអង្គរបុរី ៥.ស្រុកទ្រាំង ៦.ស្រុកកោះអណ្តែត ៧.ស្រុកបូរីជលសារ ៨.ស្រុកគិរីវង់ និង៩.ស្រុកត្រាំកក់ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តតាកែវ ត្រូវបានដោះស្រាយដោយការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង និងការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ចែកជា ៤ ប្រភេទ គឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងដូនកែវ ទី២.តំបន់ចែកចាយរបស់សេវាករឯកជនដែលយប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងចេញពីបណ្តាញជាតិ, ទី៣.តំបន់ចែកចាយនៅជាប់ព្រំដែន គឺនៅទីរួមស្រុកគីរីវង់ ដែលនាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល និងទី៤.តំបន់ចែកចាយដែលទិញប្រភពអគ្គិសនីបន្តពីអ្នកនាំចូលអគ្គិសនីពីប្រទេសវៀតណាម ។ បច្ចុប្បន្ននៅខេត្តតាកែវ មានតំបន់ចែកចាយអគ្គិសនីចំនួន ៣៣ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ជារបស់អគ្គិសនីកម្ពុជា និង ៣២ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៣២ តំបន់ មាន ៖ ១ តំបន់ទិញអគ្គិសនីផ្ទាល់ពីអនុស្ថានីយ (ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី),១៦តំបន់ទិញអគ្គិសនីពីបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល របស់ក្រុមហ៊ុន អិល.អិម.ខេ ដែលទទួលប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ

ទី ៤ ខាងលិចរាជធានីភ្នំពេញ និង ៥ តំបន់ ជាតំបន់ទិញអគ្គិសនីពីខ្សែបញ្ជូនវ៉ង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា ដែលទទួលប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយខេត្តតាកែវ, ៣ តំបន់ គឺជាតំបន់នាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម និងជាអ្នកលក់បន្តឲ្យតំបន់ចែកចាយដែលនៅជិតខាង និង ៩ តំបន់ទៀត គឺជាតំបន់ដែលទិញបន្តគ្នាពីតំបន់នាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ក្នុងលក្ខណៈបណ្ដោះអាសន្ន រង់ចាំទិញផ្ទាល់ពីខ្សែបញ្ជូនវ៉ងរបស់អគ្គិសនីកម្ពុជា ។

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តតាកែវ




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តតាកែវ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (តាកែវ) | 001 L | GS | តាកែវ |
| 2 | ក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី | 224 L | GS | ស្រុកបាទី |
| 3 | សហគ្រាស អគ្គិសនី អង្គរកា | 197 L | GS-EDC | ស្រុកត្រាំកក់ |
| 4 | សហគ្រាស ផ្សារថ្នល់បត់ អេឡិកទ្រីស៊ីធី | 101 L | GS-EDC | ផ្នែកខ្លះនៃស្រុកសំរោង |
| 5 | សេវាករ ង៉ែត សុផា | 121 L | GS-EDC | ស្រុកត្រាំកក់ |
| 6 | សេវាករ អ៊ុច ប៉ោ | 054 L | GS-LMK | ស្រុកព្រៃកប្បាស |
| 7 | សហគ្រាស អេឡិកទ្រីស៊ីធី សំពៅងយោង | 015 L | GS-LMK | ស្រុកបាទី |
| 8 | សហគ្រាស អគ្គិសនី ស៊ី.អិល ព្រៃកប្បាស | 020 L | GS-LMK | ស្រុកព្រៃកប្បាស |
| 9 | សេវាករ នូ គ្រុយ | 113 L | GS-LMK | ស្រុកអង្គរបុរី |

| | | | | |
|---|---|---|---|---|
| 10 | សហគ្រាស អគ្គិសនី បាទី | 118 L | GS-LMK | ស្រុកបាទី |
| 11 | សេវាករ តាំង ចេងអ៊ង | 141 L | GS-LMK | ស្រុកសំរោង |
| 12 | សហគ្រាស អេឡិកទ្រីស៊ីធី ពត់សរ | 174 L | GS-LMK | ស្រុកបាទី |
| 13 | សេវាករ ពេជ្រ សុភាព | 178 L | GS-LMK | ស្រុកសំរោង |
| 14 | សហគ្រាស អគ្គិសនី ញ៉ឹក មុី | 179 L | GS-LMK | ស្រុកបាទី និងស្រុកព្រៃកប្បាស |
| 15 | សេវាករ លឹម ស៊ីសុភ័ណ្ឌ | 188 L | GS-LMK | ស្រុកសំរោង |
| 16 | សេវាករ អ៊ូច គា | 195 L | GS-LMK | ស្រុកព្រៃកប្បាស |
| 17 | សហគ្រាស អេឡិចទ្រី កណ្ដឹង | 196 L | GS-LMK | ស្រុកបាទី |
| 18 | សេវាករ ង៉ែត ម៉េង | 212 L | GS-LMK | ស្រុកព្រៃកប្បាស |
| 19 | សេវាករ ហ៊ូ វាស្នា | 238 L | GS-LMK | ស្រុកអង្គរបុរី |
| 20 | សេវាករ ភី ធី | 265 L | GS-LMK | ស្រុកអង្គរបុរី |
| 21 | សេវាករ ជា សុវណ្ណារ៉ា | 273 L | GS-LMK | ស្រុកអង្គរបុរី |
| 22 | សហគ្រាស អេឡិកទ្រីស៊ីធី គីរីវង់ | 013 L | VN | ស្រុកគីរីវង់ |
| 23 | ក្រុមហ៊ុន ឈើរទីម៉ិច គ្រុប | 253 L | VN | ស្រុកគីរីវង់ |
| 24 | សហគ្រាស អគ្គិសនី ទូកមាស | 093 L | VN & EDC | ស្រុកត្រាំកក់ |
| 25 | សេវាករ កែ គុយហួយ | 016 L | VN-E.K | ស្រុកទ្រាំង - កោះអណ្ដែត |
| 26 | សេវាករ ម៉ាក់ ខុម | 055 L | VN-E.K & EDC | ស្រុកទ្រាំង |
| 27 | សេវាករ គង់ ផាត | 022 L | VN-E.K & EDC-MK | ស្រុកបូរីជលសា |
| 28 | សេវាករ ហាក់ លីសេង | 133 L | VN-E.K & EDC-MK | ស្រុកគីរីវង់ |
| 29 | សេវាករ ទ្រី ឃ្លោក | 134 L | VN-E.K & EDC-MK | ស្រុកកោះអណ្ដែត |
| 30 | សេវាករ ម៉ៅ ផៃ | 205 L | VN-E.K & EDC-MK | ស្រុកទ្រាំង |
| 31 | សេវាករ ស្ងួន សារ៉ន | 258 L | VN-E.K & EDC-MK | ស្រុកគីរីវង់ |
| 32 | សេវាករ ជួន តុំ | 373 L | VN-E.K & EDC-MK | ស្រុកោះអណ្ដែត |
| 33 | សេវាករ វ៉ូវ ទ្រហ៊ួត | 194 L | VN-E.K & EDC-MK | ស្រុកបូរីជលសា |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តតាកែវ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្ដល់ | | បានសាងសង់បណ្ដាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្ដាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| អង្គរបុរី | 34 | 28 | 82.35% | 29 | 85.29% | -1 |
| បាទី | 168 | 159 | 94.64% | 160 | 95.24% | -1 |
| បូរីជលសារ | 39 | 38 | 97.44% | 29 | 74.36% | 9 |
| គីរីវង់ | 114 | 108 | 94.74% | 85 | 74.56% | 23 |
| កោះអណ្ដែត | 68 | 68 | 100.00% | 51 | 75.00% | 17 |
| ព្រៃកប្បាស | 110 | 103 | 93.64% | 103 | 93.64% | - |
| សំរោង | 147 | 143 | 97.28% | 132 | 89.80% | 11 |
| ដូនកែវ | 40 | 40 | 100.00% | 36 | 90.00% | 4 |
| ត្រាំកក់ | 244 | 244 | 100.00% | 142 | 58.20% | 102 |
| ទ្រាំង | 154 | 151 | 98.05% | 114 | 74.03% | 37 |
| **សរុប** | **1,118** | **1,082** | **96.78%** | **881** | **78.80%** | **201** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តតាកែវ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តតាកែវ អាចបែងចែកជាផែនការទៅតាមប្រភេទនៃការផ្គត់ផ្គង់ដោយឡែកចំនួន ៥ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំ ពីបណ្តាញបញ្ជូនរង ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជន ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅតំបន់ចែកចាយរបស់សេវាករឯកជន ដែលយកប្រភពអគ្គិសនីបណ្តាញជាតិ និង៥.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅតំបន់ចែកចាយរបស់សេវាករឯកជន ដែលប្រើប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តតាកែវ ត្រូវបានបែងចែកលម្អិតតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៥ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

### ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងដូនកែវនិងនៅទីប្រជុំជនអង្គតាសោម

ស្ថានភាពថ្លៃអគ្គិសនីនៅឆ្នាំ២០១៥ និងការបន្ថយថ្លៃទៅអនាគត នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងដូនកែវ និងនៅទីប្រជុំជនអង្គតាសោម មានដូចខាងក្រោម ៖

**(១).ស្ថានភាពថ្លៃនៅឆ្នាំ ២០១៥**

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៩២០ ៛ / kWh | អតិថិជនធុនធំ | ០.១៨២ $ / kWh |
| អតិថិជនធុនមធ្យម | ០.១៩២ $ / kWh | អតិថិជនតង់ស្យុងមធ្យម | ០.១៧៥ $ / kWh |

**(២).ផែនការបន្ថយថ្លៃដែលត្រូវអនុវត្តពីខែ មីនា ឆ្នាំ ២០១៦**

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយឯកជនដែលយកអគ្គិសនីពីប្រភពបណ្ដាញជាតិ

ដូចបានជម្រាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ៣២ តំបន់ នៅខេត្តកែវ មាន ២០ តំបន់ គឺជាតំបន់ដែលយកអគ្គិសនីពីប្រភពអគ្គិសនីបណ្ដាញជាតិ តាមរយៈខ្សែបញ្ជូនរង របស់អគ្គិសនីកម្ពុជា និងខ្សែបញ្ជូនរងរបស់ក្រុមហ៊ុនអិល.អិម.ខេ ដែលទទួលប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ។ ផែនការបន្ថយថ្លៃលក់អគ្គិសនី នៅក្នុងតំបន់ចែកចាយទាំង ២០ តំបន់នេះ មានដូចខាងក្រោម ៖

សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

កំណត់សំគាល់ ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ១,០០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់របស់សេវាករឯកជនដែលយកប្រភពអគ្គិសនីនាំចូលពីវៀតណាម

ក្នុងចំណោមតំបន់ចែកចាយរបស់ឯកជនទាំង ៣២ តំបន់ នៅខេត្តតាកែវ មានតំបន់ចែកចាយចំនួន ១២ តំបន់ កំពុងប្រើប្រាស់ប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម សម្រាប់ធ្វើការផ្គត់ផ្គង់ ក្នុងនោះមានតំបន់ចែកចាយ ៣ តំបន់ គឺជាតំបន់នាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម, ២ តំបន់ទៀត ជាតំបន់ទិញបន្តពីតំបន់នាំចូលផ្ទាល់ (ហៅថាអ្នកទិញបន្តទី ១) និង ៧ តំបន់ទៀត ជាតំបន់ទិញប្រភពអគ្គិសនីបន្តពីអ្នកទិញបន្តទី ១ (ហៅថាអ្នកទិញបន្តទី ២) ។ តំបន់ដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម មាន ៖ តំបន់របស់ក្រុមហ៊ុន ឈីវទីម៉ិច គ្រុប ១ តំបន់ដែលមានថ្លៃលក់បច្ចុប្បន្ន ស្មើនឹង ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, តំបន់របស់សហគ្រាស អេឡិកទ្រីស៊ីធី គីរីវង់ ១ តំបន់ ដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ៨៥០ រៀល ក្នុង ១ គីឡូវ៉ាត់

ម៉ោង និងតំបន់របស់សហគ្រាស អគ្គិសនី ទូកមាស ១ តំបន់ទៀត ដែលមានខ្សែបញ្ជូនអគ្គិសនីក្នុងចម្ងាយឆ្ងាយពីខេត្តកំពត ដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ តំបន់ចែកចាយដែលទិញប្រភពអគ្គិសនីបន្តទី ១ ពីសហគ្រាស អេឡិកទ្រីស៊ីធី គីរីវង់ ដែលនាំចូលអគ្គិសនីផ្ទាល់ មាន ២ តំបន់ គឺតំបន់របស់សេវាករ កែ គុយហួយ និងតំបន់របស់សេវាករ ម៉ាក់ ខុម តំបន់ទាំង ២ នេះ មានថ្លៃលក់បច្ចុប្បន្នស្មើនឹង ៩៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ក្រៅពីនោះ មានតំបន់ចែកចាយ ៧ តំបន់ទៀត ដែលនៅសងខាងផ្លូវជាតិលេខ ២ ក្នុងចន្លោះពីព្រំប្រទល់វៀតណាម មកក្រុងដូនកែវ នៅក្នុងស្រុកគីរីវង់ ស្រុកកោះអណ្តែត ស្រុកទ្រាំង និងស្រុកបុរីជលសា បានទិញប្រភពអគ្គិសនីបន្តពីខ្សែបណ្តាញ ២២ គីឡូវ៉ុល របស់សេវាករ ម៉ាក់ ខុម ដែលលាតសន្ធឹងតាមផ្លូវជាតិ ពីស្រុកគិរីវង់ រហូតដល់ក្រុងដូនកែវ និងមានខ្សែបណ្តាញបែកមែកចូលទៅក្នុងស្រុកទាំង ៤ ខាងលើផងដែរ ។ ក្នុងចំណោមតំបន់ចែកចាយទាំង ៧ តំបន់ដែលទិញប្រភពអគ្គិសនីបន្តពីខ្សែបណ្តាញរបស់សេវាករ ម៉ាក់ ខុម នេះ មានតំបន់ចែកចាយចំនួន ៥ តំបន់ (សេវាករ គង់ ផាត, សេវាករ ទ្រី ឃ្លោក, សេវាករ ម៉ៅ ផៃ, សេវាករ សួន សារ៉ន, សេវាករ ហាក់ លីសេង និងសេវាករ ជួន គុំ) បច្ចុប្បន្នមានថ្លៃលក់ស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងមានតំបន់ចែកចាយ ១ តំបន់ទៀត ដែលភ្ជាប់ប្រភពអគ្គិសនីជាមួយខ្សែបណ្តាញរបស់សេវាករ ម៉ាក់ ខុម ក្រោយគេ កំពុងនៅអនុវត្តថ្លៃតាមកម្មវិធីបន្ថយថ្លៃបន្តិចម្តងៗ ដែលបច្ចុប្បន្នតំបន់របស់សេវាករ វ៉ូ ទ្រហ៊ួត បានចុះថ្លៃដល់ ១,៤០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចហើយ ។

## វិធានការណ៍ដោះស្រាយចំពោះតំបន់ដែលប្រើប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម

១. ចំពោះតំបន់នាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាមផ្ទាល់ គឺតំបន់របស់ក្រុមហ៊ុន ឈីវទីម៉ិច គ្រុប ដែលមានថ្លៃលក់បច្ចុប្បន្ន ស្មើនឹង ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងតំបន់របស់សហគ្រាស អេឡិកទ្រីស៊ីធី គីរីវង់ ដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ៨៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ការផ្គត់ផ្គង់ប្រភព និងថ្លៃអគ្គិសនីនឹងរក្សាដដែលជាបណ្តោះអាសន្ន រហូតដល់មានការចាំបាច់ត្រូវប្តូរមកយកប្រភពអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ទើបធ្វើការកែសម្រួលថ្លៃឡើងវិញ ។

២. ចំពោះតំបន់របស់សហគ្រាស អគ្គិសនី ទូកមាស ដែលមានខ្សែបញ្ជូនអគ្គិសនីចម្ងាយវែងពីប្រភពនាំចូលនៅខេត្តកំពត ដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ១,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយសារតំបន់ចែកចាយរបស់សហគ្រាស អគ្គិសនី ទូកមាស តាមពិតជាតំបន់ចែកចាយនៅក្នុងខេត្តកំពត ដោយគ្រាន់តែមានភូមិខ្លះឋិតនៅក្នុងខេត្តតាកែវ ដូច្នេះដំណោះស្រាយចំពោះតំបន់ចែកចាយនេះទាំងមូល ត្រូវបានកំណត់នៅក្នុងការសិក្សានៅខេត្តកំពត ។

៣. ចំពោះតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីសហគ្រាស អេឡិកទ្រីស៊ីធី គីរីវង់ ២ តំបន់ (អ្នកទិញបន្តទី ១) និងតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីអ្នកទិញបន្តនេះទៀត ចំនួន ៧ តំបន់ (អ្នកទិញបន្តទី ២) ដោយសារមានថ្លៃអគ្គិសនីខ្ពស់ ដូច្នេះបច្ចុប្បន្នកំពុងដោះស្រាយឲ្យតំបន់ទាំងនេះ បែរមកយកប្រភពអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិវិញ ។ ក្នុងនោះសេវាករ ម៉ាក់ ខុម ដែលមានខ្សែបណ្តាញ ២២ គីឡូវ៉ុល និងលក់ប្រភពអគ្គិសនីបន្តឲ្យតំបន់ចែកចាយ ៧ តំបន់ទៀតនោះ បានដើរតួនាទីជាស្នូល ដោយបានភ្ជាប់ជាមួយប្រភពអគ្គិសនីពីប្រព័ន្ធអគ្គិសនីក្រុងដូនកែវ របស់អគ្គិសនីកម្ពុជា រួចបន្តប្រភពអគ្គិសនីទៅផ្តល់ឲ្យតំបន់ចែកចាយ

ទាំង ៧ បន្តទៀត ។ *ដើម្បីរៀបចំឲ្យថ្លៃអគ្គិសនីនៅតំបន់របស់សេវាករ ម៉ាក់ ខុម តំបន់របស់សេវាករ កែ គុយ ហួយ ក៏ដូចជាសេវាករដែលទិញប្រភពអគ្គិសនីពីសេវាករ ម៉ាក់ ខុម ទាំង ៧ ខាងលើនេះ ឲ្យមានលទ្ធភាពអនុវត្តតាមផែនការបន្ថយអត្រា និងតម្លាតថ្លៃ របស់រាជរដ្ឋាភិបាល ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា ត្រូវអនុញ្ញាតឲ្យខ្សែបណ្តាញ ២២ គីឡូវ៉ុល របស់សេវាករ ម៉ាក់ ខុម ក្លាយទៅជាបណ្តាញបញ្ជូនរងពិតប្រាកដ ដែលអាចយកប្រភពអគ្គិសនីដុំចេញពីអនុស្ថានីយខេត្តតាកែវ រួចធ្វើការផ្គត់ផ្គង់ប្រភពអគ្គិសនីឲ្យតំបន់ចែកចាយទាំង ៧ ខាងលើ រួមទាំងតំបន់របស់សេវាករ កែ គុយហួយ ផងដោយអគ្គិសនីកម្ពុជា ជាអ្នកដោះស្រាយថ្លៃសេវាបញ្ជូនរងនេះឲ្យសេវាករ ម៉ាក់ ខុម រួចតំបន់ទាំង ៧ នេះ និងតំបន់របស់សេវាករ កែ គុយ ហួយ ជាតំបន់ដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងចេញពីបណ្តាញជាតិ និងត្រូវទទួលការប៉ះប៉ូវពីមូលនិធិអគ្គិសនីការូបនីយកម្មជនបទ ដូចតំបន់ចែកចាយដ៏ទៃទៀតដែរ ។ ពេលវេលាអនុវត្តថ្លៃតាមផែនការរួមរបស់រាជរដ្ឋាភិបាលរបស់តំបន់ទាំង ៩ នេះ គឺអាស្រ័យនឹងពេលវេលានៃការដោះស្រាយបញ្ហាខាងលើ និងការសាងសង់បណ្តាញបន្ថែម ដើម្បីឲ្យសេវាករ ម៉ាក់ ខុម អាចភ្ជាប់ប្រភពអគ្គិសនីផ្ទាល់ជាមួយអនុស្ថានីយបណ្តាញជាតិ (គម្រោងនេះ គ្រោងអនុវត្តឲ្យបាននៅខែ មីនា ឆ្នាំ ២០១៦)។*

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្ដាញជាតិនៅខេត្តកំពត សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពត

### ក.បណ្ដាញជាតិ និងបណ្ដាញបញ្ជូនរង

បច្ចុប្បន្នខេត្តកំពត មានអនុស្ថានីយបណ្ដាញជាតិមួយកន្លែងនៅក្រុងកំពត ដែលបានតភ្ជាប់ជាមួយខ្សែបណ្ដាញបញ្ជូនភ្នំពេញ តាកែវ កំពត និងព្រះសីហនុ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពតនេះ ទៅឲ្យតំបន់ចែកចាយនានា គឺបានធ្វើតាមបណ្ដាញបញ្ជូនរង ដែលបច្ចុប្បន្នមានតែបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាមួយប៉ុណ្ណោះ ក្រៅពីនេះ គឺមានតែការបញ្ជូនបន្តគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយជាបណ្ដោះអាសន្នក្នុងពេលដែលអគ្គិសនីកម្ពុជា ពុំទាន់អាចពង្រីកបណ្ដាញបញ្ជូនរងឲ្យបានទូទាំងខេត្ត ។ ក្រៅពីប្រភពអគ្គិសនីចេញពីអនុស្ថានីយបណ្ដាញជាតិ តំបន់មួយចំនួនរបស់ខេត្តកំពត ក៏បានទទួលប្រភពអគ្គិសនីមួយផ្សេងទៀត គឺការនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាមខ្សែបណ្ដាញ ២២ គីឡូវ៉ុល ដែលជាទូទៅ គឺផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់ក្បែរព្រំដែន និងការបញ្ជូនបន្តរបស់អ្នកនាំចូលអគ្គិសនី ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តកំពត មានក្រុង១ ឈ្មោះក្រុងកំពត និងស្រុកចំនួន ៧ គឺ៖ ១.ស្រុកទឹកឈូ ២.ស្រុកអង្គរជ័យ ៣.ស្រុកបន្ទាយមាស ៤.ស្រុកឈូក ៥.ស្រុកកំពង់ត្រាច ៦.ស្រុកជុំគិរី និង៧.ស្រុកដងទង់។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកំពត ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ**ពីអនុស្ថានីយ **ការផ្គត់ផ្គង់អគ្គិសនីធំ**ពីបណ្ដាញបញ្ជូនរង និង**ការផ្គត់ផ្គង់អគ្គិសនីរាយ**តាមតំបន់ចែកចាយនីមួយៗ ។ ការចែកចាយអគ្គិសនីរាយ ឲ្យអ្នកប្រើប្រាស់តាមតំបន់នានានៅខេត្តកំពត ត្រូវបានដោះស្រាយដោយការវិនិយោគមួយផ្នែករបស់អគ្គិសនីកម្ពុជា និងមួយផ្នែកទៀត របស់អ្នកវិនិយោគឯកជនក្នុងស្រុក ។ បច្ចុប្បន្ន នៅខេត្តកំពត មានតំបន់ចែកចាយអគ្គិសនីចំនួន ១០ តំបន់ ដែលក្នុងនោះមាន ៖ ២ តំបន់គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា (១ តំបន់គ្របដណ្ដប់លើក្រុងកំពត និង ១ តំបន់ទៀត គ្របដណ្ដប់លើផ្នែកខ្លះនៃស្រុកកំពង់ត្រាច) និង ៨ តំបន់ទៀត ជាតំបន់ផ្គត់ផ្គង់របស់សេវាករឯកជន ដែលគ្របដណ្ដប់លើតំបន់នានានៅជនបទ ។ ក្នុងចំណោមតំបន់ចែកចាយទាំង ១០ តំបន់នេះ បច្ចុប្បន្ននេះមាន ៥ តំបន់ទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិ និង ៥ តំបន់ ទៀត ទទួលប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម ។ តំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិមាន ៖ ១.តំបន់ក្រុងកំពត និងផ្នែកខ្លះនៃស្រុកជុំវិញក្រុងកំពត ក្នុងដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា ២.តំបន់ស្រុកឈូក ស្រុកជុំគិរី ស្រុកទឹកឈូ និងស្រុកដងទង់ ក្នុងដែនអាជ្ញាប័ណ្ណចែកចាយរបស់សហគ្រាស អគ្គិសនី ទឹកឈូ ៣.តំបន់ស្រុកទឹកឈូ របស់សេវាករឈ្មោះ គង់ សុផល ៤.តំបន់ស្រុកជុំគីរី របស់សហគ្រាស អគ្គិសនី ពេជ្រនិល អិល.អេស.ខេ និង៥.តំបន់ស្រុកជុំគីរី របស់សហគ្រាស អេឡិកទ្រីស៊ីធី អង្គរការ ។ តំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីការនាំចូលពីប្រទេសវៀតណាម មាន ៖ ១.តំបន់ស្រុកកំពង់ត្រាច ក្នុងដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា ២.តំបន់ស្រុកកំពង់ត្រាច ក្នុងដែនអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុន កែប ផោវ័រ ស៊ីបផ្លាយ (ទិញបន្តពីអគ្គិសនីកម្ពុជា ដែលនាំចូលផ្ទាល់ពីវៀតណាម) ៣.តំបន់

ស្រុកបន្ទាយមាស ស្រុកអង្គរជ័យ និងផ្នែកខ្លះស្រុកកំពង់ត្រាច ក្នុងដែនអាជ្ញាប័ណ្ណរបស់សហគ្រាស អគ្គិសនី ទូកមាស (ទិញផ្ទាល់ពីប្រទេសវៀតណាម និងពីអគ្គិសនីតាកែវ) ៤.តំបន់ស្រុកអង្គរជ័យ (តានី) ក្នុងដែនអាជ្ញាប័ណ្ណរបស់សេវាករឈ្មោះ ឃិន អ៊ិច (ទិញបន្តពីសហគ្រាស អគ្គិសនី ទូកមាស ដែលនាំចូលផ្ទាល់ពីវៀតណាម និងពីអគ្គិសនីតាកែវ) និង៥.តំបន់ស្រុកដងទង់ ក្នុងដែនអាជ្ញាប័ណ្ណរបស់សេវាករឈ្មោះ ចាន់ សុគីម (ទិញបន្តពីសហគ្រាស អគ្គិសនី ទូកមាស ដែលនាំចូលផ្ទាល់ពីប្រទេស វៀតណាម និងពីអគ្គិសនីតាកែវ)។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកំពត

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ | ចំនួនភូមិ |
|---|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (កំពត) | 001 L | GS | កំពត | |
| 2 | អគ្គិសនីកម្ពុជា (កំពត) | 001 L | VN | ស្រុកកំពង់ត្រាច | |
| 3 | សហគ្រាស អេឡិកទ្រីស៊ីធី ទឹកឈូ | 044 L | GS | ស្រុកឈូក | |
| 4 | សេវាករ គង់ សុផល | 042 L | GS-EDC | ស្រុកទឹកឈូ | |
| 5 | សហគ្រាស អគ្គិសនី ពេជ្រនិល អិល.អេស.ខេ | 082 L | GS-EDC | ផ្នែកខ្លះនៃស្រុកជុំគីរី | |
| 6 | សហគ្រាស អេឡិកទ្រីស៊ីធី អង្គរកា | 197 L | GS-EDC | ផ្នែកខ្លះនៃស្រុកជុំគីរី | |
| 7 | ក្រុមហ៊ុន កែប ផៅវ៉ែ សឺបផ្លាយ | 180 L | VN | ស្រុកដងទង់ | |
| 8 | សហគ្រាស អគ្គិសនី ទូកមាស | 093 L | VN & GS-EDC | ស្រុកបន្ទាយមាស | |
| 9 | សេវាករ ឃិន អ៊ិច | 097 L | VN & GS-EDC-ETM | ស្រុកអង្គរជ័យ | |
| 10 | សេវាករ ចាន់ សុខគីម | 225 L | VN & GS-EDC-ETM | ស្រុកដងទង់ | |

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តកំពត



## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកំពត

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| អង្គរជ័យ | 79 | 76 | 96.20% | 74 | 93.67% | 2 |
| បន្ទាយមាស | 88 | 88 | 100.00% | 81 | 92.05% | 7 |
| ឈូក | 80 | 80 | 100.00% | 50 | 62.50% | 30 |
| ជុំគិរី | 37 | 35 | 94.59% | 10 | 27.03% | 25 |
| ដងទង់ | 54 | 54 | 100.00% | 37 | 68.52% | 17 |
| កំពង់ត្រាច | 69 | 66 | 95.65% | 44 | 63.77% | 22 |
| ទឹកឈូ | 66 | 62 | 93.94% | 57 | 86.36% | 5 |
| កំពត | 15 | 15 | 100.00% | 15 | 100.00% | - |
| **សរុប** | **488** | **476** | **97.54%** | **368** | **75.41%** | **108** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្តបច្ចុប្បន្ន និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពត

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពត អាចបែងចែកជាផែនការដោយឡែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៦ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងកំពត ៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅស្រុកកំពង់ត្រាច ៥.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ និង៦.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជនដែលយកប្រភពអគ្គិសនីពីការនាំចូលអគ្គិសនីពីប្រទេសវៀតណាម ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពត ត្រូវបានបែងចែកលម្អិតជា ៦ ផែនការ ទៅតាមប្រភេទនៃការផ្គត់ផ្គង់ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជា អាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

### ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងកំពត និងតំបន់ជុំវិញ

ស្ថានភាពថ្លៃអគ្គិសនីនៅឆ្នាំ ២០១៥ និងការបន្ថយថ្លៃទៅអនាគត នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងកំពត និងតំបន់ជុំវិញក្រុងនេះ ត្រូវបានរៀបចំជាផែនការ ដូចខាងក្រោម ៖

### (១).ស្ថានភាពថ្លៃនៅឆ្នាំ ២០១៥

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៩២០ ៛ / kWh | អតិថិជនធុនធំ | 0.១៨២ $ / kWh |
| អតិថិជនធុនមធ្យម | 0.១៩២ $ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៧៥ $ / kWh |

### (២).ផែនការបន្ថយថ្លៃដែលត្រូវអនុវត្តពីខែ មីនា ឆ្នាំ ២០១៦

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែមេ EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម ១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើ ពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់ឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនីបណ្តាញជាតិ

តំបន់ស្រុកឈូក ស្រុកជុំគីរី និងស្រុកដងទង់ របស់សហគ្រាស អគ្គិសនី ទឹកឈូ, តំបន់ស្រុកទឹកឈូ របស់សេវាករឈ្មោះ គង់ សុផល, តំបន់ស្រុកជុំគីរី របស់សហគ្រាស អគ្គិសនី ពេជ្រនិល អិល.អេស.ខេ និងតំបន់ របស់សហគ្រាស អេឡិកទ្រីស៊ីធី អង្គរការ ទាំង ៤ តំបន់នេះ គឺជាតំបន់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនីរបស់បណ្តាញជាតិដែលមានថ្លៃលក់អគ្គិសនីបច្ចុប្បន្នស្មើនឹង ១,000 រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង។ ចាប់ពីខែ មីនា ឆ្នាំ២០១៦ តទៅ ថ្លៃអគ្គិសនីនៅតំបន់ចែកចាយទាំងនេះ នឹងថយចុះទៅតាមផែនការរួម ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅស្រុកកំពង់ត្រាច

អគ្គិសនីកម្ពុជា សាខាខេត្តកំពត បានធ្វើការចែកចាយអគ្គិសនីនៅផ្នែកមួយចំនួនធំ ក្នុងស្រុកកំពង់ត្រាច ដោយនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ។ បច្ចុប្បន្នថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ក្នុងដែនអាជ្ញាប័ណ្ណចែកចាយអគ្គិសនីនេះ មានដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៦៥០ ៛ / kWh | អតិថិជនធុនធំ | 0.១៤៥ $ / kWh |
| អតិថិជនធុនមធ្យម | 0.១៥៥ $ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៣៥ $ / kWh |

បច្ចុប្បន្ន អគ្គិសនីកម្ពុជា កំពុងជួបប្រទះបញ្ហាលំបាកក្នុងអាជីវកម្ម ដោយសារតែបញ្ជីថ្លៃលក់អគ្គិសនីខាងលើនេះ ត្រូវបានកំណត់តាំងពីឆ្នាំ ២០០២ នៅពេលដែលអគ្គិសនីកម្ពុជា បាននាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម តំបូង ប៉ុន្តែជាបន្តបន្ទាប់ប្រទេសវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា ។ នៅឆ្នាំ ២០១៥ នេះ ប្រទេសវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា តាមតង់ស្យុង ២២ គីឡូវ៉ុលនេះ បន្ថែម ៧.៥% ថែមទៀត ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៥ តទៅ ។

ដើម្បីឲ្យសមស្របជាមួយការតម្លើងថ្លៃលក់ប្រភពអគ្គិសនីឲ្យកម្ពុជា តាមតង់ស្យុង ២២ គីឡូវ៉ុល នេះ បន្ថែម ៧.៥% ថែមទៀត របស់ប្រទេសវៀតណាម ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០១៥ អគ្គិសនីកម្ពុជា នៅឆ្នាំ ២០១៥ នេះ មានបំណងតម្លើងថ្លៃអគ្គិសនីបន្ថែម ៧.៥% បន្ថែមទៀត ប៉ុន្តែរាជរដ្ឋាភិបាលស្នើសុំឲ្យរក្សាថ្លៃលក់ឲ្យប្រជាពលរដ្ឋនៅដដែលជាបណ្តោះអាសន្នសិន ដូច្នេះតាមផែនការនៅតំបន់នេះ គ្រោងតម្លើងថ្លៃលក់តែចំពោះអតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ប៉ុណ្ណោះ ។ តារាងផែនការតម្លើងថ្លៃនេះ មានអត្រាថ្លៃដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាប | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

**កំណត់សំគាល់ ៖** លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

ដោយសារតំបន់ចែកចាយនេះ មានថ្លៃអគ្គិសនីទាបជាងផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ដូច្នេះ តាមផែនការ នឹងរក្សាការផ្គត់ផ្គង់ និងថ្លៃអគ្គិសនីនៅដដែលជាបណ្តោះអាសន្ន រហូតដល់មានការចាំបាច់ត្រូវធ្វើការផ្លាស់ប្តូរ ទើបធ្វើការកែសម្រួលទាំងការផ្គត់ផ្គង់ ទាំងថ្លៃអគ្គិសនី ។ តំបន់ចែកចាយនេះ ត្រូវបានចាត់ទុកថាជាតំបន់នៅក្រៅពីតំបន់ផ្គត់ផ្គង់របស់ប្រភពអគ្គិសនីរបស់បណ្តាញជាតិ ។

## ២.៦ តំបន់ចែកចាយរបស់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនីនាំចូល

បច្ចុប្បន្ននៅខេត្តកំពត មានតំបន់ចែកចាយចំនួន ៤ តំបន់ ដែលយកអគ្គិសនីពីប្រភពអគ្គិសនីនាំចូលមកផ្គត់ផ្គង់ក្នុងតំបន់របស់ខ្លួន ដែលក្នុងនោះមាន ៖ ១.តំបន់ស្រុកបន្ទាយមាស ស្រុកអង្គរជ័យ និងស្រុកកំពង់ត្រាច របស់សហគ្រាស អគ្គិសនី ទូកមាស, ២.តំបន់ស្រុកអង្គរជ័យ (តានី) របស់សេវាករឈ្មោះ យិន អ៊ិច, ៣.តំបន់ស្រុកដងទង់ របស់សេវាករឈ្មោះ ចាន់ សុគីម និង ៤.តំបន់ស្រុកកំពង់ត្រាច របស់ក្រុមហ៊ុន កែប ផោវ៉ែ ស៊ឹបផ្លាយ ។ សហគ្រាស អគ្គិសនី ទូកមាស ត្រូវបានអនុញ្ញាតឲ្យនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម រួចធ្វើការចែកចាយអគ្គិសនីនៅស្រុកបន្ទាយមាស ស្រុកអង្គជ័យ និងស្រុកកំពង់ត្រាច ដែលមានដែនអាជ្ញាប័ណ្ណធំ និងលក់ប្រភពអគ្គិសនីនេះ បន្តឲ្យសេវាករ យិន អ៊ិច និងសេវាករ ចាន់ សុគីម ដែលត្រូវបានអនុញ្ញាតឲ្យធ្វើការចែកចាយនៅស្រុកអង្គរជ័យ និងស្រុកដងទង់ តាមដែនអាជ្ញាប័ណ្ណរៀងៗ ខ្លួន ។ នៅពេលថ្មីៗនេះ សហគ្រាស អគ្គិសនី ទូកមាស ត្រូវបានអនុញ្ញាតឲ្យភ្ជាប់ប្រភពអគ្គិសនីបន្ថែមជាមួយបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា។ ក្រុមហ៊ុន កែប ផោវ៉ែ ស៊ឹបផ្លាយ ត្រូវបានអនុញ្ញាតឲ្យធ្វើការចែកចាយនៅខេត្តកែប ប៉ុន្តែមានតំបន់ចែកចាយមួយចំនួនលយមកនៅក្នុងស្រុកកំពង់ត្រាច របស់ខេត្តកំពត ។

<u>**វិធានការណ៍ដោះស្រាយចំពោះតំបន់ដែលប្រើប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម**</u>

១. ចំពោះតំបន់ចែកចាយរបស់ក្រុមហ៊ុន កែប ផោវ៉ែ ស៊ឹបផ្លាយ ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាមផ្ទាល់ និងដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ដោយសារមានថ្លៃទាប ដូច្នេះការផ្គត់ផ្គង់អគ្គិសនី ប្រភពផ្គត់ផ្គង់អគ្គិសនី និងថ្លៃអគ្គិសនី នឹងនៅរក្សានៅដដែលជាបណ្តោះអាសន្ន រហូតដល់ឆ្នាំ ២០១៧ ទើបប្តូរមកយកប្រភពអគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ឬទុកឲ្យនៅប្រើបញ្ចូលគ្នា ដោយធ្វើការកែសម្រួលថ្លៃ មកអនុវត្តតាមផែនការថ្លៃរបស់រាជរដ្ឋាភិបាលវិញ ។

២. ចំពោះតំបន់របស់សហគ្រាស អគ្គិសនី ទូកមាស ដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ព្រមទាំងតំបន់ចែកចាយរបស់សេវាករ យិន អ៊ិច និងតំបន់ចែកចាយរបស់សេវាករ ចាន់ សុគីម ដែលទិញប្រភពអគ្គិសនីបន្តពីសហគ្រាស អគ្គិសនី ទូកមាស បច្ចុប្បន្នមានថ្លៃស្មើនឹង ១,០០០ រៀល ។ ដោយសារតំបន់ទាំង ៣ មានថ្លៃអគ្គិសនីនៅខ្ពស់នៅឡើយ ដូច្នេះរាជរដ្ឋាភិបាលកំពុងរុញឲ្យជួយដោះស្រាយឲ្យតំបន់ទាំង ៣ នេះ មានថ្លៃអគ្គិសនីតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ។ ក្នុងនោះ សហគ្រាស អគ្គិសនី ទូកមាស ដែលមានខ្សែបណ្តាញ ២២ គីឡូវ៉ុល និងលក់ប្រភពអគ្គិសនីបន្តឲ្យតំបន់ចែកចាយ ២ តំបន់ទៀតនោះ អាចដើរតួនាទីជាស្នូល ដោយនាំចូលអគ្គិសនីពីប្រទេសវៀតណាម ផង និងភ្ជាប់ជាមួយប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរង របស់អគ្គិសនីកម្ពុជាផង ។ ***ដើម្បីរៀបចំឲ្យថ្លៃអគ្គិសនីនៅតំបន់ចែកចាយទាំង ៣ តំបន់នេះ អាចបន្ថយតាមផែនការ របស់រាជរដ្ឋាភិបាល ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា***

*តំបូងត្រូវអនុញ្ញាតឲ្យខ្សែបណ្តាញ ២២ គីឡូវ៉ុល របស់សហគ្រាស អគ្គិសនី ទូកមាស ក្លាយទៅជាបណ្តាញបញ្ជូនរងពិតប្រាកដ ដែលអាចយកប្រភពអគ្គិសនីដុំចេញពីបណ្តាញជាតិផង និងនាំចូលអគ្គិសនីពីប្រទេសវៀតណាម ផង មកប្រើបញ្ចូលគ្នា ដើម្បីឲ្យតំបន់ទាំងនេះ ក្លាយទៅជាតំបន់ដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ អាចទទួលការប៉ះប៉ូវពីមូលនិធិអគ្គិសនីការូបនីយកម្មជនបទ ដូចតំបន់ចែកចាយដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិដ៏ទៃទៀត ដែលនឹងធ្វើឲ្យថ្លៃអគ្គិសនីនៅតំបន់ទាំង ៣ នេះ អាចនឹងថយចុះទៅតាមផែនការរួមរបស់រាជរដ្ឋាភិបាល ដូចតំបន់ដែលយកអគ្គិសនីពីប្រភពអគ្គិសនីបណ្តាញជាតិដែរ ។ ពេលវេលាអនុវត្តថ្លៃតាមផែនការរួមរបស់រាជរដ្ឋាភិបាលរបស់តំបន់ទាំង ៣ នេះ គឺអាស្រ័យនឹងពេលវេលានៃការដោះស្រាយបញ្ហាខាងលើ (គម្រោងនេះ គ្រោងអនុវត្តឲ្យបាននៅខែ មីនា ឆ្នាំ ២០១៦) ។*

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តកែប សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកែប

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តកែប គឺជាខេត្តមួយ ដែលត្រូវបានបំបែកចេញពីខេត្តកំពត ក្នុងរយៈពេលថ្មីៗនេះ ។ កន្លងមក ខេត្តកែប ទាំងមូលត្រូវបានផ្គត់ផ្គង់អគ្គិសនីដោយក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ ដែលបានសាងសង់បណ្តាញ ២២ គីឡូវ៉ុល នាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម តាមច្រកស្រុកកំពង់ត្រាច ខេត្តកំពត និងផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់នានា ក្នុងខេត្តកែប ។ ជាលក្ខណៈភូមិសាស្រ្ត ការដោះស្រាយប្រភពអគ្គិសនីពីបណ្តាញជាតិឲ្យខេត្តកែប តាមផែនការដែលបានរៀបចំកន្លងមក គឺត្រូវបានដោះស្រាយរួមគ្នាជាមួយខេត្តកំពត គឺដូច្នេះហើយដែលក្នុងផែនការអភិវឌ្ឍន៍ គេបានសាងសង់អនុស្ថានីយមួយកន្លែងនៅជិតក្រុងកំពត លើគន្លងនៃខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនីដែលភ្ជាប់ភ្នំពេញ តាកែវ កំពត និងខេត្តព្រះសីហនុ ដើម្បីទី ១.ភ្ជាប់ជាមួយស្ថានីយវារីអគ្គិសនីកំចាយ និងទី ២.ផ្តល់ប្រភពអគ្គិសនីឲ្យខេត្តកែប ផង និងខេត្តកំពត ផង ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពត នេះ ទៅឲ្យប្រព័ន្ធចែកចាយអគ្គិសនីខេត្តកែប គឺអាចធ្វើតាមខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ប៉ុន្តែបច្ចុប្បន្ន ពិតមែនតែខេត្តកែប អាចយកប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ តាមរយៈបណ្តាញបញ្ជូននេះបាន ប៉ុន្តែប្រព័ន្ធចែកចាយអគ្គិសនីរបស់ខេត្តកែប នៅបន្តយកប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម តាមច្រកស្រុកកំពង់ត្រាច ខេត្តកំពត នៅឡើយ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្រ្តខេត្តកែប មានក្រុង ១ ឈ្មោះក្រុងកែប និងស្រុកចំនួន ១ ឈ្មោះស្រុកដំណាក់ចង្អើរ ។ មកដល់ពេលនេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់នៅក្នុងខេត្តកែប ទាំងមូល ត្រូវបានដោះស្រាយដោយការផ្គត់ផ្គង់អគ្គិសនីរបស់ប្រព័ន្ធចែកចាយរបស់ក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ ដែលទទួលប្រភពអគ្គិសនីពីការនាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញ ២២ គីឡូវ៉ុល ដោយមិនទាន់ចាប់ផ្តើមយកប្រភពអគ្គិសនីពីអនុស្ថានីយរបស់បណ្តាញជាតិនៅខេត្តកំពត នៅឡើយ ។ តាមផែនការយុទ្ធសាស្រ្តដែលបានគ្រោងនៅឆ្នាំខាងមុខ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកត្រូវការប្រើប្រាស់នៅក្នុងខេត្តកែប អាចនឹងត្រូវបានពង្រីកវិសាលភាពដូចតទៅ ៖ ទី១.ចំពោះអ្នកប្រើប្រាស់អគ្គិសនីដុំ ដែលមានសេចក្តីត្រូវការប្រើប្រាស់ ចាប់ពី ១០ មេហ្គាវ៉ាត់ ឡើង អាចទិញអគ្គិសនីដុំពីអនុស្ថានីយខេត្តកំពត ទី២.ចំពោះអ្នកប្រើប្រាស់ធំៗ ដែលត្រូវប្រើលើតង់ស្យុងមធ្យម អាចទិញអគ្គិសនីធំ ពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឬក៏ពីខ្សែបណ្តាញតង់ស្យុងមធ្យមរបស់ក្រុមហ៊ុន កែប ផៅវ័រ ស៊ីបប្លាយ បាន និងទី៣.ចំពោះអ្នកប្រើប្រាស់ធម្មតា និងទូទៅដែលប្រើអគ្គិសនីតាមតង់ស្យុងទាប ធម្មតា អាចទិញអគ្គិសនីពីខ្សែបណ្តាញតង់ស្យុងទាប របស់ក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ បាន។ ដូច្នេះ តាមផែនការខាងលើនេះ ដំណោះស្រាយសម្រាប់ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងខេត្តកែប ចំពោះអ្នកប្រើប្រាស់គ្រប់ប្រភេទ និងគ្រប់ទំហំ អាចដោះស្រាយបាន ។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តកែប




## បញ្ជីឈ្មោះតំបន់ចែកចាយ និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនៅក្នុងខេត្តកែប

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ | ចំនួនភូមិ |
|---|---|---|---|---|---|
| 1 | ក្រុមហ៊ុន កែប ផៅវ៉ែរ ស៊ីបផ្លាយ | 180 L | VN-EDC | ក្រុងកែប | 7 |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកែប

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ដំណាក់ចង្អើរ | 11 | 11 | 100.00% | 9 | 81.82% | 2 |
| កែប | 7 | 7 | 100.00% | 7 | 100.00% | - |
| **សរុប** | **18** | **18** | **100.00%** | **16** | **88.89%** | **2** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្តបច្ចុប្បន្ន និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកែប

ដោយសារតែមកដល់ពេលនេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់នៅក្នុងខេត្តកែប ទាំងមូល ត្រូវបានដោះស្រាយដោយការផ្គត់ផ្គង់របស់ប្រព័ន្ធចែកចាយរបស់ក្រុមហ៊ុន កែប ផៅវ៉ែរ សិបប្លាយ ដែលទទួលប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម តាមរយៈខ្សែបណ្តាញ ២២ គីឡូវ៉ុល តែមួយគត់ ដូច្នេះ ថ្លៃអគ្គិសនីកំពុងអនុវត្ត គឺមានតែមួយប្រភេទប៉ុណ្ណោះ គឺ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង។ ដោយសារស្ថានភាពផ្គត់ផ្គង់

ប្រភពអគ្គិសនីដូចបានជម្រាបជូនខាងលើនេះខេត្តកែប ត្រូវបានចាត់ទុកថាឋិតនៅក្រៅរង្វង់នៃការផ្គត់ផ្គង់ប្រភពអគ្គិសនីរបស់បណ្តាញជាតិ ដូច្នេះនៅឆ្នាំ ២០១៥ នេះ តំបន់ផ្គត់ផ្គង់អគ្គិសនីនៅខេត្តកែប របស់ក្រុមហ៊ុន កែប ផៅវ័រ ស៊ីបផ្លាយ ដែលមានថ្លៃលក់បច្ចុប្បន្នស្មើនឹង ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង អាចរក្សាស្ថានភាពថ្លៃនៅដដែលដូចបច្ចុប្បន្ន ដើម្បីជានាឲ្យមានស្ថេរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីក្នុងខេត្តកែប ជាបណ្តោះអាសន្នសិន។ ក្នុងគោលដៅដោះស្រាយបញ្ហាថ្លៃអគ្គិសនីនៅខេត្តកែប ឲ្យបានដូចតំបន់ដ៏ទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា មានផែនការរៀបចំឲ្យប្រព័ន្ធចែកចាយរបស់ក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ នៅខេត្តកែប ប្រើបញ្ចូលគ្នារវាងប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម និងប្រភពអគ្គិសនីចេញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដើម្បីឲ្យថ្លៃអគ្គិសនីនៅក្នុងខេត្តកែបទាំងមូល អាចនឹងថយចុះទៅតាមផែនការរួមនៃថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល ដូចតំបន់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនីបណ្តាញជាតិដែរ ។ ពិតមែនតែពេលវេលាក្នុងផែនការបានកំណត់ឲ្យការបន្ថយថ្លៃអគ្គិសនីតាមផែនការរួមរបស់រាជរដ្ឋាភិបាល នឹងចាប់អនុវត្តពីខែ មីនា ឆ្នាំ២០១៦ តទៅ ប៉ុន្តែការងារនេះ គឺអាស្រ័យនឹងការចាំបាច់ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ដើម្បីរៀបចំឲ្យតំបន់ទាំងនេះ ប្រើបញ្ចូលគ្នារវាងប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម និងប្រភពអគ្គិសនីចេញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។

បន្ថែមពីលើនោះ ដោយសារការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកត្រូវការប្រើប្រាស់នៅក្នុងខេត្តកែប ត្រូវបានពង្រីកវិសាលភាពចំពោះអ្នកប្រើប្រាស់អគ្គិសនីធុំ ដែលមានសេចក្តីត្រូវការប្រើប្រាស់ចាប់ពី ១០ មេហ្គាវ៉ាត់ឡើង អាចទិញអគ្គិសនីផ្ទាល់ពីអនុស្ថានីយខេត្តកំពត និងចំពោះអ្នកប្រើប្រាស់ធំៗ ដែលត្រូវប្រើលើតង់ស្យុងមធ្យម អាចទិញអគ្គិសនីពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឬក៏ទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមរបស់ក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ បាន ដូច្នេះចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទៅ ផែនការថ្លៃអគ្គិសនីធុំ និងធំ នៅខេត្តកែប នឹងមានស្ថានភាព ដូចគម្រោងខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីក្នុងរូបភាពធំ ពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជា អាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.៣ តំបន់ចែកចាយរបស់ក្រុមហ៊ុនកែបផៅវ័រសិបប្លាយ

ចំពោះការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងខេត្តកែប ដែលត្រូវផ្គត់ផ្គង់ដោយក្រុមហ៊ុន កែប ផៅវ័រ សិបប្លាយ ដោយសារតែថ្លៃលក់រាយមានថ្លៃ ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចហើយ ដូច្នេះ យើងរក្សាស្ថានភាពផ្គត់ផ្គង់រាយនៅខេត្តកែបនេះ ឲ្យនៅក្រៅតំបន់ផ្គត់ផ្គង់របស់បណ្តាញជាតិបន្តទៀត ដោយគ្រាន់តែកំណត់ថ្លៃលក់អគ្គិសនី

នៅលើតង់ស្យុងមធ្យម ឲ្យដូចថ្លៃរបស់តំបន់ដែលឋិតនៅក្នុងប្រព័ន្ធបណ្តាញជាតិ ។ ពេលវេលាចាប់ផ្តើមអនុវត្ត ផែនការថ្លៃរបស់រាជរដ្ឋាភិបាលខាងក្រោម គឺអាស្រ័យនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ ដើម្បីរៀបចំឲ្យ តំបន់ចែកចាយកែបនេះ ប្រើបញ្ចូលគ្នារវាងប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម និងប្រភពអគ្គិសនី ចេញពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា ដែលគ្រោងនៅឆ្នាំ ២០១៧ ។ ថ្លៃដែលត្រូវអនុវត្តចាប់ពីឆ្នាំ ២០១៧ មានដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញMVពីខ្សែ MV | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញ ក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តព្រះសីហនុ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះសីហនុ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

កន្លងមក ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះសីហនុ ទទួលប្រភពអគ្គិសនីបានមកពីរោងចក្រអគ្គិសនីប្រើប្រេងខ្មៅចំនួន ២ នៅក្រុងព្រះសីហនុ ដែលក្នុងនោះមានរោងចក្រអគ្គិសនី១ ទំហំ ៥ មេហ្គាវ៉ាត់ ជារបស់អគ្គិសនីកម្ពុជា និងរោងចក្រអគ្គិសនី ១ ទៀតទំហំ ១០ មេហ្គាវ៉ាត់ ជារបស់អ្នកវិនិយោគឯកជន ដែលផលិតអគ្គិសនីលក់ឲ្យអគ្គិសនីកម្ពុជា ។ ចាប់ពីឆ្នាំ ២០១២ អគ្គិសនីកម្ពុជាបានសាកល្បងបញ្ជូនប្រភពអគ្គិសនីរបស់បណ្តាញជាតិពីអនុស្ថានីយកំពត មកបន្ថែមឲ្យខេត្តព្រះសីហនុ រួចទើបនឹងឆ្នាំ ២០១៤ កន្លងមកនេះទេ ដែលការផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះសីហនុ ត្រូវបានគ្របដណ្តប់ទាំងស្រុងដោយប្រភពអគ្គិសនីរបស់ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីដែលភ្ជាប់ភាគខាងត្បូងនៃប្រទេសកម្ពុជា ដោយសារខេត្តនេះ ចាប់ផ្តើមមានអនុស្ថានីយបណ្តាញជាតិផ្ទាល់របស់ខ្លួន។ ប្រព័ន្ធបណ្តាញជាតិនេះមានប្រភពអគ្គិសនីចេញពីស្ថានីយវារីអគ្គិសនី ចេញពីរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម និងអគ្គិសនីនាំចូលពីប្រទេសវៀតណាម ដែលក្នុងនោះ រោងចក្រអគ្គិសនីដើរដោយធ្យូងថ្មនាំចូលទី១ និងទី ២ បច្ចុប្បន្ននេះ មានទីតាំងឋិតនៅក្នុងក្រុងព្រះសីហនុ តែម្តង ។ បច្ចុប្បន្ននៅក្នុងខេត្តព្រះសីហនុ ប្រព័ន្ធបណ្តាញជាតិមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនី ២ កន្លែងគឺ ៖ អនុស្ថានីយ ១ កន្លែង មានទីតាំងឋិតនៅក្នុងខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុនិងអនុស្ថានីយបណ្តាញជាតិ១កន្លែងទៀតមានទីតាំងឋិតនៅចំកណ្តាលក្រុងជិតកំពង់ផែក្រុងព្រះសីហនុ ។ ខេត្តព្រះសីហនុ គឺជាខេត្តមួយមានសក្តានុពលឧស្សាហកម្ម ទេសចរណ៍ កសិ-ឧស្សាហកម្ម និងជាតំបន់កំពង់ផែនៃការដឹកជញ្ជូនតាមផ្លូវសមុទ្រដ៏សំខាន់ របស់ព្រះរាជាណាចក្រកម្ពុជា ដែលការប្រើប្រាស់អគ្គិសនីមានទំហំធំ និងកើនឡើងច្រើនពីមួយឆ្នាំទៅមួយឆ្នាំ ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយខេត្តព្រះសីហនុ ទៅឲ្យតំបន់ចែកចាយនានា នៅក្នុងខេត្តព្រះសីហនុ គឺបានធ្វើតាមបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តព្រះសីហនុ មានក្រុង ១ ឈ្មោះក្រុងព្រះសីហនុ និងស្រុកចំនួន ៣ គឺ ៖ ១.ស្រុកកំពង់សិលា ២.ស្រុកស្ទឹងហាវ និង៣.ស្រុកព្រៃនប់ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តព្រះសីហនុត្រូវបានដោះស្រាយដោយរបៀប ៣ យ៉ាងគឺ ៖ ទី១.**ការផ្គត់ផ្គង់អគ្គិសនីដុំ**ពីអនុស្ថានីយ ទី២.**ការផ្គត់ផ្គង់អគ្គិសនីធំ**ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីឲ្យអ្នកប្រើប្រាស់តាមតំបន់ចែកចាយនានា នៅខេត្តព្រះសីហនុ ត្រូវបានដោះស្រាយដោយការវិនិយោគមួយផ្នែករបស់អគ្គិសនីកម្ពុជា និងមួយផ្នែកទៀតរបស់អ្នកវិនិយោគឯកជនក្នុងស្រុក ។ បច្ចុប្បន្ននៅខេត្តព្រះសីហនុ មានតំបន់ចែកចាយអគ្គិសនីចំនួន ១២ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដែលគ្របដណ្តប់ ១ ផ្នែកធំ នៃក្រុងព្រះសីហនុ និង ១១ តំបន់ទៀត គឺជាតំបន់ចែកចាយអគ្គិសនីរបស់សេវាកររឯកជន ដែលគ្របដណ្តប់តំបន់ជន

បទនានា របស់ខេត្តព្រះសីហនុ ។ តំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជនទាំង ១១ តំបន់ខាងលើ គឺជាតំបន់ចែកចាយដែលបានទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដូច្នេះសុទ្ធតែជាតំបន់ចែកចាយអគ្គិសនី ដែលជាមុខសញ្ញានៃការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ តាមផែនការរួមរបស់រាជរដ្ឋាភិបាល ។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តព្រះសីហនុ




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តព្រះសីហនុ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (ក្រុងព្រះសីហនុ) | 001 L | GS | ក្រុងព្រះសីហនុ |
| 2 | សេវាករ សុខ ធី | 029 L | GS-EDC | ស្រុកព្រៃនប់ |
| 3 | សេវាករ លី ប៊ុនធី | 030 L | GS-EDC | ស្រុកស្ទឹងហាវ |
| 4 | សេវាករ គង់ សុផល | 042 L | GS-EDC | ស្រុកព្រៃនប់ |
| 5 | សេវាករ សាន កេ | 098 L | GS-EDC | ស្រុកព្រៃនប់ |
| 6 | សេវាករ ចាន់ គាត | 120 L | GS-EDC | ស្រុកស្ទឹងហាវ |
| 7 | សេវាករ ជា គឹមថាត | 184 L | GS-EDC | ស្រុកព្រៃនប់ |
| 8 | សេវាករ ហុង ហ៊ុយ | 271 L | GS-EDC | ស្រុកព្រៃនប់ |
| 9 | សេវាករ តិច ស៊ូលី | 306 L | GS-EDC | ស្រុកព្រៃនប់ |
| 10 | សេវាករ ឃុន ចាន់ធារិទ្ធ | 279 L | GS-EDC | ស្រុកកំពង់សិលា |
| 11 | សេវាករ ភាយ ឆាយសូរី | 358 L | GS-EDC | ស្រុកកំពង់សិលា |
| 12 | ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប | 304 L | GS-EDC | ស្រុកព្រៃនប់ |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តព្រះសីហនុ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ក្រុងព្រះសីហនុ | 19 | 19 | 100.00% | 15 | 78.95% | 4 |
| ព្រៃនប់ | 65 | 65 | 100.00% | 59 | 90.77% | 6 |
| ស្ទឹងហាវ | 13 | 13 | 100.00% | 13 | 100.00% | - |
| កំពង់សីលា | 14 | 14 | 100.00% | 11 | 78.57% | 3 |
| **សរុប** | **111** | **111** | **100.00%** | **98** | **88.29%** | **13** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្តបច្ចុប្បន្ន និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តព្រះសីហនុ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តព្រះសីហនុ អាចបែងចែកជាផែនការដោយឡែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៤ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីដុំ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងព្រះសីហនុ និង៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តព្រះសីហនុ ដែលចែកជាផែនការដោយឡែក ទៅតាមប្រភេទនៃការផ្គត់ផ្គង់ទាំង ៤ នេះ មានខ្លឹមសារ ដូចខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ

តាមស្ថានភាពប្រភពអគ្គិសនីនៅក្រុងព្រះសីហនុ ការទិញអគ្គិសនីដុំពីអនុស្ថានីយនៅខេត្តព្រះសីហនុត្រូវចែកចេញជា ២ ប្រភេទ គឺ ទី១.ការទិញពីអនុស្ថានីយស្ទឹងហាវ និងទី២.ការទិញពីអនុស្ថានីយក្នុងក្រុងព្រះសីហនុ ។ ការទិញពីអនុស្ថានីយស្ទឹងហាវ គឺជាការទិញផ្ទាល់ពីប្រព័ន្ធបណ្តាញជាតិដែលមិនពាក់ព័ន្ធជាមួយរោងចក្រអគ្គិសនីប្រើប្រេងដែលមានក្នុងក្រុងព្រះសីហនុ ទេ រួចថ្លៃលក់ដុំនេះត្រូវអនុវត្តទៅតាមថ្លៃកំណត់ក្នុងផែនការរួមរបស់រាជរដ្ឋាភិបាល ដោយឡែកចំពោះការទិញអគ្គិសនីដុំពីអនុស្ថានីយកណ្តាលក្រុង គឺជាការទិញពីប្រព័ន្ធមួយដែលមានការចូលរួមជួយជានាស្ថេរភាពរបស់រោងចក្រប្រើប្រេងខ្មៅ របស់អ្នកវិនិយោគឯកជន នៅក្នុងក្រុងព្រះសីហនុ ដូច្នេះអ្នកទិញដុំពីអនុស្ថានីយនេះ ត្រូវមានកាតព្វកិច្ចជួយចេញថ្លៃសេវាដែលអគ្គិសនីកម្ពុជាបានបង់ឲ្យរោងចក្រអគ្គិសនីឯកជន ក្នុងការត្រៀមបម្រុងប្រភពអគ្គិសនីរហូតដល់ចប់កិច្ចព្រមព្រៀងវិនិយោគ ។ ដូច្នេះថ្លៃទិញអគ្គិសនីដុំពីអនុស្ថានីយនៅខេត្តព្រះសីហនុ ត្រូវបានបែងចែកជា ២ ដូចខាងក្រោម ៖

- **ទិញអគ្គិសនីដុំពីអនុស្ថានីយស្ទឹងហាវ**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៥** | **ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០** |
|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.129$/kWh | 0.126$/kWh |

- **ទិញអគ្គិសនីដុំពីអនុស្ថានីយក្នុងក្រុងព្រះសីហនុ**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៥** | **ឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០** |
|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.129$/kWh + ថ្លៃសេវាមធ្យមនៃ IPP | 0.126$/kWh+ ថ្លៃសេវាមធ្យមនៃ IPP |

**កំណត់សំគាល់៖** ថ្លៃសេវាមធ្យមនេះ ត្រូវកំណត់ ១ ឆ្នាំម្តង ទៅតាមកំណើននៃបរិមាណប្រភពអគ្គិសនីដែលក្រុងព្រះសីហនុ ត្រូវការ នឹងថយចុះបន្តិចម្តងៗ រហូតដល់ចំនួនមួយដែលអាចលុបចេញបាន ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវពិនិត្យ និងគណនាថ្លៃសេវាមធ្យមនៃ IPP នៅដំណាច់ឆ្នាំនីមួយៗ ដើម្បីអនុវត្តនៅឆ្នាំបន្ទាប់ ។

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់ ៖** លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងព្រះសីហនុ

ស្ថានភាពថ្លៃអគ្គិសនីនៅឆ្នាំ ២០១៥ និងផែនការបន្ថយថ្លៃទៅអនាគត ក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងព្រះសីហនុ មានស្ថានភាព ដូចខាងក្រោម ៖

### (១).ស្ថានភាពថ្លៃនៅឆ្នាំ ២០១៥

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|
| **១.លំនៅដ្ឋានពលរដ្ឋកម្ពុជា** | |
| ដែលប្រើមិនលើសពី ២០០ kWh ក្នុង១ខែ | ៧២០ រៀល ក្នុង១kWh |
| ដែលប្រើលើសពី ២០០ kWh ក្នុង១ខែ | ៨២០ រៀល ក្នុង១kWh |
| **២.អតិថិជនទូទាត់ដោយថវិការដ្ឋ** | |
| អតិថិជនគ្រប់ទំហំទាំងអស់ | ៨២០ រៀល ក្នុង១kWh |
| **៣.អតិថិជនស្ថានទូត ផ្ទះ និងស្ថាប័ននានារបស់ជនបរទេស** | |
| គ្រប់ទំហំប្រើប្រាស់ | ៨២០ រៀល ក្នុង១kWh |
| **៤.អតិថិជនដទៃទៀត** | |
| អតិថិជនធុនតូច | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.046 $US) / kWh |
| អតិថិជនធុនមធ្យម | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.038 $US) / kWh |
| អតិថិជនធុនធំ | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.034 $US) / kWh |
| អតិថិជន MV ទំហំ 275-500 kVA | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.025 $US) / kWh |
| អតិថិជន MV ទំហំ 501-1000 kVA | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.022 $US) / kWh |
| អតិថិជន MV ទំហំ 1001-3000 kVA | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.018 $US) / kWh |
| អតិថិជន MV ទំហំលើសពី 3000 kVA | =(ថ្លៃមធ្យមនៃល្បាយប្រភព+0.015 $US) / kWh |

**កំណត់សំគាល់៖** ល្បាយប្រភពអគ្គិសនីដែលបានប្រើខាងលើ គឺជាល្បាយនៃប្រភពអគ្គិសនីពីបណ្តាញជាតិដែលមានថ្លៃថោក និងប្រភពអគ្គិសនីចេញពីរោងចក្រប្រើប្រេងនៅក្រុងព្រះសីហនុ ។ ថ្លៃមធ្យមនៃល្បាយប្រភពអគ្គិសនីសម្រាប់ឆ្នាំ ២០១៥ គឺស្មើនឹង 0.1520 $/kWh ។ ការកំណត់ថ្លៃច្រើនអត្រាតាមទំហំ ដែលមានភាពស្មុគ្រស្មាញខាងលើ នឹងត្រូវកែសម្រួលឲ្យដូចការកំណត់រួមសម្រាប់ខេត្តដ៏ទៃទៀត របស់អគ្គិសនីកម្ពុជាវិញ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ តទៅ ។

## (២).ផែនការបន្ថយថ្លៃដែលត្រូវអនុវត្តពីខែមីនា ឆ្នាំ២០១៦

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែមេ EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជននៅខេត្តព្រះសីហនុ

ដូចបានជំរាបជូនខាងលើ តំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជននៅខេត្តព្រះសីហនុ មានទាំងអស់ ១១ តំបន់ ។ តំបន់ចែកចាយរបស់សេវាករឯកជនទាំង ១១ តំបន់នេះ គឺជាតំបន់ដែលបានទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដូច្នេះសុទ្ធតែជាតំបន់ចែកចាយអគ្គិសនីដែលជាមុខសញ្ញានៃការបន្ថយអត្រាថ្លៃ និងគម្លាតថ្លៃ តាមផែនការរួមរបស់រាជរដ្ឋាភិបាល ។ ក្នុងតំបន់ចែកចាយទាំង ១១ នេះ មានតំបន់ចែកចាយ ២ តំបន់ នៅស្រុកកំពង់សិលា ដែលអ្នកចែកចាយទើបនឹងធ្វើការវិនិយោគរួច កំពុងឋិតនៅក្នុងកម្មវិធីបញ្ចុះថ្លៃអគ្គិសនីបន្តិចម្តងៗ រហូតដល់ ១,១០០ រៀល និង ៩ តំបន់ទៀត ជាតំបន់ដែលបានភ្ជាប់ជាមួយបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាយូរហើយ និងកំពុងលក់អគ្គិសនីក្នុងអត្រា ១,០០០រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ នៅឆ្នាំ ២០១៥ នេះ ចំពោះតំបន់ចែកចាយ ២ តំបន់នៅស្រុកកំពង់សិលា ដែលអ្នកចែកចាយទើបនឹងធ្វើការវិនិយោគ ត្រូវបានអនុញ្ញាតឲ្យបន្តអនុវត្តការបញ្ចុះថ្លៃអគ្គិសនីបន្តិចម្តងៗ បន្តទៀត តាមកម្មវិធីដែលបានគ្រោង ។ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ តទៅ នៅក្នុងតំបន់ទាំង ១១ ខាងលើ ថ្លៃអគ្គិសនីនឹងត្រូវថយចុះទៅតាមផែនការរួមរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## សម្រាប់លំនៅដ្ឋានទូទៅ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

## ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

* * * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តកំពង់ឆ្នាំង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពង់ឆ្នាំង

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តកំពង់ឆ្នាំង គឺជាខេត្តមួយឋិតនៅចំកន្លងនៃខ្សែបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ដែលតភ្ជាប់ភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ។ បណ្តាញបញ្ជូននេះ បានតភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅតំបន់ព្រំដែនពោធិ៍សាត់ និងកោះកុង ព្រមទាំងតភ្ជាប់ជាមួយប្រព័ន្ធបណ្តាញបញ្ជូនរបស់ប្រទេសថៃ ដើម្បីនាំចូលអគ្គិសនីពីប្រទេសថៃ ។ នៅក្នុងទឹកដីនៃខេត្តកំពង់ឆ្នាំង បណ្តាញជាតិបញ្ជូនអគ្គិសនីខាងលើនេះ មានអនុស្ថានីយមួយកន្លែង ឋិតនៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ដែលបានផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់ចែកចាយនានា នៅខេត្តកំពង់ឆ្នាំង ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយរបស់បណ្តាញជាតិនៅស្រុកទឹកផុសនេះទៅឲ្យតំបន់ចែកចាយនានា ក្នុងខេត្តកំពង់ឆ្នាំង គឺធ្វើតាមរយៈបណ្តាញបញ្ជូនរងជាច្រើនខ្សែដែលវិនិយោគដោយក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង ។ ចំពោះតំបន់ចែកចាយដែលឋិតនៅឆ្ងាយ និងឋិតនៅតំបន់កោះ នៅក្នុងខេត្តកំពង់ឆ្នាំង ក្នុងពេលដែលបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុនអូ.អេស.វី.អ ត្រេឌីង ពុំទាន់អាចពង្រីកទៅគ្របដណ្តប់តំបន់ទាំងនេះបាន ការផ្គត់ផ្គង់អគ្គិសនីត្រូវបានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជនធ្វើការផ្គត់ផ្គង់ដោយម៉ាស៊ីនដ្យេសែលតូចៗ ក្នុងលក្ខខណ្ឌបណ្តោះអាសន្នរង់ចាំការពង្រីកបណ្តាញបញ្ជូនរងទៅដល់ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តកំពង់ឆ្នាំង មានក្រុង ១ ឈ្មោះក្រុងកំពង់ឆ្នាំង និងស្រុកចំនួន ៧ គឺ ៖ ១.ស្រុកសាមគ្គីមានជ័យ ២.ស្រុកកំពង់ត្រឡាច ៣.ស្រុករលាប្អៀរ ៤.ស្រុកបរិបូរណ៍ ៥.ស្រុកទឹកផុស ៦.ស្រុកកំពង់លែង និង៧.ស្រុកជលគីរី ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកំពង់ឆ្នាំង ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយ **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរង និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ក្រៅពីប្រព័ន្ធបណ្តាញជាតិ និងអនុស្ថានីយដែលវិនិយោគដោយក្រុមហ៊ុនរដ្ឋ គឺអគ្គិសនីកម្ពុជា បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនីនៅក្នុងខេត្តកំពង់ឆ្នាំង ទាំងអស់ត្រូវបានវិនិយោគដោយសេវាករអគ្គិសនីឯកជន ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ នៅខេត្តកំពង់ឆ្នាំង ត្រូវបានបែងចែកជា ២ ប្រភេទ គឺ ៖ ទី១.តំបន់ចែកចាយដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង និងទី២.តំបន់ចែកចាយ ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ក្នុងលក្ខខណ្ឌបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តកំពង់ឆ្នាំង មានតំបន់ចែកចាយអគ្គិសនីចំនួន ១០ តំបន់ ដែលទាំងអស់ជាតំបន់ដែលវិនិយោគដោយសេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ចែកចាយឯកជនទាំង ១០ តំបន់នេះ មានតំបន់ចែកចាយ ៨ តំបន់ គឺជាតំបន់ចែកចាយដែលទិញប្រភពអគ្គិសនី

ផ្ទាល់ពីបណ្តាញបញ្ជូនរបស់ក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង និង ២ តំបន់ទៀត គឺតំបន់ដែលនៅផលិតអគ្គិសនី ពីម៉ាស៊ីនដ្យេសែល ដែលមានថ្លៃខ្ពស់ រង់ចាំបណ្តាញបញ្ជូនរងពង្រីកទៅដល់ ។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកំពង់ឆ្នាំង

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | ក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង | 300 L | GS | ស្រុករលាប្អៀរ |
| 2 | សេវាករ ទូច កក្កដា | 393 L | GS-EDC | ស្រុកសាមគ្គីមានជ័យ |
| 3 | សេវាករ ម៉ក់ ហ៊ាត | 040 L | GS-OSRV Trading | ស្រុកបរិបូរណ៍ |
| 4 | សេវាករ ទី សុគន្ធ | 041 L | GS-OSRV Trading | ស្រុកកំពង់ត្រឡាច |
| 5 | ក្រុមហ៊ុន សុវណ្ណនី អភិវឌ្ឍន៍ អគ្គិសនី | 051 L | GS-OSRV Trading | ក្រុងកំពង់ឆ្នាំង |
| 6 | សេវាករ ចាន់ ស៊ីម៉ូលី | 095 L | GS-OSRV Trading | ស្រុករលាប្អៀរ |
| 7 | សេវាករ អ៊ុន សុផល | 096 L | GS-OSRV Trading | ស្រុករលាប្អៀរ |
| 8 | សេវាករ អ៊ុន សុធា | 119 L | GS-OSRV Trading | ស្រុកទឹកផុស |
| 9 | សេវាករ កែ សារឿន | 298 L | ម៉ាស៊ីនដ្យេសែល | ស្រុកជលគីរី |
| 10 | សេវាករ ហុង សេងគ្រី | 400 L | ម៉ាស៊ីនដ្យេសែល | ស្រុកកំពង់ត្រឡាច |

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តកំពង់ឆ្នាំង



### ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកំពង់ឆ្នាំង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បរិបូណ៌ | 64 | 63 | 98.44% | 46 | 71.88% | 17 |
| ជលគីរី | 27 | 5 | 18.52% | 3 | 11.11% | 2 |
| កំពង់ឆ្នាំង | 26 | 26 | 100.00% | 26 | 100.00% | - |
| កំពង់លែង | 44 | - | - | - | - | - |
| កំពង់ត្រឡាច | 103 | 103 | 100.00% | 78 | 75.73% | 25 |
| រលាប្អៀរ | 135 | 133 | 98.52% | 85 | 62.96% | 48 |
| សាមគ្គីមានជ័យ | 86 | 84 | 97.67% | 28 | 32.56% | 56 |
| ទឹកផុស | 77 | 77 | 100.00% | 47 | 61.04% | 30 |
| **សរុប** | **562** | **491** | **87.37%** | **313** | **55.69%** | **178** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ឆ្នាំង

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ឆ្នាំង អាចបែងចែកជាផែនការដោយឡែក ទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៤ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ្.អេស.វី.អ ត្រេឌីង ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ្.អេស.វី.អ ត្រេឌីង និង៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ ដូច្នេះ ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ឆ្នាំង ដែលបានបែងចែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ទាំង ៤ នេះ មានដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

### ២.៣ តំបន់ចែកចាយឯកជនដែលយកអគ្គិសនីពីប្រភពបណ្តាញជាតិ

ដូចបានជំរាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយអគ្គិសនីទាំង ១០ តំបន់ នៅក្នុងខេត្តកំពង់ឆ្នាំង មាន តំបន់ចែកចាយចំនួន ៨ តំបន់ (ទាំងក្រុងកំពង់ឆ្នាំងផង) គឺជាតំបន់ចែកចាយឯកជន ដែលយកប្រភព

អគ្គិសនីផ្ទាល់ពីបណ្ដាញបញ្ជូនរងរបស់ក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង។ ផែនការបន្ថយថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ចែកចាយឯកជនទាំង ៨ តំបន់នេះ មានដូចខាងក្រោម ៖

**សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ១,០៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់របស់សេវាករឯកជនដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម្សៅសែលផលិតអគ្គិសនី

ក្នុងចំណោមតំបន់ផ្គត់ផ្គង់អគ្គិសនីទាំង ១០ តំបន់ នៅខេត្តកំពង់ឆ្នាំង មាន ២ តំបន់ ជាតំបន់នៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ូត គឺតំបន់អាជ្ញាប័ណ្ណលេខ ២៩៨ របស់សេវាករឈ្មោះ កែ សារឿន និងតំបន់អាជ្ញាប័ណ្ណលេខ ៤០០ របស់សេវាករឈ្មោះ ហុង សេងគ្រី ។

បញ្ហាដែលត្រូវដោះស្រាយ ចំពោះតំបន់ចែកចាយដែលនៅប្រើម៉ាស៊ីនម៉ាស៊ូត ផលិតអគ្គិសនីទាំង ២ តំបន់នៅខេត្តកំពង់ឆ្នាំង នេះ គឺជម្រុញឲ្យក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង និងអគ្គិសនីកម្ពុជា ពង្រីកបណ្ដាញបញ្ជូនរង ២២ គីឡូវ៉ុល ទៅតាមលទ្ធភាពនៃភូមិសាស្ត្រជាក់ស្ដែង តំបន់ណាគួរឲ្យក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង ពង្រីកចូលទៅ និងតំបន់ណាគួរឲ្យអគ្គិសនីកម្ពុជា ពង្រីកចូលទៅ ដើម្បីផ្ដល់ប្រភពបណ្ដាញជាតិឲ្យទៅតំបន់ចែកចាយទាំង ២ នេះ និងបន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ២ នេះ ឲ្យបានដូចផែនការរួមទូទាំងប្រទេស ។

ក្នុងរយៈពេលដែលបណ្ដាញបញ្ជូនរងមិនទាន់បញ្ជូនប្រភពអគ្គិសនីថោកទៅដល់តំបន់ចែកចាយទាំង ២ នេះ ដំបូងបំផុត គឺត្រូវធ្វើយ៉ាងណាឲ្យមានយុត្តិធម៌ រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់សិន ដោយអាជ្ញាធរអគ្គិសនីកម្ពុជា កំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយនីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដ្យេសែលផលិតអគ្គិសនីទាំង ២ តំបន់ នៅខេត្តកំពង់ឆ្នាំង យើងពុំមានជម្រើសអ្វី ក្រៅពីជម្រុញឲ្យក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង និងអគ្គិសនីកម្ពុជា ធ្វើការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនវង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាងទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដ្យេសែល ដែលមានថ្លៃខ្ពស់នៅទីនោះឡើយ (គម្រោងនេះ គ្រោងកំណត់ឲ្យក្រុមហ៊ុន អូ.អេស.វី.អ ត្រេឌីង និងអគ្គិសនីកម្ពុជា អនុវត្តឲ្យបាននៅដើមឆ្នាំ ២០១៧) ។

នៅសល់តំបន់កោះមួយទៀត នៅស្រុកកំពង់លែង ដែលបច្ចុប្បន្នមិនទាន់មានការផ្គត់ផ្គង់អគ្គិសនីនៅឡើយ ។ អ្នកស្នើសុំធ្វើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់កោះនេះ កំពុងមានវិវាទផ្ទៃក្នុងជាមួយគ្នា ដែលក្រសួងរ៉ែ និងថាមពល មិនទាន់អាចចេញប្រកាសអនុញ្ញាតឲ្យវិនិយោគទៅរូបវន្តបុគ្គលណាមួយនៅឡើយ ។ ដើម្បីដោះស្រាយការផ្គត់ផ្គង់អគ្គិសនី និងថ្លៃអគ្គិសនីឲ្យតំបន់ស្រុកកំពង់លែង នេះ ក្រសួងរ៉ែ និងថាមពល នឹងដោះស្រាយបញ្ហាវិវាទនេះ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន រួចចេញប្រកាសអនុញ្ញាតផ្តល់សម្បទានវិនិយោគឲ្យរូបវន្តបុគ្គលណាមួយដែលមានសមត្ថភាព ។ បន្ទាប់មក អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវរៀបចំចេញអាជ្ញាប័ណ្ណសម្រាប់ការធ្វើសេវាកម្មចែកចាយឲ្យរូបវន្តបុគ្គល ដែលក្រសួងរ៉ែ និងថាមពល បានសម្រេច ព្រមទាំងរៀបចំស្នើសុំឲ្យអគ្គិសនីកម្ពុជា ធ្វើការសាងសង់ខ្សែបញ្ជូនវង ២២ គីឡូវ៉ុល ផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិឲ្យតំបន់នេះ ដើម្បីដោះស្រាយការផ្គត់ផ្គង់អគ្គិសនី និងថ្លៃអគ្គិសនី ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តពោធិ៍សាត់ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តពោធិ៍សាត់

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តពោធិ៍សាត់ គឺជាខេត្តមួយឋិតនៅចំគន្លងនៃខ្សែបណ្តាញបញ្ជូន ២៣០ គីឡូវ៉ុល ដែលតភ្ជាប់ភ្នំពេញ កំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ និងសៀមរាប ។ បណ្តាញបញ្ជូននេះ បានតភ្ជាប់ជាមួយប្រភពវារីអគ្គិសនីនៅតំបន់ព្រំដែនពោធិ៍សាត់ និងកោះកុង ព្រមទាំងតភ្ជាប់ជាមួយប្រព័ន្ធបណ្តាញបញ្ជូនរបស់ប្រទេសថៃ ដើម្បីនាំចូលអគ្គិសនីពីប្រទេសថៃ ។ នៅក្នុងទឹកដីនៃខេត្តពោធិ៍សាត់ បណ្តាញជាតិបញ្ជូនអគ្គិសនីខាងលើនេះ មានអនុស្ថានីយមួយឋិតនៅសង្កាត់រលាប ក្រុងពោធិ៍សាត់ ដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់ចែកចាយនានា នៅខេត្តពាធិ៍សាត់។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិក្រុងពោធិ៍សាត់ នេះទៅឲ្យតំបន់ចែកចាយនានា ក្នុងខេត្តពោធិ៍សាត់ គឺធ្វើតាមរយៈបណ្តាញបញ្ជូនរងជាច្រើនខ្សែ ដែលវិនិយោគដោយអគ្គិសនីកម្ពុជា ។ ចំពោះតំបន់ចែកចាយដែលឋិតនៅឆ្ងាយពីអនុស្ថានីយ ដែលបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ពុំទាន់អាចពង្រីកទៅដល់ ការផ្គត់ផ្គង់អគ្គិសនីត្រូវបានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជន ធ្វើការផ្គត់ផ្គង់ដោយផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលតូចៗ ក្នុងលក្ខខណ្ឌបណ្តោះអាសន្នរង់ចាំបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាពង្រីកទៅដល់ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តពោធិ៍សាត់ មានក្រុង ១ ឈ្មោះក្រុងពោធិ៍សាត់ និងស្រុកចំនួន ៥ គឺ ៖ ១.ស្រុកក្រគរ ២.ស្រុកកណ្តៀង ៣.ស្រុកបាកាន ៤.ស្រុកភ្នំក្រវាញ និង៥.ស្រុកវាលវែង ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តពោធិ៍សាត់ ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយក្រុងពោធិ៍សាត់ **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ បណ្តាញជាតិ អនុស្ថានីយ និងបណ្តាញបញ្ជូនរង គឺជាហេដ្ឋារចនាសម្ព័ន្ធដែលវិនិយោគដោយអគ្គិសនីកម្ពុជា ដោយឡែកបណ្តាញចែកចាយអគ្គិសនីនៅក្នុងខេត្តពោធិ៍សាត់ ទាំងអស់ត្រូវបានវិនិយោគដោយសេវាករចែកចាយអគ្គិសនីឯកជន។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ នៅខេត្តពោធិ៍សាត់ ចែកជា ២ ប្រភេទគឺ ៖ ទី១.តំបន់ចែកចាយដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី២.តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលតូចៗ ក្នុងលក្ខខណ្ឌបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តពោធិ៍សាត់ មានតំបន់ចែកចាយអគ្គិសនីចំនួន ១៥ តំបន់ ដែលជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់ឯកជនទាំង ១៥ តំបន់ មាន ១២ តំបន់ គឺជាតំបន់ដែលទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង ៣ តំបន់ទៀត គឺតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ ។

# ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តពោធិ៍សាត់




# បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តពោធិ៍សាត់

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | សេវាករ ឈួ ងួន | 033 L | GS-EDC | ស្រុកបាកាន |
| 2 | សេវាករ ទឹម ទូច | 034 L | GS-EDC | ស្រុកបាកាន |
| 3 | សហគ្រាស ណារ៉េត លីមីតធីត អភិវឌ្ឍន៍ អគ្គិសនី | 052 L | GS-EDC | ក្រុងពោធិ៍សាត់ |
| 4 | សេវាករ យ៉ា សម្បត្តិ | 072 L | GS-EDC | ស្រុកបាកាន |
| 5 | សេវាករ ព្រាប វណ្ណារ៉េត | 102 L | GS-EDC | ស្រុកបាកាន |
| 6 | សេវាករ អ៊ា ឡេីស៊ាន | 124 L | GS-EDC | ស្រុកក្រវាញ |
| 7 | សេវាករ យក់ សារង្ស | 125 L | GS-EDC | ស្រុកក្រគរ |
| 8 | សេវាករ ស្រ៊ុន សុគន្ធ | 233 L | GS-EDC | ស្រុកក្រគរ |
| 9 | សេវាករ លឹម ប៉ាក | 331 L | GS-EDC | ស្រុកក្រវាញ |
| 10 | សេវាករ ប៊ឹង គៀង | 332 L | GS-EDC | ស្រុកបាកាន |
| 11 | សេវាករ គឹម ស៊ីផល | 382 L | GS-EDC | ស្រុកកណ្ដៀង |
| 12 | សេវាករ ឃឹម ហៀង | 383 L | GS-EDC | ស្រុកក្រគរ |
| 13 | សេវាករ ប៉ៃ សុបញ្ញា | 396 L | ម៉ាស៊ីនដេីសែល | ស្រុកវាលវែង |
| 14 | សេវាករ ប៉ាវ វុទ្ធី | 397 L | ម៉ាស៊ីនដេីសែល | ស្រុកវាលវែង |
| 15 | សេវាករ វង្ស សំបូរ | 281 L | ម៉ាស៊ីនដេីសែល | ស្រុកវាលវែង |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តពោធិ៍សាត់

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បាកាន | 152 | 138 | 90.79% | 113 | 74.34% | 25 |
| កណ្តៀង | 109 | 104 | 95.41% | 99 | 90.83% | 5 |
| ក្រគរ | 101 | 99 | 98.02% | 78 | 77.23% | 21 |
| ភ្នំក្រវាញ | 53 | 53 | 100.00% | 33 | 62.26% | 20 |
| ពោធិ៍សាត់ | 66 | 63 | 95.45% | 59 | 89.39% | 4 |
| វាលវែង | 20 | 20 | 100.00% | 4 | 20.00% | 16 |
| សរុប | **501** | **477** | **95.21%** | **386** | **77.05%** | **91** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តពោធិ៍សាត់

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តពោធិ៍សាត់ អាចបែងចែកជាផែនការទៅតាមប្រភេទនៃការផ្គត់ផ្គង់ដោយឡែកចំនួន ៤ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តពោធិ៍សាត់ ត្រូវបានបែងចែកលម្អិតជា ៤ ផែនការ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

### ២.៣ តំបន់ចែកចាយឯកជនដែលយកអគ្គិសនីពីប្រភពបណ្តាញជាតិ

ដូចបានជម្រាបជូនខាងលើ ក្នុងចំណោមតំបន់ផ្គត់ផ្គង់អគ្គិសនីទាំង ១៥ តំបន់ នៅក្នុងខេត្តពោធិ៍សាត់ គឺមានតំបន់ចែកចាយឯកជនចំនួន ១២ តំបន់ ជាតំបន់ដែលយកប្រភពអគ្គិសនីផ្ទាល់ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។ ផែនការបន្ថយថ្លៃលក់អគ្គិសនី នៅក្នុងតំបន់ចែកចាយឯកជនទាំង ១២ តំបន់នេះ មានដូចខាងក្រោម ៖

<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់របស់សេវាករឯកជនដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម្សៅម៉ែលផលិតអគ្គិសនី

ក្នុងចំណោមតំបន់ផ្គត់ផ្គង់អគ្គិសនីទាំង ១៥ តំបន់ នៅខេត្តពោធិ៍សាត់ មានតំបន់ចែកចាយ ៣ តំបន់ ជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ក្នុងនោះមានតំបន់ចែកចាយរបស់សេវាករ ប៉ៃ សុបញ្ញា, តំបន់របស់សេវាករ ប៉ាវ វុទ្ធី និងតំបន់របស់សេវាករ វង្ស សំបូរ ដែលឋិតនៅក្នុងស្រុកវាលវែង ។ បញ្ហាដែលត្រូវដោះស្រាយចំពោះតំបន់ដែលនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី នៅខេត្តពោធិ៍សាត់ មាន ២ សំខាន់គឺ ៖ ១.ជម្រុញការវិនិយោគពង្រីកការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិទៅគ្របដណ្តប់តំបន់ទាំង ២ នេះ និង២. បន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ២ នេះ ដើម្បីឲ្យបានដូចផែនការរួម ទូទាំងប្រទេស ។

ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែល ដំបូងបំផុត គឺត្រូវធ្វើយ៉ាងណាឲ្យមានយុត្តិធម៌រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់សិន ដោយអាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីទាំង ៣ តំបន់ នៅខេត្តពោធិ៍សាត់ យើងពុំមានជម្រើសអ្វីក្រៅពីជម្រុញឲ្យអគ្គិសនីកម្ពុជា វិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាង ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់នៅទីនោះឡើយ ។ គម្រោងនេះ គ្រោងអនុវត្តឲ្យបាននៅឆ្នាំ ២០១៧ ប៉ុន្តែ អគ្គិសនីកម្ពុជាត្រូវខិតខំជម្រុញការងារនេះ ឲ្យបានមុនផែនការដែលបានកំណត់ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តបាត់ដំបង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តបាត់ដំបង

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ចាប់ពីឆ្នាំ ២០០៩ មក ខេត្តបាត់ដំបង ត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធបណ្តាញបញ្ជូនដោយខ្សែក ដែលភ្ជាប់ខេត្តចំនួន ៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ជាមួយនឹងការនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមរយៈបណ្តាញបញ្ជូន ១១៥ គីឡូវ៉ុល ។ ប្រព័ន្ធបណ្តាញបញ្ជូនដោយខ្សែកនេះ មានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តបាត់ដំបង គឺនៅក្នុងស្រុកថ្មគោល ជិតក្រុងបាត់ដំបង ។ ដោយថ្លៃអគ្គិសនីនាំចូលពីប្រទេសថៃ ឡើងថ្លៃជារៀងរាល់ឆ្នាំ អគ្គិសនីកម្ពុជាបានសម្រេចពង្រីកបណ្តាញជាតិភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនខេត្តទាំង ៣ នេះ ដោយសាងសង់អនុស្ថានីយភ្ជាប់ជាមួយបណ្តាញជាតិ ពីភ្នំពេញ ទៅខេត្តបាត់ដំបង ធ្វើឲ្យប្រព័ន្ធបញ្ជូននៃខេត្តទាំង ៣ នេះ ។ បច្ចុប្បន្ននេះបានក្លាយទៅជាផ្នែកមួយនៃបណ្តាញជាតិដែលមានប្រភពផ្គត់ផ្គង់ចំនួន ២ គឺការនាំចូលពីប្រទេសថៃ និងប្រភពអគ្គិសនីរបស់បណ្តាញជាតិរបស់កម្ពុជាដែលក្នុងនោះ មានប្រភពមកពីវារីអគ្គិសនី និងរោងចក្រធ្យូងថ្ម ដែលរាជរដ្ឋាភិបាលបានធ្វើការអភិវឌ្ឍន៍ ។

ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅឲ្យតំបន់ចែកចាយនានា គឺធ្វើតាមបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ក្រៅពីនេះគឺមានតែការបញ្ជូនបន្តគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយជាបណ្តោះអាសន្ន ក្នុងពេលដែលអគ្គិសនីកម្ពុជាពុំទាន់ពង្រីកបណ្តាញបញ្ជូនរងទូទាំងខេត្តបាត់ដំបង បាន ។ ក្រៅពីការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅឲ្យតំបន់ចែកចាយនានា និងតំបន់ចែកចាយនានានៅជិតព្រំដែនប្រទេសថៃ ក៏មានការនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល ដើម្បីយកមកផ្គត់ផ្គង់ផងដែរ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តបាត់ដំបង មានក្រុង ១ ឈ្មោះក្រុងបាត់ដំបង និងស្រុកចំនួន ១៣ គឺ ៖ ១.ស្រុកកំរៀង ២.ស្រុកភ្នំព្រឹក ៣.ស្រុកសំពៅលូន ៤.ស្រុកថ្មគោល ៥.ស្រុកបាណន់ ៦.ស្រុកមោងឫស្សី ៧.ស្រុកឯកភ្នំ ៨.ស្រុកបវេល ៩.ស្រុកគាស់ក្រឡ ១០.ស្រុករុក្ខគិរី ១១.ស្រុករតនមណ្ឌល ១២.ស្រុកសង្កែ និង១៣.ស្រុកសំឡូត ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តបាត់ដំបង ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយ **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង **ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ចែកជា ៤ ប្រភេទគឺ ៖ ១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងបាត់ដំបង ទី២.តំបន់ចែកចាយរបស់សេវាករឯកជនមួយចំនួន ដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង ទី៣.តំបន់ចែកចាយរបស់ឯកជនមួយចំនួន ដែលបញ្ជូនប្រភពអគ្គិសនីបន្តគ្នា និងទី៤.តំបន់ចែកចាយរបស់ឯកជនមួយចំនួនដែលនាំចូលអគ្គិសនីពីប្រទេសថៃ ។ បច្ចុប្បន្ននៅខេត្តបាត់ដំបង មានតំបន់ផ្គត់ផ្គង់អគ្គិសនីចំនួន ៣១ តំបន់ ដែលក្នុងនោះ

មាន ៖ ១ តំបន់ គឺជារបស់អគ្គិសនីកម្ពុជា និង ៣០ តំបន់ទៀត ជាតំបន់ផ្គត់ផ្គង់របស់សេវាករចែកចាយអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់សេវាករឯកជនទាំង ៣០ តំបន់ មាន ១ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីប្រទេសថៃ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល (នៅទីរួមស្រុកកំរៀង ទីរួមស្រុកភ្នំព្រឹក និងនៅទីរួមស្រុកសំពៅលូន), ១ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយបណ្តាញជាតិនៅស្រុកថ្មគោល, ២៦ តំបន់ គឺជាតំបន់ដែលទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង ២ តំបន់ទៀត គឺជាតំបន់ដែលទិញបន្តគ្នាក្នុងលក្ខណៈបណ្តោះអាសន្ន រង់ចាំទិញផ្ទាល់ពីខ្សែបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តបាត់ដំបង

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (បាត់ដំបង) | 001 L | GS | បាត់ដំបង |
| 2 | សេវាករ តិច យាត្រា | 270 L | GS | ស្រុកថ្មគោល |
| 3 | ក្រុមហ៊ុន ហ្វ្រាណាស៊ី អាហ័រណេ នីហរ័ណៃ | 008 L | Thai | ស្រុកកំរៀង |
| 4 | សេវាករ សោម វិសាល | 043 L | GS-EDC | ស្រុកថ្មគោល |
| 5 | សេវាករ ទូច មន្ថា | 068 L | GS-EDC | ស្រុកបាណន់ |
| 6 | សេវាករ ណុប ប៊ិន | 069 L | GS-EDC | ស្រុករតនមណ្ឌល |
| 7 | សេវាករ យ៉ា សម្បត្តិ | 072 L | GS-EDC | ស្រុកមោងឫស្សី |
| 8 | សេវាករ ធន់ ធឿន | 079 L | GS-EDC | ស្រុកថ្មគោល |
| 9 | សេវាករ ស៊ុន ពៅ | 091 L | GS-EDC | ស្រុកឯកភ្នំ |
| 10 | សហគ្រាស មោងឫស្សី ឌីវេឡុបមេន | 109 L | GS-EDC | ស្រុកមោងឫស្សី |
| 11 | សេវាករ ស៊ា កិច | 110 L | GS-EDC | ស្រុកមោងឫស្សី |
| 12 | សេវាករ ឌុង លី | 117 L | GS-EDC | ស្រុកបាណន់ |
| 13 | ក្រុមហ៊ុន អ៊ីនជី វឌ្ឍនៈ អង្គរ | 164 L | GS-EDC | ស្រុកឯកភ្នំ |
| 14 | សេវាករ អ៊ូ ចាន់រត្ន័ | 201 L | GS-EDC | ស្រុកថ្មគោល |
| 15 | សេវាករ គង់ សាម៉ុន | 202 L | GS-EDC | ស្រុកថ្មគោល |
| 16 | សេវាករ សាន់ ឆាន់ | 242 L | GS-EDC | ស្រុកបវេល |
| 17 | ក្រុមហ៊ុន ខេ.អ.រ៉ាយ ត្រេឌីង | 244 L | GS-EDC | ស្រុកបាណន់ |
| 18 | សេវាករ សំណាង សត្យា | 246 L | GS-EDC | ស្រុកសង្កែ |
| 19 | សេវាករ អ៊ុច សុផល្លា | 251 L | GS-EDC | ស្រុកបាណន់ |
| 20 | សេវាករ ទិន សាវេត | 262 L | GS-EDC | ស្រុកសង្កែ |
| 21 | សេវាករ កុយ ម៉ាច | 275 L | GS-EDC | ស្រុកបាណន់ |
| 22 | សេវាករ សែម វុទ្ធី | 302 L | GS-EDC | ស្រុកគាស់ក្រឡ |
| 23 | សេវាករ លិម វណ្ណា | 303 L | GS-EDC | ស្រុកមោងឫស្សី |
| 24 | សេវាករ ង៉ូវ លីហួ | 309 L | GS-EDC | ស្រុករតនមណ្ឌល |
| 25 | សេវាករ ខៀវ សុខា | 324 L | GS-EDC | ស្រុកបវេល |
| 26 | ក្រុមហ៊ុន អេ អេស ឌី វី អិម ខូអិលធីឌី | 392 L | GS-EDC | ស្រុកសំឡូត |
| 27 | សេវាករ ឡាញ សុវណ្ណ | 330 L | GS-EDC-KRY Trading | ស្រុកបាណន់ |
| 28 | សេវាករ ឃុន សារុន | 182 L | GS-EDC | ស្រុកបវេល |
| 29 | សេវាករ ស្រី អូន | 283 L | GS-EDC | ស្រុកបវេល |
| 30 | សេវាករ សឿន សុភ័ណ្ឌណារ៉ា | 282 L | GS-EDC | ស្រុកបវេល |
| 31 | សេវាករ ស៊ីន សុភៈនា | 403 L | Thai-Franasia | ស្រុកសំពៅលូន |

# ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តបាត់ដំបង




# ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តបាត់ដំបង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បាណន់ | 76 | 74 | 97.37% | 66 | 86.84% | 8 |
| ថ្មគោល | 70 | 49 | 70.00% | 63 | 90.00% | -14 |
| បាត់ដំបង | 62 | 62 | 100.00% | 60 | 96.77% | 2 |
| បវេល | 100 | 74 | 74.00% | 56 | 56.00% | 18 |
| ឯកភ្នំ | 45 | 37 | 82.22% | 35 | 77.78% | 2 |
| មោងឫស្សី | 92 | 80 | 86.96% | 83 | 90.22% | -3 |
| រតនមណ្ឌល | 38 | 32 | 84.21% | 26 | 68.42% | 6 |
| សង្កែ | 64 | 64 | 100.00% | 61 | 95.31% | 3 |
| សំឡូត | 49 | 49 | 100.00% | - | - | 49 |
| សំពៅលូន | 35 | 25 | 71.43% | 29 | 82.86% | -4 |
| ភ្នំព្រឹក | 38 | 38 | 100.00% | 33 | 86.84% | 5 |
| កំរៀង | 48 | 37 | 77.08% | 34 | 70.83% | 3 |
| គាស់ក្រឡ | 51 | 44 | 86.27% | 32 | 62.75% | 12 |
| រុក្ខគិរី | 31 | 27 | 87.10% | 19 | 61.29% | 8 |
| **សរុប** | **799** | **692** | **86.61%** | **597** | **74.72%** | **95** |

## ២.ផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តបាត់ដំបង

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តបាត់ដំបង អាចបែងចែកជាផែនការដោយឡែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៦ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងបាត់ដំបង ៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលយកអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង ៥.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់របស់សេវាករចែកចាយអគ្គិសនីឯកជនដែលទិញបន្តពីគេក្នុងលក្ខណៈបណ្តោះអាសន្ន និង៦.ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់របស់សេវាករចែកចាយអគ្គិសនីឯកជន ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តបាត់ដំបង ត្រូវបានបែងចែកលម្អិតជាផែនការ ទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៦ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

### ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងបាត់ដំបង

នៅឆ្នាំ ២០១៥ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីនៅក្រុងបាត់ដំបង ថ្លៃអគ្គិសនីមិនបានបែងចែកឲ្យខុសគ្នារវាងអតិថិជនទេ គឺបានបែងចែកទៅតាមប្រភេទធំ មធ្យម តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ១,000 ៛ / kWh | អតិថិជនធុនធំ | ៨៥0 ៛ / kWh |
| អតិថិជនធុនមធ្យម | ៩00 ៛ / kWh | អតិថិជនតង់ស្យុងមធ្យម | ៧៥0 ៛ / kWh |

យោងតាម "ផែនការយុទ្ធសាស្រ្តបន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនី" ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃខាងលើនេះ នឹងត្រូវថយចុះតាមផែនការ ដូចខាងក្រោម ៖

<u>**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែមេ EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

សម្រាប់លំនៅដ្ឋានទូទៅ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

នៅក្នុងដែននៃតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងបាត់ដំបង នេះ មានតំបន់កោះមួយឈ្មោះកោះជីវាំង ក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលក្នុងនោះ មានរូបវន្តបុគ្គលម្នាក់កំពុងធ្វើការផ្គត់ផ្គង់អគ្គិសនីដោយប្រើម៉ាស៊ីនដៀសែល និងគ្មានអាជ្ញាប័ណ្ណធ្វើសេវាកម្មស្របច្បាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ដោយតំបន់នេះឋិតនៅក្នុងដែននៃតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដូច្នេះអគ្គិសនីកម្ពុជា ត្រូវរៀបចំពង្រីកបណ្តាញចែកចាយផ្គត់ផ្គង់ឲ្យកោះជីវាំង នេះ ឲ្យបានឆាប់តាមលទ្ធភាពដែលអាចធ្វើទៅបាន ។

## ២.៤ តំបន់របស់សេវាករឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិ

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករចែកចាយអគ្គិសនីឯកជនទាំង ២៩ តំបន់ មានតំបន់ចែកចាយចំនួន ២៨ តំបន់ បានយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិ (១ តំបន់យកប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ និង ២៧ តំបន់យកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរង)។ បច្ចុប្បន្នថ្លៃអគ្គិសនីរបស់សេវាករឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ និងបណ្តាញបញ្ជូនរងមានថ្លៃលក់រាយ ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ទាំង ២៨ នេះ នឹងត្រូវអនុវត្តតាមផែនការបន្ថយថ្លៃរួមនៃតំបន់ដែលទទួលប្រភពអគ្គិសនីបណ្តាញជាតិ ដូចខាងក្រោម ៖

សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយដែលនាំចូលអគ្គិសនីពីប្រទេសថៃ

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនចំនួន ២៩ តំបន់ មានតំបន់ចែកចាយ ១ តំបន់ របស់ក្រុមហ៊ុន ហ្វ្រាណាស៊ី អាហារ័ណៃ នីហារ័ណៃ នៅស្រុកកំរៀង ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន គឺជាតំបន់ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ ។ ចំពោះតំបន់នេះ អគ្គិសនីកម្ពុជាមានផែនការជម្រុញការវិនិយោគរបស់ខ្លួនដើម្បីពង្រីកបណ្តាញបញ្ជូនរងទៅគ្របដណ្តប់តំបន់នេះផងដែរ ដើម្បីឲ្យតំបន់នេះ អាចមានប្រភពអគ្គិសនី ២ គឺ ទី១.នាំចូលពីប្រទេសថៃ និងទី២.ប្រភពអគ្គិសនីពីបណ្តាញជាតិ រួចរៀបចំផែនការឲ្យតំបន់នេះមានថ្លៃអគ្គិសនីតាមផែនការរួមទូទាំងប្រទេស ។ ដូច្នេះក្នុងរយៈពេលបណ្តោះអាសន្ន ដែលបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាពុំទាន់ពង្រីកទៅដល់ តំបន់ដែលនាំចូលអគ្គិសនីពីប្រទេសថៃនេះ ត្រូវអនុវត្តតាមថ្លៃដែលកំណត់បច្ចុប្បន្នជាបណ្តោះអាសន្នមួយរយៈពេលសិន រង់ចាំរហូតដល់ពេលបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ពង្រីកទៅដល់អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា នឹងពិភាក្សាគ្នាអំពីផែនការបន្ថយថ្លៃអគ្គិសនីនៅតំបន់នេះ ឲ្យដូចតំបន់របស់សេវាករឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងខាងលើដែរ ។ គ្រោងកំណត់ឲ្យអនុវត្តឲ្យបាននៅឆ្នាំ ២០១៧ ខាងមុខ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តបន្ទាយមានជ័យ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តបន្ទាយមានជ័យ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ចាប់ពីឆ្នាំ ២០០៩ មក ខេត្តបន្ទាយមានជ័យ ត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធបណ្តាញបញ្ជូនដោយខ្សែកដែលភ្ជាប់ខេត្តចំនួន ៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ជាមួយនឹងការនាំចូលអគ្គិសនីពីប្រទេសថៃ តាមរយៈបណ្តាញបញ្ជូន ១១៥ គីឡូវ៉ុល ។ ប្រព័ន្ធបណ្តាញបញ្ជូនដោយខ្សែកនេះ មានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តបន្ទាយមានជ័យ គឺនៅក្នុងក្រុងសិរីសោភ័ណ ។ ដោយថ្លៃអគ្គិសនីនាំចូលពីប្រទេសថៃ ឡើងថ្លៃជារៀងរាល់ឆ្នាំ អគ្គិសនីកម្ពុជាបានសម្រេចពង្រីកបណ្តាញជាតិភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនខេត្តទាំង ៣ នេះ ដោយសាងសង់អនុស្ថានីយភ្ជាប់ជាមួយបណ្តាញជាតិពីភ្នំពេញ ធ្វើឲ្យប្រព័ន្ធបញ្ជូននៃខេត្តទាំង ៣ នេះ បច្ចុប្បន្នបានក្លាយទៅជាផ្នែកមួយនៃបណ្តាញជាតិ ដែលមានប្រភពផ្គត់ផ្គង់ចំនួន ២ គឺការនាំចូលពីប្រទេសថៃ និងប្រភពអគ្គិសនីរបស់បណ្តាញជាតិរបស់កម្ពុជា ដែលក្នុងនោះ មានប្រភពមកពីវារីអគ្គិសនី និងរោងចក្រធ្យូងថ្ម ដែលរាជរដ្ឋាភិបាលបានធ្វើការអភិវឌ្ឍន៍ ។

ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅឲ្យតំបន់ចែកចាយនានា នៅក្នុងខេត្តបន្ទាយមានជ័យ គឺធ្វើតាមបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ក្រៅពីនេះ គឺមានតែការនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមបណ្តាញ ២២ គីឡូវ៉ុល ដើម្បីយកមកផ្គត់ផ្គង់ឲ្យតំបន់ក្បែរព្រំដែនប៉ុណ្ណោះ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

ខេត្តបន្ទាយមានជ័យ មានក្រុង ១ ឈ្មោះក្រុងសិរីសោភ័ណ និងស្រុកចំនួន ៧ គឺ៖ ១.ស្រុកមង្គលបូរី, ២.ស្រុកព្រះនេត្រព្រះ, ៣.ស្រុកភ្នំស្រុក, ៤.ស្រុកស្វាយចេក, ៥.ស្រុកថ្មពួក, ៦.ស្រុកអូរជ្រៅ, និង៧.ស្រុកម៉ាឡៃ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តបន្ទាយមានជ័យ ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយ **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ចែកជា ៣ ប្រភេទគឺ ៖ ១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសិរីសោភ័ណ ទី២.តំបន់ចែកចាយរបស់ឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.តំបន់ចែកចាយរបស់ឯកជនដែលនាំចូលអគ្គិសនីពីប្រទេសថៃ ។ បច្ចុប្បន្ននៅខេត្តបន្ទាយមានជ័យ មានតំបន់ចែកចាយអគ្គិសនីចំនួន ២៣ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ជារបស់អគ្គិសនីកម្ពុជានៅក្រុងសិរីសោភ័ណ និង ២២ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករឯកជននៅតាមតំបន់នានា ។ ក្នុងចំណោមតំបន់ចែកចាយរបស់ឯកជនទាំង ២២ តំបន់ មាន ២ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីប្រទេសថៃ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល គឺតំបន់ស្រុកម៉ាឡៃ

និងតំបន់ក្រុងប៉ោយប៉ែត និង ២០ តំបន់ទៀត គឺជាតំបន់ទិញប្រកពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។ តំបន់ចែកចាយទាំង ២៣ តំបន់នៅក្នុងខេត្តបន្ទាយមានជ័យ មានដែនអាជ្ញាប័ណ្ណគ្របដណ្តប់លើភូមិចំនួន ៦២២ ភូមិ លើចំនួនភូមិសរុប ៦៦១ ភូមិ ដែលមានក្នុងខេត្តបន្ទាយមានជ័យ ត្រូវជា ៩៤.១០% នៃភូមិទាំងអស់ ។ បច្ចុប្បន្នអ្នកផ្គត់ផ្គង់ទាំង ២៣ តំបន់នេះ បានសាងសង់ខ្សែបណ្តាញរួចចំនួន ៤៣៩ ភូមិ ត្រូវជា ៦៦.៤២% នៃចំនួនភូមិទាំងអស់ ។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តបន្ទាយមានជ័យ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (បន្ទាយមានជ័យ) | 001 L | GS | ក្រុងសេរីសោភ័ណ |
| 2 | ក្រុមហ៊ុន អានកូ អាហារ័ណ នីហារ័ណ (ប៉ោយប៉ែត) | 011 L | Thai | ក្រុងប៉ោយប៉ែត |
| 3 | ក្រុមហ៊ុន ស៊ីន ឃីម អ៊ីមផត អ៊ិចផត | 149 L | Thai | ស្រុកម៉ាឡៃ |
| 4 | សេវាករ ចៅ នុយ | 077 L | GS-EDC | ស្រុកមង្គលបូរី |
| 5 | សេវាករ ប៉ាក់ ស៊ុនហេង | 078 L | GS-EDC | ស្រុកអូរជ្រៅ |
| 6 | សេវាករ ធន់ ធឿន | 079 L | GS-EDC | ស្រុកមង្គលបូរី |
| 7 | សេវាករ សុខ រិទិត | 080 L | GS-EDC | ស្រុកមង្គលបូរី |
| 8 | សេវាករ សឿង សុវណ្ណា | 105 L | GS-EDC | ស្រុកមង្គលបូរី |
| 9 | សេវាករ ស៊ីន សារ៉ួន | 108 L | GS-EDC | ស្រុកព្រះនេត្រព្រះ |
| 10 | សេវាករ ញឹម យ៉ាន | 257 L | GS-EDC | ស្រុកអូរជ្រៅ |
| 11 | សេវាករ ជុន រិទ្ធី | 276 L | GS-EDC | ស្រុកអូរជ្រៅ |
| 12 | សេវាករ កែវ តារាវង្ស | 323 L | GS-EDC | ស្រុកព្រះនេត្រព្រះ |
| 13 | សេវាករ ខៀវ សុខា | 324 L | GS-EDC | ស្រុកមង្គលបូរី |
| 14 | ក្រុមហ៊ុន ភូមិនិមិត្ត | 189 L | GS-EDC | ស្រុកថ្មពួក |
| 15 | សេវាករ ទេព មករា | 351 L | GS-EDC | ស្រុកព្រះនេត្រព្រះ |
| 16 | សេវាករ មក់ វ៉ាន់ | 190 L | GS-EDC | ស្រុកស្វាយចេក |
| 17 | ក្រុមហ៊ុន អ៊ីនជី វឌ្ឍនៈ អង្គរ | 164 L | GS-EDC | ស្រុកព្រះនេត្រព្រះ |
| 18 | សេវាករ មួន ហាន | 081 L | GS-EDC | ស្រុកភ្នំស្រុក |
| 19 | សេវាករ ដួង សំបិន | 289 L | GS-EDC | ស្រុកភ្នំស្រុក |
| 20 | សេវាករ អ៊ុន ពៅ | 337 L | GS-EDC | ស្រុកស្វាយចេក |
| 21 | សេវាករ កែវ ធារី | 379 L | GS-EDC | ស្រុកថ្មពួក |
| 22 | សេវាករ ប៉ោ បណ្តែត | 401 L | GS-EDC | ស្រុកភ្នំស្រុក |
| 23 | សេវាករ ម៉ែន ចាន់សុកុល | 389 L | GS-EDC | ស្រុកស្វាយចេក |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តបន្ទាយមានជ័យ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| មង្គលបូរី | 160 | 151 | 94.38% | 142 | 88.75% | 9 |
| ភ្នំស្រុក | 64 | 54 | 84.38% | 27 | 42.19% | 27 |
| ព្រះនេត្រព្រះ | 118 | 118 | 100.00% | 78 | 66.10% | 40 |
| អូរជ្រៅ | 56 | 55 | 98.21% | 54 | 96.43% | 1 |

| | | | | | | |
|---|---|---|---|---|---|---|
| សិរីសោភ័ណ | 42 | 42 | 100.00% | 25 | 59.52% | 17 |
| ថ្មពួក | 65 | 65 | 100.00% | 22 | 33.85% | 43 |
| ស្វាយចេក | 73 | 66 | 90.41% | 43 | 58.90% | 23 |
| ម៉ាឡៃ | 45 | 36 | 80.00% | 30 | 66.67% | 6 |
| ប៉ោយប៉ែត | 38 | 35 | 92.11% | 27 | 71.05% | 8 |
| **សរុប** | **661** | **622** | **94.10%** | **448** | **67.78%** | **174** |

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តបន្ទាយមានជ័យ




## ២.ផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តបន្ទាយមានជ័យ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តបន្ទាយមានជ័យ អាចបែងចែកជាផែនការដោយឡែក ទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៥ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសិរីសោភ័ណ ៤.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជនដែលយកអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង និង៥.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករចែកចាយអគ្គិសនីឯកជន ដែលនាំចូលអគ្គិសនីពីប្រទេសថៃ ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តបន្ទាយមានជ័យ ត្រូវបានបែងចែកលម្អិតទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៥ ដូចខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសិរីសោភ័ណ

នៅឆ្នាំ ២០១៥ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងសិរីសោភ័ណ ថ្លៃអគ្គិសនីមិនបានបែងចែកឲ្យខុសគ្នា រវាងអតិថិជនទេ គឺបានបែងចែកទៅតាមប្រភេទធំ មធ្យម តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ១,០០០ ៛ / kWh | អតិថិជនធុនធំ | ៨៥០ ៛ / kWh |
| អតិថិជនធុនមធ្យម | ៩០០ ៛ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៧០ $ / kWh |

យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយ អត្រានិងគម្លាតថ្លៃលក់អគ្គិសនី" ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃខាងលើនេះ នឹងត្រូវថយចុះតាមផែនការ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែមេ EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយសេវាករឯកជនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរេខ

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ២២ តំបន់ មាន ២០ តំបន់ គឺជាតំបន់ដែលបានយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរេខរបស់អគ្គិសនីកម្ពុជា ។ តំបន់ចែកចាយរបស់សេវាករឯកជនទាំង ២០ តំបន់ ដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរេខរបស់អគ្គិសនីកម្ពុជានេះ បច្ចុប្បន្នមានស្ថានភាពថ្លៃដូចតទៅ៖ ១៥ តំបន់ (ភ្ជាប់យូរហើយ) មានថ្លៃលក់ ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និង ៥ តំបន់កំពុងតែអនុវត្តតាមកម្មវិធីបន្ថយថ្លៃបន្តិចម្តង ដែលបច្ចុប្បន្នបានចុះដល់ ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ក្នុងនោះមាន ២ តំបន់នៅស្រុកស្វាយចេក និង ៣ តំបន់ នៅស្រុកភ្នំស្រុក គឺអនុញ្ញាតឲ្យបន្តការអនុវត្តថ្លៃតាមកម្មវិធីបន្ថយថ្លៃបន្តិចម្តង រហូតដល់ចប់កម្មវិធី ។ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ទាំង ២០ ខាងលើនេះ នឹងត្រូវអនុវត្តការបន្ថយថ្លៃ តាមផែនការរួមរបស់រាជរដ្ឋាភិបាលសម្រាប់តំបន់ដែលទទួលប្រភពអគ្គិសនីបណ្តាញជាតិ ដូចខាងក្រោម ៖

**សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម10kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយដែលនាំចូលអគ្គិសនីពីប្រទេសថៃ

ចំពោះតំបន់ចែកចាយ ២ តំបន់ នៅខេត្តបន្ទាយមានជ័យ ដែលកំពុងនាំចូលអគ្គិសនីពីប្រទេសថៃ គឺតំបន់ទី ១ នៅស្រុកម៉ាឡៃ ដែលវិនិយោគខ្សែបណ្តាញដោយក្រុមហ៊ុន ស៊ីន ឃីម អ៊ីមផត អ៊ិចផត និងតំបន់ទី ២ នៅក្រុងប៉ោយប៉ែត ដែលវិនិយោគខ្សែបណ្តាញដោយក្រុមហ៊ុន អានកូ អាហរ័ណ នីហរ័ណ (ប៉ោយប៉ែត) ស្ថានភាពនៃថ្លៃលក់អគ្គិសនីបច្ចុប្បន្ន មានដូចខាងក្រោម ៖

**នៅស្រុកម៉ាឡៃ**

- ថ្លៃទិញរាយពីខ្សែបណ្តាញតង់ស្យុងទាប គឺ ៨.៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអាចបង់ជាប្រាក់រៀល តាមអត្រាប្តូរប្រាក់

- ថ្លៃទិញដុំពីខ្សែបណ្ដាញតង់ស្យុងមធ្យម គឺ ៦.៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអាចបង់ជាប្រាក់រៀល តាមអត្រាប្ដូរប្រាក់

**<u>នៅក្រុងប៉ោយប៉ែត</u>**

- ថ្លៃទិញរាយពីខ្សែបណ្ដាញតង់ស្យុងទាប គឺ ៦.០ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអាចបង់ជាប្រាក់រៀល តាមអត្រាប្ដូរប្រាក់
- ថ្លៃទិញដុំពីខ្សែបណ្ដាញតង់ស្យុងមធ្យម គឺ ៥.០ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអាចបង់ជាប្រាក់រៀល តាមអត្រាប្ដូរប្រាក់

**<u>កំណត់សំគាល់</u>**៖ ថ្លៃអគ្គិសនីនៅស្រុកម៉ាឡៃ មានអត្រាខ្ពស់ជាងនៅក្រុងប៉ោយប៉ែត ដោយសារតែទីផ្សារលក់អគ្គិសនីនៅក្រុងប៉ោយប៉ែត ធំជាង មានអតិថិជនធំៗ ច្រើនជាង និងមានដង់ស៊ីតេទិញលើបណ្ដាញខ្ពស់ជាងនៅស្រុកម៉ាឡៃ ច្រើនដង ។

នៅតំបន់ចែកចាយទាំង ២ នេះ រាជរដ្ឋាភិបាលមានផែនការឲ្យអគ្គិសនីកម្ពុជា ជម្រុញការវិនិយោគពង្រីកបណ្ដាញបញ្ជូនរងទៅគ្របដណ្ដប់តំបន់ទាំង ២ នេះផងដែរ ដើម្បីឲ្យតំបន់ទាំង ២ នេះ អាចមានប្រភពអគ្គិសនី ២ គឺទី១.នាំចូលពីប្រទេសថៃ និងទី២.ប្រភពអគ្គិសនីពីបណ្ដាញជាតិ រួចរៀបចំផែនការឲ្យតំបន់ទាំង ២ នេះ មានថ្លៃអគ្គិសនីតាមផែនការរួមទូទាំងប្រទេស ។ ដូច្នេះ ក្នុងរយៈពេលបណ្ដោះអាសន្នដែលបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាពុំទាន់ពង្រីកទៅដល់ តំបន់ដែលនាំចូលអគ្គិសនីពីប្រទេសថៃ ទាំង ២ នេះ ត្រូវអនុវត្តតាមថ្លៃដែលកំណត់បច្ចុប្បន្នខាងលើនេះ ជាបណ្ដោះអាសន្នមួយរយៈសិន រង់ចាំរហូតដល់ពេលដែលបណ្ដាញបញ្ជូនរង របស់អគ្គិសនីកម្ពុជាពង្រីកទៅដល់ អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា នឹងពិភាក្សាគ្នាអំពីផែនការបន្ថយថ្លៃអគ្គិសនីនៅតំបន់នេះ ឲ្យដូចតំបន់របស់សេវាករឯកជន ដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្ដាញបញ្ជូនរងដ៏ទៃទៀត នៅក្នុងខេត្តបន្ទាយមានជ័យ ដូចក្នុងចំណុចខាងលើ ។ គម្រោងនេះ គ្រោងអនុវត្តឲ្យបាននៅឆ្នាំ ២០១៧ ខាងមុខ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តសៀមរាប សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តសៀមរាប

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ចាប់ពីឆ្នាំ ២០០៩ មក ខេត្តសៀមរាប ត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធបណ្តាញបញ្ជូនដោយឡែក ដែលភ្ជាប់ខេត្តចំនួន ៣ គឺខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប ជាមួយនឹងការនាំចូលអគ្គិសនីពីប្រទេសថៃ តាមរយៈបណ្តាញបញ្ជូន ១១៥ គីឡូវ៉ុល ។ ប្រព័ន្ធបណ្តាញបញ្ជូនដោយឡែកនេះ មានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តសៀមរាប គឺនៅក្នុងស្រុកពួក ជិតក្រុងសៀមរាប។ ដោយថ្លៃអគ្គិសនីនាំចូលពីប្រទេសថៃ ឡើងថ្លៃជារៀងរាល់ឆ្នាំ អគ្គិសនីកម្ពុជាបានសម្រេចបង្កើតជម្រើស ១ ទៀត គឺពង្រីកបណ្តាញជាតិភ្ជាប់ជាមួយប្រព័ន្ធបញ្ជូនខេត្តទាំង ៣ នេះ ធ្វើឲ្យប្រព័ន្ធបញ្ជូននៃខេត្តទាំង ៣ បច្ចុប្បន្នបានក្លាយទៅជាផ្នែកមួយនៃបណ្តាញជាតិ ដែលមានប្រភពចំនួន ២ គឺការនាំចូលពីប្រទេសថៃ និងប្រភពអគ្គិសនីរបស់បណ្តាញជាតិរបស់កម្ពុជា ដែលក្នុងនោះមានវារីអគ្គិសនី និងរោងចក្រធ្យូងថ្ម ដែលរាជរដ្ឋាភិបាលបានធ្វើការអភិវឌ្ឍន៍ ។ ដោយឡែកចំពោះខេត្តសៀមរាប បច្ចុប្បន្នដោយសេចក្តីត្រូវការរបស់ក្រុងសៀមរាប បានកើនឡើងជិតហួសសមត្ថភាពនៃអានុភាពរបស់ត្រង់ស្វូនៃអនុស្ថានីយនៅស្រុកពួកហើយ ដូច្នេះរាជរដ្ឋាភិបាលបានជម្រុញឲ្យសាងសង់អនុស្ថានីយផ្តល់ប្រភពអគ្គិសនីរបស់បណ្តាញជាតិមួយទៀតនៅស្រុកប្រាសាទបាគង ដើម្បីផ្តល់អានុភាពពីបណ្តាញជាតិបន្ថែមឲ្យក្រុងសៀមរាបផងនិងសម្រួលដល់ការពង្រីកវិសាលភាពបញ្ជូនអគ្គិសនីចេញពីបណ្តាញជាតិផង ។

ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅឲ្យតំបន់ចែកចាយនានា គឺធ្វើតាមបណ្តាញបញ្ជូនរងដែលបច្ចុប្បន្នមានបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ២ គឺ ៖ ១.បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង២.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ក្រៅពីនេះ គឺមានតែការបញ្ជូនបន្តគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ក្នុងលក្ខណៈបណ្តោះអាសន្នក្នុងពេលដែលអគ្គិសនីកម្ពុជា ពុំទាន់អាចពង្រីកបណ្តាញបញ្ជូនរងទូទាំងខេត្តសៀមរាប បាន។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តសៀមរាប មានក្រុង ១ ឈ្មោះក្រុងសៀមរាប និងស្រុកចំនួន ១១ គឺ ៖ ១.ស្រុកអង្គរជុំ ២.ស្រុកអង្គរធំ ៣.ស្រុកបន្ទាយស្រី ៤.ស្រុកជីក្រែង ៥.ស្រុកក្រឡាញ់ ៦.ស្រុកពួក ៧.ស្រុកស្រីស្នំ ៨.ស្រុកសូត្រនិគម ៩.ស្រុកប្រាសាទបាគង ១០.ស្រុកស្វាយលើ និង១១.ស្រុកវ៉ារិន ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តសៀមរាប ត្រូវបានដោះស្រាយដោយ **ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយដែលមាននៅក្នុងខេត្តសៀមរាប **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងនានា និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយ តាមតំបន់ចែកចាយនីមួយៗ នៅខេត្តសៀមរាប ចែកជា ៤ ប្រភេទគឺ ៖ ១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសៀមរាប ទី២.តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនមួយចំនួនដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង, ទី៣.តំបន់ចែកចាយ

របស់សេវាករអគ្គិសនីឯកជនមួយចំនួនដែលទិញប្រភពអគ្គិសនីដោយការបញ្ជូនបន្តគ្នា និងទី៤.តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនមួយចំនួន ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដៀសែល ។ បច្ចុប្បន្ននៅខេត្តសៀមរាប មានតំបន់ផ្គត់ផ្គង់អគ្គិសនីចំនួន ២០ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និង ១៩ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ១៩ តំបន់ មាន ១៦ តំបន់ជាតំបន់ដែលត្រូវបានចាត់ទុកថាជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិដែលក្នុងនោះមាន ៖ ៤ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ១ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ១ តំបន់ទៀតទិញបន្តមួយជាន់ទៀត ពីតំបន់ដែលទិញបន្តមុននេះ, ៩ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល, ១ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ។ ក្រៅពីពីនោះ នៅមានតំបន់ចែកចាយ ៣ តំបន់ទៀត ដែលជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ ។

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តសៀមរាប



## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តសៀមរាប

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា | 001 L | GS | ក្រុងសៀមរាប |
| 2 | ក្រុមហ៊ុន វន វីរៈ សីវីស | 035 L | GS-EDC | ស្រុកពួក |
| 3 | ក្រុមហ៊ុន ខេជីស៊ី ខេបល | 348 L | GS-EDC | បញ្ជូនវេង |
| 4 | ក្រុមហ៊ុន អ៊ីនជី វ៉ឺឡេនៈ អង្គរ | 164 L | GS-EDC | ស្រុកក្រឡាញ់ |
| 5 | សេវាករ ហេង ស៊ីមុយ | 311 L | GS-EDC | ស្រុកស្រីស្នំ |
| 6 | សេវាករ គង់ វុន | 111 L | GS-EDC-KTC | ស្រុកជីក្រែង |
| 7 | សេវាករ ចាន់ សុខ | 129 L | GS-EDC-KTC | ស្រុកជីក្រែង |
| 8 | សេវាករ ឆោម សុផៃ | 048 L | GS-EDC-KTC | ស្រុកសូត្រនិគម |
| 9 | សេវាករ ប្លោក វណ្ណៈ | 185 L | GS-EDC-KTC | ស្រុកប្រាសាទបាគង |
| 10 | សេវាករ មាស គាវ | 183 L | GS-EDC-KTC | ស្រុកសូត្រនិគម |
| 11 | សេវាករ យឹម រិទ្ធី | 083 L | GS-EDC-KTC | ស្រុកសូត្រនិគម |
| 12 | សេវាករ លី កង | 112 L | GS-EDC-KTC | ស្រុកជីក្រែង |
| 13 | សេវាករ អ៊ិង តាំងទ្បេ | 161 L | GS-EDC-KTC | ស្រុកជីក្រែង |
| 14 | សេវាករ តាន់ កង | 203 L | GS-EDC-KTC | ស្រុកប្រាសាទបាគង |
| 15 | សេវាករ ហូវ សាវី | 127 L | GS-EDC-KTC-CSP | ស្រុកជីក្រែង |
| 16 | សេវាករ អ៊ឹង ប៊ុនធី | 287 L | GS-VUNVIREAK | ស្រុកពួក |
| 17 | សេវាករ ដួង ណារិន | 139 L | GS-VUNVIREAK-BUNTHY | ស្រុកអង្គរជុំ |
| 18 | សេវាករ ឃានកែវ | 229 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកស្វាយលើ |
| 19 | សេវាករ ហ៊ូ ប៊ុនធី | 359 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកវ៉ារិន |
| 20 | សេវាករ ឡុង គឹមហេង | 240 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកវ៉ារិន |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តសៀមរាប

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| អង្គរជុំ | 84 | 52 | 61.90% | 29 | 34.52% | 23 |
| អង្គរធំ | 26 | 6 | 23.08% | 6 | 23.08% | - |
| បន្ទាយស្រី | 37 | 21 | 56.76% | 17 | 45.95% | 4 |
| ជីក្រែង | 154 | 129 | 83.77% | 83 | 53.90% | 46 |
| ក្រឡាញ់ | 99 | 86 | 86.87% | 21 | 21.21% | 65 |
| ពួក | 132 | 116 | 87.88% | 85 | 64.39% | 31 |
| ប្រាសាទបាគង | 58 | 47 | 81.03% | 36 | 62.07% | 11 |
| សៀមរាប | 108 | 108 | 100.00% | 84 | 77.78% | 24 |
| សូទ្រនិគម | 113 | 108 | 95.58% | 93 | 82.30% | 15 |
| ស្រីស្នំ | 46 | 44 | 95.65% | 8 | 17.39% | 36 |
| ស្វាយលើ | 34 | 14 | 41.18% | 6 | 17.65% | 8 |
| វ៉ារិន | 33 | 33 | 100.00% | 19 | 57.58% | 14 |
| **សរុប** | **924** | **764** | **82.68%** | **487** | **52.71%** | **277** |

## ២.ផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តសៀមរាប

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តសៀមរាប អាចបែងចែកជាផែនការដោយឡែកទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៦ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយ របស់អគ្គិសនីកម្ពុជានៅក្រុងសៀមរាប ៤.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយ របស់សេវាករឯកជនដែលយកអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៥.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជនដែលយកអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល និង៦.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករចែកចាយអគ្គិសនីឯកជន ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តសៀមរាប ត្រូវបានបែងចែកលម្អិតទៅតាមប្រភេទនៃការផ្គត់ផ្គង់ទាំង ៦ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

### ២.៣ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេធីស៊ី ខេបល

ចំពោះបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ដោយសារនៅតាមគន្លងរបស់បណ្តាញបញ្ជូនរងនេះ ពុំទាន់មានអ្នកប្រើប្រាស់ជាឧស្សាហកម្ម ពាណិជ្ជកម្មធំៗ គឺមានតែតំបន់ចែកចាយអគ្គិសនីរាយឲ្យប្រជាពលរដ្ឋ ដូច្នេះនៅឆ្នាំ ២០១៥ នេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់ថ្លៃសេវាបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ស្មើនឹង 0.024 $/kWh ដោយប្រភពអគ្គិសនីដែលត្រូវលក់ឲ្យតំបន់ចែកចាយអគ្គិសនីនីមួយៗ គឺត្រូវស្មើនឹងថ្លៃប្រភពអគ្គិសនីដែលទិញពីអគ្គិសនីកម្ពុជា បូកនឹងថ្លៃសេវាបញ្ជូនរងខាងលើ ។

ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ក្នុងករណីមានអ្នកប្រើប្រាស់អគ្គិសនីប្រភេទ MV នៅតាមគន្លងខ្សែបណ្តាញបញ្ជូនរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល អត្រាថ្លៃអគ្គិសនីដែលត្រូវលក់តាម MV ត្រូវបានកំណត់ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៤ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសៀមរាប

នៅឆ្នាំ ២០១៥ នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីនៅក្រុងសៀមរាប ថ្លៃអគ្គិសនីមិនបានបែងចែកឲ្យខុសគ្នារវាងប្រភេទអតិថិជនទេ គឺបានបែងចែកទៅតាមទំហំប្រើប្រាស់ធំ មធ្យម តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៨២០ ៛ / kWh | អតិថិជនធុនធំ | ៧៥០ ៛ / kWh |
| អតិថិជនធុនមធ្យម | ៨០០ ៛ / kWh | អតិថិជនតង់ស្យុងមធ្យម | ៧០០ ៛ / kWh |

យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ចាប់ពីខែមីនា ឆ្នាំ២០១៦ អត្រាថ្លៃអគ្គិសនីខាងលើនេះ នឹងត្រូវថយចុះតាមផែនការរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែមេ EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយឯកជនដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងអគ្គិសនីកម្ពុជា

ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់ឯកជនទាំង ១៩ តំបន់ មាន ១៦ តំបន់ជាតំបន់ដែលត្រូវបានចាត់ទុកថាជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ ដែលក្នុងនោះមាន ៥ តំបន់ គឺជាតំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។ ក្នុងចំណោមតំបន់ចែកចាយទាំង ៥ តំបន់ខាងលើនេះ មាន ៣ តំបន់ជាតំបន់ភ្ជាប់ផ្ទាល់ជាមួយបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា (ក្នុងនោះមាន ១ តំបន់ជាតំបន់ភ្ជាប់យូរមកហើយ និង ២ តំបន់ទៀត ជាតំបន់ទើបនឹងបានភ្ជាប់ថ្មីៗ នេះប៉ុណ្ណោះ) ។ ក្រៅពីនោះ មានតំបន់ចែកចាយ ១ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង ១ តំបន់ទៀត គឺជាតំបន់ដែលទិញបន្តមួយជាន់ទៀត ពីតំបន់ដែលទិញបន្តខាងដើម ។

ស្ថានភាពថ្លៃអគ្គិសនីលក់រាយបច្ចុប្បន្ន នៅក្នុងតំបន់ទាំង ៥ ខាងលើ មានដូចខាងក្រោម ៖

- តំបន់ចែកចាយអគ្គិសនីនៅស្រុកពួករបស់សេវាករ វន់ វីរៈ សីវីស ជាតំបន់ដែលបានភ្ជាប់ប្រភពអគ្គិសនីពីបណ្ដាញជាតិមុនគេយូរមកហើយ មានថ្លៃលក់បច្ចុប្បន្នស្មើនឹង១,០០០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ។
- ចំពោះតំបន់ចែកចាយ ២ តំបន់ទៀត ដែលឋិតនៅក្នុងស្រុកក្រឡាញ់ និងក្នុងស្រុកស្រីស្នំ រួចទើបនឹងបានភ្ជាប់ផ្ទាល់ជាមួយបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ថ្លៃលក់អគ្គិសនីរាយកំពុងឋិតនៅក្នុងរយៈពេលបណ្ដោះអាសន្ន ក្នុងនោះ ១ តំបន់នៅស្រុកក្រឡាញ់ ដែលថ្លៃបច្ចុប្បន្នបានចុះមក ១,១០០ រៀល ក្នុង១ គីឡូវ៉ាត់ម៉ោង និង ១ តំបន់ទៀតនៅស្រុកស្រីស្នំ ដែលទើបនឹងបានភ្ជាប់ជាមួយបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាថ្មីៗ នេះ ចុះពីថ្លៃ ២,៥០០ រៀល មក ១,៣០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។
- ចំពោះតំបន់ចែកចាយ ២ តំបន់ទៀត៖ ទី១.តំបន់ចែកចាយរបស់សេវាករឈ្មោះ អ៊ឹង ប៊ុនធី នៅស្រុកពួកបានទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយរបស់ក្រុមហ៊ុន វន់ វីរៈ សីវីស និងទី២.តំបន់ចែកចាយរបស់សេវាករឈ្មោះ ដួង ណារិន នៅស្រុកអង្គរជុំ ដែលបានទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយរបស់សេវាករឈ្មោះ អ៊ឹង ប៊ុនធី បន្តមួយជាន់ទៀត តំបន់ទាំង ២ នេះ ដែលមានថ្លៃបច្ចុប្បន្នបានបន្ថយមកស្មើនឹង ១,២០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

ចាប់ពីខែ មីនា ឆ្នាំ ២០១៦ តំបន់ទាំង ៥ ខាងលើ នឹងត្រូវអនុវត្តថ្លៃ តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

**<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៦ តំបន់ចែកចាយឯកជនដែលយកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរង ខេធីស៊ីខេបល

ក្នុងចំណោមតំបន់ចែកចាយ ១៦ តំបន់ ដែលជាតំបន់ត្រូវបានចាត់ទុកថា ជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្ដាញជាតិ ក្នុងនោះមាន ១០ តំបន់ គឺជាតំបន់ចែកចាយដែលយកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ។ តំបន់ទាំង ១០ តំបន់នេះមាន ៖ ៩ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនី

ផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល និង ១ តំបន់ គឺជាតំបន់ដែលទិញប្រភពអគ្គិសនីបន្ត ពីតំបន់ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ខេ.ធី.ស៊ី ខេបល ។ តាមផែនការដែលបានគ្រោងទុក ចំពោះតំបន់ចែកចាយទាំង ១០ ខាងលើនេះ ការបន្ថយថ្លៃអគ្គិសនីត្រូវចែកជា ២ ដំណាក់កាល គឺ ៖ **<u>ដំណាក់កាលទី ១</u>** ពីខែមីនា ឆ្នាំ២០១៥ រហូតដល់ខែ មីនា ឆ្នាំ ២០១៦ បន្ថយពីថ្លៃបច្ចុប្បន្ន ១,៣០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង មក ១,១៥០ រៀលក្នុង ១គីឡូវ៉ាត់ម៉ោង, **<u>ដំណាក់កាលទី២</u>** គឺចាប់ពីចុងខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ទាំង ១០ នេះ នឹងត្រូវកំណត់ឲ្យមានថ្លៃថយចុះតាមផែនការរួមទូទាំងប្រទេសរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

**<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម10kWh/ខែ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៧ តំបន់ចែកចាយនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី

នៅខេត្តសៀមរាប ក្នុងចំណោមតំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជនទាំង ១៩ មានតំបន់ចែកចាយ ៣ តំបន់កំពុងតែនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលនៅឡើយ ។ បញ្ហាដែលត្រូវដោះស្រាយចំពោះតំបន់ចែកកចាយ ដែលនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីមាន ២ សំខាន់គឺ ៖ ១.ជម្រុញការវិនិយោគពង្រីកបណ្តាញបញ្ជូនរងរបស់បណ្តាញជាតិឲ្យទៅគ្របដណ្តប់តំបន់ទាំងនេះ និង២.បន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំងនេះតាមថ្លៃដែលកំណត់ក្នុងផែនការរួមរបស់រាជរដ្ឋាភិបាល ។

នៅក្នុងរយៈពេលដែលប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី ដើម្បីឲ្យមានយុត្តិធម៌ រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនីគឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ។ តាមនីតិវិធីប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះនឹងយកទៅផលិត

អគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនម៉ាស៊ូតផលិតអគ្គិសនីទាំង ៣ តំបន់ នៅខេត្តសៀមរាប យើងពុំមានជម្រើសអ្វី ក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាង ពីអនុស្ថានីយនៅខេត្តសៀមរាប ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ូតដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធនខុសពីគោលការណ៍របស់ច្បាប់បានឡើយ ។ គ្រោងអនុវត្តឲ្យបាននៅឆ្នាំ ២០១៧ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកំពង់ចាម សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពង់ចាម

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

តាមផែនការ ខេត្តកំពង់ចាម ត្រូវបានគ្របដណ្តប់ដោយប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី ដែលត្រូវសាងសង់ចេញពីភ្នំពេញ ឆ្លងកាត់ខេត្តកំពង់ចាម ឆ្ពោះទៅក្រចេះ និងស្ទឹងត្រែង ដើម្បីតភ្ជាប់ជាមួយវារីអគ្គិសនីសេសានក្រោម ២ នៅខេត្តស្ទឹងត្រែង ។ ខ្សែបណ្តាញតង់ស្យុងខ្ពស់ ភ្នំពេញ-កំពង់ចាម និងអនុស្ថានីយខេត្តកំពង់ចាម បានសាងសង់រួចនៅឆ្នាំ ២០១១ រួចតាមគម្រោងនេះ ចាប់ពីឆ្នាំ ២០១១ មក ខេត្តកំពង់ចាម មានអនុស្ថានីយបណ្តាញជាតិមួយឋិតនៅក្នុងស្រុកកំពង់សៀម ជិតក្រុងកំពង់ចាម ។ ទោះជាយ៉ាងនេះក៏ដោយ តាមលក្ខណៈភូមិសាស្ត្រការផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្គត់ផ្គង់ឲ្យតំបន់ចែកចាយនានាក្នុងខេត្តកំពង់ចាម គឺចេញពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ផង និងចេញពីអនុស្ថានីយបណ្តាញជាតិភ្នំពេញ ផង ។ ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅផ្តល់ឲ្យតំបន់ចែកចាយនានា នៅខេត្តកំពង់ចាម គឺធ្វើតាមបណ្តាញបញ្ជូនរងចំនួន៤ក្រុមហ៊ុនគឺ៖ ទី១.បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាដែលយកចេញពីអនុស្ថានីយកំពង់ចាម,ទី២.បណ្តាញបញ្ជូនរងរបស់សហគ្រាស អេឡិកទ្រីស៊ីធី ស្តន់-ចំការលើ ដែលយកចេញពីអនុស្ថានីយខេត្តកំពង់ចាម, ទី៣.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមេន ដែលយកចេញពីអនុស្ថានីយខេត្តកំពង់ចាម និងទី៤.បណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង ដែលយកអគ្គិសនីចេញពីអនុស្ថានីយទី ១ និងអនុស្ថានីយខាងជើងភ្នំពេញ ។ ក្រៅពីការបញ្ជូនអគ្គិសនីតាមរយៈបណ្តាញបញ្ជូនរងនានានេះ ក៏នៅមានការបញ្ជូនបន្តគ្នា ពីតំបន់ចែកចាយមួយទៅតំបន់ចែកចាយមួយទៀតជាបណ្តោះអាសន្ន ចំពោះតំបន់ចែកចាយនៅឆ្ងាយពីបណ្តាញបញ្ជូនរងទាំង ៤ ខាងលើ ក្នុងពេលដែលបណ្តាញបញ្ជូនរងទាំង ៤ ខាងលើនេះ ពុំទាន់អាចពង្រីកបណ្តាញបញ្ជូនរងឲ្យរាយពាសពេញទូទាំងខេត្តកំពង់ចាម ។ ក្រៅពីនេះ ក្នុងខេត្តកំពង់ចាម ក៏មាននៅសល់តំបន់ចែកចាយខ្លះ ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលជាបណ្តោះអាសន្ននៅឡើយដែរ ដោយសារបណ្តាញបញ្ជូនរងពុំទាន់អាចពង្រីកទៅដល់ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តកំពង់ចាម មានក្រុង ១ ឈ្មោះក្រុងកំពង់ចាម និងស្រុកចំនួន ៩ គឺ ៖ ១.ស្រុកស្ទឹងត្រង់ ២.ស្រុកចំការលើ ៣.ស្រុកព្រៃឈរ ៤.ស្រុកកងមាស ៥.ស្រុកជើងព្រៃ ៦.ស្រុកបាធាយ ៧.ស្រុកកំពង់សៀម ៨.ស្រុកកោះសុទិន និង៩.ស្រុកស្រីសន្ធរ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកំពង់ចាម ត្រូវបានដោះស្រាយដោយ**ការផ្គត់ផ្គង់អគ្គិសនីដុំ** ពីអនុស្ថានីយខេត្តកំពង់ចាម **ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងនានា និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនៅខេត្តកំពង់ចាម បែងចែកជា ៤ ប្រភេទគឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងកំពង់ចាមដែលយកប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ ទី២.តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន

ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងនានា ចេញពីអនុស្ថានីយផ្ទាល់, ទី៣.តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទទួលប្រភពអគ្គិសនី ដោយការបញ្ជូនបន្តគ្នាជាបណ្តោះអាសន្ន និងទី៤.តំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែលជាបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តកំពង់ចាម មានតំបន់ចែកចាយអគ្គិសនីសរុបចំនួន ៤០ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់នៅក្រុងកំពង់ចាម គឺជាតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា និង ៣៩ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ៣៩ តំបន់នេះ មាន ១២ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ១ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ គឺសហគ្រាសអេឡិកទ្រីស៊ីធី ស្តន់-ចំការលើ យកមកផ្គត់ផ្គង់ក្រោមខ្សែបញ្ជូនរងរបស់ខ្លួនចំនួន ១២ តំបន់, ៥ តំបន់ ជាតំបន់ទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវេឡុបមេន, ៤ តំបន់ ជាតំបន់ទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង, ២ តំបន់ ជាតំបន់ដែលទទួលប្រភពអគ្គិសនីដោយការបញ្ជូនបន្តគ្នារបស់តំបន់ចែកចាយជាបណ្តោះអាសន្ន និង ៣ តំបន់ទៀត គឺជាតំបន់នៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ដែលមានថ្លៃខ្ពស់ (ឃុំសណ្តែក កោះសំរោង និងកោះប៉ែន)។

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកំពង់ចាម

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (កំពង់ចាម) | 001 L | GS | ក្រុងកំពង់ចាម |
| 2 | ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ | 090 L | GS-EDC | ស្រុកបាធាយ |
| 3 | សហគ្រាស អេឡិកទ្រីស៊ីធី ស្តន់ ចំការលើ | 220 L | GS | ស្រុកកំពង់សៀម |
| 4 | សេវាករ ញ៉េប សេង | 357 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 5 | សេវាករ អេង កល្យាន | 356 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 6 | សេវាករ ជិន សុខហីន | 057 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 7 | សេវាករ លាង សុវារង្ស | 295 L | GS-EDC | ស្រុកកោះសូទិន |
| 8 | ឡុង ស្រេង អ៊ិនធើណេសិនណល | 375 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 9 | សេវាករ លូន សុភាព | 340 L | GS-EDC | ស្រុកកំពង់សៀម |
| 10 | សេវាករ សេង គ្រី | 292 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 11 | សេវាករ ឱ ពិសី | 369 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 12 | សេវាករ យៀប ម៉ី | 285 L | GS-EDC | ស្រុកកងមាស |
| 13 | សេវាករ វ៉ាត ណារុណ | 394 L | GS-EDC | ស្រុកស្ទឹងត្រង់ |
| 14 | សេវាករ សាយ សោភា | 297 L | GS-EDC | ស្រុកកោះសូទិន |
| 15 | សេវាករ អ៊ុង គឹមស៊ាន | 241 L | GS – BVC | ស្រុកព្រៃឈរ |
| 16 | សេវាករ ញ៉ឹក ធារី | 056 L | GS – BVC | ស្រុកចំការលើ |
| 17 | សេវាករ ឡាយ ប៊ុនធឿន | 376 L | GS – BVC | ស្រុកចំការលើ |
| 18 | សេវាករ សោម សុខាលីន | 255 L | GS - TPLC | ស្រុកបាធាយ |
| 19 | សេវាករ តឹក និមល | 216 L | GS - TPLC | ស្រុកបាធាយ |
| 20 | សេវាករ ឃុន ណៃគាង (KNK) | 335 L | GS - TPLC | ស្រុកស្រីសន្ធរ |
| 21 | សេវាករ ទ្រី ឡេង | 130 L | GS - TPLC | ស្រុកបាធាយ |
| 22 | ក្រុមហ៊ុន មេគង្គ ស្មាត ផៅវ័រ | 023 L | GS – SCL | ស្រុកព្រៃឈរ |
| 23 | សេវាករ ផេង សុផាត | 254 L | GS – SCL | ស្រុកបាធាយ |
| 24 | សេវាករ អ៊ាម ស្រេង | 060 L | GS – SCL | ស្រុកស្ទឹងត្រង់ |

| | | | | |
|---|---|---|---|---|
| 25 | សេវាករ ស៊ូ រ៉ុង | 286 L | GS – SCL | ស្រុកជើងព្រៃ |
| 26 | សហគ្រាស អេឡិកទ្រីស៊ីធី កងមាស | 165 L | GS – SCL | ស្រុកកងមាស |
| 27 | សេវាករ ចាំង ប៊ុនណារ៉េត | 026 L | GS – SCL | ស្រុកបាធាយ |
| 28 | សេវាករ សរ ម៉ាលីស | 047 L | GS – SCL | ស្រុកជើងព្រៃ |
| 29 | សេវាករ ឆាយ គឹមហ៊្សៀរ | 075 L | GS – SCL | ស្រុកចំការលើ |
| 30 | សេវាករ មាន វណ្ណា | 074 L | GS – SCL | ស្រុកចំការលើ |
| 31 | សេវាករ ដា ចាន់ណារឿន | 140 L | GS – SCL | ស្រុកចំការលើ |
| 32 | សហគ្រាស ថ្នល់បែក ចំការលើ អេឡិកទ្រីស៊ីធី | 038 L | GS – SCL | ស្រុកចំការលើ |
| 33 | សេវាករ ឃុន សុភាព | 159 L | GS – SCL | ស្រុកបាធាយ |
| 34 | សេវាករ សេង ជិនលាង SCL | 160 L | GS - TPLC - KNK | ស្រុកស្រីសន្ធរ |
| 35 | សេវាករ ឡាយ វ៉េងឃាង | 207 L | GS - TPLC - KNK - SCL | ស្រុកស្រីសន្ធរ |
| 36 | សេវាករ ងិន គង់ | 032 L | GS – BVC | ស្រុកចំការលើ |
| 37 | សេវាករ តែ គឹមសុង | 256 L | GS – BVC | ស្រុកចំការលើ |
| 38 | សេវាករ លាង ផល្លា | 363 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកកំពង់សៀម |
| 39 | សេវាករ ឃិន គឹមលី | 288 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកបាធាយ |
| 40 | សេវាករ ហាក់ សៀកវេង | 301 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកកំពង់សៀម |

# ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តកំពង់ចាម



## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកំពង់ចាម

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បាធាយ | 80 | 58 | 72.50% | 46 | 57.50% | 12 |
| ចំការលើ | 83 | 53 | 63.86% | 56 | 67.47% | -3 |
| ជើងព្រៃ | 74 | 71 | 95.95% | 48 | 64.86% | 23 |
| កំពង់ចាម | 31 | 31 | 100.00% | 30 | 96.77% | 1 |
| កំពង់សៀម | 112 | 110 | 98.21% | 83 | 74.11% | 27 |
| កងមាស | 93 | 93 | 100.00% | 77 | 82.80% | 16 |
| កោះសូទិន | 85 | 85 | 100.00% | 72 | 84.71% | 13 |
| ព្រៃឈរ | 176 | 169 | 96.02% | 97 | 55.11% | 72 |
| ស្រីសន្ធរ | 86 | 85 | 98.84% | 68 | 79.07% | 17 |
| ស្ទឹងត្រង់ | 96 | 81 | 84.38% | 54 | 56.25% | 27 |
| **សរុប** | **916** | **836** | **91.27%** | **631** | **68.89%** | **205** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ចាម

តាមស្ថានភាពនៃការផ្គត់ផ្គង់ និងថ្លៃអគ្គិសនីកំពុងអនុវត្តនៅខេត្តកំពង់ចាម យើងអាចបែងចែកផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ចាម ជាផែនការដោយឡែក ទៅតាមប្រភេទនៃការផ្គត់ផ្គង់ចំនួន ៦ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងទាំងឡាយ ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជន ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងកំពង់ចាម ៤.ការផ្គត់ផ្គង់អគ្គិសនីរាយ នៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលយកអគ្គិសនីបណ្តាញបញ្ជូនរងផ្ទាល់ ៥.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលទទួលប្រភពអគ្គិសនីដោយការបញ្ជូនបន្តគ្នាជាបណ្តោះអាសន្ន និងទី៦.ការផ្គត់ផ្គង់អគ្គិសនីរាយនៅក្នុងតំបន់ចែកចាយរបស់សេវាករឯកជន ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលបណ្តោះអាសន្ន។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ចាម ត្រូវបានកំណត់ ទៅតាមការផ្គត់ផ្គង់ដោយឡែកទាំង ៦ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.129$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានិងរបស់ឯកជន

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងកំពង់ចាម

### (១).ស្ថានភាពថ្លៃនៅឆ្នាំ ២០១៥

ដោយសារនៅក្រុងកំពង់ចាម ប្រភពអគ្គិសនីដែលប្រើប្រាស់មាន ២ ប្រភេទ គឺទី១.ប្រភពអគ្គិសនីមកពីអនុស្ថានីយបណ្តាញជាតិ និងទី២.រោងចក្រអគ្គិសនីប្រើប្រេងខ្មៅ ទំហំ ៧.៥ មេហ្គាវ៉ាត់ របស់ផលិតករអគ្គិសនីឯករាជ(IPP) ដូច្នេះទោះបីជាបច្ចុប្បន្ននេះ រោងចក្រអគ្គិសនីប្រើប្រេងខ្មៅរបស់ផលិតករអគ្គិសនីឯករាជ (IPP) ត្រូវបានទុកត្រៀមបម្រុងដោយមិនដំណើរការក៏ដោយ ក៏ការចំណាយសម្រាប់ប្រភពអគ្គិសនីនៅក្រុងកំពង់ចាម ត្រូវចំណាយលើប្រភពទាំង ២ នេះផងដែរ ដូច្នេះថ្លៃដើមនៃប្រភពអគ្គិសនីសម្រាប់ក្រុងកំពង់ចាម គឺបានកំណត់យកស្មើនឹងថ្លៃមធ្យមនៃថ្លៃចំណាយលើប្រភពអគ្គិសនីទាំង២ ខាងលើ ។ ស្ថានភាពថ្លៃអគ្គិសនីនៅក្រុងកំពង់ចាម នៅឆ្នាំ ២០១៥ រក្សាទុកដូចខាងក្រោម ៖

➢ **សម្រាប់អតិថិជនលំនៅដ្ឋាន**

| **ប្រភេទអតិថិជន** | **អត្រាថ្លៃលក់** |
|---|---|
| អតិថិជនធុនតូច | ៩២០ ៛/ kWh |

➢ **សម្រាប់អតិថិជនពាណិជ្ជកម្ម ឧស្សាហកម្ម**

| **ប្រភេទអតិថិជន** | **អត្រាថ្លៃលក់** |
|---|---|
| អតិថិជនធុនតូច | = (ថ្លៃមធ្យមនៃល្បាយប្រភព + 0.០៤៦ $US) / kWh |
| អតិថិជនធុនមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភព + 0.០៣៨ $US) / kWh |
| អតិថិជនធុនធំ | = (ថ្លៃមធ្យមនៃល្បាយប្រភព + 0.០៣៤ $US) / kWh |
| អតិថិជនតង់ស្យុងមធ្យម | = (ថ្លៃមធ្យមនៃល្បាយប្រភព + 0.០៣០ $US) / kWh |

<u>**កំណត់សំគាល់**</u>៖ ថ្លៃមធ្យមនៃល្បាយប្រភពថាមពលនៅខេត្តកំពង់ចាម នៅក្នុងខែមករា និងខែកុម្ភៈ ឆ្នាំ២០១៥ នេះ មានអត្រាស្មើនឹង 0.១៥១ $US/kWh។

### (២).ផែនការបន្ថយថ្លៃដែលត្រូវអនុវត្តពីខែមីនា ឆ្នាំ២០១៦

ចាប់ពីខែ មីនា ឆ្នាំ២០១៦ ទៅ ទោះបីជាក្រុងកំពង់ចាម នៅរក្សាការប្រើប្រាស់រោងចក្រអគ្គិសនីប្រើប្រេងខ្មៅរបស់ផលិតករអគ្គិសនីឯករាជ (IPP) ទុកជាប្រភពបម្រុងបន្តទៀតក៏ដោយ ប៉ុន្តែថ្លៃអគ្គិសនីនៅក្រុងកំពង់ចាម នឹងត្រូវកំណត់តាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៦** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|---|
| ទិញ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៦** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

***ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ***

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

***ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក***

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយឯកជនដែលយកអគ្គិសនីផ្ទាល់ពីបណ្តាញជាតិ

ដូចបានជម្រាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយរបស់ឯកជនទាំង ៣៩ តំបន់ ក្រៅពីតំបន់ចែកចាយដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ូតដៀសែលចំនួន ៣ តំបន់ និងតំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីដោយការបញ្ជូនបន្តគ្នារបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយជាបណ្តោះអាសន្នចំនួន ២ តំបន់ គឺមាន ៣៤ តំបន់ គឺត្រូវបានចាត់ទុកថាជាតំបន់យកប្រភពអគ្គិសនីពីបណ្តាញជាតិផ្ទាល់ ។ ក្នុងចំណោមតំបន់ចែកចាយទាំង ៣៤ តំបន់នេះមាន ៖ ១ តំបន់ ជាតំបន់ទទួលប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយ និង ៣៣ តំបន់ទៀត ជាតំបន់ដែលទទួលប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង ។ តំបន់ទាំង ៣៣ តំបន់នេះមាន ៖ ១២ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា, ១២ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីសហគ្រាស អេឡិកទ្រីស៊ីធី ស្តន់-ចំការលើ, ៥ តំបន់ ជាតំបន់ទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវេឡុបមេន និង ៤ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ធី.ភី.អិល.ស៊ី ហូលឌីង។ ផែនការបន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយទាំង ៣៤ តំបន់នេះ មានដូចខាងក្រោម ៖

***សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម***

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

***សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ***

- ១ តំបន់របស់ក្រុមហ៊ុន វាសនា ញូលែន ផៅវ័រ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

- ៣១ តំបន់ ទិញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងឯកជន

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

- ១ តំបន់ ទិញបន្តគ្នា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,១០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

➢ ១ តំបន់ ទិញបន្តគ្នាមួយជាន់ទៀត

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ១,១៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

➢ ២ តំបន់ ទិញពីបណ្តាញបញ្ជូនរង របស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ឌីវ៉េឡុបមិន

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ១,២០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយរបស់សេវាករឯកជនដែលទិញបន្តគ្នា

នៅខេត្តកំពង់ចាម មានតំបន់ចែកចាយឯកជន ២ តំបន់ នៅស្រុកស្រីសន្ធរ ជាតំបន់ចែកចាយដែលទទួលប្រភពអគ្គិសនីពីការបញ្ជូនបន្តគ្នា ពីតំបន់ចែកចាយជាបណ្តោះអាសន្ន ដែលថ្លៃប្រភពអគ្គិសនីដែលតំបន់ទាំង ២ នេះ មានអត្រាខ្ពស់ជាងតំបន់ចែកចាយដ៏ទៃទៀត ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង ដូច្នេះថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយទាំង ២ ខាងលើនេះ ក៏មានអត្រាខ្ពស់ជាងតំបន់ចែកចាយ ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងផ្ទាល់ដែរ ។ តាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ចំពោះតំបន់ទាំង ២ តំបន់ នេះ នៅឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនឹងបន្តអនុវត្តតាមកម្មវិធីកំណត់បញ្ជីថ្លៃលក់ធម្មតា រហូតដល់បណ្តាញបញ្ជូនរងត្រូវបានពង្រីកទៅគ្របដណ្តប់តំបន់ចែកចាយទាំង ២ នោះដែលអាចឲ្យតំបន់ចែកចាយទាំង ២ នេះ អាចយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង ទើបថ្លៃអគ្គិសនីលក់រាយនៅតំបន់ចែកចាយទាំង ២ នេះ នឹងត្រូវថយចុះតាមផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ដូចតំបន់ដែលទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងផ្ទាល់ ។ ទោះជាយ៉ាងនេះក៏ដោយ ចំពោះតំបន់ទាំង ២ នេះ កំណត់ឲ្យអគ្គិសនីកម្ពុជា ជាអ្នកប៉ះប៉ូវថ្លៃសេវាបញ្ជូនបន្តដើម្បីឲ្យអាចអនុវត្តថ្លៃតាមផែនការ ចាប់ពីឆ្នាំ ២០១៦ ដូចតំបន់ដ៏ទៃទៀតដែរ ។

## ២.៦ តំបន់ចែកចាយដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម៉ាស៊ីនដ្យេសែលផលិតអគ្គិសនី

ចំពោះតំបន់ចែកចាយដែលនៅប្រើម៉ាស៊ីនដ្យេសែលទាំង ៣ តំបន់ នៅខេត្តកំពង់ចាម នៅពេលបច្ចុប្បន្ននេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយនីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះអត្រាថ្លៃលក់អគ្គិសនីគឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីរបស់តំបន់នេះនឹងថយចុះនៅចុងខែ ឬដើមខែក្រោយនៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីទាំង ៣ តំបន់ នៅខេត្តកំពង់ចាម យើងពុំមានជម្រើសអ្វីក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនវង ២២ គីឡូវ៉ុលបញ្ជូនប្រភពអគ្គិសនីដែលថោកជាងពីអនុស្ថានីយបណ្ដាញជាតិ ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ។ ក្រៅពីនេះយើងក៏នៅត្រូវការឲ្យឯកជនចូលរួមវិនិយោគពង្រីកបណ្ដាញចែកចាយនៅតំបន់ដែលប្រជាពលរដ្ឋពុំទាន់មានអគ្គិសនីប្រើប្រាស់នៅខេត្តកំពង់ចាម ផងដែរ ពីព្រោះរដ្ឋមានលទ្ធភាពវិនិយោគតែត្រឹមខ្សែបណ្ដាញបញ្ជូនវងខ្លះៗ តែប៉ុណ្ណោះ។ គ្រោងភ្ជាប់ប្រភពបណ្ដាញជាតិឲ្យតំបន់ទាំង ៣ នេះនៅឆ្នាំ ២០១៧ ខាងមុខ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តកោះកុង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកោះកុង

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តកោះកុង មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយ ដោយសារតែខេត្តនេះ ពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់នានាក្នុងខេត្ត មានតែការបញ្ជូនប្រភពពីឆ្ងាយជាបណ្តោះអាសន្នប៉ុណ្ណោះ ។ តាមផែនការរបស់រាជរដ្ឋាភិបាលគ្រោងយកអនុស្ថានីយសម្រាប់ភ្ជាប់ស្ថានីយវារីអគ្គិសនីស្ទឹងតាតៃ ដែលឋិតនៅចម្ងាយប្រហែល ៣០ គីឡូម៉ែត្រពីក្រុងខេមរភូមិន្ទ នៃទីរួមខេត្តកោះកុង ដើម្បីដាក់តម្លើងត្រង់ស្វូផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តកោះកុង ។ ក្រៅពីនេះក៏មានគម្រោងសាងសង់បណ្តាញបញ្ជូនតង់ស្យុងខ្ពស់ ២៣០ គីឡូវ៉ុល ភ្ជាប់អនុស្ថានីយតាតៃនេះ ទៅភ្ជាប់ជាមួយប្រព័ន្ធបណ្តាញបញ្ជូនរបស់រាជធានីភ្នំពេញ ១ ខ្សែទៀតដែរ ដើម្បីបង្កើនស្ថេរភាពនៃការតភ្ជាប់ និងបញ្ជូនប្រភពអគ្គិសនីពីវារីអគ្គិសនីទៅកាន់ភ្នំពេញ ។ គម្រោងផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្ទាល់ តាមរយៈអនុស្ថានីយវារីអគ្គិសនីស្ទឹងតាតៃឲ្យខេត្តកោះកុងនេះ គ្រោងនឹងដាក់ឲ្យដំណើរការនៅចុងឆ្នាំ ២០១៥ ខាងមុខនេះ មុនពេលសម្ពោធដាក់ឲ្យដំណើរការស្ថានីយវារីអគ្គិសនីស្ទឹងតាតៃ ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់ចែកចាយនានា ក្នុងខេត្តកោះកុងជាបណ្តោះអាសន្ន រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាធ្វើការសាងសង់បណ្តាញបញ្ជូនរង បញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិនៅខេត្តព្រះសីហនុ មកផ្គត់ផ្គង់ឲ្យតំបន់ចែកចាយមួយចំនួននៅស្រុកស្រែអំបិល និងស្រុកបទុមសាគរ ។ ចំពោះតំបន់ចែកចាយនៅជាប់ព្រំដែនក្នុងស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប នាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល ដើម្បីចែកចាយអគ្គិសនីឲ្យអ្នកប្រើប្រាស់នៅតំបន់នោះ ។ ចំពោះតំបន់ចែកចាយដែលនៅឆ្ងាយៗ ដូចជានៅស្រុកកោះកុង ស្រុកគិរីសាគរ និងស្រុកថ្មបាំង ដោយសារពុំទាន់មានបណ្តាញបញ្ជូនរងផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិ ដែលមានថ្លៃថោកទៅផ្តល់ឲ្យ ដូច្នេះរាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យសេវាករចែកចាយឯកជនធ្វើការផ្គត់ផ្គង់អគ្គិសនីដោយប្រើម៉ាស៊ីនដ្យេសែលតូចៗ ក្នុងលក្ខខណ្ឌបណ្តោះអាសន្នសិន ទម្រាំអគ្គិសនីកម្ពុជា អាចធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង បញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្តល់ឲ្យ ។ តាមបទដ្ឋានបច្ចេកទេសការបញ្ជូនអគ្គិសនីរបស់ខ្សែ ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ ទៅ ៧០ គីឡូម៉ែត្រ ប៉ុណ្ណោះ ប៉ុន្តែដោយសភាពការណ៍ចាំបាច់ចំពោះមុខអគ្គិសនីកម្ពុជាបានបញ្ជូនអគ្គិសនីជាបណ្តោះអាសន្នសម្រាប់ខេត្តកោះកុង នេះ រហូតដល់ជាង ២០០ គីឡូម៉ែត្រលើសពីបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីមានអតុល្យភាព និងមានការរអាក់រអួលជាញឹកញាប់ចំណែកការបាត់បង់ថាមពលអគ្គិសនីលើខ្សែបណ្តាញមានបរិមាណច្រើនលើសពីខេត្តដទៃ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ នៅខេត្តកោះកុង យើងពុំមានជម្រើសអ្វីផ្សេងក្រៅពីនេះទេ ពីព្រោះមានតែធ្វើបែបនេះទេទើបយើងអាចប្តូរពីការផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល និងបន្ថយថ្លៃអគ្គិសនីនៅតំបន់មួយចំនួនធំ ឲ្យថយចុះពីជាង

៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យមកនៅត្រឹមជាង ១,៣០០ រៀល ដូចបច្ចុប្បន្នបាន ។ ម្យ៉ាងទៀត មានតែធ្វើយ៉ាងនេះ ទើបយើងអាចអភិវឌ្ឍន៍បណ្ដាញបញ្ជូនរង និងបណ្ដាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនធំ ហើយស្រេច ។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តកោះកុង មានក្រុង ១ ឈ្មោះក្រុងខេមរភូមិន្ទ និងស្រុកចំនួន ៦ គឺ ៖ ១.ស្រុកបុទុមសាគរ ២.ស្រុកគិរីសាគរ ៣.ស្រុកកោះកុង ៤.ស្រុកមណ្ឌលសីមា ៥.ស្រុកស្រែអំបិល និង៦.ស្រុកថ្មបាំង ។ កន្លងមកថ្មីៗនេះដោយសារតែខេត្តនេះពុំទាន់មានប្រភពអគ្គិសនីពីអនុស្ថានីយបណ្ដាញជាតិការផ្គត់ផ្គង់អគ្គិសនី គឺមានតែ ២ ប្រភេទប៉ុណ្ណោះ គឺ**ការផ្គត់ផ្គង់អគ្គិសនីធំ** តាមបណ្ដាញបញ្ជូនរងខ្លះរបស់អគ្គិសនីកម្ពុជា និង **ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយ ។ ការដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់ចែកចាយនៅខេត្តកោះកុង មាន ៣ ប្រភេទ គឺ ៖ ទី១.ចំពោះស្រុកមណ្ឌលសីមា ក្រុងខេមរភូមិន្ទ និងតំបន់ជុំវិញ ដោះស្រាយដោយការនាំចូលប្រភពអគ្គិសនីពីប្រទេសថៃតាមខ្សែបណ្ដាញ ២២ គីឡូវ៉ុល ទី២.ចំពោះស្រុកស្រែអំបិល និងស្រុកបទុមសាគរ ដោះស្រាយដោយការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្ដាញជាតិ នៅស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ មកផ្គត់ឲ្យ និងទី៣.ស្រុកកោះកុង និងស្រុកថ្មបាំង ដោះស្រាយដោយអនុញ្ញាតឲ្យឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនដៀសែល ផលិតអគ្គិសនីជាបណ្ដោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តកោះកុង មានតំបន់ចែកចាយអគ្គិសនីចំនួន ៨ តំបន់ ដែលតំបន់ទាំង ៨ នេះ សុទ្ធតែជាតំបន់ចែកចាយអគ្គិសនីរបស់ឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់ឯកជនទាំង ៨ តំបន់នោះ មាន ១ ជាតំបន់នាំចូលប្រភពផ្ទាល់ពីប្រទេសថៃ, ៥ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជាដែលចេញពីអនុស្ថានីយស្ទឹងហាវ ខេត្តព្រះសីហនុ និង ២ តំបន់ទៀត គឺតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលបណ្ដោះអាសន្នដែលមានថ្លៃខ្ពស់ ។ តាមប្រកាសរបស់ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងនឹងចេញអាជ្ញាប័ណ្ណផ្គត់ផ្គង់អគ្គិសនីដោយប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី នៅស្រុកថ្មបាំង ១ កន្លែងទៀត ដែលធ្វើឲ្យតំបន់ចែកចាយនៅកោះកុង សរុបឡើងដល់ ៩ តំបន់ ។

### បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកោះកុង

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | ក្រុមហ៊ុន អ៊ិល. វ៉ាយ. ភី គ្រុប (កោះកុង) | 014 L | នាំចូលពី Thai | ក្រុងខេមរភូមិន្ទ ស្រុកមណ្ឌលសីមា |
| 2 | សេវាករ សំរិទ្ធ សុទ្ធី | 028 L | GS-EDC | ស្រុកស្រែអំបិល |
| 3 | សេវាករ ឃុន ចាន់ធារិទ្ធ | 279 L | GS-EDC | ស្រុកស្រែអំបិល |
| 4 | ក្រុមហ៊ុន ម៉ុង ឬទ្ធី គ្រុប | 304 L | GS-EDC | ស្រុកស្រែអំបិល |
| 5 | សេវាករ អ៊ូច ង៉ាក់ | 358 L | GS-EDC | ស្រុកស្រែអំបិល |
| 6 | សេវាករ ហេង ហ៊ុយ | 371 L | GS-EDC | ស្រុកបុទុមសាគរ |
| 7 | សេវាករ អាន់ សំឡាន | 106 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកគីរីសាគរ |
| 8 | សេវាករ ផាត សុធា | 370 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកកោះកុង |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកោះកុង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បុទុមសាគរ | 20 | 20 | 100.00% | 5 | 25.00% | 15 |
| គិរីសាគរ | 9 | 3 | 33.33% | 1 | 11.11% | 2 |
| កោះកុង | 11 | 6 | 54.55% | 2 | 18.18% | 4 |
| ខេមរភូមិន្ទ | 11 | 11 | 100.00% | 10 | 90.91% | 1 |
| មណ្ឌលសីមា | 13 | 7 | 53.85% | 5 | 38.46% | 2 |
| ស្រែ អំបិល | 36 | 31 | 86.11% | 22 | 61.11% | 9 |
| ថ្មបាំង | 17 | 6 | 35.29% | - | - | 6 |
| **សរុប** | **117** | **84** | **71.79%** | **45** | **38.46%** | **39** |

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តកោះកុង




## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកោះកុង

### ២-១.ថ្លៃលក់អគ្គិសនីកំពុងអនុវត្ត និងផែនការថ្លៃឆ្នាំ ២០១៥ នៅខេត្តកោះកុង

ដោយសារតែស្ថានភាពផ្គត់ផ្គង់ប្រភពអគ្គិសនីដូចបានជម្រាបជូនខាងលើ ខេត្តកោះកុង ត្រូវបានចាត់ទុកថា ជាតំបន់បិតនៅក្រៅវង្វង់នៃការផ្គត់ផ្គង់ប្រភពអគ្គិសនីរបស់បណ្តាញជាតិ ដូច្នេះនៅឆ្នាំ ២០១៥ នេះ

តំបន់ផ្គត់ផ្គង់អគ្គិសនីនៅខេត្តកោះកុង មានថ្លៃលក់ខុសៗគ្នា ទៅតាមប្រភពអគ្គិសនីដែលទទួលបាននៅតំបន់ចែកចាយនីមួយៗ ដូចខាងក្រោម ៖

**តំបន់ស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ របស់ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប**

តំបន់ចែកចាយអគ្គិសនីនៅក្រុងខេមរៈភូមិន្ទ និងស្រុកមណ្ឌលសីមា របស់ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប បានទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសថៃ ដែលមានថ្លៃលក់រាយជូនប្រជាពលរដ្ឋក្នុងអត្រា ៦,៥ បាត ឬស្មើនឹង ៨៤០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ថ្លៃនាំចូលពីប្រទេសថៃ គឺប្រែប្រួលតាមការកំណត់របស់ភាគីថៃ ជារៀងរាល់ឆ្នាំ ។

**តំបន់របស់សេវាករឯកជននៅស្រុកស្រែអំបិល និងស្រុកបទុមសាគរ**

តំបន់ចែកចាយរបស់ឯកជន ៥ តំបន់ គឺនៅស្រុកស្រែអំបិល និងស្រុកបទុមសាគរ ដែលបានទទួលប្រភពអគ្គិសនីបន្តពីខ្សែបណ្តាញបញ្ជូនរង ចេញពីខេត្តព្រះសីហនុ របស់អគ្គិសនីកម្ពុជា កំពុងអនុវត្តថ្លៃលក់តាមកម្មវិធីបន្ថយបន្តិចម្តងៗ។ ក្នុងនោះមានតំបន់ចែកចាយចំនួន ២ គឺតំបន់ចែកចាយរបស់សេវាករ សំរិទ្ធ សុទ្ធី នៅទីរួមស្រុកស្រែអំបិល តាមកម្មវិធីបន្ថយថ្លៃបន្តិចម្តងៗ នៅខែមេសា ឆ្នាំ ២០១៥ នេះ អត្រាថ្លៃលក់នៅតំបន់នេះត្រូវថយចុះដល់ ១,៤០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចនៅតំបន់ចែកចាយរបស់សេវាករ ហេង ហ៊ុយ នៅស្រុកស្រែអំបិល និងស្រុកបទុមសាគរ តាមកម្មវិធីបន្ថយថ្លៃបន្តិចម្តងៗ នៅខែមេសា ឆ្នាំ ២០១៥ នេះ អត្រាថ្លៃលក់រាយនៅតំបន់ចែកចាយនេះត្រូវថយចុះដល់ ១,៦០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ប៉ុន្តែយោងតាមសំណើរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងពិធីសម្ពោធដាក់ឲ្យដំណើរការស្ថានីយវារីអគ្គិសនីស្ទឹងឬស្សីជ្រុំក្រោម តំបន់ចែកចាយទាំង ២ ខាងលើនេះត្រូវបានបន្ថយថ្លៃលក់អគ្គិសនីមកនៅត្រឹម ១,០០០រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអគ្គិសនីកម្ពុជាជាអ្នកប៉ះប៉ូវបន្ថយអត្រាថ្លៃលក់ប្រភពអគ្គិសនី ដើម្បីឲ្យអ្នកចែកចាយអាចធ្វើអាជីវកម្មតាមថ្លៃ ១,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ទៅបាន ។

**តំបន់ដែលនៅប្រើម៉ាស៊ីនដៀសែល**

តំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជន ២ តំបន់ នៅក្នុងស្រុកមណ្ឌលសីមា និងស្រុកគិរីសាគរ និង ១ តំបន់ទៀត ដែលនឹងផ្តល់អាជ្ញាប័ណ្ណឲ្យថ្មី គឺនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីនៅឡើយ ។ ថ្លៃលក់អគ្គិសនីរាយឲ្យប្រជាពលរដ្ឋនៅតំបន់ចែកចាយទាំង ២ នេះ បច្ចុប្បន្នមានអត្រាថ្លៃលក់ ២,៧០០ រៀល និង ៣,២០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

នៅឆ្នាំ ២០១៥ ដើម្បីធានាឲ្យមានស្ថេរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ខេត្តកោះកុង យើងគ្រោងរក្សាស្ថានភាពថ្លៃលក់អគ្គិសនីឲ្យនៅដដែល ដូចខាងលើនេះ ជាបណ្តោះអាសន្នសិន ។

**២-២.ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅខេត្តកោះកុង**

ក្នុងគោលដៅដោះស្រាយបញ្ហាថ្លៃអគ្គិសនីនៅខេត្តកោះកុង ឲ្យបានដូចតំបន់ដ៏ទៃទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលមានផែនការរៀបចំការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ដើម្បីបញ្ជូនប្រភពអគ្គិសនីពី

អនុស្ថានីយបណ្តាញជាតិតាតៃ ទៅផ្តល់ឲ្យតំបន់ចែកចាយរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប នៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ តំបន់ចែកចាយនានា នៅស្រុកគិរីសាគរ (លើកលែងតែតំបន់កោះ) និងតំបន់ចែកចាយនានា ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដៀសែលនៅស្រុកមណ្ឌលសីមា និងស្រុកថ្មបាំង ដើម្បីធ្វើឲ្យថ្លៃលក់អគ្គិសនីនៅក្នុងខេត្តកោះកុង ទាំងមូល (លើកលែងតែតំបន់កោះ) អាចនឹងថយចុះទៅតាមផែនការបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល ។ ពិតមែនតែពេលវេលាក្នុងផែនការ បានកំណត់ឲ្យការបន្ថយថ្លៃអគ្គិសនី តាមផែនការបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល នឹងចាប់អនុវត្តពីខែ មីនា ឆ្នាំ ២០១៦ តទៅ ប៉ុន្តែការងារបន្ថយថ្លៃលក់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ នៅខេត្តកោះកុង គឺអាស្រ័យនឹងពេលវេលានៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង ដើម្បីរៀបចំឲ្យតំបន់នោះប្រើប្រភពអគ្គិសនីពីបណ្តាញជាតិ ។ មានន័យថាពេលវេលានៃការបន្ថយថ្លៃលក់អគ្គិសនី តាមផែនការរបស់រាជរដ្ឋាភិបាលនៃតំបន់ចែកចាយនីមួយៗ អាចខុសៗគ្នា ទៅតាមលទ្ធភាពនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង បញ្ជូនប្រភពអគ្គិសនីទៅកាន់តំបន់ចែកចាយនីមួយៗ ។

បន្ថែមពីលើនោះចាប់ពីឆ្នាំ ២០១៦ ដោយសារនៅក្នុងខេត្តកោះកុង មានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិ ដូច្នេះអ្នកប្រើប្រាស់អគ្គិសនីធំ ដែលមានសេចក្តីត្រូវការប្រើប្រាស់ចាប់ពី ១០ មេហ្គាវ៉ាត់ ឡើងអាចទិញអគ្គិសនីធំពីអនុស្ថានីយបណ្តាញជាតិតាតៃបាន ដោយឡែកអ្នកប្រើប្រាស់ធំៗ ដែលត្រូវប្រើអគ្គិសនីលើតង់ស្យុងមធ្យម ក៏អាចទិញអគ្គិសនីពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឬទិញពីខ្សែបណ្តាញតង់ស្យុងមធ្យមរបស់ក្រុមហ៊ុន អិល.វ៉ាយ.ភី គ្រុប បានដែរ ។ ដូច្នេះ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទៅ ផែនការថ្លៃអគ្គិសនីនៅខេត្តកោះកុង នឹងមានស្ថានភាព ដូចផែនការខាងក្រោម ៖

### ក.ការផ្គត់ផ្គង់អគ្គិសនីធំពីអនុស្ថានីយ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

### ខ.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជា អាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

### គ.តំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប និងតំបន់ចែកចាយរបស់សេវាករឯកជននានា ដែលបានទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ដូចបានជម្រាបជូនខាងលើ តាមផែនការរបស់រាជរដ្ឋាភិបាល អគ្គិសនីកម្ពុជាគ្រោងរៀបចំការអភិវឌ្ឍន៍ខ្សែបណ្តាញបញ្ជូនរង ដើម្បីបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិតាតៃ ទៅផ្តល់ឲ្យតំបន់ចែកចាយរបស់សេវាករឯកជននានានៅក្នុងខេត្តកោះកុង។ នៅពេលដែលតំបន់ចែកចាយរបស់សេវាករឯកជននានាទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា រួមទាំងតំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប ផង ពេលនោះថ្លៃអគ្គិសនីនឹងត្រូវអនុវត្តតាមផែនការបន្ថយថ្លៃ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញMVពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ឃ.តំបន់ចែកចាយដែលនៅប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនី

ចំពោះតំបន់ចែកចាយដែលប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីទាំង ២ តំបន់ នៅខេត្តកោះកុង គឺ ទី១ តំបន់របស់សេវាករ ផាត សុជា នៅឃុំជ្រោយប្រស់ តាតៃក្រោម និងត្រពាំងរូង ស្រុកកោះកុង និងទី២ តំបន់របស់សេវាករ អាន់ សំឡាន នៅឃុំកោះស្តេច ស្រុកគិរីសាគរ (នឹងអាចមាន ២ តំបន់ទៀត នៅតំបន់កោះក្នុងសមុទ្រ គ្រោងចេញអាជ្ញាប័ណ្ណឲ្យក្នុងពេលឆាប់ៗ នេះ) ។ នៅពេលបច្ចុប្បន្ននេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយនីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនីនឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីរបស់តំបន់នេះនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីទាំង ២ តំបន់ នៅខេត្តកោះកុង យើងពុំមានជម្រើសអ្វីក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាងពីអនុស្ថានីយបណ្តាញជាតិ ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ ។ ចំពោះតំបន់របស់សេវាករ ផាត សុជា នៅឃុំជ្រោយប្រស់ ឃុំតាតៃក្រោម និងឃុំត្រពាំងរូង ស្រុកកោះកុង នឹងអាចមានខ្សែបញ្ជូនរងទៅគ្របដណ្តប់ នៅឆ្នាំ ២០១៦ ដែលអាចអនុវត្តថ្លៃអគ្គិសនីតាមផែនការបាន ។ ដោយឡែកចំពោះតំបន់កោះក្នុងសមុទ្រ អគ្គិសនីកម្ពុជាកំពុងពិនិត្យមើលលទ្ធភាពក្នុងការដាក់ខ្សែកាបនៅបាតសមុទ្របញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅឲ្យ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្ដាញជាតិ នៅខេត្តព្រៃវែង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រៃវែង

### ក.បណ្ដាញជាតិ និងបណ្ដាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តព្រៃវែង មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ។ តាមផែនការរបស់រាជរដ្ឋាភិបាល គឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិន ចំនួន ១៥០ លានដុល្លាអាមេរិក នៅឆ្នាំ ២០១៤ ដើម្បីអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយភ្ជាប់ពីភ្នំពេញ ទៅខេត្តស្វាយរៀង ឆ្លងកាត់តាមខេត្តព្រៃវែង ដោយក្នុងនោះមានការសាងសង់អនុស្ថានីយចំនួន ២ កន្លែង មួយកន្លែងនៅទីរួមខេត្តព្រៃវែង ដើម្បីផ្គល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តព្រៃវែង និងមួយកន្លែងនៅទីរួមខេត្តស្វាយរៀង ដើម្បីផ្គល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តស្វាយរៀង។ អនុស្ថានីយទាំង ២ នេះ គ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៧ ខាងមុខ ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តព្រៃវែង ជាបណ្តោះអាសន្ន ក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យក្រុមហ៊ុន ភី.អេស.ភី.ស៊ី អ៊ិនវេសមេន និងក្រុមហ៊ុន ញ៉េម ហ៊ិន អេឡិកទ្រីខល ធ្វើការអភិវឌ្ឍន៍សាងសង់បណ្តាញ ២២ គីឡូវ៉ុល នាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្គល់ឲ្យតំបន់ចែកចាយរបស់ក្រុមហ៊ុនទាំង ២ ផ្ទាល់ និងលក់ដុំបន្តឲ្យអគ្គិសនីកម្ពុជា និងសេវាករចែកចាយឯកជនមួយចំនួននៅភាគខាងត្បូង និងខាងកើតនៃខេត្តព្រៃវែង ។ ក្រៅពីនោះក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា ក៏បានអនុញ្ញាតឲ្យក្រុមហ៊ុន អ៊ី.ឌី.ឧន ធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល នាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្គល់ឲ្យតំបន់ចែកចាយរបស់ក្រុមហ៊ុនផ្ទាល់ និងលក់ដុំបន្តឲ្យបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី ស៊ីលូស៊ិន ឧបភើរេស៊ិន និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលបានធ្វើការបញ្ជូនរងប្រភពអគ្គិសនីនេះ បន្តផ្គល់ឲ្យសេវាករឯកជនមួយចំនួននៅភាគខាងជើង និងខាងលិចនៃខេត្តព្រៃវែង ផងដែរ ។ ក្រៅពីនេះ អគ្គិសនីកម្ពុជាបានប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិន ចំនួន ៥០ លានដុល្លាអាមេរិក នៅឆ្នាំ ២០១៣ ដើម្បីធ្វើការអភិវឌ្ឍន៍ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីពីប្រទេសវៀតណាម ដែលខ្លួនបានទិញពីសេវាករឯកជននាំចូលអគ្គិសនីពីប្រទេសវៀតណាម ទាំងនោះ ទៅផ្គល់ឲ្យតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និងរបស់សេវាករចែកចាយឯកជនមួយចំនួនធំ ក្នុងខេត្តព្រៃវែង ។ តាមបទដ្ឋានបច្ចេកទេសការបញ្ជូនអគ្គិសនីរបស់ខ្សែ ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ ទៅ ៧០ គីឡូម៉ែត្រ ប៉ុណ្ណោះ ប៉ុន្តែយើងបានអនុញ្ញាតឲ្យបណ្តាញបញ្ជូនរងដូចបានរៀបរាប់ខាងលើ ជួយបញ្ជូនអគ្គិសនីជាបណ្តោះអាសន្ននេះ រហូតដល់ជាង ១០០ គីឡូម៉ែត្រ លើសពីបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីមានអគុណភាព និងមានអោក់អេ្ហលញឹកញាប់ ចំណែកការបាត់បង់អគ្គិសនីលើបណ្តាញ មានបរិមាណច្រើនលើសពីខេត្តដទៃ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ នៅខេត្តព្រៃវែង យើងពុំមានជម្រើសអ្វីផ្សេងក្រៅពីនេះទេ ពីព្រោះមានតែការធ្វើបែបនេះទេ ទើបយើងអាចបន្ថយថ្លៃអគ្គិសនីនៅតំបន់មួយចំនួនធំនៃខេត្តព្រៃវែង ឲ្យថយចុះពីជាង ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យមកនៅក្នុងចន្លោះ ១,០៥០ទៅ១,១០០រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដូចបច្ចុប្បន្នបាន ។

ម្យ៉ាងទៀតមានតែធ្វើយ៉ាងនេះទេ ទើបយើងអាចអភិវឌ្ឍន៍បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនធំហើយស្រេច រង់ចាំពេលណាមានអនុស្ថានីយផ្ទាល់នៅខេត្តព្រៃវែង ពេលនោះយើងអាចបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ ទៅកាន់តំបន់ចែកចាយនានាក្នុងខេត្តនេះបានតែម្តង រួចទុកពេលនៅសល់ ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់ដែលនៅពុំទាន់មានអគ្គិសនីប្រើប្រាស់វិញ ។

ដូច្នេះដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តព្រៃវែងគឺការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនី ភ្ជាប់ភ្នំពេញ-ព្រៃវែង-ស្វាយរៀង ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តព្រៃវែង រួចបង្វែរបណ្តាញបញ្ជូនរងដែលមានស្រាប់របស់ក្រុមហ៊ុនឯកជនខាងលើ និងបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ឲ្យមកភ្ជាប់ប្រភពអគ្គិសនីពីអនុស្ថានីយខេត្តព្រៃវែង វិញ។ ពេលនោះបញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនី មុខជាអាចដោះស្រាយបាន ដូចខេត្តដទៃទៀត ជាមិនខាន ។

ទោះជាគម្រោងបង្កើតអនុស្ថានីយបណ្តាញជាតិមួយនៅខេត្តព្រៃវែង ផ្ទាល់ខាងលើ មិនទាន់ដាក់ឲ្យដំណើរការក្នុងចន្លោះឆ្នាំ ២០១៥-២០១៦ ក៏ដោយ ក៏ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានរៀបផែនការបន្ថយថ្លៃលក់អគ្គិសនីមួយ ដែលនឹងចាប់ផ្តើមអនុវត្តពីខែ មីនា ឆ្នាំ ២០១៦ នៅតំបន់ចែកចាយមួយចំនួនធំក្នុងខេត្តព្រៃវែងដោយមិនរង់ចាំការដាក់ឲ្យដំណើរការអនុស្ថានីយខេត្តព្រៃវែងទេ។ ផែនការបន្ថយថ្លៃលក់អគ្គិសនីនេះ មានគោលដៅធ្វើឲ្យ ៖ ១.អត្រាថ្លៃលក់ដុំប្រភពអគ្គិសនីឲ្យតំបន់ចែកចាយអគ្គិសនី និង២.អត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់លើតង់ស្យុងមធ្យម ចេញពីបណ្តាញបញ្ជូនរងទាំងឡាយ ទាំងរបស់អគ្គិសនីកម្ពុជា និងទាំងរបស់ឯកជននៅខេត្តព្រៃវែង ទាំងមូល មានអត្រាដូចគ្នាជាមួយខេត្តដែលបណ្តាញជាតិគ្របដណ្តប់ផ្ទាល់ដែរ ដោយអគ្គិសនីកម្ពុជា ជាអ្នកប៉ះប៉ូវការបាត់បង់ដែលខ្ពស់ជាងកម្រិតកំណត់ ដោយសារការបញ្ជូនឆ្ងាយហួសពីបទដ្ឋាន ។ នៅពេលដែលអនុស្ថានីយខេត្តព្រៃវែង បានសង់រួច អត្រាថ្លៃទាំងនេះ ក៏នៅបន្តតាមផែនការដដែលទៀត ដោយគ្រាន់តែពេលនោះ អគ្គិសនីកម្ពុជាអាចដកចេញបាននូវបន្ទុកដែលខ្លួនត្រូវប៉ះប៉ូវតែប៉ុណ្ណោះ ។ អ្វីដែលលើសនៅពេលដែលខេត្តព្រៃវែង មានអនុស្ថានីយ គឺពេលនោះបណ្តាញបញ្ជូនរងខាងលើ និងរោងចក្រឧស្សាកម្មធំៗ អាចទិញប្រភពអគ្គិសនីពីទ្វារចេញអនុស្ថានីយផ្ទាល់បាន ។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តព្រៃវែង មានក្រុង ១ ឈ្មោះក្រុងព្រៃវែង និងស្រុកចំនួន ១២ គឺ ៖ ១.ស្រុកពារាំង ២.ស្រុកស៊ីធរកណ្តាល ៣.ស្រុកកញ្ជ្រៀច ៤.ស្រុកកំពង់លាវ ៥.ស្រុកមេសាង ៦.ស្រុកកំពង់ត្របែក ៧.ស្រុកបាភ្នំ ៨.ស្រុកពាមរក៍ ៩.ស្រុកពោធិ៍រៀង ១០.ពាមជរ ១១.ស្រុកកំចាយមារ និង១២.ស្រុកព្រះស្តេច។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តព្រៃវែង មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ពីអនុស្ថានីយទេ ដោយសារក្នុងខេត្តព្រៃវែង នេះ មិនទាន់មានអនុស្ថានីយរបស់ខ្លួនផ្ទាល់ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តព្រៃវែង បច្ចុប្បន្ន គឺមានតែការផ្គត់ផ្គង់តាមតង់ស្យុងមធ្យមឲ្យអ្នកប្រើប្រាស់ធំៗ ពីបណ្តាញបញ្ជូនរងនានាដែលមាន និងការផ្គត់ផ្គង់អគ្គិសនីរាយឲ្យអ្នកប្រើប្រាស់ធម្មតា តាមតំបន់ចែកចាយនីមួយៗ។ការផ្គត់ផ្គង់អគ្គិសនីរាយឲ្យអ្នកប្រើប្រាស់អគ្គិសនីតាមតំបន់ចែកចាយ ត្រូវបានដោះស្រាយដោយរបៀប ២យ៉ាងគឺ ៖ ទី១.ចំពោះក្រុងព្រៃវែង និងតំបន់ចែកចាយសំខាន់ៗ មួយចំនួន ដោះស្រាយដោយការបញ្ជូនប្រភព

អគ្គិសនីពីអនុស្ថានីយរាជធានីភ្នំពេញ ទៅផ្តល់ឲ្យ រួមបន្ថែមជាមួយប្រភពអគ្គិសនីដែលអគ្គិសនីកម្ពុជាទិញពីអ្នកនាំចូលអគ្គិសនីពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល របស់ក្រុមហ៊ុនឯកជននានា ទី២.ចំពោះតំបន់ចែកចាយខ្លះ ដោះស្រាយដោយអនុញ្ញាតឲ្យអ្នកបញ្ជូនរងឯកជនទិញប្រភពអគ្គិសនីបន្តពីអគ្គិសនីកម្ពុជា ឬទិញបន្តពីអ្នកនាំចូលអគ្គិសនីពីប្រទេសវៀតណាម មកផ្គត់ផ្គង់ឲ្យតំបន់ចែកចាយ និងទី៣.ចំពោះតំបន់ចែកចាយខ្លះទៀតដែលនៅឆ្ងាយ អនុញ្ញាតឲ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយឯកជនខ្លះ បញ្ជូនបន្តគ្នាជាលក្ខណៈបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តព្រៃវែង ពុំមានតំបន់ចែកចាយអគ្គិសនីដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដ្យេសែលទៀតទេ ។ បច្ចុប្បន្ន នៅក្នុងខេត្តព្រៃវែង មានតំបន់ចែកចាយអគ្គិសនីចំនួន ២៦ តំបន់ ដែលក្នុងនោះ ១ តំបន់ ជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងព្រៃវែង និង ២៥ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ២៥ តំបន់ នៅក្នុងខេត្តព្រៃវែងនោះ ចែកចេញជា ៖

- តំបន់ចែកចាយចំនួន ១២ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលភ្ជាប់ពីក្រុងព្រៃវែង ទៅបណ្តាញនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម របស់ក្រុមហ៊ុន ភី.អេស.ភី.ស៊ី អ៊ិនវេសមេន (ក្នុង ១២ តំបន់នោះ មាន ១ តំបន់ក៏បានទិញអគ្គិសនីបន្ថែមពីក្រុមហ៊ុន ញ៉ែម ហ៊ន អេឡិកទ្រិកខល ផងដែរ)
- តំបន់ចែកចាយចំនួន ២ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់សហគ្រាស អេឡិចទ្រីស៊ីធី ត្បូងឃ្មុំ ដែលភ្ជាប់ប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពង់ចាម
- តំបន់ចែកចាយចំនួន ៤ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើប៊ីភី សឺលូសិន ខបភើរេសិន ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងពីក្រុមហ៊ុន អ៊ី.ឌី.ខន ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម ក្នុងចំណោម ៤ តំបន់នោះ មាន ១ តំបន់ ជាតំបន់របស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខ្លួនឯង (ក្នុង ៤ តំបន់នោះ មាន ២ តំបន់ក៏បានទិញអគ្គិសនីបន្ថែមពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ផងដែរ)
- តំបន់ចែកចាយចំនួន ៤ តំបន់ គឺជាតំបន់ទិញប្រភពអគ្គិសនីដោយការបញ្ជូនបន្តគ្នា របស់តំបន់ចែកចាយដែលបានទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខបភើរេសិន
- តំបន់ចែកចាយចំនួន ៣ តំបន់ ជាតំបន់ចែកចាយ ដែលនាំចូលប្រភពគ្គិសនីពីប្រទេសវៀតណាម ក្នុងនោះមានក្រុមហ៊ុន អ៊ី.ឌី.ខន ក្រុមហ៊ុន ភី.អេស.ភី.ស៊ី អ៊ិនវេសមេន និងក្រុមហ៊ុន ញ៉ែម ហ៊ន អេឡិកទ្រិខល ។

**បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនៅក្នុងខេត្តព្រៃវែង**

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | ក្រុមហ៊ុន ឃុន សុផល | 088 L | GS-TBK | ស្រុកស្វាយអន្ទរ |
| 2 | សេវាករ ស្រ៊ិន ឈន | 310 L | GS-TBK | ស្រុកមេសាង |
| 3 | សហគ្រាស កំពង់ចម្លង បាក់ដាវ | 272 L | GS-TPLC | ស្រុកពារាំង |
| 4 | ក្រុមហ៊ុន អ៊ី ឌី ខន | 122 L | VN | ស្រុកកំចាយមារ |
| 5 | ក្រុមហ៊ុន ភីអ៊ិនវេសមេន ស៊ី.ភី.អេស. | 206 L | VN | ស្រុកពាមរក៍ព្រះស្តេច- |
| 6 | ក្រុមហ៊ុន ញ៉ែម ហ៊ន អេឡិចទ្រីខល | 343 L | VN | ស្រុកបាភ្នំ |
| 7 | សេវាករ សៀន ណារិទ្ធ | 247 L | VN-EDC | ស្រុកកំពង់ត្របែក |

| | | | | |
|---|---|---|---|---|
| 8 | ក្រុមហ៊ុន អ៊ីនជើ ប៊ីភី សឺលូសិន ឧបភើរេសិន | 259 L | VN-EDCon & GS-EDC | ស្រុកស្វាយអន្ទរកំចាយមា- |
| 9 | សេវាករ គី សុភា | 018 L | VN-EDCon-IBPSC | ស្រុកពារាំង |
| 10 | សេវាករ ជួប នាង | 045 L | VN-EDCon-IBPSC & EDC | ស្រុកពារាំង |
| 11 | សេវាករ ឆេង គីមហៀក | 294 L | VN-EDCon-IBPSC | ស្រុកពារាំង |
| 12 | សេវាករ អៃ លីហួរ | 299 L | VN-EDCon-IBPSC & EDC | ស្រុកពារាំង |
| 13 | សេវាករ ពោជ គីម | 036 L | VN-NHEM HORN | ស្រុកកំពង់ត្របែក |
| 14 | អគ្គិសនីកម្ពុជា(ព្រៃវែង) | 001 L | VN-PSPC & VN-EDCon | ក្រុងព្រៃវែង |
| 15 | សេវាករ សេង សុគន្ធ | 046 L | VN-PSPC-EDC | ស្រុកស្វាយអន្ទរ |
| 16 | សេវាករ ខឹម វ៉ានី | 187 L | VN-PSPC-EDC & N.HORN | ស្រុកកំពង់ត្របែក |
| 17 | សេវាករ កែវ ចំរើន | 208 L | VN-PSPC-EDC | ស្រុកកញ្ជ្រៀច |
| 18 | លោក ចាន់ សុធា | 239 L | VN-PSPC-EDC | ស្រុកមេសាង |
| 19 | សេវាករ នៅ សុភា | 267 L | VN-PSPC-EDC | ស្រុកបាភ្នំ |
| 20 | សេវាករ គង់ យោន | 269 L | VN-PSPC-EDC | ស្រុកមេសាង |
| 21 | សេវាករ ឡុង ហៃ | 284 L | VN-PSPC-EDC | ស្រុកពាមរក៍ |
| 22 | សេវាករ លាង សុវាវង្ស | 295 L | VN-PSPC-EDC | ស្រុកស៊ីធរកណ្ដាល |
| 23 | សេវាករ ជួក សាមាន | 320 L | VN-PSPC-EDC | ស្រុកមេសាង |
| 24 | សេវាករ ម៉ុង សុភាព | 322 L | VN-PSPC-EDC | ស្រុកពោធិ៍រៀង |
| 25 | សេវាករ ហ៊ាង ផល្លី | 336 L | VN-PSPC-EDC | ស្រុកមេសាង |
| 26 | លោក ឈរ វែងងួន | 355 L | VN-PSPC-EDC | ស្រុកពោធិ៍រៀង |

# ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តព្រៃវែង



## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តព្រៃវែង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បាភ្នំ | 108 | 108 | 100.00% | 79 | 73.15% | 29 |
| កំចាយមារ | 129 | 128 | 99.22% | 58 | 44.96% | 70 |
| កំពង់ត្របែក | 122 | 119 | 97.54% | 57 | 46.72% | 62 |
| ក្រញៀច | 99 | 99 | 100.00% | 66 | 66.67% | 33 |
| មេសាង | 118 | 118 | 100.00% | 105 | 88.98% | 13 |
| ពាមជរ | 50 | 49 | 98.00% | 8 | 16.00% | 41 |
| ពាមរក៍ | 40 | 40 | 100.00% | 26 | 65.00% | 14 |
| ពារាំង | 74 | 67 | 90.54% | 60 | 81.08% | 7 |
| ព្រះស្តេច | 145 | 131 | 90.34% | 20 | 13.79% | 111 |
| ព្រៃវែង | 15 | 15 | 100.00% | 15 | 100.00% | - |
| កំពង់លាវ | 39 | 39 | 100.00% | 28 | 71.79% | 11 |
| ស៊ីធរកណ្តាល | 60 | 49 | 81.67% | 40 | 66.67% | 9 |
| ស្វាយអន្ទរ | 138 | 137 | 99.28% | 95 | 68.84% | 42 |
| **សរុប** | **1,137** | **1,099** | **96.66%** | **657** | **57.78%** | **442** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តព្រៃវែង

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តព្រៃវែង អាចបែងចែកជាផែនការដោយឡែក ទៅតាមការផ្គត់ផ្គង់អគ្គិសនីចំនួន ៦ ប្រភេទ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង ទាំងរបស់ឯកជន និងទាំងរបស់អគ្គិសនីកម្ពុជា ៣.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងព្រៃវែង ៤.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទិញប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា ចេញពីក្រុងព្រៃវែង និងទិញពីសហគ្រាសអេឡិចទ្រីស៊ីធី ត្បូងឃ្មុំ ៥.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលបានទិញប្រភពអគ្គិសនី ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី ស៊ីលូសិន ឧបករើរសិន ដែលទិញប្រភពអគ្គិសនីបន្តពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ៦.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយ ដែលទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី ស៊ីលូសិន ឧបករើរសិន និង៧.ការផ្គត់ផ្គង់អគ្គិសនីរាយនៅតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលបាននាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តព្រៃវែង ត្រូវបានបែងចែកជា ៧ ផែនការទៅតាមប្រភេទនៃការផ្គត់ផ្គង់អគ្គិសនី ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

ដូចបានជំរាបជូនខាងលើ តាមផែនការវិនិយោគដែលរាជរដ្ឋាភិបាលបានសម្រេច គឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិន ចំនួន ១៥០ លានដុល្លាអាមេរិក ដើម្បីអភិវឌ្ឍន៍បណ្តាញ

ជាតិ និងអនុស្ថានីយភ្ជាប់ភ្នំពេញ-ព្រៃវែង-ស្វាយរៀង ដោយក្នុងនោះ មានការសាងសង់អនុស្ថានីយបណ្តាញជាតិមួយកន្លែងនៅខេត្តព្រៃវែង ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៧ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តព្រៃវែង ។ ដូច្នេះនៅមុនឆ្នាំ ២០១៧ នៅខេត្តព្រៃវែង ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំឲ្យអ្នកប្រើប្រាស់ផ្ទាល់ពីអនុស្ថានីយឡើយ រួចចាប់ពីឆ្នាំ ២០១៧ ទៅ ទើបខេត្តព្រៃវែង មានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ។ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយចាប់ពីឆ្នាំ ២០១៧ នឹងមានអត្រាថ្លៃអគ្គិសនី តាមផែនការដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនវងនានានៅខេត្តព្រៃវែង

ដោយសារនៅខេត្តព្រៃវែង ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះការផ្គត់ផ្គង់អគ្គិសនីធំចេញពីបណ្តាញបញ្ជូនវងនានា នៅក្នុងរយៈពេលមិនទាន់មានអនុស្ថានីយនៅខេត្តព្រៃវែង (២០១៥-២០១៦) ត្រូវបានអគ្គិសនីកម្ពុជាជួយប៉ះប៉ូវការបាត់បង់លើខ្សែខ្លះ ដើម្បីឲ្យថ្លៃលក់អគ្គិសនីធំចេញពីបណ្តាញបញ្ជូនវងទាំងនេះ មានអត្រាដូចគ្នាជាមួយការលក់របស់បណ្តាញបញ្ជូនវងដែលចេញពីបណ្តាញជាតិដ៏ទៃទៀត ។ ថ្លៃលក់អគ្គិសនីធំចេញពីបណ្តាញបញ្ជូនវង សម្រាប់អ្នកប្រើប្រាស់ធំៗ ចេញពីបណ្តាញបញ្ជូនវងនានា នៅក្នុងខេត្តព្រៃវែង នឹងអនុវត្តតាមផែនការ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនវង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនវងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងព្រៃវែង

នៅឆ្នាំ ២០១៥ ដោយសារប្រភពអគ្គិសនីផ្តល់ឲ្យក្រុងព្រៃវែងពុំទាន់ត្រូវបានដោះស្រាយបានពេញលេញ ដូច្នេះថ្លៃលក់អគ្គិសនី នឹងនៅបន្តតាមបញ្ជីថ្លៃលក់ដែលកំពុងអនុវត្តបច្ចុប្បន្នដដែល ដូចខាងក្រោម៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ១,០៥០ ៛ / kWh | ស្ថាប័នរដ្ឋ | ១,០៥០ ៛ / kWh |
| **ពាណិជ្ជកម្ម-ឧស្សាហកម្ម** | | | |
| តង់ស្យុងទាបធុនតូច | ១,០៥០ ៛ / kWh | តង់ស្យុងទាបធុនមធ្យម | ៩៨០ ៛ / kWh |
| តង់ស្យុងទាបធុនធំ | ៩២០ ៛ / kWh | តង់ស្យុងមធ្យម | ៨៥០ ៛ / kWh |
| **កសិកម្ម** | | | |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | | | ៨៥០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | | | ៦០០ ៛ / kWh |
| **អតិថិជនក្រៅដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា នៅខេត្តព្រៃវែង ដែលជាវពីបណ្តាញបញ្ជូនវង** | | | |
| ពាណិជ្ជកម្ម-ឧស្សាហកម្ម | | | ៨០០ ៛ / kWh |

| កសិកម្ម | |
|---|---|
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | ៨០០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | ៦០០ ៛ / kWh |

យោងតាម «ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី» របស់រាជរដ្ឋាភិបាល ចាប់ពីខែ មីនា ឆ្នាំ ២០១៦ លើមូលដ្ឋាននៃការប៉ះប៉ូវរបស់អគ្គិសនីកម្ពុជា ថ្លៃខាងលើនេះ នឹងត្រូវអនុវត្តតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលយកប្រភពអគ្គិសនី ពីអគ្គិសនីកម្ពុជា ចេញពីក្រុងព្រៃវែង និងទិញពីសហគ្រាសអេឡិចទ្រីស៊ីធីត្បូងឃ្មុំ

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២៥ តំបន់ មានតំបន់ចែកចាយអគ្គិសនីចំនួន ១៤ តំបន់ អាចចាត់ទុកថាជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិបាន ក្នុងនោះ ១២ តំបន់ គឺជាតំបន់ចែកចាយដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាចេញពីក្រុងព្រៃវែង ដែលបច្ចុប្បន្ននៅទីនោះ EDC មានប្រភពអគ្គិសនីចំនួន ២ គឺ ទី១.ប្រភពអគ្គិសនីចេញពីក្រុងព្រៃវែង ដែលទទួលបានពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលបានភ្ជាប់ពីអនុស្ថានីយរាជធានីភ្នំពេញ និងទី២.ប្រភពអគ្គិសនីដែលអគ្គិសនីកម្ពុជាទិញបន្តពីសេវាករឯកជននាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និង ២ តំបន់ទៀត ដែលមានដែនចែកចាយបន្តពីខេត្តត្បូងឃ្មុំ ដែលបានទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់សហគ្រាស អេឡិចទ្រីស៊ីធីត្បូងឃ្មុំ ។ បច្ចុប្បន្នតំបន់ចែកចាយទាំង ១៤ តំបន់នេះ មានថ្លៃលក់អគ្គិសនី ស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង។ ដោយសារប្រភពអគ្គិសនីរបស់ EDC នៅយកប្រភពអគ្គិសនីពីប្រទេសវៀតណាម រួចថ្លៃអគ្គិសនីនាំចូលពីប្រទេសវៀតណាម ត្រូវបានវៀតណាមតម្លើងថ្លៃចំនួន ៧.៥០% បន្ថែមទៀត ចាប់ពីថ្ងៃទី ១៦ ខែ មីនា

ឆ្នាំ ២០១៥ ដូច្នេះនៅឆ្នាំ ២០១៥ នេះ ថ្លៃលក់អគ្គិសនីនៅតំបន់ទាំង ១៤ នេះ នឹងរក្សាអត្រាទុកស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដដែល រួចចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទើបថ្លៃលក់អគ្គិសនីនៅតំបន់ទាំង ១៤ នេះ នឹងត្រូវបន្ថយចុះតាមផែនការបន្ថយថ្លៃរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម10kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខបភើរេសិន ដែលទិញប្រភពអគ្គិសនីបន្តពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២៥ តំបន់ មានតំបន់ចែកចាយអគ្គិសនីចំនួន ៤ តំបន់ គឺជាតំបន់ចែកចាយអគ្គិសនី ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខបភើរេសិន ដែលទិញប្រភពអគ្គិសនីបន្តពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។ បច្ចុប្បន្នតំបន់ចែកចាយទាំង ៤ តំបន់ខាងលើនេះ មានថ្លៃលក់អគ្គិសនីស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់នេះ នឹងត្រូវបន្ថយចុះតាមផែនការរួម ដូចខាងក្រោម ៖

<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,០៥០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៦** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៦** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៦ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយដែលទិញផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខបភើរេសិន

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២៥ តំបន់ខាងលើ មានតំបន់ចែកចាយអគ្គិសនីចំនួន ៤ តំបន់ គឺជាតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយដែលយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ិនធើ ប៊ីភី សឺលូសិន ខបភើរេសិន ដែលក៏បានយកប្រភពអគ្គិសនីបន្តពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា។ បច្ចុប្បន្នតំបន់ចែកចាយទាំង ៤ តំបន់ខាងលើនេះ មានថ្លៃលក់អគ្គិសនីស្មើនឹង ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងកំពុងបន្ថយថ្លៃមកនៅត្រឹម ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដោយអគ្គិសនីកម្ពុជាជាអ្នកជួយទទួលបន្ទុកចេញថ្លៃសេវាបញ្ជូនបន្តចំនួន០.៥០ សេនអាមេរិកក្នុង១ គីឡូវ៉ាត់ម៉ោង ឲ្យទៅតំបន់ចែកចាយដែលបានជួយបញ្ជូនបន្ត។ យោងតាមផែនការដែលបានគ្រោងអគ្គិសនីកម្ពុជាត្រូវរៀបចំយ៉ាងណាឲ្យតំបន់ចែកចាយទាំង ៤ តំបន់ខាងលើនេះអាចទទួលប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរង រួចចាប់ពីខែមីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់នេះ នឹងត្រូវបន្ថយចុះតាមផែនការរួម ដូចតំបន់ខាងលើដែរ ។

## ២.៧ តំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលបាននាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២៥ តំបន់ មានតំបន់ចែកចាយអគ្គិសនីឯកជនចំនួន ៣ តំបន់ដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម គឺក្រុមហ៊ុន ភី.អេស.ភី.ស៊ី អ៊ិនវេសមេន ក្រុមហ៊ុន ញ៉ែម ហ៊ន អេឡិកទ្រិខល និងក្រុមហ៊ុន អ៊ី.ឌី.ឌន ។ បច្ចុប្បន្នតំបន់ចែកចាយរបស់ក្រុមហ៊ុន ភី.អេស.ភី.ស៊ី អ៊ិនវេសមេន មានថ្លៃលក់អគ្គិសនី ស្មើនឹង ៨០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង តំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ី.ឌី.ឌន មានថ្លៃលក់អគ្គិសនី ស្មើនឹង ៨០០រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងតំបន់ចែកចាយរបស់ក្រុមហ៊ុន ញ៉ែម ហ៊ន អេឡិកទ្រិខល មានថ្លៃលក់អគ្គិសនី ស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ដោយសារតំបន់ចែកចាយទាំងនេះ នៅយកប្រភពអគ្គិសនីពីប្រទេសវៀតណាម រួចថ្លៃអគ្គិសនីនាំចូលពីប្រទេសវៀតណាមត្រូវបានវៀតណាម តម្លើងថ្លៃចំនួន ៧.៥០% បន្ថែមទៀត ចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ ដូច្នេះនៅឆ្នាំ ២០១៥ នេះ ថ្លៃលក់អគ្គិសនីនៅតំបន់ទាំង ៣ នេះ នឹងរក្សាអត្រាទុកដដែល ។ យើងបន្តកំណត់ថ្លៃលក់អគ្គិសនីតាមស្ថានភាពថ្លៃដើមជាក់ស្តែង និងការវិនិយោគធ្វើយ៉ាងណា ដើម្បីធានាឲ្យមានស្ថេរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីរបស់តំបន់ទាំង ៣ នេះ ដាបណ្តោះអាសន្នសិន រហូតដល់ខេត្តព្រៃវែង មានអនុស្ថានីយ

បណ្តាញជាតិបិតនៅក្នុងខេត្តរបស់ខ្លួននៅឆ្នាំ ២០១៧ ដែលអគ្គិសនីកម្ពុជាអាចបញ្ចូលតំបន់ចែកចាយទាំង ៣ នេះ ទៅក្នុងតំបន់ផ្គត់ផ្គង់ប្រភពអគ្គិសនីរបស់បណ្តាញជាតិបាន ។ ក្នុងគោលដៅដោះស្រាយបញ្ហាថ្លៃអគ្គិសនីនៅតំបន់ទាំង ៣ នេះ នៅពេលដែលខេត្តព្រៃវែង មានអនុស្ថានីយរបស់ខ្លួនផ្ទាល់រួចហើយ ជាពិសេសតំបន់ចែកចាយរបស់ក្រុមហ៊ុន ញ៉ែម ហ៊ិន អេឡិកទ្រិខល ដែលមានថ្លៃអគ្គិសនីខ្ពស់ ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៧ ពេលដែលខេត្តព្រៃវែង មានអនុស្ថានីយបណ្តាញជាតិផ្ទាល់ខ្លួនហើយ អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា មានផែនការរៀបចំឲ្យតំបន់ទាំង ៣ នេះ ប្រើបញ្ចូលគ្នារវាងប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម និងប្រភពអគ្គិសនីចេញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលចេញពីអនុស្ថានីយបណ្តាញជាតិខេត្តព្រៃវែង ដើម្បីឲ្យថ្លៃលក់អគ្គិសនីនៅតំបន់ខាងលើនេះ អាចនឹងថយចុះទៅតាមផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដូចតំបន់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនីបណ្តាញជាតិដែរ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តត្បូងឃ្មុំ សម្រាប់ឆ្នាំ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តត្បូងឃ្មុំ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

ខេត្តត្បូងឃ្មុំ គឺជាខេត្តមួយដែលបានបំបែកចេញពីខេត្តកំពង់ចាម ក្នុងរយៈពេលថ្មីៗនេះ ។ ពីមុនមក តំបន់ទាំងឡាយក្នុងខេត្តត្បូងឃ្មុំនេះ គឺជាតំបន់ដែលផ្គត់ផ្គង់ដោយប្រព័ន្ធទោលដាច់ដោយឡែក តំបន់ខ្លះក៏បាន ទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម តំបន់ខ្លះក៏ផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដៀសែល ។ ចាប់តាំង ពីឆ្នាំ ២០១៣ ក្រោយពេលដែលអនុស្ថានីយបណ្តាញជាតិនៅខេត្តកំពង់ចាម ត្រូវបានសាងសង់រួច តំបន់ចែក ចាយមួយចំនួនក្នុងខេត្តនេះ ទទួលបានប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរង ដែលបានបញ្ជូនប្រភពអគ្គិសនីពី អនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ។

ការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ទៅឲ្យតំបន់ចែកចាយនានា នៅ ខេត្តត្បូងឃ្មុំ គឺធ្វើតាមបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុនចំនួន ២ គឺ ៖ បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងបណ្តាញបញ្ជូនរងរបស់សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ ។ ក្រៅពីការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយ បណ្តាញជាតិខេត្តកំពង់ចាម ដោយបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុនទាំង ២ ខាង លើនេះ ក៏នៅមានការបញ្ជូន ប្រភពអគ្គិសនីបន្តរបស់តំបន់ចែកចាយមួយ ទៅឲ្យតំបន់ចែកចាយមួយទៀតជាបណ្តោះអាសន្ន ក្នុងពេលដែល បណ្តាញបញ្ជូនរងក្នុងខេត្តត្បូងឃ្មុំ ពុំទាន់អាចពង្រីកខ្លួនគ្របដណ្តប់ទូទាំងខេត្តត្បូងឃ្មុំបាន និងបន្ថែមពីលើនោះ ចំពោះតំបន់ចែកចាយដែលនៅក្បែរព្រំដែនប្រទេសវៀតណាម ក៏មានការនាំចូលប្រភពអគ្គិសនីពីប្រទេសវៀត ណាម តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល ផងដែរ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តត្បូងឃ្មុំ មានក្រុង ១ ឈ្មោះក្រុងសួង និងស្រុកចំនួន ៦ គឺ៖ ១.ស្រុកអូររាំងឪ ២.ស្រុកក្រូចឆ្មារ ៣.ស្រុកមេមត់ ៤.ស្រុកពញាក្រែក ៥.ស្រុកដំបែរ និង៦.ស្រុកត្បូងឃ្មុំ ។ បច្ចុប្បន្ននេះការផ្គត់ ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តត្បូងឃ្មុំ មិនមាន**ការផ្គត់ផ្គង់អគ្គិសនីធំ** ពីអនុស្ថានីយទេ ដោយសារក្នុងខេត្តនេះ មិនទាន់មានអនុស្ថានីយ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តត្បូងឃ្មុំ គឺមានតែ**ការផ្គត់ផ្គង់អគ្គិសនីធំ**ពីបណ្តាញបញ្ជូនរងចំនួន ២ ក្រុមហ៊ុនខាងលើ និង**ការផ្គត់ផ្គង់អគ្គិសនី រាយ** តាមតំបន់ចែកចាយនីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ ត្រូវបានដោះស្រាយដោយ របៀប ២ យ៉ាង ទី១.ចំពោះតំបន់ចែកចាយចំនួន ៤ តំបន់ ក្នុងនោះមានតំបន់រដ្ឋបាលសាលាខេត្តត្បូងឃ្មុំ ដែល រាជរដ្ឋាភិបាលទើបបង្កើតថ្មីផងដែរ ត្រូវបានប្រគល់ឲ្យអគ្គិសនីកម្ពុជាជាអ្នកផ្គត់ផ្គង់ និងទី២.ចំពោះតំបន់ដ៏ទៃ ទៀត ត្រូវបានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ ដោយមួយចំនួនយកប្រភពអគ្គិសនី ផ្ទាល់ពីបណ្តាញបញ្ជូនរងប្រភពចេញពីបណ្តាញជាតិ មួយចំនួនយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ អគ្គិសនីប្រភពចេញពីទីរួមខេត្តក្រចេះ មួយចំនួនយកប្រភពអគ្គិសនីផ្ទាល់ពីការនាំចូលពីប្រទេសវៀតណាម និង

មួយចំនួនយកប្រភពអគ្គិសនីពីការបញ្ជូនបន្តគ្នា ។ បច្ចុប្បន្ននៅខេត្តត្បូងឃ្មុំ មានតំបន់ចែកចាយអគ្គិសនីចំនួន ១៩តំបន់ ដែលក្នុងនោះមាន ៤ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា (តំបន់ខាងកើតស្ពានគីហ្សូណា ជាប់តំបន់ទីរួមខេត្តកំពង់ចាម, តំបន់រដ្ឋបាលសាលាខេត្តត្បូងឃ្មុំ នៅក្រុងសួង, តំបន់ទីរួមស្រុកមេមត់ និងតំបន់ទីរួមស្រុកពញាក្រែក) និង ១៥ តំបន់ទៀត ជាតំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជន ។ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ២ តំបន់ គឺតំបន់ខាងកើតស្ពានគីហ្សូណា និងតំបន់រដ្ឋបាលសាលាខេត្តត្បូងឃ្មុំ យកប្រភពអគ្គិសនីផ្ទាល់ពីខ្សែបញ្ជូនរងចេញអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម និង ២ តំបន់ទៀត គឺតំបន់នៅទីរួមស្រុកមេមត់ និងតំបន់នៅទីរួមស្រុកពញាក្រែក ជាតំបន់យកប្រភពអគ្គិសនីពីការនាំចូលពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល។

តំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជនទាំង ១៥ តំបន់ខាងលើ ចែកចេញជា ៖

- ១ តំបន់ ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម គឺសហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ ហើយសហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ នេះ បញ្ជូនរងលក់បន្តឲ្យតំបន់ចែកចាយមួយចំនួនបន្តទៀត
- ៤ តំបន់ គឺជាតំបន់ចែកចាយ ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ បន្ថែមទៀត
- ៧ តំបន់ គឺជាតំបន់យកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា តចេញពីតំបន់ទីរួមខេត្តក្រចេះរបស់អគ្គិសនីកម្ពុជា(មានប្រភពអគ្គិសនីដោយការនាំចូលពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ៣៥ គីឡូវ៉ុល និង ២២ គីឡូវ៉ុល) ក្នុង ៧ តំបន់នេះ មាន ១ តំបន់ ជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយដែលបានភ្ជាប់ផ្ទាល់ជាមួយបណ្តាញបញ្ជូនរងរបស់ EDC
- ៣ តំបន់ គឺជាតំបន់ចែកចាយដែលយកប្រភពអគ្គិសនីពីប្រទេសវៀតណាម ក្នុងនោះមាន ២ នាំចូលផ្ទាល់ គឺក្រុមហ៊ុន អ៊ី.ឌី.ខន និងសហគ្រាស អេឡិកទ្រីស៊ីធី ដូនរ័ត្ន និង ១ តំបន់ទៀត គឺតំបន់របស់សហគ្រាស អេឡិកទ្រីស៊ីធី ជីពាំង ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់អគ្គិសនីកម្ពុជា ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម

## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តត្បូងឃ្មុំ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (តំបន់ទន្លេបិទ) | 001 L | GS | ត្បូងឃ្មុំ |
| 2 | អគ្គិសនីកម្ពុជា (តំបន់រដ្ឋបាលត្បូងឃ្មុំ) | 001 L | EDC | ត្បូងឃ្មុំ |
| 3 | សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ | 085 L | GS | ស្រុកត្បូងឃ្មុំ |
| 4 | សេវាករ សាយ សោភា | 297 L | GS-TBK | ស្រុកកោះសូទិន |
| 5 | សហគ្រាស អេឡិកទ្រីស៊ីធី សួង | 027 L | GS-TBK | ក្រុងសួង |
| 6 | ក្រុមហ៊ុន ឃុន សុផល | 088 L | GS-TBK | ស្រុកអូររាំងឪ |
| 7 | សេវាករ ស៊ុំ ហ៊ាត | 310 L | GS-TBK | ស្រុកអូររាំងឪ |
| 8 | អគ្គិសនីកម្ពុជា (តំបន់ស្រុកមេម៉ត់) | 001 L | VN | មេម៉ត់ |
| 9 | អគ្គិសនីកម្ពុជា (តំបន់ពញាក្រែក) | 001 L | VN | ពញាក្រែក |
| 10 | សហគ្រាស អេឡិកទ្រីស៊ីធី ដូនរ័ត្ន | 280 L | VN | ស្រុកមេមត់ |

| | | | | |
|---|---|---|---|---|
| 11 | ក្រុមហ៊ុន អ៊ី.ឌី.ខន | 122 L | VN-SCL | ស្រុកពញាក្រែក |
| 12 | សហគ្រាស អេឡិកទ្រីស៊ីធី ជីពាំង | 200 L | VN-EDC | ស្រុកពញាក្រែក |
| 13 | សេវាករ ថូវ នី | 339 L | VN-EDC | ស្រុកតំបែរ |
| 14 | សេវាករ ប៉ាត់ ស៊ាងហ៊ុន | 192 L | VN-EDC-PV | ស្រុកក្រូចឆ្មារ |
| 15 | សេវាករ ភិន វិភាវី | 191 L | VN-EDC | ស្រុកឆ្លូង |
| 16 | សេវាករ គឹម ម៉េង | 181 L | VN-EDC | ស្រុកតំបែរ |
| 17 | សេវាករ ភិន ថៃ | 308 L | VN-EDC | ស្រុកតំបែរ |
| 18 | សេវាករ ស៊ាន ស៊ីផាន | 277 L | VN-EDC | ស្រុកមេមត់ |
| 19 | សេវាករ សូ ថាវិន | 321 L | VN-EDC | ស្រុកមេមត់ |

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តត្បូងឃ្មុំ




## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តត្បូងឃ្មុំ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| តំបែរ | 74 | 65 | 87.84% | 50 | 67.57% | 15 |
| ក្រូចឆ្មារ | 76 | 71 | 93.42% | 49 | 64.47% | 22 |
| មេមត់ | 175 | 131 | 74.86% | 74 | 42.29% | 57 |
| អូររាំងឪ | 141 | 133 | 94.33% | 121 | 85.82% | 12 |

| | | | | | | |
|---|---|---|---|---|---|---|
| ពញាក្រែក | 149 | 142 | 95.30% | 69 | 46.31% | 73 |
| ត្បូងឃ្មុំ | 208 | 202 | 97.12% | 136 | 65.38% | 66 |
| សួង | 30 | 21 | 70.00% | 24 | 80.00% | -3 |
| **សរុប** | **853** | **765** | **89.68%** | **523** | **61.31%** | **242** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តត្បូងឃ្មុំ

ដោយសារនៅខេត្តត្បូងឃ្មុំ ពុំមានអនុស្ថានីយបណ្ដាញជាតិនៅឡើយ ដូច្នេះនៅខេត្តត្បូងឃ្មុំ **ពុំមានការផ្គត់ផ្គង់អគ្គិសនីធំ** ពីអនុស្ថានីយឡើយនៅពេលបច្ចុប្បន្ន។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តត្បូងឃ្មុំ គឺមានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.**ការផ្គត់ផ្គង់អគ្គិសនីធំ**ពីបណ្ដាញបញ្ជូនរងរបស់ក្រុមហ៊ុនបញ្ជូនរងទាំង ៣ នៅខេត្តត្បូងឃ្មុំ និងទី២.**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តត្បូងឃ្មុំ អាចចែកចេញជា ៤ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយគឺ ៖ ទី១.តំបន់យកប្រភពអគ្គិសនីពីអនុស្ថានីយបណ្ដាញជាតិខេត្តកំពង់ចាម ទី៣.តំបន់នាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម និងទី៤.តំបន់យកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរងអគ្គិសនីកម្ពុជាចេញពីទីរួមខេត្តក្រចេះ ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តត្បូងឃ្មុំ ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តត្បូងឃ្មុំ ត្រូវបានបែងចែកជា ៥ ផែនការទៅតាមប្រភេទនៃការផ្គត់ផ្គង់ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្ដាញបញ្ជូនរងនានា នៅខេត្តត្បូងឃ្មុំ

ដូចបានជំរាបជូនខាងលើ នៅខេត្តត្បូងឃ្មុំ មានបណ្ដាញបញ្ជូនរងរបស់ក្រុមហ៊ុន ២ គឺ៖ បណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងបណ្ដាញបញ្ជូនរងរបស់សហគ្រាស អេឡិកទ្រីស៊ីធី ត្បូងឃ្មុំ ។ ដោយសារនៅខេត្តត្បូងឃ្មុំ ពុំមានអនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលមានទំហំធំៗ គឺត្រូវដោះស្រាយតាមរយៈការផ្គត់ផ្គង់របស់បណ្ដាញបញ្ជូនរងទាំង ២ ខាងលើ ។ ផែនការបន្ថយថ្លៃ និងគម្លាតថ្លៃអគ្គិសនីសម្រាប់ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ដែលមានទំហំធំៗ ទិញលើតង់ស្យុងមធ្យមពីបណ្ដាញបញ្ជូនរងនៅខេត្តត្បូងឃ្មុំ មានដូចខាងក្រោម ៖

**សម្រាប់បណ្ដាញបញ្ជូនរងដែលយកប្រភពអគ្គិសនីពីបណ្ដាញជាតិ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

**សម្រាប់បណ្ដាញបញ្ជូនរងដែលយកប្រភពអគ្គិសនីពីការនាំចូលពីប្រទេសវៀតណាម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.155$/kWh | 0.160$/kWh | 0.1650$/kWh | 0.1640$/kWh | 0.1630$/kWh | 0.1620$/kWh |
| ទិញ MV ពីបញ្ជូនរងឯកជន | 0.1725$/kWh | 0.1675$/kWh | 0.1650$/kWh | 0.164$/kWh | 0.1630$/kWh | 0.1620$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.២ តំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅខាងកើតស្ពានគីហ្សូណា និងតំបន់រដ្ឋបាលខេត្តត្បូងឃ្មុំ

នៅក្នុខេត្តត្បូងឃ្មុំ អគ្គិសនីកម្ពុជាមានតំបន់ចែកចាយ ២ តំបន់ដោយឡែកពីគ្នា ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ គឺតំបន់ខាងកើតស្ពានគីហ្សូណា ជាប់តំបន់ទីរួមខេត្តកំពង់ចាម និងតំបន់រដ្ឋបាលខេត្តត្បូងឃ្មុំ ដែលត្រូវបានផ្ទេរមកឲ្យនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា ។ អគ្គិសនីកម្ពុជាកំពុងរៀបចំសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា សម្រាប់ធ្វើការផ្គត់ផ្គង់នៅតំបន់រដ្ឋបាលនេះ ទោះជាបច្ចុប្បន្នតំបន់នេះ ពុំទាន់មានប្រជាពលរដ្ឋរស់នៅក៏ដោយ ។ យោងតាម "ផែន ការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃលក់អគ្គិសនីនៅតំបន់ទាំង ២ ខាងលើនេះ នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៣ តំបន់ចែកចាយរបស់សេវាកររឯកជនដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ

ដូចបានជម្រាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាកររឯកជនទាំង ១៥ តំបន់ នៅខេត្តត្បូងឃ្មុំ មាន ៥ តំបន់ គឺជាតំបន់ដែលត្រូវបានចាត់ទុកថា ជាតំបន់ទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ ព្រោះក្នុងនោះ ១ តំបន់ទិញផ្ទាល់ពីអនុស្ថានីយកំពង់ចាម និង ៤ តំបន់ទៀត ទិញផ្ទាល់ពីបណ្តាញបញ្ជូនរងចេញពីអនុស្ថានីយកំពង់ចាម ។ តំបន់ចែកចាយអគ្គិសនីទាំង ៥ បច្ចុប្បន្នកំពុងអនុវត្តអត្រាថ្លៃ ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ចែកចាយទាំង ៥ ខាងលើនេះ នឹងត្រូវអនុវត្តតាមផែនការ ដូចខាងក្រោម ៖

**សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់សេវាករឯកជនដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ចេញពីខេត្តក្រចេះ

ដូចបានជំរាបជូនខាងលើ ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់ឯកជនទាំង ១៥ តំបន់ មានតំបន់ចែកចាយចំនួន ៧ តំបន់ គឺជាតំបន់យកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលមានប្រភពផ្គត់ផ្គង់ចំនួន ២ ប្រភព គឺ ទី១.ប្រភពពីតំបន់ទីរួមខេត្តក្រចេះរបស់អគ្គិសនីកម្ពុជា (នាំចូលពីប្រទេសវៀតណាម តាមខ្សែបណ្តាញបញ្ជូនរង ៣៥ គីឡូវ៉ុល និង ២២ គីឡូវ៉ុល) និងទី២.ប្រភពពីបណ្តាញបញ្ជូនរងរបស់ឯកជនចេញពីអនុស្ថានីយកំពង់ចាម ។ ការផ្គត់ផ្គង់ប្រភពដូចខាងលើនេះ គឺជាដំណោះស្រាយបណ្តោះអាសន្នរង់ចាំការអភិវឌ្ឍន៍អនុស្ថានីយបណ្តាញជាតិនៅទីរួមខេត្តក្រចេះ ។ ក្នុងតំបន់ចែកចាយ ៧ តំបន់នេះ មាន ១ តំបន់ គឺតំបន់ចែកចាយរបស់សេវាករ ប៉ាត់ ស៊ាងហ៊ុន ដែលជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយដែលបានភ្ជាប់ផ្ទាល់ជាមួយបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។

តាមដំណោះស្រាយខាងលើនេះ បច្ចុប្បន្នតំបន់ទាំង ៧ នេះ បានបន្ថយថ្លៃអគ្គិសនីមកស្មើនឹង ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចហើយ ។ យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" បានកំណត់ថា ក្នុងករណីចាំបាច់ក្នុងគោលបំណងផ្តល់នូវផលប្រយោជន៍បណ្តោះអាសន្នឲ្យតំបន់ណាមួយដែលនៅក្បែរតំបន់គ្របដណ្តប់របស់បណ្តាញជាតិ ឬប្រភពថោកជាងប្រើម៉ាស៊ីនដ្យេសែល ប៉ុន្តែពុំទាន់អាចពង្រីកបណ្តាញបញ្ជូនរងឲ្យទៅគ្របដណ្តប់តំបន់នោះ តាមបទដ្ឋានបច្ចេកទេសបាន អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា អាចឯកភាពគ្នាអនុញ្ញាតឲ្យមានការផ្តល់ប្រភពបន្តគ្នាជាបណ្តោះអាសន្ន ដោយកំណត់ថ្លៃលក់អគ្គិសនីដោយឡែកណាមួយខុសពីផែនការរួម ក្នុងរយៈពេលបណ្តោះអាសន្ន រហូតដល់តំបន់នោះត្រូវបានគ្របដណ្តប់ត្រឹមត្រូវដោយបណ្តាញបញ្ជូនរង តាមបទដ្ឋានបច្ចេកទេស ។ ដូច្នេះចំពោះតំបន់ទាំង ៧ នេះ ក្នុងស្ថានភាពបណ្តោះអាសន្នរបៀបនេះ យើងអាចរក្សាថ្លៃលក់អគ្គិសនីសម្រាប់តំបន់ទាំង ៧ នេះ ដូចថ្លៃបច្ចុប្បន្នរហូត

ដល់អនុស្ថានីយខេត្តក្រចេះ ត្រូវបានដាក់ឲ្យដំណើរការនៅឆ្នាំ ២០១៨ ដែលពេលនោះបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាអាចបង្វែរមកយកប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយនេះ ទើបពេលនោះតំបន់ចែកចាយទាំង ៧ អាចអនុវត្តតាមផែនការបន្ថយថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាល ដូចតំបន់ចែកចាយរបស់សេវាករឯកជនដែលទទួលបានប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិដែរ ។

## ២.៥ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម

ក្នុងចំណោមតំបន់ផ្គត់ផ្គង់ទាំង ៤ តំបន់ របស់អគ្គិសនីកម្ពុជានៅខេត្តត្បូងឃ្មុំ មានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់ដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម ក្នុងនោះមានតំបន់ស្រុកមេមត់ និងតំបន់ស្រុកពញាក្រែក ។ ចំពោះតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាទាំង ២ តំបន់នេះ បច្ចុប្បន្នកំពុងអនុវត្តថ្លៃលក់អគ្គិសនីដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៦៥០ ៛ / kWh | អតិថិជនធុនធំ | 0.១៤៥ $ / kWh |
| អតិថិជនធុនមធ្យម | 0.១៥៥ $ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៣៥ $ / kWh |

បច្ចុប្បន្ន អគ្គិសនីកម្ពុជាកំពុងជួបប្រទះបញ្ហាលំបាកក្នុងអាជីវកម្ម ដោយសារតែបញ្ជីថ្លៃលក់អគ្គិសនីខាងលើនេះ ត្រូវបានកំណត់តាំងពីឆ្នាំ ២០០២ នៅពេលដែលអគ្គិសនីកម្ពុជានាំចូលអគ្គិសនីពីប្រទេសវៀតណាមតំបូង ប៉ុន្តែរហូតដល់ពេលនេះ ប្រទេសវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីនេះចំនួន ៣ ដង រួចទៅហើយ ។ ចុងក្រោយនៅឆ្នាំ ២០១៥ នេះ ប្រទេសវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា តាមរយៈនៃការនាំចូលអគ្គិសនីលើតង់ស្យុងមធ្យម ២២ គីឡូវ៉ុល បន្ថែម ៧.៥% ទៀតនេះ ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ តទៅ ។ ដើម្បីឲ្យសមស្របជាមួយការតម្លើងថ្លៃលក់អគ្គិសនីបន្ថែម ៧.៥%នេះ អគ្គិសនីកម្ពុជាគ្រោងនឹងតម្លើងថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ដោយរក្សាថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនលំនៅដ្ឋាននៅដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាប | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.៦ តំបន់ចែកចាយរបស់ឯកជនដែលប្រើប្រភពនាំចូលអគ្គិសនីពីប្រទេសវៀតណាម

ក្នុងចំណោមតំបន់ចែកចាយឯកជន ៣ តំបន់ នៅខេត្តត្បូងឃ្មុំ ដែលប្រើប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម មានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់ចែកចាយដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម (តំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន និងតំបន់ចែកចាយរបស់សហគ្រាស អេឡិកទ្រីស៊ីធី ដួនវត្ថ) ដោយឡែក ១ តំបន់ទៀត គឺជាតំបន់ដែលទិញអគ្គិសនីពីតំបន់នាំចូលអគ្គិសនី របស់អគ្គិសនីកម្ពុជា ។

តំបន់ចែកចាយដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម (តំបន់ចែកចាយរបស់ក្រុមហ៊ុនអ៊ី.ឌី.ខន និងតំបន់ចែកចាយរបស់សហគ្រាស អេឡិកទ្រីស៊ីធី ដូនរ័ត្ន) បច្ចុប្បន្ននេះ កំពុងអនុវត្តថ្លៃលក់អគ្គិសនី ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៧៥០ ៛ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៧៥ $ / kWh |

ដោយសារអត្រាថ្លៃអគ្គិសនីខាងលើនេះ ជាអត្រាមួយសមស្រប ដូច្នេះអាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងរក្សាអត្រាថ្លៃខាងលើនេះ ជាបន្តទៀត ដោយកែសម្រួលបន្ថយថ្លៃខ្លះ តែអត្រាថ្លៃសម្រាប់អតិថិជនតង់ស្យុងមធ្យម ដើម្បីឲ្យចុះមកប្រហាក់ប្រហែល ជាមួយអត្រាថ្លៃតាមផែនការរបស់រាជរដ្ឋាភិបាល ។

ដោយឡែក តំបន់ឯកជនចំនួន ១ តំបន់ទៀត គឺតំបន់ចែកចាយរបស់សហគ្រាស អេឡិកទ្រីស៊ីធី ជីពាំង ដែលទិញប្រភពអគ្គិសនីពីតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ដែលនាំចូលអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម បច្ចុប្បន្ននេះ កំពុងអនុវត្តថ្លៃលក់អគ្គិសនី ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | ៩៤០ ៛ / kWh | អតិថិជនតង់ស្យុងមធ្យម | 0.១៧៥ $ / kWh |

ទោះជានៅឆ្នាំ ២០១៥ នេះ ប្រទេសវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា តាមរយៈនៃការនាំចូលអគ្គិសនីលើតង់ស្យុងមធ្យម ២២ គីឡូវ៉ុល បន្ថែម ៧.៥% ទៀតនេះ ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ មក ក៏ដោយ ដោយសារតំបន់ចែកចាយរបស់សហគ្រាស អេឡិកទ្រីស៊ីធី ជីពាំង បានលក់អគ្គិសនីក្នុងអត្រាថ្លៃ ៩៤០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នេះយូរមកហើយ ម្យ៉ាងទៀតទំហំទីផ្សារក៏កើនឡើងខ្លះដែរ ដូច្នេះអាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងថានឹងធ្វើការពិភាក្សាជាមួយអគ្គិសនីកម្ពុជា ដើម្បីរកវិធីបន្ថយអត្រាថ្លៃខាងលើនេះខ្លះ ដើម្បីឲ្យមកប្រហាក់ប្រហែលជាមួយតំបន់ចែកចាយជិតខាង ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងតម្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តស្វាយរៀង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តស្វាយរៀង

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តស្វាយរៀង មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ។ តាមផែនការរបស់រាជរដ្ឋាភិបាល គឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ចិនចំនួន ១៥០ លានដុល្លាអាមេរិក នៅឆ្នាំ ២០១៤ ដើម្បីអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយភ្ជាប់ភ្នំពេញ-ព្រៃវែង-ស្វាយរៀង ដោយក្នុងនោះមានការសាងសង់អនុស្ថានីយចំនួន ២ កន្លែង មួយកន្លែងនៅទីរួមខេត្តព្រៃវែង ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តព្រៃវែង និងមួយកន្លែងនៅទីរួមខេត្តស្វាយរៀង ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តស្វាយរៀង ។ អនុស្ថានីយទាំង ២ នេះ គ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៧ ខាងមុខ ។ កន្លងមកដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តស្វាយរៀង ជាបណ្តោះអាសន្ន ក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា បានអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល នាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ជាបណ្តោះអាសន្ន មកផ្តល់ឲ្យតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និងលក់ដុំបន្តឲ្យតំបន់ចែកចាយរបស់សេវាករឯកជនមួយចំនួនទៀតនៅខេត្តស្វាយរៀង ។ តាមបទដ្ឋានបច្ចេកទេស ការបញ្ជូនអគ្គិសនីតាមខ្សែបណ្តាញ ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ ទៅ ៧០ គីឡូម៉ែត្រប៉ុណ្ណោះ ប៉ុន្តែយើងបានអនុញ្ញាតឲ្យអគ្គិសនីកម្ពុជា បញ្ជូនអគ្គិសនីតាមខ្សែបណ្តាញ ២២ គីឡូវ៉ុល ជាបណ្តោះអាសន្ននេះ រហូតដល់ជាង ១០០ គីឡូម៉ែត្រ លើសពីបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីកើតមានអគុល្យភាព និងមានអាក់អួលញឹកញាប់ ចំណែកការបាត់បង់អគ្គិសនីលើខ្សែបណ្តាញមានបរិមាណច្រើនលើសពីខេត្តដទៃ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ នៅខេត្តស្វាយរៀង យើងពុំមានជម្រើសអ្វីផ្សេងក្រៅពីធ្វើរបៀបនេះទេពីព្រោះមានតែធ្វើបែបនេះទេទើបយើងអាចជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ដើម្បីបន្ថយថ្លៃអគ្គិសនីនៅតំបន់ចែកចាយអគ្គិសនីនៅខេត្តស្វាយរៀង ថយចុះពីថ្លៃ ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យមកនៅត្រឹមចន្លោះ ១,០៥០ ទៅ ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដូចបច្ចុប្បន្នបាន ។ ម្យ៉ាងទៀតធ្វើយ៉ាងនេះ ទើបយើងអាចធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនធំហើយស្រេច រង់ចាំពេលណាមានអនុស្ថានីយផ្ទាល់នៅខេត្តស្វាយរៀង ពេលនោះយើងអាចបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយនេះ ទៅកាន់តំបន់នានានៃខេត្តស្វាយរៀងបានតែម្តង រួចទុកពេលពង្រីកវិសាលភាពការផ្គត់ផ្គង់ទៅតំបន់ទាំងឡាយដែលពុំទាន់មានអគ្គិសនីប្រើប្រាស់ ។ ដូច្នេះដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តស្វាយរៀង គឺការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនីភ្ជាប់ភ្នំពេញ-ព្រៃវែង-ស្វាយរៀង ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តស្វាយរៀង រួចបង្វែរខ្សែបញ្ជូនរងរបស់អគ្គិសនីកម្ពុជា មកយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តស្វាយរៀងវិញ ។ ពេលនោះបញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២. ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនី មុខជាអាចដោះស្រាយបាន ដូចខេត្តដទៃទៀតជាមិនខាន។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្រ្តខេត្តស្វាយរៀង មានក្រុង ១ ឈ្មោះក្រុងស្វាយរៀង និងស្រុកចំនួន ៦ គឺ ៖ ១.ស្រុករមាសហែក ២.ស្រុកកំពង់រោទិ៍ ៣.ស្រុកចន្ទ្រា ៤.ស្រុកស្វាយជ្រំ ៥.ស្រុករំដួល និង ៦.ស្រុកស្វាយទាប។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តស្វាយរៀង **មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយទេ** គឺមានតែ**ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ។ កន្លងមកការអភិវឌ្ឍន៍តំបន់ចែកចាយអគ្គិសនីនៅខេត្តស្វាយរៀង ត្រូវបានដោះស្រាយដោយរបៀប ២ យ៉ាង ទី១.ចំពោះក្រុងស្វាយរៀង ក្រុងបាវិត និងតំបន់ចន្លោះក្រុងទាំង ២ ដោះស្រាយដោយការវិនិយោគរបស់អគ្គិសនីកម្ពុជា និងទី២.ចំពោះតំបន់ដ៏ទៃទៀត ដោះស្រាយដោយអនុញ្ញាតឲ្យឯកជនធ្វើការវិនិយោគ ដោយចាប់ផ្តើមពីការប្រើប្រាស់ម៉ាស៊ីនដ្យេសែលផលិតអគ្គិសនីរួចបង្វែរមកទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរង របស់អគ្គិសនីកម្ពុជាវិញ ដែលបច្ចុប្បន្នបានបញ្ជូនប្រភពអគ្គិសនីនាំចូលទៅជំនួសការផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែលរួចរាល់ហើយ ។ បច្ចុប្បន្ននៅខេត្តស្វាយរៀង មានតំបន់ចែកចាយអគ្គិសនីចំនួន ៤ តំបន់ ដែលក្នុងនោះមានតំបន់ចែកចាយអគ្គិសនី ១ តំបន់ គឺជាតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា (ក្រុងស្វាយរៀង ក្រុងបាវិត និងតំបន់ចន្លោះក្រុងទាំង ២) និងតំបន់ចែកចាយ ៣ តំបន់ទៀត គឺជាតំបន់ចែកចាយអគ្គិសនីរបស់សេវាករអគ្គិសនីឯកជន ។ បច្ចុប្បន្នតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៣ តំបន់នេះ បានទិញប្រភពអគ្គិសនីផ្ទាល់ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជារួចរាល់ហើយ មានន័យថា ពុំមានតំបន់ចែកចាយដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដ្យេសែលដែល មានថ្លៃខ្ពស់នោះទេ។

### ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តស្វាយរៀង



## បញ្ជីឈ្មោះតំបន់ចែកចាយ និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយនៅក្នុងខេត្តស្វាយរៀង

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ | ខេត្ត-រាជធានី |
|---|---|---|---|---|---|
| ១ | អគ្គិសនីកម្ពុជា (ស្វាយរៀង) | 001 L | VN | ក្រុងស្វាយរៀង | ខេត្តស្វាយរៀង |
| ២ | អគ្គិសនីកម្ពុជា (បាវិត) | 001 L | VN | ក្រុងបាវិត | ខេត្តស្វាយរៀង |
| ៣ | សេវាករ សៀន ណារិទ្ធ | 247 L | VN-EDC | ស្រុកស្វាយជ្រំ | ខេត្តស្វាយរៀង |
| ៤ | សេវាករ ខាន់ ស៊ីផេន | 268 L | VN-EDC | ស្រុកកំពង់រោទ៍ | ខេត្តស្វាយរៀង |
| ៥ | ក្រុមហ៊ុន ខ្មែរ យូជីឡឺជី ត្រេឌីង (ខេយូជី) ខូមភេនី | 319 L | VN-EDC | ស្រុករមាសហែក | ខេត្តស្វាយរៀង |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តស្វាយរៀង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ចន្ទ្រា | 29 | 15 | 51.72% | 15 | 51.72% | - |
| កំពង់រោទិ៍ | 80 | 51 | 63.75% | 50 | 62.50% | 1 |
| រំដួល | 78 | 2 | 2.56% | 1 | 1.28% | 1 |
| រមាសហែក | 204 | 147 | 72.06% | 3 | 1.47% | 144 |
| ស្វាយជ្រំ | 158 | 54 | 34.18% | 13 | 8.23% | 41 |
| ស្វាយរៀង | 43 | 40 | 93.02% | 24 | 55.81% | 16 |
| ស្វាយទាប | 63 | 18 | 28.57% | 6 | 9.52% | 12 |
| បាវិត | 35 | 28 | 80.00% | 16 | 45.71% | 12 |
| **សរុប** | **690** | **355** | **51.45%** | **128** | **18.55%** | **227** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តស្វាយរៀង

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តស្វាយរៀង អាចបែងចែកជាផែនការដោយឡែក ទៅតាមប្រភេទនៃការផ្គត់ផ្គង់អគ្គិសនីចំនួន៣គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីក្នុងរូបភាពជុំពីអនុស្ថានីយបណ្តាញជាតិ ២.ការផ្គត់ផ្គង់អគ្គិសនីជំពីបណ្តាញបញ្ជូនរង និង៣.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តស្វាយរៀង ត្រូវបានបែងចែកជា ៣ ផែនការ ទៅតាមប្រភេទនៃការផ្គត់ផ្គង់អគ្គិសនី ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

ដូចបានជម្រាបជូនខាងលើតាមផែនការវិនិយោគដែលរាជរដ្ឋាភិបាលបានសម្រេចគឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិន ចំនួន ១៥០ លានដុល្លាអាមេរិក ដើម្បីអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយភ្ជាប់ពីភ្នំពេញ ទៅខេត្តស្វាយរៀង ដោយក្នុងនោះ មានការសាងសង់អនុស្ថានីយបណ្តាញជាតិមួយកន្លែងនៅខេត្តស្វាយរៀង ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៧ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តស្វាយរៀង ។ ដូច្នេះនៅមុនឆ្នាំ ២០១៧ នៅខេត្តស្វាយរៀង ពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយឡើយ រួចចាប់ពីឆ្នាំ ២០១៧ ទៅ ទើបនៅខេត្តស្វាយរៀង អាចមានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយបណ្តាញជាតិ ។ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ចាប់ពីឆ្នាំ ២០១៧ នឹងមានអត្រាថ្លៃអគ្គិសនីតាមផែនការរបស់រាជរដ្ឋាភិបាល ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងនានា នៅខេត្តស្វាយរៀង

ដោយសារនៅខេត្តស្វាយរៀង ពុំទាន់មានអនុស្ថានីយបណ្តាញជាតិនៅឡើយ ដូច្នេះនៅពេលបច្ចុប្បន្ននេះ បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តស្វាយរៀង គឺប្រើប្រាស់ប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាមទាំងស្រុង ។ បណ្តាញបញ្ជូនរងទាំងអស់នៅក្នុងខេត្តស្វាយរៀងនេះ គឺជារបស់អគ្គិសនីកម្ពុជាដែលអគ្គិសនីកម្ពុជាមានកាតព្វកិច្ចធ្វើការអភិវឌ្ឍន៍ឲ្យគ្របដណ្តប់ពេញខេត្តស្វាយរៀង ទាំងមូល ។ បច្ចុប្បន្ននៅក្រៅតំបន់ចែកចាយផ្ទាល់របស់អគ្គិសនីកម្ពុជា (ក្រុងស្វាយរៀង និងក្រុងបាវិត) គឺពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធំៗ តាមតង់ស្យុងមធ្យមចេញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅឡើយទេ គឺមានតែការផ្គត់ផ្គង់ប្រភពអគ្គិសនីឲ្យសេវាករចែកចាយអគ្គិសនី តាមតំបន់ចែកចាយនីមួយៗ ប៉ុណ្ណោះ។ ថ្លៃលក់ប្រភពអគ្គិសនីឲ្យសេវាករចែកចាយអគ្គិសនីនៅតំបន់ចែកចាយនីមួយៗ របស់អគ្គិសនីកម្ពុជា នៅពេលបច្ចុប្បន្ននេះមានស្ថានភាព ដូចខាងក្រោម ៖

| លក្ខខណ្ឌ | អត្រាថ្លៃលក់ | ជាដុល្លា(1$=4050៛) |
|---|---|---|
| អ្នកកាន់អាជ្ញាប័ណ្ណដែលទិញអគ្គិសនីតាមនាឡិកាស្ទង់តង់ស្យុងមធ្យម | ៥៣០ ៛ / kWh | 0.131 $/kWh |
| អ្នកកាន់អាជ្ញាប័ណ្ណវិនិយោគត្រង់ស្វូ និងទិញតាមនាឡិកាស្ទង់ LV | ៥៥០ ៛ / kWh | 0.136 $/kWh |
| អគ្គិសនីកម្ពុជាវិនិយោគត្រង់ស្វូ និងទិញតាមនាឡិកាស្ទង់ LV | ៦០០ ៛ / kWh | 0.148 $/kWh |

បញ្ជីថ្លៃលក់នេះ នឹងត្រូវកែសម្រួល ដើម្បីឲ្យដូចផែនការយុទ្ធសាស្ត្របន្ថយអត្រានិងគម្លាតថ្លៃលក់អគ្គិសនីរួមរបស់រាជរដ្ឋាភិបាល នៅពេលដែលអនុស្ថានីយបណ្តាញជាតិដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៧ ។

**កំណត់សំគាល់៖**

ចំពោះការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធំៗ តាមតង់ស្យុងមធ្យមចេញពីបណ្តាញបញ្ជូនរង ប្រសិនបើមាន ចាប់ពីពេលនេះទៅ ត្រូវអនុវត្តតាមផែនការយុទ្ធសាស្ត្ររួមតែម្តង ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា

នៅឆ្នាំ ២០១៥ នៅក្នុងតំបន់ចែកចាយអគ្គិសនីនៅក្រុងស្វាយរៀង និងក្រុងបាវិត របស់អគ្គិសនីកម្ពុជាថ្លៃអគ្គិសនីមិនបានបែងចែកឲ្យខុសគ្នា រវាងអតិថិជនទេ គឺបានបែងចែកទៅតាមប្រភេទធំតូច ដែលមានអត្រាថ្លៃដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | 650 ៛ / kWh | អតិថិជនធុនធំ | 0.145 $US / kWh |
| អតិថិជនធុនមធ្យម | 0.155 $US / kWh | អតិថិជនតង់ស្យុងមធ្យម | 0.135 $US / kWh |

បច្ចុប្បន្ន អគ្គិសនីកម្ពុជាកំពុងជួបប្រទះបញ្ហាលំបាកក្នុងអាជីវកម្ម ដោយសារតែបញ្ជីថ្លៃលក់អគ្គិសនីខាងលើនេះ ត្រូវបានកំណត់តាំងពីឆ្នាំ ២០០២ នៅពេលដែលអគ្គិសនីកម្ពុជា នាំចូលអគ្គិសនីពីប្រទេសវៀតណាមតំបូង ប៉ុន្តែរហូតដល់ពេលនេះ អគ្គិសនីវៀតណាមបានតម្លើងថ្លៃលក់អគ្គិសនីនេះចំនួន ៣ ដង រួចទៅហើយ ។ ចុងក្រោយនៅឆ្នាំ ២០១៥ នេះ អគ្គិសនីវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា តាមរយៈនៃការនាំចូលអគ្គិសនីលើតង់ស្យុងមធ្យម ២២ គីឡូវ៉ុល បន្ថែម ៧.៥% ទៀតនេះ ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥តទៅ។ ដើម្បីឲ្យសមស្របជាមួយការតម្លើងថ្លៃលក់អគ្គិសនីបន្ថែម ៧.៥%នេះ អគ្គិសនីកម្ពុជាគ្រោងនឹងតម្លើងថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ដោយរក្សាថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនលំនៅដ្ឋាននៅដដែល ដូចខាងក្រោម ៖

| **ប្រភេទអតិថិជន** | **អត្រាថ្លៃលក់អគ្គិសនី** |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាប | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

នៅឆ្នាំ ២០១៧ នៅពេលដែលអនុស្ថានីយបណ្តាញជាតិត្រូវបានដាក់ឲ្យដំណើរការ យោងតាម «ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី» របស់រាជរដ្ឋាភិបាល បញ្ជីថ្លៃលក់អគ្គិសនីនៅក្រុងស្វាយរៀង និងក្រុងបាវិត របស់អគ្គិសនីកម្ពុជា នឹងត្រូវអនុវត្តតាមផែនការ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញ MV | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៦៥០៛/kWh | ៦៥០៛/kWh | ៧០០៛/kWh | ៧០០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់សេវាករឯកជន

ដូចបានជម្រាបជូនខាងលើ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ០៣ តំបន់ នៅខេត្តស្វាយរៀង គឺមានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់ដែលបានទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលមានថ្លៃលក់អគ្គិសនីរាយបច្ចុប្បន្ន ស្មើនឹង ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ យោងតាម «ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី» នៅខែ សីហា ឆ្នាំ ២០១៥ គ្រោងបន្ថយថ្លៃពី ១,០៥០ រៀល មក ១,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃលក់អគ្គិសនីរាយនៅតំបន់ទាំង ២ នេះ អាចនឹងបន្ថយមកនៅ ៩៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង។

នៅឆ្នាំ ២០១៧ នៅពេលដែលអនុស្សាវរីយបណ្តាញជាតិដាក់ឲ្យដំណើរការ យោងតាម «ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី» របស់រាជរដ្ឋាភិបាល បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២ តំបន់នេះ នឹងត្រូវអនុវត្តតាមផែនការ ដូចខាងក្រោម ៖

<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៨០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៧** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ចំពោះតំបន់ចែកចាយរបស់ឯកជន ១ តំបន់ទៀត នៅស្រុករមាសហែក ដែលជាតំបន់ចែកចាយទើបតែបានផ្លាស់ប្តូរពីការផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល មកទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងយកប្រភពពីខេត្តព្រៃវែង របស់អគ្គិសនីកម្ពុជាថ្មីៗនេះ ថ្លៃអគ្គិសនីបានបន្ថយថ្លៃពីជិត ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង មកស្មើនឹង ១,៣០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចនឹងចុះបន្តិចម្តងតាមកម្មវិធីបន្ថយថ្លៃរហូតដល់ ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នៅចុងឆ្នាំ ២០១៥ ។ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ស្រុករមាសហែក នេះ នឹងត្រូវអនុវត្តដូចតំបន់ចែកចាយរបស់សេវាករឯកជន ២ ផ្សេងទៀត ក្នុងខេត្តស្វាយរៀង ខាងលើ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តក្រចេះ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តក្រចេះ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ២០១៥ ខេត្តក្រចេះ មិនទាន់ឋិតនៅក្នុងតំបន់ផ្គត់ផ្គង់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិឲ្យខេត្តនេះនៅឡើយ បើមាន គឺមានតែការបញ្ជូនប្រភពអគ្គិសនីពីឆ្ងាយមកឲ្យខេត្តនេះ ជាបណ្តោះអាសន្ន ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីដែលមានថ្លៃថោកឲ្យខេត្តក្រចេះ ជាបណ្តោះអាសន្ន អគ្គិសនីកម្ពុជាបានធ្វើការសាងសង់បណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល ផង និង ៣៥ គីឡូវ៉ុល ផង បញ្ជូនប្រភពអគ្គិសនីចំនួន ៣ ប្រភពមកផ្តល់ឲ្យតំបន់ចែកចាយមួយចំនួនក្នុងខេត្តក្រចេះ ទី១.ប្រភពចេញពីអនុស្ថានីយខេត្តកំពង់ចាម ដោយធ្វើការភ្ជាប់បន្តពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន ទី២.ប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម មកឲ្យស្រុកស្នួល ដោយភ្ជាប់បន្តបញ្ជូនប្រភពនេះ រហូតដល់ក្រុងក្រចេះ និងទី៣.ប្រភពអគ្គិសនីទិញពីរោងចក្រផលិតអគ្គិសនីបាយអូម៉ាស់ (ដុតកាកអំពៅ) របស់ក្រុមហ៊ុនដាំអំពៅឯកជន នៅស្រុកសម្បូរ ប៉ុន្តែជាអកុសលរោងចក្រផលិតអគ្គិសនីបាយអូម៉ាស់នេះ មិនអាចដំណើរការបានដោយហេតុផលផ្ទៃក្នុងរបស់ក្រុមហ៊ុន ។ ចំពោះតំបន់ដ៏ទៃទៀត ដែលមិនអាចយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងបាន ដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនម៉ាស៊ីនដៀសែលផលិតអគ្គិសនី ជាបណ្តោះអាសន្ន ។

ដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តក្រចេះ គឺការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនីភ្ជាប់កំពង់ចាម-ក្រចេះ-ស្ទឹងត្រែង និងស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅទីរួមខេត្តក្រចេះ រួចបង្វែរបណ្តាញបញ្ជូនរងទាំងអស់ ដែលមាននៅខេត្តក្រចេះ ឲ្យមកយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តក្រចេះវិញ ព្រមទាំងពង្រីកបណ្តាញបញ្ជូនរងទៅគ្របដណ្តប់តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ នៅពេលនោះបញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនីមុខជាអាចដោះស្រាយបានដូចខេត្តដ៏ទៃទៀតជាមិនខាន ។ តាមកិច្ចព្រមព្រៀងវិនិយោគគម្រោងភ្ជាប់កំពង់ចាម-ក្រចេះ និងការបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅទីរួមខេត្តក្រចេះ អាចនឹងដាក់ឲ្យដំណើរការរហូតដល់ឆ្នាំ ២០១៨ ដូច្នេះមុនឆ្នាំ ២០១៨ ខេត្តក្រចេះ មិនទាន់គ្របដណ្តប់ដោយប្រភពអគ្គិសនីរបស់បណ្តាញជាតិទាំងស្រុងនៅឡើយ រួចថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់នៅខេត្តនេះ ក៏មិនទាន់អាចអនុវត្តតាមផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាលនៅឡើយដែរ ។ ទោះជាគម្រោងបង្កើតអនុស្ថានីយបណ្តាញជាតិនៅខេត្តក្រចេះនេះ មិនទាន់ដាក់ឲ្យដំណើរការក៏ដោយ ក្នុងរយៈពេលពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ រាជរដ្ឋាភិបាលនឹងរៀបចំផែនការបញ្ជូនប្រភពអគ្គិសនី ដែលមានថ្លៃទាបបន្ថែមទៅជួយបន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយនានា នៅខេត្តក្រចេះ ឲ្យបានសមស្របជាបណ្តោះអាសន្នសិន ទម្រាំដល់ពេលវេលាដែលអនុស្ថានីយបណ្តាញជាតិនៅខេត្តក្រចេះ អាចដាក់ឲ្យដំណើរការបាន ។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តក្រចេះ មានក្រុង ១ ឈ្មោះក្រុងក្រចេះ និងស្រុកចំនួន ៥ គឺ ៖ ១.ស្រុកឆ្លូង ២.ស្រុកចិត្របុរី ៣.ស្រុកសម្បូរ ៤.ស្រុកស្នួល និង៥.ស្រុកព្រែកប្រសប់ ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តក្រចេះ **មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ** ពីព្រោះខេត្តនេះពុំទាន់មានអនុស្ថានីយផ្ទាល់របស់ខ្លួន គឺ**មានការផ្គត់ផ្គង់អគ្គិសនីធំ ពីបណ្តាញបញ្ជូនខេ**នានាដែលទទួលប្រភពអគ្គិសនីបន្តពីគេ និង**ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ**នីមួយៗ ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនៅខេត្តក្រចេះ កន្លងមកត្រូវបានដោះស្រាយដោយរបៀប ៣ យ៉ាង គឺ ៖ ទី១.ចំពោះតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅក្រុងក្រចេះ និងស្រុកស្នួល ដោះស្រាយដោយការនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម តាមរយៈខ្សែបញ្ជូនរង ២២ គីឡូវ៉ុល ផង និង ៣៥ គីឡូវ៉ុល ផង របស់អគ្គិសនីកម្ពុជា ទី២.ចំពោះតំបន់ចែកចាយមួយចំនួនទៀត ដោះស្រាយដោយការបញ្ជូនប្រភពអគ្គិសនីនានាតាមបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលក្នុងនោះមានប្រភពអគ្គិសនីចេញពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន ដែលយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពង់ចាម និងប្រភពអគ្គិសនីចេញពីក្រុងក្រចេះដែលយកប្រភពអគ្គិសនីពីប្រទេសវៀតណាម និងទី៣.ចំពោះតំបន់ឆ្ងាយៗ ដែលមិនមានប្រភពណាទៅដល់ដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជនធ្វើការផ្គត់ផ្គង់ ដោយប្រើម៉ាស៊ីនដ្យេសែលផលិតអគ្គិសនីជាបណ្តោះអាសន្ន។ បច្ចុប្បន្ននៅខេត្តក្រចេះ មានតំបន់ចែកចាយអគ្គិសនីចំនួន ១០ តំបន់ ដែលក្នុងនោះមាន ៖ ២ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា (ក្រុងក្រចេះ និងទីរួមស្រុកស្នួល) ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និង ៨ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៨ តំបន់នេះ មាន ៤ តំបន់ គឺជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង ៤ តំបន់ទៀត គឺជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ។

### បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តក្រចេះ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (ក្រុងក្រចេះ) | 001 L | VN | ក្រុងក្រចេះ |
| 2 | អគ្គិសនីកម្ពុជា (ស្រុកស្នួល) | 001 L | VN | ស្រុកស្នួល |
| 3 | សេវាករ ភិន វិការី | 191 L | VN-EDC | ស្រុកឆ្លូង |
| 4 | សេវាករ ហ៊ាង ពៅ | 217 L | VN-EDC | ស្រុកព្រែកប្រសព្វ |
| 5 | សេវាករ ភិន ហម | 227 L | VN-EDC | ស្រុកព្រែកប្រសព្វ |
| 6 | ក្រុមហ៊ុន យោន សុក រិទ្ធ | 342 L | VN-EDC | ស្រុកស្នួល, ស្រុកចិត្របូរី |
| 7 | សេវាករ ពេជ្រ ឧត្តម | 263 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសម្បូរ |
| 8 | សេវាករ ជា សុខខេង | 346 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសម្បូរ |
| 9 | សេវាករ ជា គ្រី | 352 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសម្បូរ |
| 10 | សេវាករ សុខ ហេងស៊ាង | 353 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកព្រែកប្រសព្វ |

# ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តក្រចេះ




## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តក្រចេះ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ឆ្លូង | 40 | 37 | 92.50% | 27 | 67.50% | 10 |
| ក្រចេះ | 16 | 12 | 75.00% | 14 | 87.50% | -2 |
| ព្រែកប្រសព្វ | 48 | 43 | 89.58% | 34 | 70.83% | 9 |
| សំបូរ | 52 | 22 | 42.31% | 4 | 7.69% | 18 |
| ស្នួល | 36 | 30 | 83.33% | 10 | 27.78% | 20 |
| ចិត្របុរី | 58 | 36 | 62.07% | 13 | 22.41% | 23 |
| **សរុប** | **250** | **180** | **72.00%** | **102** | **40.80%** | **78** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តក្រចេះ

ដោយសារនៅខេត្តក្រចេះ ពុំទាន់មានអនុស្ថានីយបណ្តាញជាតិនៅឡើយ ដូច្នេះនៅខេត្តក្រចេះ ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេនៅពេលបច្ចុប្បន្ននេះ ។ រហូតដល់ឆ្នាំ ២០១៨ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តក្រចេះ អាចមានតែ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.ការផ្គត់ផ្គង់អគ្គិសនីដុំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី២.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ តំបន់ចែកចាយ

អគ្គិសនីនៅក្នុងខេត្តក្រចេះ អាចចែកចេញជា ៣ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយ គឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងក្រចេះ និងទីរួមស្រុកស្នួល ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ទី២.តំបន់ចែកចាយរបស់សេវាករឯកជន ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.តំបន់ចែកចាយរបស់សេវាករឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តក្រចេះ ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីនៅខេត្តក្រចេះ នឹងមានផែនការ ដូចខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ

ដូចបានជម្រាបជូនខាងលើតាមផែនការវិនិយោគរបស់រាជរដ្ឋាភិបាលគឺគ្រោងនឹងអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយពីខេត្តកំពង់ចាម ឆ្លងតាមខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដើម្បីភ្ជាប់ទៅវារីអគ្គិសនីសេសានក្រោម ២ ដោយក្នុងនោះ មានការសាងសង់អនុស្ថានីយបណ្តាញជាតិមួយកន្លែងនៅទីរួមខេត្តក្រចេះ ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៨ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តក្រចេះ ។ ដូច្នេះនៅមុន ឆ្នាំ២០១៨ នៅខេត្តក្រចេះ ពុំមានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយទេ ប៉ុន្តែចាប់ពីឆ្នាំ ២០១៨ ទើបនៅខេត្តក្រចេះអាចមានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ។ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយចាប់ពីឆ្នាំ ២០១៨ នឹងមានអត្រាថ្លៃអគ្គិសនីតាមផែនការ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចរន្តអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ដោយសាររហូតដល់ឆ្នាំ ២០១៨ នៅខេត្តក្រចេះ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួននៅឡើយ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលមានទំហំធំ គឺត្រូវដោះស្រាយ តាមរយៈការផ្គត់ផ្គង់របស់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលបញ្ជូនប្រភពអគ្គិសនីបន្តក្នុងចម្ងាយឆ្ងាយ ពីអនុស្ថានីយបណ្តាញជាតិនៅខេត្តកំពង់ចាម ឬពីប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម ។ ទោះជាប្រភពអគ្គិសនីរបស់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តក្រចេះនេះ មានការផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតក៏ដោយ ប៉ុន្តែផែនការបន្ថយថ្លៃ និងគម្លាតថ្លៃអគ្គិសនីសម្រាប់ការផ្គត់ផ្គង់ឲ្យអ្នកប្រើប្រាស់ធុនធំ ទិញលើតង់ស្យុងមធ្យមពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តក្រចេះ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ នឹងត្រូវកំណត់ដូចខាងក្រោម ៖

**សម្រាប់បណ្តាញបញ្ជូនរងដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.170$/kWh | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីរាយក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា

### ក-ការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយក្រុងក្រចេះ

នៅឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅក្រុងក្រចេះ ត្រូវបានបែងចែកទៅតាមប្រភេទធំ តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ១,០៥០ ៛ / kWh | ស្ថាប័នរដ្ឋ | ១,០៥០ ៛ / kWh |
| **ពាណិជ្ជកម្ម-ឧស្សាហកម្ម** | | | |
| តង់ស្យុងទាបធុនតូច | ១,០៥០ ៛ / kWh | តង់ស្យុងទាបធុនមធ្យម | ៩៨០ ៛ / kWh |
| តង់ស្យុងទាបធុនធំ | ៩២០ ៛ / kWh | តង់ស្យុងមធ្យម | ៨៥០ ៛ / kWh |
| **កសិកម្ម** | | | |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | | | ៨៥០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | | | ៦០០ ៛ / kWh |
| **អតិថិជនក្រៅដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា នៅខេត្តក្រចេះ ដែលជាវពីបណ្តាញបញ្ជូនរង** | | | |
| ពាណិជ្ជកម្ម-ឧស្សាហកម្ម | | | ៨០០ ៛ / kWh |
| **កសិកម្ម** | | | |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | | | ៨០០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | | | ៦០០ ៛ / kWh |

( យោងតាមសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ០២៧.សរ-១៤ អអក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤ )

ដោយសារនៅខេត្តក្រចេះ ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះ ផែនការថ្លៃលក់អគ្គិសនីនៅក្រុងក្រចេះ របស់អគ្គិសនីកម្ពុជាអាចចែកជា ២ ដំណាក់កាល ៖ ដំណាក់កាលទី១ គឺដំណាក់កាលបណ្តោះអាសន្នពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ និងដំណាក់កាលទី ២ គឺដំណាក់កាលចាប់ពីឆ្នាំ ២០១៨ ដែលត្រូវអនុវត្តតាមផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

### ដំណាក់កាលបណ្តោះអាសន្ន

គ្រោងបន្តអនុវត្តតាមតារាងថ្លៃលក់ឆ្នាំ ២០១៥ ដដែល ប៉ុន្តែនឹងខិតខំកាត់បន្ថយថ្លៃក្នុងតារាងថ្លៃដដែលនេះ ចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នៅឆ្នាំ ២០១៦ និងបន្ថយចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង បន្ថែមទៀត នៅឆ្នាំ ២០១៧ ទៅតាមលទ្ធភាពជាក់ស្តែង ។

### ដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល

ចាប់ពីឆ្នាំ ២០១៨ នៅពេលខេត្តក្រចេះ មានអនុស្ថានីយបណ្តាញជាតិហើយ មានន័យថានៅពេលដែលខេត្តក្រចេះ ត្រូវគ្របដណ្តប់ដោយប្រភពអគ្គិសនីពីបណ្តាញជាតិ ដូច្នេះយោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ថ្លៃលក់អគ្គិសនីនៅក្រុងក្រចេះ របស់អគ្គិសនីកម្ពុជានឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ខ-ការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ចែកចាយស្រុកស្នួល របស់អគ្គិសនីកម្ពុជា

នៅឆ្នាំ ២០១៥ ដោយសារស្រុកស្នួលនាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសវៀតណាម រួចដោយសារមានឥទ្ធិពលនយោបាយលើថ្លៃលក់អគ្គិសនីនេះតាំងពីតំបូងផង ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជានៅស្រុកស្នួលនេះ មានអត្រាថ្លៃទាប រួចត្រូវបានបែងចែកទៅតាមប្រភេទ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនធុនតូច | ៦០០ រៀល/kWh ដដែល |
| អតិថិជនធុនមធ្យម | 0.១៥៥ US$/kWh |
| អតិថិជនធុនធំ | 0.១៤៥ US$/kWh |
| អតិថិជនតង់ស្យុងមធ្យម | 0.១៣៥ US$/kWh |

បច្ចុប្បន្ន អគ្គិសនីកម្ពុជាកំពុងជួបប្រទះបញ្ហាលំបាកក្នុងអាជីវកម្ម ដោយសារតែបញ្ជីថ្លៃលក់អគ្គិសនីខាងលើនេះ ត្រូវបានកំណត់តាំងពីស្រុលស្នួលភ្ជាប់ប្រភពអគ្គិសនីជាមួយប្រទេសវៀតណាម ពីតំបូង ប៉ុន្តែរហូតដល់ពេលនេះ អគ្គិសនីវៀតណាមបានតម្លើងថ្លៃលក់អគ្គិសនីនេះចំនួន ៣ ដង រួចទៅហើយ ។ ចុងក្រោយនៅឆ្នាំ ២០១៥ នេះ អគ្គិសនីវៀតណាម បានតម្លើងថ្លៃលក់អគ្គិសនីឲ្យកម្ពុជា តាមរយៈនៃការនាំចូលអគ្គិសនីលើតង់ស្យុងមធ្យម ២២ គីឡូវ៉ុល បន្ថែម ៧.៥% ទៀតនេះ ដែលចាប់អនុវត្តពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ តទៅ ។ ដើម្បីឲ្យសមស្របជាមួយការតម្លើងថ្លៃលក់អគ្គិសនីបន្ថែម ៧.៥%នេះ អគ្គិសនីកម្ពុជា គ្រោងនឹងតម្លើងថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ដោយរក្សាថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនលំនៅដ្ឋាននៅដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាប | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

ចាប់ពីឆ្នាំ២០១៨ នៅពេលដែលខេត្តក្រចេះ មានអនុស្ថានីយបណ្តាញជាតិផ្ទាល់ យោងតាម «ផែនការយុទ្ធសាស្រ្តបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី» របស់រាជរដ្ឋាភិបាល ចាប់ពីឆ្នាំ ២០១៨ ថ្លៃខាងលើនេះ អាចនឹងកែសម្រួលអនុវត្តផែនការរួមវិញ ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧០០៛/kWh | ៧០០៛/kWh | ៧០០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម10kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ០៨ តំបន់ នៅខេត្តក្រចេះ មាន ០៤ តំបន់ បានយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ក្នុងអត្រាថ្លៃ ០.១៦១ ដុល្លា ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចលក់រាយជូនអ្នកប្រើប្រាស់ក្នុងអត្រាថ្លៃ ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង។

ដោយសារពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ខេត្តក្រចេះ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន រួចបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ត្រូវយកប្រភពអគ្គិសនីបន្តពីក្រុងក្រចេះ ឬពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន អ៊ី.ឌី.ខន ជាបណ្តោះអាសន្ន ដូច្នេះផែនការថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនទាំង ០៤ តំបន់នេះ អាចចែកជា ២ ដំណាក់កាល ៖ ដំណាក់កាលទី ១ គឺដំណាក់កាលបណ្តោះអាសន្នពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ និងដំណាក់កាលទី ២ គឺដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

### ដំណាក់កាលបណ្តោះអាសន្ន

ក្នុងដំណាក់កាលបណ្តោះអាសន្ននេះ គ្រោងនឹងខិតខំកាត់បន្ថយអត្រាថ្លៃលក់រាយជូនប្រជាពលរដ្ឋក្នុង ១ ឆ្នាំ ចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង គឺនៅឆ្នាំ ២០១៦ នឹងបន្ថយចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង បន្ថែមទៀត រួចនៅឆ្នាំ ២០១៧ ចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោងបន្ថែមទៀត ដោយចែករំលែកការទទួលបន្ទុកបន្ថយថ្លៃនេះ រវាងអគ្គិសនីកម្ពុជា និងសេវាករចែកចាយអគ្គិសនី។

## ដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល

យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ចាប់ពីឆ្នាំ ២០១៨ នៅពេលខេត្តក្រចេះ មានអនុស្ថានីយបណ្តាញជាតិហើយ ថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

**<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**<u>សម្រាប់លំនៅដ្ឋានទូទៅ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ ការផ្គត់ផ្គង់នៅតំបន់ចែកចាយឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល

នៅខេត្តក្រចេះ មានតំបន់ចែកចាយចំនួន ៤ តំបន់ ដែលជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល។ បញ្ហាដែលត្រូវដោះស្រាយចំពោះតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលទាំង ៤ តំបន់នេះ មាន ២ សំខាន់គឺ ៖ ១.ជម្រុញការវិនិយោគពង្រីកការផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ ឲ្យទៅគ្របដណ្តប់តំបន់ទាំង ៤ នេះ និង២.បន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ៤ នេះ ដូចផែនការរួមទូទាំងប្រទេស ។

ចំពោះតំបន់ចែកចាយអគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែល អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនីនឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះនឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ទុយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដ្យេសែលផលិតអគ្គិសនីទាំង ៤ តំបន់ នៅខេត្តក្រចេះ យើងពុំមានជម្រើសអ្វីក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនវង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាង ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដ្យេសែល ដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ។ គម្រោងសាងសង់ខ្សែបណ្ដាញបញ្ជូនវង ២២ គីឡូវ៉ុល ដាក់ឆ្លងទន្លេមេគង្គ បញ្ជូនប្រភពអគ្គិសនីពីបណ្ដាញជាតិទៅផ្ដល់ឲ្យតំបន់ទាំង ៤ នេះ អាចធ្វើទៅបាននៅពេលដែលខេត្តក្រចេះ មានអនុស្ថានីយបណ្ដាញជាតិ គឺនៅឆ្នាំ ២០១៨ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តស្ទឹងត្រែង សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តស្ទឹងត្រែង

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តស្ទឹងត្រែង មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិ ផ្គត់ផ្គង់ឲ្យតំបន់នានាក្នុងខេត្តនៅឡើយ ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីដែលមានថ្លៃថោកឲ្យខេត្តស្ទឹងត្រែងជាបណ្តោះអាសន្ន អគ្គិសនីកម្ពុជាបានធ្វើការសាងសង់បណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល ពីព្រំដែនប្រទេសឡាវមកក្រុងស្ទឹងត្រែង ដើម្បីនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ មកផ្តល់ឲ្យក្រុងស្ទឹងត្រែង និងតំបន់ចែកចាយមួយចំនួនក្នុងខេត្តស្ទឹងត្រែង ជាបណ្តោះអាសន្ន ។ ចំពោះតំបន់ដ៏ទៃទៀត ដែលមិនអាចយកប្រភពអគ្គិសនីពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានេះ បានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនម៉ាស៊ូតផលិតអគ្គិសនីជាបណ្តោះអាសន្ន ។

ដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តស្ទឹងត្រែង គឺការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនី ភ្ជាប់ពីកំពង់ចាម-ក្រចេះ-ស្ទឹងត្រែង និងភ្ជាប់ជាមួយស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិមួយនៅទីរួមខេត្តស្ទឹងត្រែង រួចបង្វែរបណ្តាញបញ្ជូនរងទាំងអស់ដែលមាន ឲ្យមកយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តស្ទឹងត្រែងវិញ ព្រមទាំងពង្រីកបណ្តាញបញ្ជូនរងនេះ ទៅគ្របដណ្តប់តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ូត ។ នៅពេលនោះ បញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនីមុខជាអាចដោះស្រាយបានដូចខេត្តដ៏ទៃទៀតជាមិនខាន។ តាមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខា គម្រោងអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនី ភ្ជាប់ពីកំពង់ចាម-ក្រចេះ-ស្ទឹងត្រែង និងស្ថានីយវារីអគ្គិសនីសេសានក្រោម ២ និងការបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅទីរួមខេត្តស្ទឹងត្រែង ដែលនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៨ មានន័យថា មុនឆ្នាំ ២០១៨ ខេត្តស្ទឹងត្រែង មិនទាន់គ្របដណ្តប់ដោយប្រភពអគ្គិសនីរបស់បណ្តាញជាតិទាំងនៅឡើយ ដូច្នេះផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីរបស់រាជរដ្ឋាភិបាល នឹងត្រូវអនុវត្តនៅខេត្តនេះ ចាប់ពីឆ្នាំ ២០១៨ ទៅ។ ក្នុងរយៈពេលពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ ដែលគម្រោងអភិវឌ្ឍន៍អនុស្ថានីយបណ្តាញជាតិនៅខេត្តស្ទឹងត្រែង មិនទាន់ដាក់ឲ្យដំណើរការរាជរដ្ឋាភិបាល នឹងរៀបចំផែនការពង្រីកបណ្តាញបញ្ជូនរងបញ្ជូនប្រភពអគ្គិសនីនាំចូលពីប្រទេសឡាវ ទៅជួយបន្ថយថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយនានា ឲ្យបានសមស្របជាបណ្តោះអាសន្នសិន ទម្រាំដល់អនុស្ថានីយបណ្តាញជាតិនៅខេត្តស្ទឹងត្រែង ដាក់ឲ្យដំណើរការ ទើបអនុវត្តថ្លៃអគ្គិសនីតាមផែនការយុទ្ធសាស្ត្របន្ថយអត្រា និងបន្ថយគម្លាតថ្លៃរបស់រាជរដ្ឋាភិបាល ។

## ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តស្ទឹងត្រែង មានក្រុង ១ ឈ្មោះក្រុងស្ទឹងត្រែង និងស្រុកចំនួន ៤ គឺ៖ ១.ស្រុកថាឡាបរិវ៉ាត់ ២.ស្រុកសេសាន ៣.ស្រុកសៀមបូក និង៤.ស្រុកសៀមប៉ាង ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តស្ទឹងត្រែង **មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយទេ** ពីព្រោះខេត្តនេះ ពុំទាន់មានអនុស្ថានីយ គឺ**មានតែការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនវេ** ដែលនាំចូលប្រភពអគ្គិសនីបន្តពីប្រទេសឡាវ និងការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធម្មតា តាមតំបន់ចែកចាយនីមួយៗ ។ ចំពោះការផ្គត់ផ្គង់អគ្គិសនីវាយតាមតំបន់ចែកចាយក្នុងខេត្តស្ទឹងត្រែង ត្រូវបានដោះស្រាយដោយរបៀប ៣ យ៉ាងគឺ ៖ ទី១.ចំពោះក្រុងស្ទឹងត្រែង និងតំបន់តាមគន្លងខ្សែបណ្តាញពីប្រទេសឡាវ មកក្រុងស្ទឹងត្រែងដោះស្រាយដោយយកប្រភពអគ្គិសនីនាំចូលផ្ទាល់ពីប្រទេសឡាវ និងទី២.ចំពោះតំបន់ដែលនៅឆ្ងាយ ដោះស្រាយដោយអនុញ្ញាតឲ្យឯកជនធ្វើការផ្គត់ផ្គង់ដោយម៉ាស៊ីនម៉ាស៊ីនដៀសែលតូចៗ ជាបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តស្ទឹងត្រែង មានតំបន់ផ្គត់ផ្គង់អគ្គិសនីចំនួន ០៣ តំបន់ ដែលក្នុងនោះមាន ៖ ១ តំបន់គឺជារបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា ដែលគ្របដណ្តប់លើតំបន់ក្រុងស្ទឹងត្រែង និងតំបន់តាមបណ្តាយផ្លូវពីព្រំដែនប្រទេសឡាវ មកក្រុងស្ទឹងត្រែង និង ២ តំបន់ទៀត ជាតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករអគ្គិសនីឯកជនទាំង ២ តំបន់ មាន ១ តំបន់ នៅស្រុកសៀមបូក ជាតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីពីប្រព័ន្ធបណ្តាញតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា និង ១ តំបន់ទៀត នៅស្រុកសៀមប៉ាង គឺជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ ។

### ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តស្ទឹងត្រែង



## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តស្ទឹងត្រែង

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា ( ស្ទឹង ត្រែង ) | 001 L | LAO | ស្ទឹង ត្រែង |
| 2 | សេវាករ ឃុន សុខហ្គិច | 395 L | LAO-EDC | ស្រុកសៀមបូក |
| 3 | សេវាករ ហ៊ុយ ចេង | 296 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសៀមប៉ាង |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តស្ទឹងត្រែង

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| សេសាន | 22 | 13 | 59.09% | 4 | 18.18% | 9 |
| សៀមបូក | 17 | 8 | 47.06% | 5 | 29.41% | 3 |
| សៀមប៉ាង | 28 | 5 | 17.86% | 3 | 10.71% | 2 |
| ស្ទឹងត្រែង | 17 | 17 | 100.00% | 13 | 76.47% | 4 |
| ថាឡាបរិវ៉ាត់ | 44 | 7 | 15.91% | 6 | 13.64% | 1 |
| **សរុប** | **128** | **50** | **39.06%** | **31** | **24.22%** | **19** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តស្ទឹងត្រែង

ដោយសារនៅខេត្តស្ទឹងត្រែង ពុំទាន់មានអនុស្ថានីយបណ្តាញជាតិនៅឡើយ ដូច្នេះនៅខេត្តស្ទឹងត្រែង ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ នៅពេលបច្ចុប្បន្ននេះ ។ រហូតដល់ឆ្នាំ ២០១៨ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តស្ទឹងត្រែង អាចមានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.ការផ្គត់ផ្គង់អគ្គិសនីដុំពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ និងទី២.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តស្ទឹងត្រែង អាចចែកចេញជា ៣ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយ គឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងស្ទឹងត្រែង និងតំបន់នានាតាមគន្លងខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា គឺពីព្រំដែនប្រទេសឡាវមកក្រុងស្ទឹងត្រែង ទី២.តំបន់ចែកចាយឯកជនដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តស្ទឹងត្រែង ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីនៅខេត្តស្ទឹងត្រែង នឹងមានផែនការដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ

ដូចបានជម្រាបជូនខាងលើតាមផែនការវិនិយោគរបស់រាជរដ្ឋាភិបាលគឺគ្រោងនឹងអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយ ពីខេត្តកំពង់ចាម ភ្ជាប់ទៅខេត្តស្ទឹងត្រែង និងទៅវារីអគ្គិសនីសេសានក្រោម ២ ដោយក្នុងនោះមានការសាងសង់អនុស្ថានីយបណ្តាញជាតិមួយកន្លែងនៅទីរួមខេត្តស្ទឹងត្រែង ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅដើមឆ្នាំ ២០១៨ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តស្ទឹងត្រែង ។ ដូច្នេះនៅមុនឆ្នាំ២០១៨ នៅខេត្តស្ទឹងត្រែងពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយឡើយប៉ុន្តែចាប់ពីឆ្នាំ២០១៨ ទើបនៅខេត្តស្ទឹងត្រែង

មានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ។ ការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយ ចាប់ពីឆ្នាំ ២០១៨ នឹងមានអត្រាថ្លៃអគ្គិសនីតាមផែនការ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញនៃអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

រហូតដល់ឆ្នាំ ២០១៨ ដោយសារនៅខេត្តស្ទឹងត្រែង ពុំមានអនុស្ថានីយផ្ទាល់ខ្លួននៅឡើយ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលមានទំហំធំ គឺត្រូវដោះស្រាយតាមរយៈការផ្គត់ផ្គង់របស់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាដែលនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ ។ បន្ទាប់មក ចាប់ពីឆ្នាំ ២០១៨ បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានេះ នឹងបង្វែរមកយកប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិវិញ ។ ទោះជាប្រភពអគ្គិសនីរបស់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា មានការផ្លាស់ប្តូរពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀតក៏ដោយ ប៉ុន្តែផែនការបន្ថយថ្លៃ និងគម្លាតថ្លៃអគ្គិសនីសម្រាប់ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធុនធំទិញលើតង់ស្យុងមធ្យម ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តស្ទឹងត្រែង ពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០២០ នឹងត្រូវកំណត់ ដូចខាងក្រោម ៖

**សម្រាប់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.190$/kWh | 0.175$/kWh | 0.170$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>កំណត់សំគាល់</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.៣ តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា

នៅឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅខេត្តស្ទឹងត្រែង ត្រូវបានបែងចែកទៅតាមប្រភេទធំ តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ៩៨០ ៛ / kWh | ស្ថាប័នរដ្ឋ | ៩៨០ ៛ / kWh |
| **ពាណិជ្ជកម្ម-ឧស្សាហកម្ម** | | | |
| តង់ស្យុងទាបធុនតូច | ៩៨០ ៛ / kWh | តង់ស្យុងទាបធុនមធ្យម | ៩២០ ៛ / kWh |
| តង់ស្យុងទាបធុនធំ | ៨៧០ ៛ / kWh | តង់ស្យុងមធ្យម | ៨៣០ ៛ / kWh |

ដោយសារនៅខេត្តស្ទឹងត្រែង ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះផែនការថ្លៃលក់អគ្គិសនីនៅដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា នៅក្នុងខេត្តស្ទឹងត្រែង អាចចែកជា ២ ដំណាក់កាលគឺ ៖ ដំណាក់កាលទី ១ ដំណាក់កាលបណ្តោះអាសន្នពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ និងដំណាក់កាលទី ២ គឺដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

### ដំណាក់កាលបណ្តោះអាសន្ន

គ្រោងបន្តអនុវត្តតាមតារាងថ្លៃលក់ឆ្នាំ ២០១៥ ដដែល ។

## ដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល

យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ចាប់ពីឆ្នាំ ២០១៨ នៅពេលខេត្តស្ទឹងត្រែង មានអនុស្ថានីយបណ្តាញជាតិហើយ ថ្លៃលក់អគ្គិសនីនៅក្នុងដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជានៅខេត្តស្ទឹងត្រែង នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៥០៛/kWh | ៧៤០៛/kWh | ៧៣០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់ឯកជនដែលយកអគ្គិសនីពីអគ្គិសនីកម្ពុជា

នៅក្នុងខេត្តស្ទឹងត្រែង មានតំបន់ចែកចាយរបស់សេវាករឯកជន ១ តំបន់ ដែលបានយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ក្នុងអត្រាថ្លៃប្រភពអគ្គិសនីបច្ចុប្បន្ន ០.១៦១ ដុល្លា ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចលក់រាយជូនអ្នកប្រើប្រាស់ទៅតាមផែនការ និងកម្មវិធីថ្លៃលក់ចុះបន្តបន្ទាប់ពីពេលបច្ចុប្បន្ន ១,៤០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រហូតដល់ ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ដែលតំណាងភូមិ-ឃុំ តំណាងអ្នកប្រើប្រាស់ តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា បានឯកភាពគ្នាក្នុងពេលរៀបចំការផ្គត់ផ្គង់ និងការភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ។

ដោយសារពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ ខេត្តស្ទឹងត្រែង ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន រួចបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ត្រូវនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ ជាបណ្តោះអាសន្ន ដូច្នេះផែនការថ្លៃលក់ដុំប្រភពអគ្គិសនីរបស់អគ្គិសនីកម្ពុជាឲ្យតំបន់ចែកចាយរបស់ឯកជនមួយនេះ អាចនៅរក្សាថ្លៃដដែល រហូតដល់ឆ្នាំ ២០១៨ ។ ក្នុងចន្លោះឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ ដោយសារថ្លៃប្រភពអគ្គិសនីមានអត្រាដដែល ម្យ៉ាងទៀត តំបន់ចែកចាយរបស់ឯកជននៅក្នុងខេត្តស្ទឹងត្រែងនេះ គឺជាតំបន់រាយប៉ាយដែលពុំសូវមានការប្រើប្រាស់ធំៗ ដូច្នេះ ដើម្បីរក្សាឲ្យមាននិរន្តរភាពក្នុងការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីនៅតំបន់នោះ អត្រាថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជននេះ នឹងរក្សាទុកតាមអត្រាដដែល រួចចាប់ពីឆ្នាំ ២០១៨ ទើបអនុវត្តតាមផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។ ដូច្នេះ ផែនការថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់

ឯកជននេះ អាចចែកជា ២ ដំណាក់កាល ៖ ដំណាក់កាលទី ១ គឺដំណាក់កាលបណ្តោះអាសន្នពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៧ និងដំណាក់កាលទី ២ គឺដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

**ដំណាក់កាលបណ្តោះអាសន្ន**

ក្នុងដំណាក់កាលបណ្តោះអាសន្ននេះ អត្រាថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជននេះ នឹងរក្សាទុកតាមអត្រាដដែល ។

**ដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល**

ចាប់ពីឆ្នាំ ២០១៨ នៅពេលខេត្តស្ទឹងត្រែង មានអនុស្ថានីយបណ្តាញជាតិហើយ យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាល ថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានេះ នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| **ប្រភេទនៃការទិញ** | **ឆ្នាំ ២០១៨** | **ឆ្នាំ ២០១៩** | **ឆ្នាំ ២០២០** |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ ការផ្គត់ផ្គង់នៅតំបន់ចែកចាយឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល

នៅខេត្តស្ទឹងត្រែង មានតំបន់ចែកចាយ ១ តំបន់ នៅស្រុកសៀមប៉ាង គឺជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ បញ្ហាដែលត្រូវដោះស្រាយចំពោះតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលនេះមាន ២ សំខាន់គឺ ៖ ១.ជម្រុញការវិនិយោគពង្រីកបណ្តាញបញ្ជូនរងទៅគ្របដណ្តប់តំបន់នេះ និង២.បន្ថយថ្លៃអគ្គិសនីនៅតំបន់នេះ ដូចផែនការរួមទូទាំងប្រទេស ។

ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ

ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយ នៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីនេះ យើងពុំមានជម្រើសអ្វីក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្ដាញបញ្ជូនវង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាង ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ។ គម្រោងសាងសង់ខ្សែបណ្ដាញបញ្ជូនវង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីពីបណ្ដាញជាតិទៅផ្ដល់ឲ្យតំបន់ នេះ អាចធ្វើទៅបាន នៅពេលដែលខេត្តស្ទឹងត្រែងមានអនុស្ថានីយបណ្ដាញជាតិ គឺនៅឆ្នាំ ២០១៨ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តកំពង់ធំ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពង់ធំ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តកំពង់ធំ មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ។ តាមផែនការវិនិយោគដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានពិភាក្សាឯកភាពគ្នា គឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិនចំនួន ១៦៧ លានដុល្លាអាមេរិក នៅឆ្នាំ ២០១៥ ដើម្បីអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយតភ្ជាប់កំពង់ចាម-កំពង់ធំ-សៀមរាប ដោយក្នុងនោះមានការសាងសង់អនុស្ថានីយមួយកន្លែងនៅទីរួមខេត្តកំពង់ធំ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តកំពង់ធំ ។ តាមផែនការនេះ អនុស្ថានីយខេត្តកំពង់ធំ អាចនឹងដាក់ឲ្យដំណើរការរហូតដល់ចុងឆ្នាំ ២០១៧ ខាងមុខ ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តកំពង់ធំ ជាបណ្តោះអាសន្ន ក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា បានអនុញ្ញាតឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីចេញពីអនុស្ថានីយខេត្តកំពង់ចាម ទៅផ្តល់ឲ្យតំបន់ចែកចាយមួយចំនួននៅខេត្តកំពង់ធំ ជាបណ្តោះអាសន្ន ។ តាមបទដ្ឋានបច្ចេកទេស ការបញ្ជូនអគ្គិសនីរបស់ខ្សែបណ្តាញ ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ ទៅ ៧០ គីឡូម៉ែត្រ ប៉ុណ្ណោះ ប៉ុន្តែក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា បានអនុញ្ញាតឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន បញ្ជូនអគ្គិសនីជាបណ្តោះអាសន្ននេះ រហូតដល់ជាង ២០០ គីឡូម៉ែត្រ លើសពីបទដ្ឋានបច្ចេកទេស ដើម្បីបញ្ជូនប្រភពអគ្គិសនីទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ ។ ការបញ្ជូនវែងជាងបទដ្ឋានបៀបនេះ ពិតមែនតែបានដោះស្រាយបញ្ហាថ្លៃអគ្គិសនីខ្ពស់ខ្លះ ប៉ុន្តែការផ្គត់ផ្គង់អគ្គិសនីដោយការបញ្ជូនវែងនេះ ក៏កើតមានអគុណភាព និងមានភាពរអាក់រអួលជាញឹកញាប់ដែរ រួចជាមួយគ្នានោះ ការបាត់បង់អគ្គិសនីលើខ្សែបណ្តាញក៏មានបរិមាណច្រើនលើសពីខេត្តដ៏ទៃ ធ្វើឲ្យថ្លៃចំណាយសម្រាប់ការផ្គត់ផ្គង់អគ្គិសនីនៅខេត្តកំពង់ធំ មានកម្រិតខ្ពស់ជាងការចំណាយនៅខេត្តដ៏ទៃ ។ ប៉ុន្តែទោះជាកើតមានអគុណភាព និងមានរអាក់រអួលជាញឹកញាប់ និងថ្លៃដើមអគ្គិសនីនៅខេត្តកំពង់ធំ មានកម្រិតខ្ពស់ជាងថ្លៃដើមនៅខេត្តដ៏ទៃក៏ដោយ ក៏នៅតែប្រសើរជាងការទុកឲ្យខេត្តកំពង់ធំ នៅប្រើប្រាស់ការផលិតអគ្គិសនីដោយម៉ាស៊ីនដ្យសែលដែលមានថ្លៃអគ្គិសនីខ្ពស់ជាង ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោងដែរ ។ គឺមានតែធ្វើបែបនេះទេ ទើបយើងអាចបន្ថយថ្លៃអគ្គិសនីនៅតំបន់មួយចំនួនធំ ឲ្យថយចុះពីជាង ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យមកនៅត្រឹមជាង ១,២០០ រៀល ទៅ ១,៥០០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ដូចបច្ចុប្បន្នបាន ម្យ៉ាងទៀតធ្វើយ៉ាងនេះ ទើបយើងអាចអភិវឌ្ឍន៍បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនធំរួចជាស្រេច រង់ចាំពេលណាមានអនុស្ថានីយផ្ទាល់នៅខេត្តកំពង់ធំ ពេលនោះយើងអាចបញ្ជូនប្រភពអគ្គិសនីនេះ ទៅកាន់តំបន់នានា ក្នុងខេត្តកំពង់ធំ បានតែម្តង រួចទុកពេលពង្រីកវិសាលភាពផ្គត់ផ្គង់ទៅតំបន់ដែលពុំទាន់មានអគ្គិសនីប្រើប្រាស់ ។

ដូច្នេះដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តកំពង់ធំ នេះ គឺការអភិវឌ្ឍន៍ខ្សែបណ្តាញជាតិបញ្ជូនអគ្គិសនី ភ្ជាប់កំពង់ចាម-កំពង់ធំ-សៀមរាប ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅទីរួមខេត្តកំពង់ធំ រួចបង្វែរបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលមានស្រាប់ និងខ្សែបញ្ជូនរងរបស់អគ្គិសនីកម្ពុជា មកយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពង់ធំ វិញ ។ នៅពេលនោះ បញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនី មុខជាអាចដោះស្រាយបាន ដូចខេត្តដ៏ទៃទៀតជាមិនខាន ។ ទោះជាគម្រោងបង្កើតអនុស្ថានីយបណ្តាញជាតិមួយនៅខេត្តកំពង់ធំ ផ្ទាល់ខាងលើ មិនទាន់ដាក់ឲ្យដំណើរការក៏ដោយក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានរៀបផែនការបន្ថយថ្លៃលក់ដុំអគ្គិសនីជាបណ្តើរៗ ដោយមិនរង់ចាំការសាងសង់អនុស្ថានីយនៅខេត្តកំពង់ធំ ទេ ។ ផែនការនេះ នឹងមានគោលដៅធ្វើឲ្យ ៖ ១.អត្រាថ្លៃលក់ប្រភពអគ្គិសនីឲ្យតំបន់ចែកចាយ និង២.អត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ តាមតង់ស្យុងមធ្យមចេញពីបណ្តាញបញ្ជូនរងទាំងរបស់អគ្គិសនីកម្ពុជានិងទាំងរបស់ឯកជននៅខេត្តកំពង់ធំ ទាំងមូលនឹងមានអត្រាប្រហាក់ប្រហែល ឬលើសបន្តិចបន្តួចជាមួយខេត្តដែលបណ្តាញជាតិគ្របដណ្តប់ផ្ទាល់ដែរ ដោយអគ្គិសនីកម្ពុជា ជាអ្នកប៉ះប៉ូវការបាត់បង់ដែលខ្ពស់ហួសពីកម្រិតកំណត់ ដោយសារការបញ្ជូនឆ្ងាយហួសពីបទដ្ឋាន។ នៅពេលដែលអនុស្ថានីយខេត្តកំពង់ធំ បានសង់រួច និងដាក់ឲ្យដំណើរការ អត្រាថ្លៃទាំងនេះនឹងថយចុះមកដូចផែនការរួមដែលបានគ្រោង រួចនៅពេលនោះ អគ្គិសនីកម្ពុជានឹងអាចដកចេញនូវបន្ទុកដែលខ្លួនត្រូវប៉ះប៉ូវ ។ អ្វីដែលលើសនៅពេលមានអនុស្ថានីយរួច គឺពេលនោះ ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងឧស្សាកម្មធំៗ អាចទិញប្រភពអគ្គិសនីពីទ្វារចេញអនុស្ថានីយផ្ទាល់បាន ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមលក្ខណៈភូមិសាស្ត្រខេត្តកំពង់ធំ មានក្រុង ១ ឈ្មោះក្រុងស្ទឹងសែន និងស្រុកចំនួន ៧ គឺ ៖ ១.ស្រុកបារាយណ៍ ២.ស្រុកកំពង់ស្វាយ ៣.ស្រុកប្រាសាទបល្ល័ង្គ ៤.ស្រុកប្រាសាទសម្បូរ ៥.ស្រុកសណ្តាន់ ៦.ស្រុកសន្ទុក និង៧.ស្រុកស្ទោង។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តកំពង់ធំ **មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ** គឺ**មានការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងនានា** និង**ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ**នីមួយៗ ដែលនៅក្រោមការវិនិយោគរបស់ឯកជន ។ ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ ត្រូវបានដោះស្រាយដោយរបៀប ២ យ៉ាង ទី១.ចំពោះក្រុងស្ទឹងសែន និងតំបន់ចែកចាយសំខាន់ៗ មួយចំនួនក្បែរផ្លូវជាតិ ដោះស្រាយដោយការបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាមតាមបណ្តាញបញ្ជូនរងមកផ្តល់ឲ្យនិងទី២.ចំពោះតំបន់ដែលនៅឆ្ងាយ ដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ ដោយម៉ាស៊ីនផ្សៃសែលជាបណ្តោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តកំពង់ធំ មានតំបន់ចែកចាយអគ្គិសនីចំនួន ១៩ តំបន់ ដែលតំបន់ទាំង ១៩ នេះ សុទ្ធតែជាតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់ឯកជន ។ ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់ឯកជនទាំង ១៩ តំបន់ មាន ១២ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលបានបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ២ តំបន់ទៀត គឺជាតំបន់ដែលទិញបន្តពីតំបន់ចែកចាយដែលបានភ្ជាប់ជាមួយបណ្តាញបញ្ជូនរង ជាបណ្តោះអាសន្ន រង់ចាំទិញផ្ទាល់ពីខ្សែបញ្ជូនរងរបស់

អគ្គិសនីកម្ពុជា និង ៥ តំបន់ទៀត គឺតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដ្យេសែល ដែលមានថ្លៃខ្ពស់ជាបណ្តោះអាសន្ន រង់ចាំទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា។

## ផែនទីបង្ហាញពីតំបន់ចែកចាយអគ្គិសនីដែលមានបច្ចុប្បន្ននៅខេត្តកំពង់ធំ




## បញ្ជីឈ្មោះតំបន់ចែកចាយ និងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តកំពង់ធំ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | ក្រុមហ៊ុន ផេង គៀង អេឡិកទ្រីស៊ីធី | 006 L | GS-BVC | ស្រុកបារាយណ៍ |
| 2 | ក្រុមហ៊ុន ខេម ជិលបូ អេឡិកទ្រីស៊ីធី ផៅវ័រ | 012 L | GS-BVC | ក្រុងស្ទឹងសែន |
| 3 | សេវាករ តែ កុកអេង | 019 L | GS-BVC | ស្រុកបារាយណ៍ |
| 4 | សេវាករ ងិន គង់ | 032 L | GS-BVC | ស្រុកបារាយណ៍ |
| 5 | សេវាករ គឹម ច័ន្ទតារា | 039 L | GS-BVC | ស្រុកបារាយណ៍ |
| 6 | សេវាករ ត្រឹង សាន | 073 L | GS-BVC | ស្រុកសន្ទុក |
| 7 | សេវាករ ឈា សុខុម | 245 L | GS-BVC | ស្រុកបារាយណ៍ |
| 8 | សេវាករ សឿន សុផល | 367 L | GS-BVC | ស្រុកបារាយណ៍ |
| 9 | សេវាករ សើ ទាងកុក | 228 L | GS-BVC | ស្រុកកំពង់ស្វាយ |
| 10 | សេវាករ កើត ចន្ធី | 327 L | GS-BVC | ស្រុកប្រាសទបាលង្គ |
| 11 | សេវាករ អ៊ូច ច្រឹប | 387 L | GS-BVC | ស្រុកកំពង់ស្វាយ |
| 12 | សេវាករ អ៊ុង ហុកស៊ីន (OHS) | 063 L | GS-BVC | ស្រុកស្ទោង |
| 13 | សេវាករ ឃុន ណៃហៀក | 354 L | GS-BVC-OHS | ស្រុកប្រាសាទបាល័ង្គ |
| 14 | សេវាករ ថៃ សុធន់ | 314 L | GS-EDC-KTC-KV | ស្រុកស្ទោង |

| | | | | |
|---|---|---|---|---|
| 15 | សេវាករ ស៊ឹម ឡៃអ៊ី | 199 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសណ្ដាន់ |
| 16 | សេវាករ ជិត ឡៃហ៊ីម | 326 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកប្រាសទសំបូរ |
| 17 | សេវាករ សៀង ទី | 328 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសណ្ដាន់ |
| 18 | សេវាករ ថៃ ធីតា | 365 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសណ្ដាន់ |
| 19 | សេវាករ ម៉េង សុក្រវិរៈ | 368 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកប្រាសាទបាល័ង្គ |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តកំពង់ធំ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| បារាយណ៍ | 182 | 164 | 90.11% | 151 | 82.97% | 13 |
| កំពង់ស្វាយ | 93 | 75 | 80.65% | 25 | 26.88% | 50 |
| ស្ទឹងសែន | 39 | 37 | 94.87% | 35 | 89.74% | 2 |
| ប្រាសាទបល្ល័ង្គ | 64 | 64 | 100.00% | 17 | 26.56% | 47 |
| ប្រាសាទសំបូរ | 66 | 11 | 16.67% | 10 | 15.15% | 1 |
| សណ្តាន់ | 80 | 39 | 48.75% | 9 | 11.25% | 30 |
| សន្ទុក | 77 | 73 | 94.81% | 47 | 61.04% | 26 |
| ស្ទោង | 137 | 112 | 81.75% | 60 | 43.80% | 52 |
| **សរុប** | **738** | **575** | **77.91%** | **354** | **47.97%** | **221** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តកំពង់ធំ

ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ធំ អាចបែងចែកជាផែនការដោយឡែក ទៅតាមការផ្គត់ផ្គង់អគ្គិសនីចំនួន ៣ ប្រភេទ គឺ ៖ ១.ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ២.ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង ទាំងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងទាំងរបស់អគ្គិសនីកម្ពុជា និង៣.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយ ។ តំបន់ចែកចាយចែកជា ៣ ប្រភេទគឺ៖ ១.តំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលបានបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ២.តំបន់ដែលទិញបន្តពីតំបន់ចែកចាយដែលបានភ្ជាប់ជាមួយបណ្តាញបញ្ជូនរងនិងតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល។ ដូច្នេះថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅក្នុងខេត្តកំពង់ធំ ត្រូវបានបែងចែកជា ៥ ផែនការ ទៅតាមការផ្គត់ផ្គង់អគ្គិសនី ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ

ដូចបានជម្រាបជូនខាងលើ តាមផែនការវិនិយោគដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងរ៉ែ និងថាមពល អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា បានពិភាក្សាឯកភាពគ្នា គឺគ្រោងនឹងប្រើប្រាស់ឥណទានពីធនាគារ EXIM Bank របស់ប្រទេសចិនចំនួន ១៦៧ លានដុល្លាអាមេរិក ដើម្បីអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយ តភ្ជាប់កំពង់ចាម-កំពង់ធំ-សៀមរាប ដោយក្នុងនោះមានការសាងសង់អនុស្ថានីយមួយកន្លែងនៅទីរួមខេត្តកំពង់ធំ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តកំពង់ធំ ដែលគ្រោងនឹងដាក់ឲ្យដំណើរការនៅចុងឆ្នាំ ២០១៧ ដើម្បីផ្តល់ប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញជាតិឲ្យខេត្តកំពង់ធំ ។ ដូច្នេះនៅមុនឆ្នាំ ២០១៨ នៅ

ខេត្តកំពង់ធំ ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយឡើយ រួចចាប់ពីឆ្នាំ ២០១៨ ទៅ ទើបខេត្តកំពង់ធំ មានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយ ។ ការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយចាប់ពីឆ្នាំ ២០១៨ នឹងមានអត្រាថ្លៃអគ្គិសនី តាមផែនការ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញផ្ទាល់ពីទ្វារចេញអនុស្ថានីយ | 0.126$/kWh | 0.126$/kWh | 0.126$/kWh |

## ២.២ ការផ្គត់ផ្គង់អគ្គិសនីដុំពីបណ្តាញបញ្ជូនវងនានានៅខេត្តកំពង់ធំ

ដោយសារនៅខេត្តកំពង់ធំ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះការផ្គត់ផ្គង់អគ្គិសនីចេញពីបណ្តាញបញ្ជូនវងសម្រាប់អ្នកប្រើប្រាស់ធំៗ ដែលទិញអគ្គិសនីតាមតង់ស្យុងមធ្យម នៅក្នុងរយៈពេលមិនទាន់មានអនុស្ថានីយនៅខេត្តកំពង់ធំ (២០១៦-២០១៨) ត្រូវបានចែកចេញជា ២ ប្រភេទគឺ ៖ ទី១.ខ្សែបណ្តាញបញ្ជូនវងដែលអគ្គិសនីកម្ពុជា សម្រេចជួយប៉ះប៉ូវការបាត់បង់លើខ្សែ ដើម្បីឲ្យថ្លៃលក់អគ្គិសនីធំលើខ្សែនេះ មានអត្រាប្រហាក់ប្រហែលជាមួយថ្លៃលក់អគ្គិសនីធំរបស់បណ្តាញបញ្ជូនវងដែលចេញពីបណ្តាញជាតិដ៏ទៃទៀត និងទី២. ខ្សែបណ្តាញបញ្ជូនវង ដែលអគ្គិសនីកម្ពុជាពុំអាចជួយប៉ះប៉ូវការបាត់បង់បាន។ ដោយសារពុំទាន់មានការសម្រេចណាមួយនៅឡើយ នៅឆ្នាំ ២០១៥ នេះ ស្ថានភាពថ្លៃអគ្គិសនីលក់ចេញពីបណ្តាញបញ្ជូនវងរបស់ក្រុមហ៊ុន ប៊ី.វី .ស៊ី ផៅវ័រ ឌីវែឡុបមិន សម្រាប់អ្នកប្រើប្រាស់ធំៗ នឹងនៅរក្សាតាមកម្មវិធីថ្លៃដែលបានកំណត់រួចហើយដដែល រួចចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទៅ ទើបថ្លៃលក់អគ្គិសនីធំចេញពីបណ្តាញបញ្ជូនវង សម្រាប់អ្នកប្រើប្រាស់ធំៗ នឹងអនុវត្តតាមផែនការ ដូចខាងក្រោម ៖

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនវងដែល EDC ប៉ះប៉ូវ | 0.1675$/kWh | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |
| ទិញ MV ពីបញ្ជូនវងដែល EDC មិនប៉ះប៉ូវ | 0.180$/kWh | 0.170$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

## ២.៣ តំបន់ចែកចាយរបស់ឯកជននៅក្រុងស្ទឹងសែន

ក្រុងស្ទឹងសែន គឺជាទីរួមខេត្តរបស់ខេត្តកំពង់ធំ ។ ការផ្គត់ផ្គង់អគ្គិសនីនៅក្នុងក្រុងនេះ ធ្វើដោយក្រុមហ៊ុនឯកជនមួយឈ្មោះថា ក្រុមហ៊ុន ខេម ជីលបូ អេឡិកទ្រីក ផៅវ័រ ដែលបានទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនវងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងមានរោងចក្រអគ្គិសនីដុតអង្កាមមួយ ទំហំ ១.៥០ មេហ្គាវ៉ាត់បន្ថែមទៀត ។ នៅឆ្នាំ ២០១៥ នៅក្នុងតំបន់ចែកចាយក្រុងស្ទឹងសែននេះ ថ្លៃលក់អគ្គិសនីមានអត្រាស្មើនឹង ១,២០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង សម្រាប់គ្រប់ប្រភេទអ្នកប្រើប្រាស់ទាំងអស់ ។ ដោយសារក្រុងនេះ គឺជាទីរួមខេត្ត ដូច្នេះតំបន់ចែកចាយអគ្គិសនីរបស់ក្រុងនេះ គ្រោងនឹងអនុញ្ញាតឲ្យភ្ជាប់ប្រភពអគ្គិសនីផ្ទាល់ពីអនុស្ថានីយខេត្តកំពង់ធំ នៅពេលដែលអនុស្ថានីយនេះដាក់ឲ្យដំណើរការ ។ ដូច្នេះផែនការបន្ថយថ្លៃអគ្គិសនីនៅក្រុងស្ទឹងសែន ចែកចេញជា ២ វគ្គ គឺវគ្គទី ១ ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧ និងវគ្គទី ២ ពីឆ្នាំ២០១៨ ដល់ឆ្នាំ ២០២០ ។ ផែនការបន្ថយថ្លៃអគ្គិសនីនៅក្រុងស្ទឹងសែនទាំង ២ វគ្គនេះ មានដូចខាងក្រោម ៖

**<u>សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.225$/kWh | 0.180$/kWh | 0.170$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

យោងតាមផែនការប៉ះប៉ូវរបស់អគ្គិសនីកម្ពុជា ផែនការលក់រាយឲ្យប្រជាពលរដ្ឋនៅក្រុងស្ទឹងសែន ខេត្តកំពង់ធំ មានដូចខាងក្រោម ៖

**<u>សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ១,២០០៛/kWh | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ តំបន់ចែកចាយរបស់ឯកជនដែលទិញប្រភពអគ្គិសនីផ្ទាល់ ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន

នៅខេត្តកំពង់ធំ ក្នុងចំណោមតំបន់ចែកចាយ ដែលបានទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ក្រៅពីតំបន់ចែកចាយក្រុងស្ទឹងសែន គឺមានតំបន់ចែកចាយឯកជនចំនួន ១៣ តំបន់ទៀត ។ តំបន់ចែកចាយទាំង ១៣ នេះ មានថ្លៃលក់បច្ចុប្បន្ននៅខុសៗ គ្នាខ្លះនៅឡើយទៅតាមផែនការ និងកម្មវិធីថ្លៃលក់ដែលតំណាងសាលាខេត្ត តំណាងអ្នកប្រើប្រាស់ តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា បានឯកភាពគ្នាតាមតំបន់ចែកចាយនីមួយៗ ក្នុងពេលរៀបចំការផ្គត់ផ្គង់ និងការភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ជាបន្តបន្ទាប់ ។ ការបន្ថយថ្លៃអគ្គិសនីនៅតំបន់ចែកចាយទាំង ១៣ ខាងលើនេះ អាចចែកជា ២ ដំណាក់កាល ៖ គឺដំណាក់កាលទី ១ ពីឆ្នាំ ២០១៥ រហូតដល់ខែ មីនា ឆ្នាំ ២០១៦ ថ្លៃលក់អគ្គិសនីត្រូវអនុវត្តតាមផែនការ និងកម្មវិធីថ្លៃដែលតំណាងសាលាខេត្ត តំណាងអ្នកប្រើប្រាស់ តំណាងអាជ្ញាធរអគ្គិសនីកម្ពុជា បានឯកភាពគ្នាតាមតំបន់នីមួយៗ ខាងលើរួចហើយ ដំណាក់កាលទី ២ គឺចាប់ពីខែ មីនា ឆ្នាំ ២០១៦ ថ្លៃអគ្គិសនីនៅតំបន់ចែកចាយចំនួន ៨ តំបន់ មាននៅស្រុកបាយណ៍ ស្រុកសន្ទុក និងក្រុងស្ទឹងសែន (ស្រុកបារាយណ៍ ដល់ក្រុងស្ទឹងសែន) ដែលបានទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន នឹងត្រូវថយចុះទៅតាមផែនការ ដូចខាងក្រោម ៖

**សម្រាប់អ្នកប្រើប្រាស់ពាណិជ្ជកម្ម ឧស្សាហកម្ម**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីខ្សែ MV | 0.180$/kWh | 0.170$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់អ្នកប្រើប្រាស់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៨០០៛/kWh | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៨០៛/kWh | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៥ តំបន់ចែកចាយរបស់ឯកជនដែលមានចម្ងាយឆ្ងាយ និងតំបន់ដែលទិញបន្តគ្នាជាបណ្តោះអាសន្ន

ក្នុងចំណោមតំបន់ផ្គត់ផ្គង់របស់ឯកជន ១៤ តំបន់ នៅខេត្តកំពង់ធំ ដែលបានទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន មានតំបន់ចែកចាយ ៦ តំបន់ នៅដែលមានចម្ងាយឆ្ងាយហួសពីក្រុងស្ទឹងសែន នៅស្រុកកំពង់ស្វាយ ស្រុកប្រាសាទបល័ង្គ និងស្រុកស្ទោង ក្នុងនោះមានតំបន់ចែកចាយ ២ តំបន់ ជាតំបន់ដែលទិញប្រភពអគ្គិសនីបន្តពីតំបន់ចែកចាយមួយទៀតជាបណ្តោះអាសន្ន ។ ការបង្កើតឲ្យមានការទិញបន្តគ្នាជាបណ្តោះអាសន្ននេះ ពីព្រោះល្អជាងទុកឲ្យតំបន់ទាំងនោះ នៅប្រើម៉ាស៊ីនដ្យេសែលដែលមានថ្លៃជិត ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ តាមដំណោះស្រាយនេះ បច្ចុប្បន្នតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីបន្តគ្នានេះ បានចុះថ្លៃមកស្មើនឹង ១,៥០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចហើយ ។ យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាលបានកំណត់ថា ក្នុងករណីចាំបាច់ក្នុងគោលបំណង ផ្តល់នូវផលប្រយោជន៍បណ្តោះអាសន្នឲ្យតំបន់ណាមួយ ដែលឋិតនៅក្បែរតំបន់គ្របដណ្តប់របស់បណ្តាញជាតិ ប៉ុន្តែពុំទាន់អាចពង្រីកបណ្តាញបញ្ជូនរងឲ្យទៅគ្របដណ្តប់តំបន់នោះ តាមបទដ្ឋានបច្ចេកទេសបាន អាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា អាចឯកភាពគ្នាអនុញ្ញាតឲ្យមានការផ្តល់ប្រភពបន្តគ្នាជាបណ្តោះអាសន្នដោយ កំណត់ថ្លៃលក់អគ្គិសនីដោយឡែកណាមួយខុសពីផែនការរួមក្នុងរយៈពេលបណ្តោះអាសន្នរហូតដល់តំបន់នោះ ត្រូវបានគ្របដណ្តប់ត្រឹមត្រូវដោយបណ្តាញបញ្ជូនរង តាមបទដ្ឋានបច្ចេកទេស ។ ដូច្នេះចំពោះតំបន់ដែលបញ្ជូនអគ្គិសនីដ៏ឆ្ងាយពីអនុស្ថានីយខេត្តកំពង់ចាម ជាបណ្តោះអាសន្ន មកខេត្តកំពង់ធំ និងទិញបន្តគ្នា ២ តំបន់ក្នុងស្ថានភាពបណ្តោះអាសន្ន និងក្នុងស្ថានភាពនៃការប៉ះប៉ូវខាតដ៏ធំនេះ យើងអាចកំណត់ផែនការបន្ថយថ្លៃលក់អគ្គិសនីសម្រាប់តំបន់ទាំងនេះ ខុសពីផែនការរួមបាន ដោយចែកជា ២ ដំណាក់កាល គឺ ៖ **ដំណាក់កាលទី១** ចាប់ពីខែ មីនា ឆ្នាំ ២០១៦ គឺស្មើនឹងអត្រាថ្លៃតាមផែនការរួមក្នុងខេត្តកំពង់ធំ បូក

នឹងថ្លៃសេវាបញ្ជូនបន្ត និង**ដំណាក់កាលទី២** គឺចាប់ពីពេលដែលមានអនុស្ថានីយ បានភ្ជាប់ផ្ទាល់ជាមួយបណ្តាញជាតិ នៅឆ្នាំ ២០១៨ នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៦ តំបន់ចែកចាយរបស់ឯកជនដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម្យសែលផលិតអគ្គិសនី

ក្នុងចំណោមតំបន់ចែកចាយទាំង ១៩ តំបន់ដែលមាននៅខេត្តកំពង់ធំ មានតំបន់ចែកចាយចំនួន ៥ តំបន់ ជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ីនម្យសែល ។ បញ្ហាដែលត្រូវដោះស្រាយ ចំពោះតំបន់ដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម្យសែលផលិតអគ្គិសនី មាន ៣ សំខាន់គឺ ៖ ១.ជម្រុញការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនីតភ្ជាប់កំពង់ចាម កំពង់ធំ សៀមរាប និងការសាងសង់អនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តកំពង់ធំ ២.ជម្រុញការវិនិយោគពង្រីកបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយទៅគ្របដណ្តប់តំបន់ទាំង ៥ នេះ និង ៣.បន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ៥ នេះ ដូចផែនការរួមទូទាំងប្រទេស ។ ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនម៉ាស៊ីនម្យសែល អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនីនឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះរួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែឬដើមខែក្រោយនៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយ ផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនម៉ាស៊ីនម្យសែលផលិតអគ្គិសនី នៅខេត្តកំពង់ធំ យើងពុំមានជម្រើសអ្វី ក្រៅពីជម្រុញការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោកជាង ទៅជំនួសការផលិតអគ្គិសនីពីម៉ាស៊ីនម៉ាស៊ីនម្យសែលដែលមានថ្លៃខ្ពស់ឡើយ ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ។ ក្រៅពី

នេះយើងក៏នៅត្រូវការឲ្យឯកជនចូលរួមវិនិយោគពង្រីកបណ្តាញចែកចាយ នៅតំបន់ដែលប្រជាពលរដ្ឋពុំទាន់មានអគ្គិសនីប្រើប្រាស់នៅខេត្តកំពង់ធំ ផងដែរ ពីព្រោះរដ្ឋមានលទ្ធភាពវិនិយោគតែត្រឹមខ្សែបណ្តាញបញ្ជូនរងខ្លះៗ តែប៉ុណ្ណោះ។

ចំពោះតំបន់ដែលពុំទាន់មានការផ្គត់ផ្គង់អគ្គិសនីនៅឡើយនៅខេត្តកំពង់ធំ យើងត្រូវជម្រុញការវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីដែលថោក ទៅគ្របដណ្តប់តំបន់នោះ និងអនុញ្ញាតឲ្យសេវាករឯកជនធ្វើការវិនិយោគសាងសង់បណ្តាញចែកចាយអគ្គិសនី ដើម្បីផ្គត់ផ្គង់អគ្គិសនីនៅតំបន់ទាំងនោះ។ គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីពីបណ្តាញជាតិទៅផ្តល់ឲ្យតំបន់ផលិតអគ្គិសនីពីម៉ាស៊ីនភ្លើងឌីស្សែលទាំងនេះ អាចធ្វើទៅបាននៅពេលដែលខេត្តកំពង់ធំ ចាប់ផ្តើមមានអនុស្ថានីយបណ្តាញជាតិផ្ទាល់ គឺនៅឆ្នាំ ២០១៨ ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តរតនគិរី សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តរតនគិរី

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តរតនគិរី មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិ នៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់នានាក្នុងខេត្តនៅឡើយ ។ កន្លងមកប្រភពផ្គត់ផ្គង់អគ្គិសនីសម្រាប់ខេត្តរតនគិរី ត្រូវបានដោះស្រាយដោយការសាងសង់វារីអគ្គិសនីខ្នាតតូច ១ កន្លែង ដែលមានឈ្មោះថា វារីអគ្គិសនីអូរជុំ ។ ប៉ុន្តែដោយសារបន្ទុកប្រើប្រាស់នៅក្រុងបានលុង និងតំបន់ផ្សេងៗ ទៀតនៅខេត្តរតនគិរី បានកើនឡើងជាលំដាប់ ធ្វើឲ្យលទ្ធភាពនៃប្រភពផ្គត់ផ្គង់ដោយវារីអគ្គិសនីខ្នាតតូច១កន្លែងនេះកាន់តែលំបាក ទើបនៅឆ្នាំ ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចឲ្យអគ្គិសនីកម្ពុជាធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង៣៥ គីឡូវ៉ុល ដើម្បីនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្គត់ផ្គង់ឲ្យក្រុងបានលុង និងតំបន់ចែកចាយនានា ក្នុងខេត្តរតនគិរី បន្ថែម ។ ទោះបីជាថ្លៃប្រភពអគ្គិសនីដែលនាំចូលពីប្រទេសវៀតណាម ត្រូវបានវៀតណាមតម្លើងថ្លៃជាបន្តបន្ទាប់ ធ្វើឲ្យស្ថានភាពអាជីវកម្មរបស់អគ្គិសនីកម្ពុជាកាន់តែលំបាក ប៉ុន្តែរាជរដ្ឋាភិបាលមិនទាន់មានគម្រោងវិនិយោគ ពង្រីកបណ្តាញជាតិតង់ស្យុងខ្ពស់ ដើម្បីបង្កើតអនុស្ថានីយបណ្តាញជាតិនៅខេត្តរតនគិរី នៅឡើយទេ ដោយសារបន្ទុកប្រើប្រាស់នៅខេត្តនេះនៅមានទំហំតូចនៅឡើយ ។ ការបញ្ជូនប្រភពអគ្គិសនីទៅឲ្យតំបន់ចែកចាយនានានៅក្នុងខេត្តនេះ គឺធ្វើតាមបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និងបំពេញបន្ថែមដោយការផ្គត់ផ្គង់ប្រភពអគ្គិសនីពីវារីអគ្គិសនីខ្នាតតូច ១ កន្លែង ។ ចំពោះតំបន់ចែកចាយដ៏ទៃទៀត ដែលមិនអាចយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានេះ បានដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនដៀសែលផលិតអគ្គិសនីជាបណ្តោះអាសន្ន ។ នៅពេលដែលវារីអគ្គិសនីសេសានក្រោម ២ ដាក់ឲ្យដំណើរការ រាជរដ្ឋាភិបាលមានគម្រោងសាងសង់បណ្តាញបញ្ជូនរងតង់ស្យុង ៣៥ គីឡូវ៉ុល ពីអនុស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ទៅខេត្តរតនគិរី ដើម្បីផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិទៅឲ្យខេត្តរតនគិរី បន្ថែម ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

តាមភូមិសាស្ត្រខេត្តរតនគិរី មានក្រុង ១ ឈ្មោះក្រុងបានលុង និងស្រុកចំនួន ៨ គឺ៖ ១.ស្រុកអូរជុំ ២.ស្រុកវើនសៃ ៣.ស្រុកបរកែវ ៤.ស្រុកលំផាត់ ៥.ស្រុកកូនមុំ ៦.ស្រុកអណ្តូងមាស ៧.ស្រុកអូរយ៉ាដាវ និង ៨.ស្រុកតាវែង ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តរតនគិរី **មិនមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ** ពីព្រោះនៅខេត្តនេះ ពុំមានអនុស្ថានីយបណ្តាញជាតិនៅឡើយ គឺ**មានតែការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង** ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និង **ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ ចំពោះការផ្គត់ផ្គង់អគ្គិសនីរាយ តាមតំបន់ចែកចាយក្នុងខេត្តរតនគិរី ត្រូវបានដោះស្រាយដោយរបៀប ៣ យ៉ាង ទី១.ចំពោះក្រុងបានលុង ដោះស្រាយដោយ

ការបញ្ជូនប្រភពអគ្គិសនី តាមបណ្តាញតង់ស្យុងមធ្យមពីប្រទេសវៀតណាម និងបំពេញបន្ថែមដោយការផ្គត់ផ្គង់ពីវារីអគ្គិសនីខ្នាតតូចអូរជុំ ទី២.ចំពោះតំបន់ចែកចាយមួយចំនួនទៀត ដោះស្រាយដោយការផ្តល់ប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម និងទី៣.ចំពោះតំបន់ដែលនៅឆ្ងាយដោះស្រាយដោយអនុញ្ញាតឲ្យសេវាករឯកជនធ្វើការផ្គត់ផ្គង់ដោយម៉ាស៊ីនដៀសែលជាបណ្តោះអាសន្ន។ បច្ចុប្បន្ននៅខេត្តរតនគិរី មានតំបន់ចែកចាយអគ្គិសនីចំនួន ៥ តំបន់ ដែលក្នុងនោះមាន ១ តំបន់ គឺជាតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា និង ៤ តំបន់ទៀត ជាតំបន់ចែកចាយរបស់ឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៤ តំបន់ មាន ២ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា គឺតំបន់នៅស្រុកបរកែវ និងតំបន់នៅស្រុកអូរយ៉ាដាវ និង ២ តំបន់ទៀត គឺជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ដែលមានថ្លៃខ្ពស់ គឺតំបន់នៅស្រុកអណ្តូងមាស និងតំបន់នៅស្រុកកូនមុំ ។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តរតនគិរី




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តរតនគិរី

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (រតនគិរី) | 001 L | VN | ក្រុងបាលុង |
| 2 | សេវាករ សំរិទ្ធ ហន | 291 L | VN-EDC | ស្រុកបរកែវ |
| 3 | សេវាករ ឈឹម គឹមឈន | 333 L | VN-EDC | ស្រុកអូរយ៉ាដាវ |
| 4 | សេវាករ ស៊ាវ ពិសិដ្ឋ | 372 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកអណ្តូងមាស |
| 5 | សេវាករ ស៊ាង សុលីនដា | 380 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកកូនមុំ |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តរតនគិរី

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| អណ្តូងមាស | 21 | 21 | 100.00% | 2 | 9.52% | 19 |
| បានលុង | 16 | 16 | 100.00% | 15 | 93.75% | 1 |
| បរកែវ | 34 | 28 | 82.35% | 13 | 38.24% | 15 |
| កូនមុំ | 23 | 8 | 34.78% | - | - | 8 |
| លំផាត់ | 26 | - | - | - | - | - |
| អូរជុំ | 37 | 5 | 13.51% | 5 | 13.51% | - |
| អូរយ៉ាដាវ | 29 | 26 | 89.66% | 16 | 55.17% | 10 |
| តាវែង | 20 | - | - | - | - | - |
| វើនសៃ | 34 | - | - | - | - | - |
| **សរុប** | **240** | **104** | **43.33%** | **51** | **21.25%** | **53** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តរតនគិរី

ដោយសារនៅខេត្តរតនគិរី ពុំមានអនុស្ថានីយបណ្តាញជាតិ ដូច្នេះនៅខេត្តរតនគិរី ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តរតនគិរី មានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.**ការផ្គត់ផ្គង់អគ្គិសនីធំ** ពីខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និងទី២.**ការផ្គត់ផ្គង់អគ្គិសនីរាយ** តាមតំបន់ចែកចាយនីមួយៗ ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តរតនគិរី អាចចែកចេញជា ៣ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយគឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងបានលុង ទី២.តំបន់ចែកចាយឯកជនដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តរតនគិរី ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីនៅខេត្តរតនគិរី មានផែនការ ដូចខាងក្រោម ៖

## ២.១ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ដោយសារនៅខេត្តរតនគិរី ពុំមានគម្រោងសាងសង់អនុស្ថានីយផ្ទាល់ខ្លួន ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលមានទំហំធំ គឺត្រូវដោះស្រាយតាមរយៈការផ្គត់ផ្គង់របស់បណ្តាញបញ្ជូនរង របស់អគ្គិសនីកម្ពុជាដែលនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ។ ចាប់ពីឆ្នាំ ២០១៨ នៅពេលវារីអគ្គិសនីសេសានក្រោម ២ ដាក់ឲ្យដំណើរការ អគ្គិសនីកម្ពុជានឹងមានបណ្តាញបញ្ជូនរងមួយទៀត ចេញពីអនុស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ឆ្ពោះទៅក្រុងបានលុង ពេលនោះប្រព័ន្ធផ្គត់ផ្គង់ប្រភពអគ្គិសនីអាចនឹងត្រូវផ្គត់ផ្គង់ពីប្រភពបណ្តាញជាតិវិញ ដែលការផ្គត់ផ្គង់អគ្គិសនីធំ តាមបណ្តាញបញ្ជូនរងត្រូវកែសម្រួលពីអត្រាថ្លៃបច្ចុប្បន្នមកជាថ្លៃតាមផែនការរួមនៃប្រភពអគ្គិសនីចេញពីបណ្តាញជាតិវិញ ។ ដូច្នេះផែនការថ្លៃអគ្គិសនីសម្រាប់ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធុនធំ ទិញលើតង់ស្យុងមធ្យមពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តរតនគិរី ពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ អាចត្រូវបានកំណត់ ដូចខាងក្រោម ៖

## សម្រាប់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៥ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.155$/kWh | 0.155$/kWh | 0.155$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

__កំណត់សំគាល់__ ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ២.២ ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងបានលុង

នៅឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅក្រុងបានលុង ត្រូវបានបែងចែកទៅតាមប្រភេទធំ តូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនធុនតូច | 670 ៛ / kWh | អតិថិជនធុនធំ | 0.145 $US / kWh |
| អតិថិជនធុនមធ្យម | 0.155 $US / kWh | អតិថិជនតង់ស្យុងមធ្យម | 0.135 $US / kWh |

ដោយសារឥទ្ធិពលនៃការកំណត់ថ្លៃតាំងពីដំបូងនៅក្រុងបានលុង ស្មើនឹង ៦០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជានៅក្រុងបានលុង បច្ចុប្បន្ននេះ មានអត្រាថ្លៃស្មើនឹង ៦៧០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ប៉ុណ្ណោះ។ កន្លងមកអគ្គិសនីកម្ពុជាខិតខំរក្សាអត្រាថ្លៃលក់អគ្គិសនីខាងលើឲ្យនៅទាបដដែល រហូតដល់ឆ្នាំ ២០១៥ ហើយនៅក្នុងឆ្នាំ ២០១៥ ចាប់ពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០១៥ មក ប្រទេសវៀតណាម បានតម្លើងថ្លៃអគ្គិសនីលក់ឲ្យកម្ពុជាចំនួន ៧.៥% បន្ថែមទៀត ដែលធ្វើឲ្យប្រភពអគ្គិសនីផ្គត់ផ្គង់ឲ្យក្រុងបានលុង កើនឡើងថែមទៀត ធ្វើឲ្យអាជីវកម្មចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជានៅទីនោះកាន់តែលំបាក។ដើម្បីឲ្យសមស្របជាមួយការតម្លើងថ្លៃលក់អគ្គិសនីបន្ថែម៧.៥% នេះ អគ្គិសនីកម្ពុជាគ្រោងនឹងតម្លើងថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម ដោយរក្សាថ្លៃលក់អគ្គិសនីសម្រាប់អតិថិជនលំនៅដ្ឋាននៅដដែល ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់អគ្គិសនី |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាបនៅក្រុងបានលុង | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

__កំណត់សំគាល់__ ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

ចាប់ពីឆ្នាំ ២០១៨ នៅពេលវារីអគ្គិសនីសេសានក្រោម ២ ដាក់ឲ្យដំណើរការ ពេលនោះអគ្គិសនីកម្ពុជានឹងមានបណ្តាញបញ្ជូនរងចេញពីអនុស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ទៅផ្គត់ផ្គង់ឲ្យខេត្តរតនគិរី និងក្រុងបានលុង ដើម្បីឲ្យការផ្គត់ផ្គង់អគ្គិសនីនៅខេត្តរតនគិរី មានស្ថេរភាព និងគុណភាពពេញលេញ ។ ដូច្នេះនៅពេលនោះ យោងតាម "ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី" របស់រាជរដ្ឋាភិបាលចាប់ពីឆ្នាំ ២០១៨ ទៅថ្លៃលក់អគ្គិសនីនៅក្រុងបានលុង នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

__សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ__

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្តាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

កំណត់សំគាល់ ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៧០០៛/kWh | ៧០០៛/kWh | ៧០០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៣ តំបន់ចែកចាយឯកជនដែលយកប្រភពអគ្គិសនីពីអគ្គិសនីកម្ពុជា

នៅក្នុងខេត្តរតនគិរី មានតំបន់ចែកចាយរបស់សេវាករឯកជន ២ តំបន់ ដែលបានយកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលនាំចូលអគ្គិសនីពីប្រទេសវៀតណាម ក្នុងអត្រាថ្លៃ 0.133 ដុល្លា ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចលក់រាយជូនអ្នកប្រើប្រាស់ក្នុងអត្រាថ្លៃ ១,១០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ហើយនៅខែសីហា ឆ្នាំ ២០១៥ នឹងបន្ថយ មក ១,០៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

ដោយសារពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៧ បណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានៅខេត្តរតនគិរី ត្រូវនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ដូច្នេះផែនការថ្លៃលក់ដុំប្រភពអគ្គិសនីរបស់អគ្គិសនីកម្ពុជាឲ្យតំបន់ចែកចាយរបស់ឯកជន អាចនៅរក្សាថ្លៃដដែល រហូតដល់ឆ្នាំ ២០១៨ ។ ក្នុងចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៨ ដោយសារថ្លៃប្រភពអគ្គិសនីលក់ឲ្យតំបន់ចែកចាយទាំងនេះ មានអត្រាដដែល ប៉ុន្តែការប្រើប្រាស់នៅតំបន់ទាំងនេះអាចកើនឡើង ដូច្នេះ អត្រាថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២ តំបន់នៅខេត្តរតនគិរី អាចនឹងពិនិត្យបន្ថយថ្លៃបានមួយចំនួនទៀត ។ ចាប់ពីឆ្នាំ ២០១៨ ទៅ ពេលវារីអគ្គិសនីសេសានក្រោម ២ដាក់ឲ្យដំណើរការអគ្គិសនីកម្ពុជានឹងមានបណ្ដាញបញ្ជូនរងមួយទៀត ចេញពីអនុស្ថានីយវារីអគ្គិសនីសេសានក្រោម ២ មកបន្ថែម ដែលអាចបញ្ជូនប្រភពអគ្គិសនីបណ្ដាញជាតិមកឲ្យតំបន់ចែកចាយទាំង ២ នេះ រួចអាចឲ្យយើងអនុវត្តតាមផែនការបន្ថយថ្លៃរួម របស់រាជរដ្ឋាភិបាលបាន ។ ដូច្នេះផែនការថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់ឯកជនទាំង ២ នេះ អាចចែកជា ២ ដំណាក់កាល ៖ ដំណាក់កាលទី ១ គឺដំណាក់កាលបណ្ដោះអាសន្នពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៧ និងដំណាក់កាលទី ២ គឺដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

### ដំណាក់កាលបណ្ដោះអាសន្ន

ក្នុងដំណាក់កាលបណ្ដោះអាសន្ននេះ អត្រាថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជននៅខេត្តរតនគិរី នឹងពិនិត្យបន្ថយថ្លៃខ្លះ តាមស្ថានភាពជាក់ស្ដែង ។

### ដំណាក់កាលអនុវត្តផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល

ចាប់ពីឆ្នាំ២០១៨ នៅពេលខេត្តរតនគិរី មានបណ្ដាញបញ្ជូនរងមួយទៀត ចេញពីអនុស្ថានីយវារីអគ្គិសនីសេសានក្រោម ២ ថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនដែលយកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជានេះ នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្ដាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**កំណត់សំគាល់** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

**សម្រាប់លំនៅដ្ឋានទូទៅ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១0kWh/ខែ**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

**ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក**

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

## ២.៤ ការផ្គត់ផ្គង់នៅតំបន់ចែកចាយឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ីនដៀសែល

ខេត្តរតនគិរី មានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ បញ្ហាដែលត្រូវដោះស្រាយចំពោះតំបន់ ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលនេះ មាន ២ សំខាន់គឺ ៖ ១.ជម្រុញការវិនិយោគពង្រីកបណ្ដាញបញ្ជូនរងទៅគ្របដណ្ដប់តំបន់នេះ និង២.បន្ថយថ្លៃអគ្គិសនីនៅតំបន់នេះដូចផែនការរួមទូទាំងប្រទេស។

ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយនៅពេលចេញវិក្កយបត្រ ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តមណ្ឌលគិរី សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តមណ្ឌលគិរី

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តមណ្ឌលគិរី មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់នានាក្នុងខេត្តនៅឡើយ ។ កន្លងមក ប្រភពផ្គត់ផ្គង់អគ្គិសនីសម្រាប់ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ត្រូវបានដោះស្រាយដោយការសាងសង់វារីអគ្គិសនីខ្នាតតូច ២ កន្លែង និងរោងចក្រដើរដោយម៉ាស៊ីនម្យ (ដោយជ្រៀសែល) ១ កន្លែង ដែលជាជំនួយរបស់ប្រទេសជប៉ុន ។ ប៉ុន្តែដោយសារបន្ទុកប្រើប្រាស់នៅក្រុងសែនមនោរម្យ និងតំបន់ជុំវិញក្រុងបានកើនឡើងជាលំដាប់ ធ្វើឲ្យលទ្ធភាពនៃប្រភពផ្គត់ផ្គង់ដោយប្រភពដែលបានមកដោយជំនួយរបស់ប្រទេសជប៉ុនខាងលើនេះ កាន់តែលំបាក ទើបនៅឆ្នាំ ២០០៩ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចឲ្យអគ្គិសនីកម្ពុជាធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល ដើម្បីនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្គត់ផ្គង់ឲ្យក្រុងសែនមនោរម្យ បន្ថែម ។ ក្រៅពីក្រុងសែនមនោរម្យ អគ្គិសនីកម្ពុជាក៏បានធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល ដើម្បីនាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម ១ ប្រភពទៀត មកផ្គត់ផ្គង់ឲ្យស្រុកកែវសីមា ផងដែរ ។

ចំពោះខេត្តមណ្ឌលគិរី នេះ រាជរដ្ឋាភិបាលមិនទាន់មានគម្រោងវិនិយោគពង្រីកបណ្តាញជាតិតង់ស្យុងខ្ពស់ដើម្បីបង្កើតអនុស្ថានីយបណ្តាញជាតិនៅខេត្តនេះនៅឡើយទេ ដោយសារបន្ទុកប្រើប្រាស់នៅខេត្តនេះនៅមានទំហំតូចនៅឡើយ មិនសមស្របនឹងការវិនិយោគ ។ ប៉ុន្តែប្រសិនបើគម្រោងផលិតកម្មរ៉ែមាស នៅក្នុងតំបន់ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី អាចដំណើរការបាន ពេលនោះអគ្គិសនីកម្ពុជាអាចធ្វើការវិនិយោគរួមគ្នា ជាមួយអ្នកវិនិយោគអាជីវកម្មរ៉ែមាស ដើម្បីពង្រីកបណ្តាញជាតិតង់ស្យុងខ្ពស់ពីខេត្តក្រចេះ ឆ្ពោះទៅតំបន់អាជីវកម្មរ៉ែ និងបន្តបន្ថែមឆ្ពោះទៅបង្កើតអនុស្ថានីយបណ្តាញជាតិមួយនៅក្បែរក្រុងសែនមនោរម្យ ដើម្បីផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិឲ្យខេត្តនេះ ។ ប៉ុន្តែប្រសិនបើគម្រោងផលិតកម្មរ៉ែមាស នៅតំបន់ខាងលើមិនអាចធ្វើទៅមុខបាន គម្រោងបង្កើតអនុស្ថានីយបណ្តាញជាតិមួយ នៅក្បែរក្រុងសែនមនោរម្យ មិនអាចកើតឡើងបានទេ នៅក្នុងចន្លោះឆ្នាំ ២០១៥ ទៅឆ្នាំ ២០២០ នេះ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

ខេត្តមណ្ឌលគិរី មានក្រុង ១ ឈ្មោះក្រុងសែនមនោរម្យ និងស្រុកចំនួន ៤ គឺៈ ១.ស្រុកកែវសីមា ២.ស្រុកកោះញែក ៣.ស្រុកអូររាំង និង៤.ស្រុកពេជ្រាដា ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តមណ្ឌលគិរី មិនមានការផ្គត់ផ្គង់អគ្គិសនីផ្ទាល់ពីអនុស្ថានីយទេ ពីព្រោះនៅក្នុងខេត្តនេះពុំទាន់មានអនុស្ថានីយបណ្តាញជាតិ គឺមានការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធុនធំពីបណ្តាញបញ្ជូនរងដែលអគ្គិសនីកម្ពុជានាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម និងការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធម្មតាតាមតំបន់ចែក

ចាយ ។ តំបន់ចែកចាយអគ្គិសនីនៅខេត្តមណ្ឌលគិរី មានតែ ២ កន្លែងទេ គឺមួយកន្លែងនៅក្រុងសែនមនោរម្យ និងមួយកន្លែងទៀត នៅស្រុកកែវសីមា ដែលទាំង ២ តំបន់នេះ ជាតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់អគ្គិសនីកម្ពុជា។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តមណ្ឌលគិរី




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តមណ្ឌលគិរី

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា (ក្រុងសែនមនោរម្យ) | ០០១ | នាំចូលពីវៀតណាម | ក្រុងសែនមនោរម្យ |
| 2 | អគ្គិសនីកម្ពុជា (ស្រុកកែវសីមា) | ០០១ | នាំចូលពីវៀតណាម | ស្រុកកែវសីមា |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តមណ្ឌលគិរី

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| កែវសីមា | 25 | 10 | 40.00% | 5 | 20.00% | 5 |
| កោះញែក | 26 | - | - | - | - | - |
| អូររាំង | 7 | 7 | 100.00% | 3 | 42.86% | 4 |
| ពេជ្រាដា | 18 | - | - | - | - | - |
| សែនមនោរម្យ | 14 | 14 | 100.00% | 12 | 85.71% | 2 |
| សរុប | 90 | 31 | 34.44% | 20 | 22.22% | 11 |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តមណ្ឌលគិរី

ដោយសារនៅខេត្តមណ្ឌលគិរី ពុំមានអនុស្ថានីយបណ្តាញជាតិ ដូច្នេះនៅខេត្តនេះ **ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ** ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនី នៅក្នុងខេត្តមណ្ឌលគិរី មានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.**ការផ្គត់ផ្គង់អគ្គិសនីតាមតង់ស្យុងមធ្យម** និងទី២.**ការផ្គត់ផ្គង់អគ្គិសនីរាយ** ឲ្យអ្នកប្រើប្រាស់តាមតំបន់ចែកចាយ ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តមណ្ឌលគិរី មានតែ ២ តំបន់ប៉ុណ្ណោះ គឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសែនមនោរម្យ ទី២.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅស្រុកកែវសីមា ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តមណ្ឌលគិរី ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីនៅខេត្តមណ្ឌលគិរី មានផែនការ ដូចខាងក្រោម ៖

### ក.ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅក្រុងសែនមនោរម្យ

នៅឆ្នាំ ២០១៥ ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅក្រុងសែនមនោរម្យ ត្រូវបានបែងចែកទៅតាមប្រភេទធំ និងតូច ដែលមានអត្រាថ្លៃ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ១,០៥០ ៛ / kWh | ស្ថាប័នរដ្ឋ | ១,០៥០ ៛ / kWh |
| **ពាណិជ្ជកម្ម-ឧស្សាហកម្ម** | | | |
| តង់ស្យុងទាបធុនតូច | ១,០៥០ ៛ / kWh | តង់ស្យុងទាបធុនមធ្យម | ៩៨០ ៛ / kWh |
| តង់ស្យុងទាបធុនធំ | ៩២០ ៛ / kWh | តង់ស្យុងមធ្យម | ៨៥០ ៛ / kWh |
| **កសិកម្ម** | | | |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | | | ៨៥០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | | | ៦០០ ៛ / kWh |
| **អតិថិជនក្រៅដែនអាជ្ញាប័ណ្ណរបស់អគ្គិសនីកម្ពុជា នៅខេត្តមណ្ឌលគិរី ដែលជាវពីបណ្តាញបញ្ជូនវង** | | | |
| ពាណិជ្ជកម្ម-ឧស្សាហកម្ម | | | ៨០០ ៛ / kWh |
| **កសិកម្ម** | | | |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ០៧:០០ ព្រឹក ដល់ ម៉ោង ២២:០០ យប់ | | | ៨០០ ៛ / kWh |
| តង់ស្យុងមធ្យម ប្រើប្រាស់ពីម៉ោង ២២:០០ យប់ ដល់ ម៉ោង ០៧:០០ ព្រឹក | | | ៦០០ ៛ / kWh |

(យោងតាមសេចក្តីសម្រេចលេខ០២៧.សរ-១៤ អអក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤)

តាមផែនការ ប្រសិនបើការប្រើប្រាស់អគ្គិសនីនៅក្រុងសែនមនោរម្យ កើនឡើងតាមការគ្រោងទុក ថ្លៃលក់ក្នុងតារាងខាងលើនេះ អាចនឹងបន្ថយបាន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នៅឆ្នាំ២០១៦ និង ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ទៀត នៅឆ្នាំ២០១៧ ។ ប្រសិនបើស្ថានភាពអំណោយផល ដែលគម្រោងផលិតកម្មរ៉ែមាសនៅក្នុងតំបន់ខេត្តក្រចេះ និងខេត្តមណ្ឌលគិរី អាចដំណើរការបាន រួចអគ្គិសនីកម្ពុជាអាចធ្វើការវិនិយោគរួមគ្នាជាមួយអ្នកវិនិយោគអាជីវកម្មរ៉ែមាស ដើម្បីពង្រីកបណ្តាញជាតិឆ្ពោះទៅតំបន់អាជីវកម្មរ៉ែ និងបន្តឆ្ពោះទៅបង្កើតអនុស្ថានីយបណ្តាញជាតិមួយ នៅក្បែរក្រុងសែនមនោរម្យ ផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិទៅឲ្យខេត្តនេះ ពេលនោះថ្លៃអគ្គិសនីនៅក្រុងសែនមនោរម្យ អាចនឹងត្រូវបន្ថយទៅតាមផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល សម្រាប់តំបន់ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ។

**ខ.ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅស្រុកកែវសីមា**

នៅស្រុកកែវសីមាខេត្តមណ្ឌលគិរី មានតំបន់ចែកចាយតូចមួយរបស់អគ្គិសនីកម្ពុជា ដែលអគ្គិសនីកម្ពុជា បាននាំចូលប្រភពអគ្គិសនីពីប្រទេសវៀតណាម មកផ្គត់ផ្គង់ឲ្យតំបន់នេះ។ ដោយសារការកំណត់ថ្លៃតាំងពីតំបូង និងការខិតខំរក្សាទុកអត្រាថ្លៃនេះ ថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជានៅស្រុកកែវសីមា មានអត្រាថ្លៃទាបស្មើនឹង ៦៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ប៉ុណ្ណោះ ។ កន្លងមកថ្លៃនាំចូលអគ្គិសនីពីប្រទេសវៀតណាម បានឡើងថ្លៃជាបន្តបន្ទាប់ តាំងពីស្រុកកែវសីមាបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រទេសវៀតណាម ពីតំបូងម្ល៉េះ ប៉ុន្តែទោះជាវៀតណាម តម្លើងថ្លៃជាបន្តបន្ទាប់ក៏ដោយ កន្លងមកអគ្គិសនីកម្ពុជាខិតខំរក្សាអត្រាថ្លៃលក់អគ្គិសនីខាងលើឲ្យនៅដដែល រហូតដល់ឆ្នាំ២០១៥ ។ នៅក្នុងឆ្នាំ២០១៥ ចាប់ពីថ្ងៃទី ១៦ ខែ មីនា ទៅ ប្រទេសវៀតណាម បានតម្លើងថ្លៃអគ្គិសនីលក់ឲ្យកម្ពុជាចំនួន ៧.៥% បន្ថែមទៀត ដែលធ្វើឲ្យអាជីវកម្មចែកចាយអគ្គិសនីរបស់អគ្គិសនីកម្ពុជា នៅទីនោះកាន់តែលំបាក ។ ទោះជាយ៉ាងនេះក៏ដោយ អគ្គិសនីកម្ពុជាគ្រោងថានឹងរក្សាថ្លៃលក់អគ្គិសនីឲ្យប្រជាពលរដ្ឋនៅទីនោះ នៅដដែល ប៉ុន្តែកែសម្រួលថ្លៃលក់អគ្គិសនីឲ្យអតិថិជនឧស្សាហកម្ម ពាណិជ្ជកម្ម តាមបញ្ជីថ្លៃលក់ ដូចខាងក្រោម ៖

| **ប្រភេទអតិថិជន** | **អត្រាថ្លៃលក់អគ្គិសនី** |
|---|---|
| អតិថិជនធុនតូចតង់ស្យុងទាប | នៅរក្សាដដែល |
| អតិថិជនតង់ស្យុងមធ្យម | 0.១៥៥ US$/kWh |

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តព្រះវិហារ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះវិហារ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តព្រះវិហារ មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានការអភិវឌ្ឍន៍បណ្តាញជាតិទៅដល់ និងពុំទាន់មានអនុស្ថានីដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់នានា ក្នុងខេត្តនៅឡើយ ធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់នានាក្នុងខេត្តនេះ ភាគច្រើន គឺដោះស្រាយដោយការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ ។ កន្លងមកថ្មីៗនេះ អគ្គិសនីកម្ពុជាបានធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល នាំចូលអគ្គិសនីពីប្រទេសឡាវ តាមច្រកកំពង់ស្រឡៅ ដើម្បីយកប្រភពអគ្គិសនីមកផ្តល់ឲ្យខេត្តព្រះវិហារ ជំនួសការផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលតូចៗ ។ គម្រោងនេះ បច្ចុប្បន្នបានដាក់ឲ្យដំណើរការដល់ឃុំកំពង់ស្រឡៅ ១ ស្រុកឆែបរួចហើយ រួចកំពុងដាក់ឲ្យដំណើរដោយបណ្តើរៗ បន្តបន្ទាប់ទៀត ។ ជាមួយគ្នានេះដែរ ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តព្រះវិហារ បន្ថែមទៀត អាជ្ញាធរអគ្គិសនីកម្ពុជាក៏បានអនុញ្ញាតឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីចេញពីខេត្តកំពង់ធំ ដែលទទួលបានប្រភពអគ្គិសនីពីអនុស្ថានីយខេត្តកំពង់ចាម បន្តទៅផ្តល់ឲ្យតំបន់ចែកចាយមួយចំនួននៅខេត្តព្រះវិហារ ជាបណ្តោះអាសន្នបន្ថែមទៀត ។ តាមបទដ្ឋានបច្ចេកទេស ការបញ្ជូនអគ្គិសនីរបស់ខ្សែ ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ទៅ ៧០ គីឡូម៉ែត្រ ប៉ុណ្ណោះ ប៉ុន្តែយើងបានអនុញ្ញាតឲ្យក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន បញ្ជូនអគ្គិសនីជាបណ្តោះអាសន្ននេះ រហូតដល់ជាង ២០០ គីឡូម៉ែត្រ លើសពីបទដ្ឋានបច្ចេកទេសដែលធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះវិហារ កើតមានអតុល្យភាព និងមានរអាក់រអួលញឹកញាប់ ចំណែកការបាត់បង់អគ្គិសនីលើខ្សែបណ្តាញមានបរិមាណច្រើនលើសពីខេត្តដ៏ទៃ ធ្វើឲ្យថ្លៃប្រភពអគ្គិសនីដែលបញ្ជូនទៅឲ្យនេះ ខ្ពស់ជាងធម្មតាច្រើន ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ចំពោះខេត្តព្រះវិហារ យើងពុំមានជម្រើសអ្វីផ្សេងក្រៅពីនេះទេ ពីព្រោះមានតែធ្វើបែបនេះទេទើបយើងអាចបន្ថយថ្លៃអគ្គិសនីនៅតំបន់ចែកចាយមួយចំនួនធំឲ្យថយចុះពីជាង ៣,០០០ រៀលក្នុង ១ គីឡូវ៉ាត់ម៉ោងឲ្យមកនៅក្នុងចន្លោះ ១,៤០០ រៀល ទៅ ១,៦០០ រៀល បាន ម្យ៉ាងទៀតធ្វើយ៉ាងនេះទើបយើងអាចអភិវឌ្ឍន៍បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនហើយស្រេច រង់ចាំពេលណាមានអនុស្ថានីយផ្ទាល់នៅខេត្តព្រះវិហារ ពេលនោះយើងអាចបញ្ជូនប្រភពអគ្គិសនីនេះ ទៅកាន់តំបន់ចែកចាយនានា និងផ្គត់ផ្គង់អគ្គិសនីរាយឲ្យអ្នកប្រើប្រាស់បានតែម្តង ។

ដំណោះស្រាយប្រភពអគ្គិសនី សម្រាប់អនាគតយូរអង្វែងរបស់ខេត្តព្រះវិហារ គឺការពង្រីកបណ្តាញជាតិបញ្ជូនអគ្គិសនីទៅកាន់ខេត្តនេះ និងការបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅខេត្តព្រះវិហារ រួចបង្វែរបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលមានស្រាប់មកយកប្រភពអគ្គិសនីពីអនុស្ថានីយនេះវិញ ។ ប៉ុន្តែទោះជាក្នុងករណីដែលរាជរដ្ឋាភិបាល មិនទាន់អាចអភិវឌ្ឍន៍

បណ្តាញបញ្ជូន និងអនុស្ថានីយនៅខេត្តព្រះវិហារ ដូចខាងលើក៏ដោយ ការអភិវឌ្ឍន៍បណ្តាញជាតិ និងអនុស្ថានីយនៅខេត្តកំពង់ធំ ក៏អាចជួយស្តាស្ថានភាពផ្គត់ផ្គង់របស់ខេត្តព្រះវិហារ បានមួយចំណែកធំដែរ ។

**ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់**

តាមលក្ខណៈភូមិសាស្ត្រខេត្តព្រះវិហារ មានក្រុង ១ ឈ្មោះក្រុងព្រះវិហារ និងស្រុកចំនួន ៧ គឺ ៖ ១.ស្រុកជ័យសែន ២.ស្រុកឆែប ៣.ស្រុកជាំក្សាន្ត ៤.ស្រុកគូលែន ៥.ស្រុករវៀង ៦.ស្រុកត្បែងមានជ័យ និង ៧.ស្រុកសង្គមថ្មី ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តព្រះវិហារ **មិនទាន់មានការផ្គត់ផ្គង់អគ្គិសនីពីអនុស្ថានីយទេ** ពីព្រោះនៅខេត្តនេះ ពុំទាន់មានអនុស្ថានីយ **គឺមានការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង**នានា ដែលបានបញ្ជូនប្រភពអគ្គិសនីពីឆ្ងាយ គឺពីអនុស្ថានីយកំពង់ចាម ឆ្លងកាត់ខេត្តកំពង់ធំ និងពីការនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ តាមច្រកកំពង់ស្រឡៅ ។ ក្រៅពីការផ្គត់ផ្គង់ធំនេះ **មានតែការផ្គត់ផ្គង់រាយតាមតំបន់ចែកចាយ**នីមួយៗ ។ បច្ចុប្បន្នការផ្គត់ផ្គង់អគ្គិសនីតាមតំបន់ចែកចាយនានាក្នុងខេត្តព្រះវិហារត្រូវបានដោះស្រាយតាមរបៀប ៣ យ៉ាង ទី១.ចំពោះតំបន់ចែកចាយមួយចំនួនដែលនៅតាមផ្លូវជាតិលេខ ៦៧ ចេញពីខេត្តកំពង់ធំ ដែលឋិតតាមគន្លងខ្សែបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដោះស្រាយដោយការទិញប្រភពអគ្គិសនីពីខ្សែបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលបានបញ្ជូនប្រភពអគ្គិសនីបន្តពីអនុស្ថានីយបណ្តាញជាតិខេត្តកំពង់ចាម ទី២.តំបន់ក្រុងព្រះវិហារ តំបន់ជុំវិញក្រុង និងតំបន់ចែកចាយនានាបន្តពីព្រំដែនប្រទេសឡាវ ដោះស្រាយដោយការនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ តាមច្រកកំពង់ស្រឡៅ និងទី៣.តំបន់នៅឆ្ងាយ ដោះស្រាយដោយអនុញ្ញាតឲ្យឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនដៀសែលតូចៗ ផលិតអគ្គិសនីក្នុងលក្ខខណ្ឌបណ្តោះអាសន្ន រង់ចាំបណ្តាញបញ្ជូនរងពង្រីកទៅដល់ ។ បច្ចុប្បន្ននៅខេត្តព្រះវិហារ មានតំបន់ផ្គត់ផ្គង់អគ្គិសនីចំនួន ១៤ តំបន់ ក្នុងនោះ ១ តំបន់គឺជាតំបន់ផ្គត់ផ្គង់របស់អគ្គិសនីកម្ពុជា ដែលឋិតនៅតាមគន្លងខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជាដែលនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ និង ១៣ តំបន់ទៀត គឺជាតំបន់ចែកចាយអគ្គិសនីរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ១៣ តំបន់នោះ មានតំបន់ចែកចាយ ៤ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងតំបន់ចែកចាយ ៩ តំបន់ទៀត ជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលដែលមានថ្លៃខ្ពស់ រង់ចាំការពង្រីកខ្សែបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន នៅពេលឆាប់ៗ ខាងមុខនេះ ។

**បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តព្រះវិហារ**

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | អគ្គិសនីកម្ពុជា | 001 L | LAO | ស្រុកឆែប |
| 2 | សេវាករ សៅ សូរិយា | 344 L | GS Kg.C-BVC | ស្រុករវៀង |
| 3 | សេវាករ អៀង ខន | 128 L | GS Kg.C-BVC | ស្រុករវៀង |
| 4 | សេវាករ ទៀង បូនីកា | 329 L | GS Kg.C-BVC | ស្រុកសង្គមថ្មី |
| 5 | សេវាករ កាន សុជាតា | 345 L | GS Kg.C-BVC | ស្រុកជ័យសែន |
| 6 | សេវាករ ចាន់ ថុន | 031 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ក្រុងព្រះវិហារ |
| 7 | សេវាករ លាក ស្រីអ៊ីង | 162 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកជាំក្សាន្ត |
| 8 | សេវាករ អ៊ូ គឹមសៀង | 172 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកគូលេន |

| | | | | |
|---|---|---|---|---|
| 9 | សេវាករ កែវ ងួន | 307 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកជាំក្សាន្ត |
| 10 | សេវាករ ផុំ ភ័ក្រ | 312 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកជាំក្សាន្ត |
| 11 | សេវាករ ចក់ ស៊ាន | 334 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកគូលែន |
| 12 | សេវាករ ឡឹក ដាណា | 364 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកសង្គមថ្មី |
| 13 | សេវាករ ផាង ចាន់ដារ៉ា | 391 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកគូលែន |
| 14 | សេវាករ ប៊ិន ឌីណា | 399 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកជាំក្សាន្ត |

# ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តព្រះវិហារ




# ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តព្រះវិហារ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ជ័យសែន | 21 | 6 | 28.57% | 3 | 14.29% | 3 |
| ឆែប | 26 | 3 | 11.54% | 3 | 11.54% | - |
| ជាំក្សាន្ត | 46 | 16 | 34.78% | 10 | 21.74% | 6 |
| គូលែន | 23 | 15 | 65.22% | 4 | 17.39% | 11 |
| រវៀង | 57 | 54 | 94.74% | 17 | 29.82% | 37 |
| សង្គមថ្មី | 24 | 17 | 70.83% | 6 | 25.00% | 11 |
| ត្បែងមានជ័យ | 12 | 2 | 16.67% | - | - | 2 |
| ព្រះវិហារ | 20 | 11 | 55.00% | 12 | 60.00% | -1 |
| **សរុប** | **229** | **124** | **54.15%** | **55** | **24.02%** | **69** |

## ផែនទីបង្ហាញអំពីការពង្រីកបណ្តាញបញ្ជូនរងអគ្គិសនីនៅខេត្តព្រះវិហារ




## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តព្រះវិហារ

ដោយសារនៅខេត្តព្រះវិហារ ពុំទាន់មានអនុស្ថានីយបណ្តាញជាតិនៅឡើយ ដូច្នេះនៅខេត្តព្រះវិហារ ពុំមានការផ្គត់ផ្គង់អគ្គិសនីដុំពីអនុស្ថានីយទេ នៅពេលបច្ចុប្បន្ននេះ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តព្រះវិហារ មានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.ការផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យមឲ្យអ្នកប្រើប្រាស់ដែលមានទំហំធំ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងទី២.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តព្រះវិហារ អាចចែកចេញជា ៣ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយគឺ ៖ ទី១.តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជាដែលនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ ទី២.តំបន់ចែកចាយដែលទិញប្រភពអគ្គិសនីពីបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងតំបន់ចែកចាយដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន និងទី៣.តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តព្រះវិហារ ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនីនៅខេត្តព្រះវិហារ នឹងមានផែនការដូចខាងក្រោម ៖

### ក.ការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញបញ្ជូនរងនានារបស់អគ្គិសនីកម្ពុជា

ដោយសារនៅខេត្តព្រះវិហារ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួននៅឡើយ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ ដែលមានទំហំធំល្មម គឺត្រូវដោះស្រាយតាមរយៈការផ្គត់ផ្គង់របស់បណ្តាញបញ្ជូនរងរបស់

ក្រុមហ៊ុនអគ្គិសនីកម្ពុជា និងក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ដែលកំពុងអភិវឌ្ឍន៍បន្តនៅពេលបច្ចុប្បន្ននេះ និងដែលបញ្ជូនប្រភពអគ្គិសនីបន្តក្នុងចម្ងាយឆ្ងាយ ។ ដោយសារការបញ្ជូនអគ្គិសនីឆ្ងាយដូច្នេះ និងដើម្បីឲ្យការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់ធុនធំមានការឯកភាពថ្លៃគ្នា អត្រាថ្លៃអគ្គិសនីទិញលើតង់ស្យុងមធ្យមពីបណ្តាញបញ្ជូនរងទាំង ២ ខាងលើ នៅខេត្តព្រះវិហារ ពីឆ្នាំ ២០១៦ ដល់ឆ្នាំ ២០២០ នឹងត្រូវកំណត់តាមយន្តការអត្រាថ្លៃតាមផែនការរួមរបស់រាជរដ្ឋាភិបាល បូកបន្ថែមថ្លៃបាត់បង់បន្ថែមលើការបញ្ជូនឆ្ងាយគិតជា % នៃថ្លៃមូលដ្ឋានដូចខាងក្រោម ៖

## សម្រាប់បណ្តាញបញ្ជូនរងដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ

គិតជា $/kWh

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.1675+%Loss | 0.165+%Loss | 0.164+%Loss | 0.163+%Loss | 0.162+%Loss |
| ទិញ MV ពីបញ្ជូនរង BVC | 0.1675+%Loss | 0.165+%Loss | 0.164+%Loss | 0.163+%Loss | 0.162+%Loss |

**កំណត់សំគាល់** ៖ % Loss កំណត់ជា % នៃថ្លៃមូលដ្ឋាន យោងទៅតាមការគណនាការបាត់បង់បន្ថែមលើការបញ្ជូនកាន់តែឆ្ងាយបន្ថែម ។ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

## ខ.ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា

តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅខេត្តព្រះវិហារ គឺជាតំបន់ចែកចាយដែលនាំចូលប្រភពអគ្គិសនីពីប្រទេសឡាវ ដូចតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅខេត្តស្ទឹងត្រែង ដែរ ដូច្នេះថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីនេះ គួរមានអត្រាថ្លៃតែមួយ ដូចអត្រាថ្លៃនៅតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា នៅខេត្តស្ទឹងត្រែង ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ៩៨០ ៛ / kWh | ស្ថាប័នរដ្ឋ | ៩៨០ ៛ / kWh |
| ពាណិជ្ជកម្ម-ឧស្សាហកម្ម | | | |
| តង់ស្យុងទាបធុនតូច | ៩៨០ ៛ / kWh | តង់ស្យុងទាបធុនមធ្យម | ៩២០ ៛ / kWh |
| តង់ស្យុងទាបធុនធំ | ៨៧០ ៛ / kWh | តង់ស្យុងមធ្យម | ៨៣០ ៛ / kWh |

## គ.ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់សេវាករ ដែលទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន

នៅខេត្តព្រះវិហារ ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ១៣ តំបន់ មានតំបន់ចែកចាយ ៤ តំបន់ បានប្តូរពីការផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល មកទិញប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ។ បច្ចុប្បន្នថ្លៃលក់អគ្គិសនីនៅក្នុងតំបន់នេះ បានបន្ថយថ្លៃលក់ពីជាង ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង មក ១,៦០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចហើយ សម្រាប់ឆ្នាំ២០១៥ ទៅតាមផែនការ និងកម្មវិធីថ្លៃលក់ដែលតំណាងអាជ្ញាធរឃុំ អាជ្ញាធរស្រុក តំណាងអ្នកប្រើប្រាស់ និងតំណាង

អាជ្ញាធរអគ្គិសនីកម្ពុជាបានឯកភាពគ្នា នៅតាមតំបន់នីមួយៗ ក្នុងពេលពិភាក្សាអំពីការភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ជំនួសការផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ ក្នុងរយៈពេលបណ្តោះអាសន្នដែលខេត្តព្រះវិហារ មិនទាន់មានអនុស្ថានីយបណ្តាញជាតិផ្ទាល់ខ្លួន តំបន់ខាងលើនេះ ត្រូវបានចាត់ទុកថាជាតំបន់នៅក្រៅតំបន់គ្របដណ្តប់ដោយបណ្តាញជាតិ ដែលថ្លៃអគ្គិសនីនឹងត្រូវដោះស្រាយដោយលក្ខណៈបណ្តោះអាសន្ន ។ ក្នុងដំណាក់កាលបណ្តោះអាសន្ននេះ គ្រោងនឹងខិតខំកាត់បន្ថយអត្រាថ្លៃលក់រាយជូនប្រជាពលរដ្ឋនៅឆ្នាំ ២០១៦ ចំនួន ៥០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងនៅឆ្នាំ ២០១៧ចំនួន៥០រៀល ក្នុង ១គីឡូវ៉ាត់ម៉ោងបន្ថែមទៀត ទៅតាមកំណើននៃទំហំទីផ្សារនៅតំបន់ចែកចាយនេះ។

**គ.ការផ្គត់ផ្គង់នៅតំបន់ចែកចាយឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល**

នៅខេត្តព្រះវិហារ មានតំបន់ចែកចាយ ៩ តំបន់ នៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ បញ្ហាដែលត្រូវដោះស្រាយចំពោះមុខ ចំពោះតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលទាំង ៩ តំបន់នេះ មាន ២ សំខាន់គឺ ៖ ១.ការកំណត់ថ្លៃឲ្យបានយុត្តិធម៌ក្នុងរយៈពេលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល និង២.ជម្រុញការពង្រីកបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងបណ្តាញបញ្ជូនរងរបស់ក្រុមហ៊ុនប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន ឲ្យទៅគ្របដណ្តប់តំបន់ទាំង ៩ នេះ ដើម្បីបន្ថយថ្លៃអគ្គិសនីនៅតំបន់ទាំង ៩ នេះ ជាបណ្តោះអាសន្នរង់ចាំការអភិវឌ្ឍន៍អនុស្ថានីយបណ្តាញជាតិ នៅខេត្តព្រះវិហារ ផ្ទាល់ ។ តាមផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០១៨ ខេត្តព្រះវិហារ នឹងពុំទាន់មានអនុស្ថានីយបណ្តាញជាតិផ្ទាល់ខ្លួននៅឡើយទេ ដូច្នេះដំណោះស្រាយចំពោះតំបន់ចែកចាយដែលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែលនេះ គឺមានតែសាងសង់បណ្តាញបញ្ជូនរង ដើម្បីបញ្ជូនប្រភពអគ្គិសនីទៅជំនួសការប្រើប្រាស់ម៉ាស៊ីនដៀសែលជាបណ្តោះអាសន្ន ដូច្នេះផែនការថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៩ តំបន់នេះ អាចចែកជា ៣ ដំណាក់កាលគឺ ៖ ១.ដំណាក់កាល នៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ២.ដំណាក់កាលទទួលបានប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងជាបណ្តោះអាសន្ន និង៣.ដំណាក់កាលដែលខេត្តព្រះវិហារ មានអនុស្ថានីយបណ្តាញជាតិផ្ទាល់ខ្លួន ។

**(១)ដំណាក់កាលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល**

ដើម្បីកំណត់ថ្លៃឲ្យបានយុត្តិធម៌ក្នុងរយៈពេលផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដៀសែល អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះអត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនីនឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះនឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយនៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

**(២)ដំណាក់កាលទទួលបានប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងជាបណ្តោះអាសន្ន**

បច្ចុប្បន្នអគ្គិសនីកម្ពុជា និងក្រុមហ៊ុនប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន កំពុងសាងសង់បណ្តាញបញ្ជូនរងជាបន្តបន្ទាប់ ដើម្បីបញ្ជូនប្រភពអគ្គិសនីដែលមានថ្លៃទាបជាង ទៅជំនួសការផលិតអគ្គិសនីដោយម៉ាស៊ីនដៀសែល ។ នៅពេលដែលតំបន់ចែកចាយនីមួយៗ បានតភ្ជាប់ប្រភពអគ្គិសនី ជាមួយបណ្តាញបញ្ជូនរងណាមួយរួចហើយ

អាជ្ញាធរអគ្គិសនីកម្ពុជា គ្រោងនឹងកាត់បន្ថយអត្រាថ្លៃលក់រាយជូនប្រជាពលរដ្ឋ នៅតំបន់ចែកចាយនោះឲ្យចុះមកនៅក្នុងអត្រាមួយទាបជាងមុនជាបន្តបន្ទាប់ឲ្យអស់លទ្ធភាព ដោយរក្សាឲ្យបាននូវនិរន្តរភាពនៃអាជីវកម្មចែកចាយអគ្គិសនីនៅតំបន់នោះ ។

## (៣) ដំណាក់កាលដែលខេត្តព្រះវិហារ មានអនុស្ថានីយបណ្ដាញជាតិផ្ទាល់ខ្លួន

យោងតាមផែនការអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ប្រសិនបើពុំមានការយឺតយូរទេ ចាប់ពីចុងឆ្នាំ ២០១៨ ខេត្តព្រះវិហារ នឹងមានអនុស្ថានីយបណ្ដាញជាតិមួយនៅក្នុងខេត្តរបស់ខ្លួន ពេលនោះបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងបណ្ដាញបញ្ជូនរងរបស់ក្រុមហ៊ុន ប៊ី.វី.ស៊ី ផៅវ័រ ឌីវែឡុបមិន នឹងត្រូវបង្វែរមកយកប្រភពអគ្គិសនីពីអនុស្ថានីយបណ្ដាញជាតិនេះវិញ ពេលនោះតំបន់ចែកចាយទាំងអស់ដែលភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្ដាញបញ្ជូនរងទាំង ២ នេះ នឹងត្រូវចាត់ទុកថាជាតំបន់ដែលប្រភពអគ្គិសនីរបស់បណ្ដាញជាតិគ្របដណ្ដប់ ។ ក្នុងដំណាក់កាលនេះ ថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយ របស់សេវាករឯកជន ដែលយកប្រភពអគ្គិសនីពីបណ្ដាញបញ្ជូនរងទាំង ២ ខាងលើ នឹងត្រូវអនុវត្តតាមផែនការថ្លៃ ដូចខាងក្រោម ៖

<u>សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញ MV ពីបណ្ដាញ MV | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

**<u>កំណត់សំគាល់</u>** ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>សម្រាប់លំនៅដ្ឋានទូទៅ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១០kWh/ខែ</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

<u>ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្ម ដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|
| ទិញពីបណ្ដាញសាធារណៈ | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិនៅខេត្តឧត្តរមានជ័យ សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តឧត្តរមានជ័យ

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តឧត្តរមានជ័យ មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានបណ្តាញជាតិទៅដល់ និងពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យខេត្តនេះនៅឡើយ ធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តនេះ ភាគច្រើន គឺដោះស្រាយដោយនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ និងដោយការផលិតអគ្គិសនីពីម៉ាស៊ីនដៀសែល ។ ទោះបីជារាជរដ្ឋាភិបាលពុំទាន់មានគម្រោងពង្រីកបណ្តាញបញ្ជូនតង់ស្យុងខ្ពស់ទៅកាន់ខេត្តឧត្តរមានជ័យ និងបង្កើតអនុស្ថានីយបណ្តាញជាតិនៅខេត្តឧត្តរមានជ័យក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលមានផែនការធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល ដើម្បីបញ្ជូនប្រភពអគ្គិសនីដែលមានថ្លៃថោកជាង ទៅជួយតំបន់ចែកចាយមួយចំនួននៅស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ និងស្រុកត្រពាំងអំពិល នៃខេត្តឧត្តរមានជ័យ ជាបណ្តោះអាសន្នសិន ។ គម្រោងជួយផ្តល់ប្រភពអគ្គិសនីថោកជាងជាបណ្តោះអាសន្ន ដោយធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា បន្តចូលទៅក្នុងខេត្តឧត្តរមានជ័យ មានបង្ហាញក្នុងផែនទីខាងក្រោម ៖



តាមបទដ្ឋានបច្ចេកទេស ការបញ្ជូនអគ្គិសនីរបស់ខ្សែ២២ គីឡូវ៉ុល គឺកម្រិតត្រឹម ៥០ ទៅ៧០ គីឡូម៉ែត្រ ប៉ុណ្ណោះ ប៉ុន្តែចំពោះខេត្តឧត្តរមានជ័យយើងបានអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាបញ្ជូនប្រភពអគ្គិសនីបណ្តោះអាសន្ន នេះ រហូតដល់ជាង ២០០ គីឡូម៉ែត្រ លើសពីបទដ្ឋានបច្ចេកទេស ដែលធ្វើឲ្យការផ្គត់ផ្គង់អគ្គិសនីកើតមាន អតុល្យភាព និងមានភាពអាក់រអួលញឹកញាប់ ចំណែកការបាត់បង់អគ្គិសនីលើខ្សែបណ្តាញ មានបរិមាណច្រើន លើសពីខេត្តដទៃ ធ្វើឲ្យថ្លៃប្រភពអគ្គិសនីដែលបញ្ជូនទៅឲ្យខេត្តឧត្តរមានជ័យនេះ ខ្ពស់ជាងធម្មតាច្រើន។ ប៉ុន្តែ ទោះជាយ៉ាងនេះក៏ដោយ ចំពោះខេត្តឧត្តរមានជ័យនេះ យើងពុំមានជម្រើសអ្វីផ្សេងក្រៅពីនេះទេ ពីព្រោះមានតែ ធ្វើបែបនេះទេ ទើបយើងអាចបន្ថយថ្លៃអគ្គិសនីនៅតំបន់ចែកចាយមួយចំនួនធំឲ្យថយចុះពីជាង ៣,០០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ឲ្យមកនៅក្នុងចន្លោះ ១,៣០០ រៀល បាន ម្យ៉ាងទៀតធ្វើយ៉ាងនេះ ទើបយើងអាចអភិវឌ្ឍន៍ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយតភ្ជាប់គ្នាបានមួយចំនួនហើយស្រេច រង់ចាំពេលណាយើងអាចពង្រីក បណ្តាញបញ្ជូនតង់ស្យុងខ្ពស់ និងអនុស្ថានីយនៅខេត្តឧត្តរមានជ័យបាន ពេលនោះយើងអាចបញ្ជូនប្រភព អគ្គិសនីបណ្តាញជាតិនេះ ទៅកាន់តំបន់ចែកចាយនានារបស់ខេត្ត និងផ្គត់ផ្គង់អគ្គិសនីវាយឲ្យអ្នកប្រើប្រាស់បាន តែម្តង។

ដំណោះស្រាយប្រភពអគ្គិសនីសម្រាប់អនាគតយូរអង្វែងរបស់ខេត្តឧត្តរមានជ័យ គឺការពង្រីកបណ្តាញ ជាតិបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ទៅកាន់ខេត្តនេះ និងការបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីមួយនៅ ខេត្តឧត្តរមានជ័យ រួចបង្វែរបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងរបស់ក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប ដែល មានស្រាប់ មកយកប្រភពអគ្គិសនីពីអនុស្ថានីយនេះវិញ ។ ពេលនោះបញ្ហាទាំង ៣ គឺទី១.ការផ្គត់ផ្គង់អគ្គិសនី ឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាពនៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនី មុខជា អាចដោះស្រាយបាន ដូចខេត្តដទៃទៀត ជាមិនខាន ។

**ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់**

តាមលក្ខណៈភូមិសាស្ត្រខេត្តឧត្តរមានជ័យ មានក្រុង ១ ឈ្មោះក្រុងសំរោង និងស្រុកចំនួន ៤ គឺ៖ ១. ស្រុកអន្លង់វែង ២.ស្រុកបន្ទាយអំពិល ៣.ស្រុកត្រពាំងប្រាសាទ ៤.ស្រុកចុងកាល ។ បច្ចុប្បន្ននេះ ការផ្គត់ផ្គង់ អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅខេត្តឧត្តរមានជ័យ មិនទាន់មាន**ការផ្គត់ផ្គង់អគ្គិសនីដុំ**ពីអនុស្ថានីយទេ ពីព្រោះនៅខេត្តនេះពុំទាន់មានអនុស្ថានីយ គឺមាន**ការផ្គត់ផ្គង់អគ្គិសនីធំ** ពីបណ្តាញបញ្ជូនរងនានា ដែល បានបញ្ជូនប្រភពអគ្គិសនីបន្តពីឆ្ងាយ គឺពីអនុស្ថានីយខេត្តបន្ទាយមានជ័យដោយអគ្គិសនីកម្ពុជា ពីការនាំចូល ប្រភពអគ្គិសនីពីប្រទេសថៃ តាមច្រកអូរស្មាច់ របស់ក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប និងពីការនាំចូលប្រភពអគ្គិសនី ពីប្រទេសឡាវតាមច្រកកំពង់ស្រឡៅ ឆ្លងកាត់ខេត្តព្រះវិហារ ដោយអគ្គិសនីកម្ពុជា។ ក្រៅពីការផ្គត់ផ្គង់នេះ មាន តែ**ការផ្គត់ផ្គង់អគ្គិសនីវាយ** តាមតំបន់ចែកចាយនីមួយៗ ។ បច្ចុប្បន្ន ការផ្គត់ផ្គង់អគ្គិសនីវាយតាមតំបន់ ចែកចាយនានាក្នុងខេត្តឧត្តរមានជ័យ ត្រូវបានដោះស្រាយតាមរបៀប ៣ យ៉ាង ទី១.ចំពោះក្រុងសំរោង តំបន់ មួយចំនួនក្បែរផ្លូវជាតិពីក្រុងសំរោង ទៅទីប្រជុំជនអូរស្មាច់ និងពីក្រុងសំរោង ទៅទីរួមស្រុកអន្លង់វែង ដែលចែក ចាយដោយក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប ត្រូវដោះស្រាយដោយការនាំចូលប្រភពអគ្គិសនី តាមតង់ស្យុង ២២ គីឡូវ៉ុល ពីប្រទេសថៃ ទី២.ចំពោះតំបន់ដែលជាប់ព្រំប្រទល់ជាមួយខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និង ខេត្តព្រះវិហារ ដោះស្រាយឲ្យតំបន់ចែកចាយទិញប្រភពអគ្គិសនីពីខ្សែបណ្តាញបញ្ជូនរង របស់អគ្គិសនីកម្ពុជា

ដែលបានបញ្ជូនប្រភពអគ្គិសនីពីឆ្ងាយពីខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តព្រះវិហារ និងទី៣.ចំពោះតំបន់ដែលនៅឆ្ងាយពីខ្សែបញ្ជូនរងទាំងនេះ ដោះស្រាយដោយអនុញ្ញាតឲ្យសេវាករអគ្គិសនីឯកជនធ្វើការផ្គត់ផ្គង់ដោយប្រើម៉ាស៊ីនដៀសែលតូចៗ ផលិតអគ្គិសនីជាបណ្ដោះអាសន្ន ។ បច្ចុប្បន្ននៅខេត្តឧត្តរមានជ័យ មានតំបន់ចែកចាយអគ្គិសនីចំនួន ៦ តំបន់ ដែលតំបន់ទាំង ៦ នេះ គឺជាតំបន់ចែកចាយអគ្គិសនីរបស់សេវាករអគ្គិសនីឯកជន ។ ក្នុងចំណោមតំបន់ផ្គត់ផ្គង់អគ្គិសនីរបស់ឯកជនទាំង ៦ តំបន់នោះ មានតំបន់ចែកចាយ ១ តំបន់ ជាតំបន់នាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសថៃ តាមតង់ស្យុងមធ្យម ២២គីឡូវ៉ុល, ២ តំបន់ជាតំបន់ទិញប្រភពអគ្គិសនីពីខ្សែបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និង ៣ តំបន់ទៀត គឺជាតំបន់ដែលនៅផលិតអគ្គិសនីពីម៉ាស៊ីនដៀសែលបណ្ដោះអាសន្ន ដែលមានថ្លៃខ្ពស់ រង់ចាំផ្ទេរមកទិញអគ្គិសនីពីខ្សែបណ្ដាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តឧត្តរមានជ័យ




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តឧត្តរមានជ័យ

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| 1 | សេវាករ ឈឹម សារោទ៍ | 313 L | GS-EDC | ស្រុកចុងកាល |
| 2 | សេវាករ ខៀវ សុផល | 388 L | GS-EDC | ស្រុកចុងកាល់ |
| 3 | ក្រុមហ៊ុន អ៊ិល.វ៉ាយ.ភី គ្រុប (អូរស្មាច់) | 014 L | Thai | អូរស្មាច់ និងក្រុងសំរោង |
| 4 | សេវាករ កង ឈី | 163 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកត្រពាំងប្រាសាទ |
| 5 | សេវាករ ផុំ ភ័ក្រ | 312 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកជាំក្សាន្ត |
| 6 | ក្រុមហ៊ុន លឹម ហេង គ្រុប | 374 L | ម៉ាស៊ីនផ្ទាល់ខ្លួន | ស្រុកបន្ទាយអំពិល |

## ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តឧត្តរមានជ័យ

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| អន្លង់វែង | 51 | 51 | 100.00% | 25 | 49.02% | 26 |
| បន្ទាយអំពិល | 79 | 79 | 100.00% | 6 | 7.59% | 73 |
| ចុងកាល់ | 25 | 25 | 100.00% | 6 | 24.00% | 19 |
| សំរោង | 53 | 53 | 100.00% | 20 | 37.74% | 33 |
| ត្រពាំងប្រាសាទ | 46 | 35 | 76.09% | 22 | 47.83% | 13 |
| **សរុប** | **254** | **243** | **95.67%** | **79** | **31.10%** | **164** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តឧត្តរមានជ័យ

ដោយសារនៅខេត្តឧត្តរមានជ័យ ពុំទាន់មានអនុស្ថានីយបណ្តាញជាតិនៅឡើយ ដូច្នេះនៅខេត្តនេះ ពុំមានការផ្គត់ផ្គង់អគ្គិសនីជុំពីអនុស្ថានីយទេ នៅពេលបច្ចុប្បន្ននេះ ។ ការផ្គត់ផ្គង់អគ្គិសនីឲ្យអ្នកប្រើប្រាស់អគ្គិសនីនៅក្នុងខេត្តឧត្តរមានជ័យមានតែ ២ ប្រភេទប៉ុណ្ណោះ គឺ ៖ ទី១.ការផ្គត់ផ្គង់អគ្គិសនីធំ ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី២.ការផ្គត់ផ្គង់អគ្គិសនីរាយតាមតំបន់ចែកចាយនីមួយៗ ។ តំបន់ចែកចាយអគ្គិសនីនៅក្នុងខេត្តឧត្តរមានជ័យ អាចចែកចេញជា ៣ ប្រភេទ ទៅតាមប្រភេទនៃប្រភពអគ្គិសនីរបស់តំបន់ចែកចាយ គឺ ៖ ទី១.តំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសថៃផ្ទាល់ និងមានខ្សែ ២២ គីឡូវ៉ុល វែង ទី២.តំបន់ចែកចាយដែលទិញប្រភពអគ្គិសនីពីបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងទី៣.តំបន់ចែកចាយដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនម៉ាស៊ូត ។ តាមស្ថានភាពនៃការផ្គត់ផ្គង់អគ្គិសនីនៅខេត្តឧត្តរមានជ័យ ដូចរៀបរាប់ខាងលើ ថ្លៃលក់អគ្គិសនី នឹងមានផែនការ ដូចខាងក្រោម ៖

### ២.១ ការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរបស់អគ្គិសនីកម្ពុជា

ដោយសារនៅខេត្តឧត្តរមានជ័យ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួននៅឡើយ ដូច្នេះការផ្គត់ផ្គង់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ដែលមានទំហំធំ គឺត្រូវដោះស្រាយតាមរយៈការផ្គត់ផ្គង់អគ្គិសនីធំ ចេញពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលបញ្ជូនប្រភពអគ្គិសនីបន្តក្នុងចម្ងាយឆ្ងាយ ។ ដោយសារការបញ្ជូនអគ្គិសនីឆ្ងាយដូច្នេះ និងដើម្បីឲ្យការផ្គត់ផ្គង់អគ្គិសនីធំពីបណ្តាញបញ្ជូនរង មានការឯកភាពថ្លៃគ្នា អត្រាថ្លៃអគ្គិសនីទិញលើតង់ស្យុងមធ្យមពីបណ្តាញបញ្ជូនរងទាំង ២ ប្រភេទ របស់អគ្គិសនីកម្ពុជា (ទាំងការបញ្ជូនពីអនុស្ថានីយខេត្តបន្ទាយមានជ័យ និងសៀមរាប និងទាំងការបញ្ជូនរងពីការនាំចូលពីប្រទេសឡាវ ឆ្លងកាត់ខេត្តព្រះវិហារ) នៅខេត្តឧត្តរមានជ័យ ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ នឹងត្រូវកំណត់តាមអត្រាថ្លៃនៃផែនការរួមរបស់រាជរដ្ឋាភិបាល បូកបន្ថែមថ្លៃបាត់បង់បន្ថែមលើការបញ្ជូនឆ្ងាយ គិតជា % នៃថ្លៃមូលដ្ឋាន ដូចខាងក្រោម ៖

#### សម្រាប់បណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

គិតជា $/kWh

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៦ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.1675+%Loss | 0.165+%Loss | 0.164+%Loss | 0.163+%Loss | 0.162+%Loss |
| ទិញ MV ពីបញ្ជូនរង BVC | 0.1675+%Loss | 0.165+%Loss | 0.164+%Loss | 0.163+%Loss | 0.162+%Loss |

**កំណត់សំគាល់** ៖ %Loss កំណត់ជា % នៃថ្លៃមូលដ្ឋាន យោងទៅតាមការគណនាការបាត់បង់បន្ថែមលើការបញ្ជូនកាន់តែឆ្ងាយបន្ថែម។ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវ យកអត្រាខាងលើជាមូលដ្ឋាន។

## ២.២ ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប

តំបន់ចែកចាយរបស់ក្រុមហ៊ុន អ៊ិល.វាយ.ភី នៅខេត្តឧត្តរមានជ័យ គឺជាតំបន់ចែកចាយធំដែលបានគ្របដណ្តប់ស្រុកចំនួន ៣ គឺក្រុងសំរោង ស្រុកអន្លង់វែង និងស្រុកត្រពាំងប្រាសាទ ដូច្នេះថ្លៃអគ្គិសនីនៅក្នុងតំបន់ចែកចាយអគ្គិសនីនេះ ត្រូវមានអត្រាថ្លៃតែមួយ ប៉ុន្តែដោយសារស្ថានភាពនៃការវិនិយោគហេដ្ឋារចនាសម្ព័ន្ធបន្តបន្ទាប់គ្នា ធ្វើឲ្យថ្លៃលក់អគ្គិសនីបណ្តោះអាសន្ននៅតំបន់នេះមាន ៣ ប្រភេទខុសគ្នាទៅតាមតំបន់ គឺនៅតំបន់អូរស្មាច់មានថ្លៃស្មើនឹង ៥.៧៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង នៅតំបន់ក្រុងសំរោង មានថ្លៃស្មើនឹង ៧.២៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង និងនៅស្រុកអន្លង់វែង ថ្លៃស្មើនឹង ១១ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

តាមផែនការដែលបានគ្រោងទុក ការកំណត់អត្រាថ្លៃលក់អគ្គិសនីនៅក្នុងតំបន់ចែកចាយ របស់ក្រុមហ៊ុន អ៊ិល.វាយ.ភី គ្រុប នៅខេត្តឧត្តរមានជ័យ ចាប់ពីខែ មីនា ឆ្នាំ ២០១៦ ទៅ មានដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន (អូរស្មាច់) | ៥.៧៥ បាត | ស្ថាប័នរដ្ឋ | ៥.៧៥ បាត |
| អតិថិជនលំនៅដ្ឋាន (ក្រុងសំរោង) | ៧.០០បាត ឬ៨៤០រៀល | ស្ថាប័នរដ្ឋ | ៧.០០បាត ឬ៨៤០រៀល |
| អតិថិជនលំនៅដ្ឋាន (ស្រុកអន្លង់វែង) | ៩.១៧បាត ឬ១,១០០រៀល | ស្ថាប័នរដ្ឋ | ៩.១៧បាត ឬ១,១០០រៀល |
| **ពាណិជ្ជកម្ម-ឧស្សាហកម្ម** | | | |
| តង់ស្យុងទាបធុនតូច | ៨.៧៥បាត ឬ១,០៥០ រៀល | តង់ស្យុងទាបធុនមធ្យម | ៨.៣០បាត ឬ១,០០០ រៀល |
| តង់ស្យុងទាបធុនធំ | ៧.៩បាត ឬ៩៥០ រៀល | តង់ស្យុងមធ្យម | ៧.៥បាត ឬ៩០០ រៀល |

## ២.៣ ការផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ចែកចាយឯកជន ដែលយកប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

ក្នុងចំណោមតំបន់ចែកចាយរបស់សេវាករឯកជនទាំង ៦ តំបន់ នៅខេត្តឧត្តរមានជ័យ មាន ២ តំបន់ បានយកប្រភពអគ្គិសនីផ្ទាល់ពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ក្នុងអត្រាថ្លៃ ៦៦០ រៀល ឬ ០.១៦១ ដុល្លា ក្នុង ១ គីឡូវ៉ាត់ម៉ោង រួចលក់រាយជូនអ្នកប្រើប្រាស់ក្នុងអត្រាថ្លៃ ១,៣០០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

ដោយសារពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ ខេត្តឧត្តរមានជ័យ ពុំទាន់មានអនុស្ថានីយផ្ទាល់ខ្លួន រួចបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ត្រូវយកប្រភពអគ្គិសនីបន្តឆ្ងាយពីខេត្តដ៏ទៃជាបណ្តោះអាសន្ន ដូច្នេះផែនការថ្លៃលក់អគ្គិសនីនៅតំបន់ចែកចាយរបស់សេវាករឯកជនទាំង ២ តំបន់នេះ គឺឋិតនៅក្នុងដំណាក់កាលបណ្តោះអាសន្ន ដែលត្រូវអនុវត្តផែនការដោយឡែក ខុសពីផែនការបន្ថយថ្លៃរួមរបស់រាជរដ្ឋាភិបាល ។

ក្នុងដំណាក់កាលបណ្តោះអាសន្ន ដែលមិនទាន់មានអនុស្ថានីយផ្ទាល់ខ្លួន រួចបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ត្រូវយកប្រភពអគ្គិសនីបន្តឆ្ងាយពីខេត្តដទៃ ដូច្នេះ រាជរដ្ឋាភិបាលគ្រោងនឹងខិតខំកាត់បន្ថយអត្រាថ្លៃលក់រាយជូនប្រជាពលរដ្ឋនៅតំបន់ទាំង ២ នេះ ដូចខាងក្រោម ៖

| ប្រភេទអតិថិជន | អត្រាថ្លៃលក់ | ប្រភេទអតិថិជន | អត្រាថ្លៃលក់ |
|---|---|---|---|
| អតិថិជនលំនៅដ្ឋាន | ១,១០០ រៀល | ស្ថាប័នរដ្ឋ | ១,១០០ រៀល |
| ពាណិជ្ជកម្ម-ឧស្សាហកម្ម | | | |
| តង់ស្យុងទាបធុនតូច | ១,០៥០ រៀល | តង់ស្យុងទាបធុនមធ្យម | ១,០០០ រៀល |
| តង់ស្យុងទាបធុនធំ | ៩៥០ រៀល | តង់ស្យុងមធ្យម | ៩០០ រៀល |

## ២.៤ ការផ្គត់ផ្គង់នៅតំបន់ចែកចាយឯកជនដែលផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល

នៅខេត្តឧត្តរមានជ័យ មានតំបន់ចែកចាយ ២ តំបន់ គឺជាតំបន់ដែលនៅផលិតអគ្គិសនីដោយម៉ាស៊ីនដ្យេសែល ។ ក្នុងពេលមិនទាន់មានការបញ្ជូនប្រភពអគ្គិសនីដែលមានថ្លៃថោកជាងទៅផ្តល់ឲ្យ ចំពោះតំបន់ផ្គត់ផ្គង់អគ្គិសនីដែលនៅប្រើម៉ាស៊ីនដ្យេសែល អាជ្ញាធរអគ្គិសនីកម្ពុជា បានកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅតំបន់នីមួយៗ ជាតារាងថ្លៃដែលមានអត្រាកំណត់តាមកម្រិតថ្លៃប្រេងម៉ាស៊ូត ។ តាមតារាងថ្លៃនេះ នៅពេលថ្លៃប្រេងធ្លាក់ចុះ អត្រាថ្លៃលក់អគ្គិសនី គឺត្រូវចុះជាស្វ័យប្រវត្តិទៅតាមថ្លៃប្រេង ប៉ុន្តែបើថ្លៃប្រេងឡើងថ្លៃវិញ គឺអត្រាថ្លៃលក់អគ្គិសនី នឹងត្រូវឡើងជាស្វ័យប្រវត្តិតាមថ្លៃប្រេងដែរ ។ តាមនីតិវិធី ប្រសិនបើថ្លៃប្រេងចុះនៅខែណាមួយ ប្រេងដែលចុះថ្លៃនេះ នឹងយកទៅផលិតអគ្គិសនីក្នុងខែនោះ រួចថ្លៃលក់អគ្គិសនីនឹងថយចុះនៅចុងខែ ឬដើមខែក្រោយនៅពេលចេញវិក្កយបត្រ។ ថ្លៃប្រេងដែលយកមកកំណត់ថ្លៃក្នុងតារាងនេះ គឺជាថ្លៃប្រេងលក់នៅស្ថានីយផ្គត់ផ្គង់ប្រេងនៅខេត្ត ។

ដើម្បីដោះស្រាយបន្ថយថ្លៃអគ្គិសនីខ្ពស់ នៅតំបន់ប្រើម៉ាស៊ីនដ្យេសែលផលិតអគ្គិសនី ទាំង ២ តំបន់ នៅខេត្តឧត្តរមានជ័យ យើងពុំមានជម្រើសអ្វីក្រៅពីត្រូវពង្រីកបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា បញ្ជូនប្រភពអគ្គិសនីដែលមានថ្លៃថោកជាង ទោះបីជាបញ្ជូនឆ្ងាយក៏ដោយ ទៅផ្តល់ឲ្យតំបន់ទាំង ២ នេះ ដើម្បីបញ្ឈប់ការផលិតអគ្គិសនីពីម៉ាស៊ីនដ្យេសែល ដើម្បីបន្ថយថ្លៃអគ្គិសនីខ្លះជាបណ្តោះអាសន្ន ពីព្រោះយើងពុំអាចបង្ខំអាជីវកម្មឯកជនរហូតដល់ទាល់ច្រកដល់ក្ស័យធន ខុសពីគោលការណ៍របស់ច្បាប់បានឡើយ។ ក្រៅពីនេះ យើងក៏នៅត្រូវការឲ្យឯកជនចូលរួមវិនិយោគពង្រីកបណ្តាញចែកចាយនៅតំបន់ដែលប្រជាពលរដ្ឋពុំទាន់មានអគ្គិសនីប្រើប្រាស់នៅខេត្តឧត្តរមានជ័យ ផងដែរ ពីព្រោះរដ្ឋមានលទ្ធភាពវិនិយោគតែត្រឹមខ្សែបណ្តាញបញ្ជូនរងខ្លះៗ តែប៉ុណ្ណោះ។

* * * * * * * * *

# ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ចេញពីប្រភពអគ្គិសនីរបស់បណ្តាញជាតិ នៅខេត្តប៉ៃលិន សម្រាប់ឆ្នាំ ២០១៥-២០២០

## ១.ស្ថានភាពផ្គត់ផ្គង់អគ្គិសនីនៅខេត្តប៉ៃលិន

### ក.បណ្តាញជាតិ និងបណ្តាញបញ្ជូនរង

រហូតដល់ឆ្នាំ ២០១៥ ខេត្តប៉ៃលិន មិនទាន់ឋិតនៅក្នុងតំបន់គ្របដណ្តប់ផ្ទាល់របស់បណ្តាញជាតិនៅឡើយទេ ដោយសារតែខេត្តនេះ ពុំទាន់មានអនុស្ថានីយដែលផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គត់ផ្គង់ឲ្យតំបន់នានាក្នុងខេត្ត មានតែការបញ្ជូនប្រភពអគ្គិសនីតាមខ្សែបញ្ជូនរងពីខេត្តបាត់ដំបង មានចម្ងាយឆ្ងាយជាបណ្តោះអាសន្ន ។ កន្លងមក ដើម្បីដោះស្រាយប្រភពផ្គត់ផ្គង់អគ្គិសនីឲ្យតំបន់មួយចំនួននៅជាប់ព្រំដែន ក្នុងខេត្តប៉ៃលិន ជាបណ្តោះអាសន្ន ក្រសួងរ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា បានអនុញ្ញាតឲ្យក្រុមហ៊ុន អឹម.អេស.ភី ឌីវែឡុមិន ធ្វើការអភិវឌ្ឍន៍ខ្សែបណ្តាញ ២២ គីឡូវ៉ុល នាំចូលប្រភពអគ្គិសនីផ្ទាល់ពីប្រទេសថៃ សម្រាប់ចែកចាយឲ្យតំបន់ចែកចាយខ្លួនឯងផង និងបញ្ជូនប្រភពនេះ មកលក់បន្តឲ្យតំបន់ចែកចាយជាប់គ្នាមួយទៀត នៅទីរួមខេត្តប៉ៃលិន ដែលឋិតនៅក្រោមការផ្គត់ផ្គង់របស់ក្រុមហ៊ុន វណ្ណៈភាព ឌីវែឡុមិន ។ ក្រៅពីនោះ អគ្គិសនីកម្ពុជា ក៏បានធ្វើការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង បញ្ជូនប្រភពអគ្គិសនីបណ្តាញជាតិពីខេត្តបាត់ដំបង ទៅជួយខេត្តប៉ៃលិន ជាបណ្តោះអាសន្នផងដែរ ។

ចំពោះដំណោះស្រាយប្រភពអគ្គិសនី សម្រាប់អនាគតយូរអង្វែងរបស់ខេត្តប៉ៃលិន ពុំមានអ្វីក្រៅពីការអភិវឌ្ឍន៍បណ្តាញជាតិបញ្ជូនអគ្គិសនីភ្ជាប់ពីអនុស្ថានីយនៅខេត្តបាត់ដំបង ទៅកាន់ខេត្តប៉ៃលិន ដោយបង្កើតឲ្យមានអនុស្ថានីយផ្តល់ប្រភពអគ្គិសនីពីបណ្តាញជាតិមួយនៅខេត្តប៉ៃលិន បន្ទាប់មកបង្វែរបណ្តាញបញ្ជូន ២២ គីឡូវ៉ុល មកយកប្រភពអគ្គិសនីពីអនុស្ថានីយខេត្តប៉ៃលិន វិញប៉ុណ្ណោះ ។ ពេលនោះ បញ្ហាទាំង ៣ គឺ ទី១.ការផ្គត់ផ្គង់អគ្គិសនីឲ្យឧស្សាហកម្ម ពាណិជ្ជកម្មធំៗ ទី២.ស្ថេរភាព និងគុណភាព នៃការផ្គត់ផ្គង់ និងទី៣.បញ្ហាថ្លៃអគ្គិសនី មុខជាអាចដោះស្រាយបាន ដូចខេត្តដ៏ទៃទៀតជាមិនខាន ។

ទោះជាគម្រោងបង្កើតអនុស្ថានីយបណ្តាញជាតិមួយ នៅខេត្តប៉ៃលិនផ្ទាល់ខាងលើ មិនទាន់ដាក់ឲ្យដំណើរការក៏ដោយ ក្នុងរយៈពេលមិនទាន់មានអនុស្ថានីយនៅខេត្តប៉ៃលិន រាជរដ្ឋាភិបាលមានផែនការជម្រុញឲ្យតំបន់ចែកចាយអគ្គិសនីនៅខេត្តប៉ៃលិន បែរមកប្រើប្រាស់ប្រភពអគ្គិសនីពីបណ្តាញជាតិផ្គុំជាមួយប្រភពអគ្គិសនីនាំចូលពីប្រទេសថៃ ដើម្បីគោលដៅធ្វើឲ្យ ៖ ១.អត្រាថ្លៃលក់ដុំឲ្យអ្នកចែកចាយបន្ត និង២.អត្រាថ្លៃលក់សម្រាប់អ្នកប្រើប្រាស់លើតង់ស្យុងមធ្យម ចេញពីបណ្តាញបញ្ជូនរងទាំងអស់របស់អគ្គិសនីកម្ពុជា នៅក្នុងខេត្តប៉ៃលិនទាំងមូលមានអត្រាដូចគ្នាជាមួយខេត្ត ដែលបណ្តាញជាតិគ្របដណ្តប់ផ្ទាល់ដែរ ។

### ខ.ការផ្គត់ផ្គង់អគ្គិសនីដល់អ្នកប្រើប្រាស់

ខេត្តប៉ៃលិន មានក្រុង ១ ឈ្មោះក្រុងប៉ៃលិន និងស្រុកចំនួន ១ គឺ ៖ ១.ស្រុកសាលាក្រៅ ។ កន្លងមក ការផ្គត់ផ្គង់អគ្គិសនីឲ្យខេត្តប៉ៃលិន ត្រូវបានដោះស្រាយដោយការនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមច្រកផ្សារព្រំ មកផ្គត់ផ្គង់ឲ្យតំបន់ជាប់ព្រំដែន (ផ្សារព្រំ) និងបញ្ជូនបន្តមកផ្គត់ផ្គង់ឲ្យដល់តំបន់ក្រុងប៉ៃលិន ។ ថ្មីៗ

នេះ អគ្គិសនីកម្ពុជាបានអភិវឌ្ឍន៍បណ្តាញបញ្ជូនវង ២២ គីឡូវ៉ុល បញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយបណ្តាញជាតិខេត្តបាត់ដំបង មកផ្គត់ផ្គង់បន្ថែមឲ្យតំបន់ទាំង ២ ។ បច្ចុប្បន្ននៅខេត្តប៉ៃលិន មានតំបន់ចែកចាយអគ្គិសនីចំនួន ២ តំបន់ ដែលវិនិយោគដោយក្រុមហ៊ុនឯកជន ។ ក្នុងចំណោមតំបន់ចែកចាយរបស់ឯកជនទាំង ២ តំបន់នេះ មាន ១ តំបន់ ចាប់ពីផ្សារព្រំរហូតដល់ស្រុកសាលាក្រៅ ជាតំបន់ផ្គត់ផ្គង់របស់ក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន ដែលនាំចូលប្រភពអគ្គិសនីពីប្រទេសថៃ តាមខ្សែបណ្តាញ ២២ គីឡូវ៉ុល និង ១ តំបន់ទៀត នៅក្រុងប៉ៃលិន ជាតំបន់ផ្គត់ផ្គង់របស់ក្រុមហ៊ុន វណ្ណៈភាព ឌីវេឡុបមេន ដែលពីមុនទិញប្រភពអគ្គិសនីបន្តពីក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន ប៉ុន្តែបច្ចុប្បន្ននេះ បានទិញប្រភពអគ្គិសនីបន្ថែមពីបណ្តាញបញ្ជូនវង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា ។ បច្ចុប្បន្ននេះ ក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន ក៏បានគ្រោងភ្ជាប់យកប្រភពអគ្គិសនីបន្ថែមពីខ្សែបណ្តាញបញ្ជូនវង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា ដែលបានពង្រីកមកដល់ព្រំដែនតំបន់ចែកចាយរបស់ខ្លួនផងដែរ ។

## ផែនទីបង្ហាញអំពីតំបន់ចែកចាយអគ្គិសនីនៅខេត្តប៉ៃលិន




## បញ្ជីឈ្មោះតំបន់ចែកចាយនិងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងខេត្តប៉ៃលិន

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | លេខអ.ប | ប្រភពអ្នកផ្គត់ផ្គង់ | ស្រុក-ខណ្ឌ |
|---|---|---|---|---|
| ១ | ក្រុមហ៊ុនអ៊ឹមភី.អេស្ស. ឌីវ៉ែលឡុបមិន | 009 L | THA & GS-EDC | ផ្សារព្រំ និងសាលាក្រៅ |
| ២ | ក្រុមហ៊ុនវណ្ណៈភាព ឌីវេឡុបមេន | 089 L | THAI-MSP & GS-EDC | ក្រុងប៉ៃលិន |

### ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធចែកចាយអគ្គិសនីនៅក្នុងខេត្តប៉ៃលិន

| ស្រុក/ខណ្ឌ | ស្ថិតិភូមិដែលមានសរុប | ដែននៃអាជ្ញាប័ណ្ណផ្តល់ | | បានសាងសង់បណ្តាញរួច | | ចំនួនភូមិដែលត្រូវសង់បណ្តាញថែម |
|---|---|---|---|---|---|---|
| | | ចំនួនភូមិ | %នៃភូមិសរុប | ចំនួនភូមិ | %នៃភូមិសរុប | |
| ប៉ៃលិន | 36 | 24 | 66.67% | 24 | 66.67% | 0 |
| សាលាក្រៅ | 43 | 31 | 72.09% | 18 | 41.86% | 13 |
| **សរុប** | **79** | **55** | **69.62%** | **42** | **53.16%** | **13** |

## ២.ថ្លៃអគ្គិសនីកំពុងអនុវត្ត និងផែនការបន្ថយថ្លៃអគ្គិសនីនៅខេត្តប៉ៃលិន

### ២-១.ថ្លៃលក់អគ្គិសនីកំពុងអនុវត្ត និងផែនការថ្លៃឆ្នាំ ២០១៥ នៅខេត្តប៉ៃលិន

ដោយសារតែស្ថានភាពផ្គត់ផ្គង់ប្រភពអគ្គិសនីដូចបានជម្រាបជូនខាងលើ នៅខេត្តប៉ៃលិន ត្រូវបានចាត់ទុកថា ឋិតនៅក្រៅវង្វង់នៃការផ្គត់ផ្គង់ប្រភពអគ្គិសនីរបស់បណ្តាញជាតិ ដូច្នេះនៅឆ្នាំ ២០១៥ នេះ តំបន់ផ្គត់ផ្គង់អគ្គិសនីនៅខេត្តប៉ៃលិន មានថ្លៃលក់ទៅតាមប្រភពអគ្គិសនី ដែលទទួលបាននៅតំបន់ចែកចាយនីមួយៗ ដូចខាងក្រោម ៖

### តំបន់ផ្សារព្រំ និងស្រុកសាលាក្រៅ របស់ក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន

តំបន់ចែកចាយអគ្គិសនីនៅតំបន់ផ្សារព្រំនិងស្រុកសាលាក្រៅ របស់ក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន បានទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសថៃ រួចមានថ្លៃជូនអ្នកប្រើប្រាស់ក្នុងតំបន់របស់ខ្លួន ដូចខាងក្រោម ៖

- លក់ឲ្យលំនៅដ្ឋាននៅតំបន់ក្បែរព្រំដែន (តំបន់ផ្សារព្រំ) ស្មើនឹង ៨,0 បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង
- លក់ឲ្យលំនៅដ្ឋាននៅតំបន់ឆ្ងាយៗ ក្នុងស្រុកសាលាស្រុក ដែលក្រុមហ៊ុនត្រូវវិនិយោគហេដ្ឋារចនាសម្ព័ន្ធបន្ថែមច្រើនទៀត ស្មើនឹង ៨,៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង
- លក់ឲ្យអ្នកប្រើប្រាស់ធំៗ ដូចជាកាស៊ីណូ និងរោងចក្រ ស្មើនឹង ៥,៨ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

### តំបន់ក្រុងប៉ៃលិន របស់ក្រុមហ៊ុន វណ្ណៈភាព ឌីវេឡុបមេន

តំបន់ចែកចាយនៅក្រុងប៉ៃលិន របស់ក្រុមហ៊ុន វណ្ណៈភាព ឌីវេឡុបមេន ដែលពីទិញប្រភពអគ្គិសនីបន្តពីក្រុមហ៊ុន អឹម.អេស្ស.ភី ឌីវេឡុបមេន ប៉ុន្តែបច្ចុប្បន្ន បានទិញប្រភពអគ្គិសនីបន្ថែមពីបណ្តាញបញ្ជូនរង ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជា បច្ចុប្បន្នមានថ្លៃលក់រាយជូនប្រជាពលរដ្ឋតែ ១ អត្រាប៉ុណ្ណោះ គឺ ៨,៥ បាត ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

នៅឆ្នាំ២០១៥ ដើម្បីធានាឲ្យមានស្ថេរភាព និងនិរន្តរភាពនៃអាជីវកម្មផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់ខេត្តប៉ៃលិន យើងគ្រោងរក្សាស្ថានភាពថ្លៃលក់អគ្គិសនីឲ្យនៅដដែល ដូចខាងលើនេះជាបណ្តោះអាសន្នសិន ដើម្បីទុកពេលវេលាពង្រីកប្រភពអគ្គិសនីពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា ទៅគ្របដណ្តប់ឲ្យបានច្រើនលើតំបន់នានា ក្នុងខេត្តប៉ៃលិន ។

## ២-២.ផែនការបន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅខេត្តប៉ៃលិន

ក្នុងគោលដៅដោះស្រាយបញ្ហាថ្លៃអគ្គិសនីនៅខេត្តប៉ៃលិន ឲ្យបានដូចតំបន់ដ៏ទៃទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលត្រូវការពេលវេលា ដើម្បីអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធបញ្ជូលប្រភពអគ្គិសនីនាំចូលពីប្រទេសថៃ និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ជាមួយគ្នាបន្ថែមទៀត ដើម្បីឲ្យថ្លៃលក់អគ្គិសនីនៅក្នុងខេត្តប៉ៃលិន ទាំងមូលអាចនឹងថយចុះតាមផែនការបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល ដូចតំបន់របស់សេវាករឯកជនដែលយកអគ្គិសនីពីប្រភពអគ្គិសនី របស់បណ្តាញជាតិដែរ។ ពិតមែនតែពេលវេលាក្នុងផែនការបានកំណត់ឲ្យការបន្ថយថ្លៃអគ្គិសនី តាមផែនការបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាលនឹងចាប់អនុវត្តពីខែ មីនា ឆ្នាំ ២០១៦ តទៅ ប៉ុន្តែការងារបន្ថយថ្លៃតាមតំបន់ចែកចាយនីមួយៗ នៅខេត្តប៉ៃលិន គឺអាស្រ័យនឹងពេលវេលានៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង និងខ្សែមេ ២២ គីឡូវ៉ុល របស់តំបន់ចែកចាយនីមួយៗ ដើម្បីរៀបចំ ឲ្យប្រភពអគ្គិសនីពីបណ្តាញជាតិគ្របដណ្តប់តំបន់ចែកចាយទាំងមូល ។ តាមផែនការ យើងគ្រោងរៀបចំសាងសង់ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង និងខ្សែមេ ២២ គីឡូវ៉ុល របស់អគ្គិសនីកម្ពុជាឲ្យទៅគ្របដណ្តប់តំបន់ទាំងនោះទាំងស្រុងនៅឆ្នាំ ២០១៧ រួចកំណត់ឲ្យការអនុវត្តផែនការបន្ថយថ្លៃអគ្គិសនីរបស់រាជរដ្ឋាភិបាល នឹងចាប់អនុវត្តនៅឆ្នាំ ២០១៧ នៅពេលដែលហេដ្ឋារចនាសម្ព័ន្ធទាំងនេះបានអភិវឌ្ឍន៍រួច រួចថ្លៃអគ្គិសនីនៅខេត្តប៉ៃលិន នឹងមានស្ថានភាព ដូចផែនការខាងក្រោម ៖

### ក.ការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ទិញ MV ពីបញ្ជូនរង EDC | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជា អាចកំណត់ថ្លៃទិញអគ្គិសនីដែលទិញក្នុងលក្ខខណ្ឌផ្សេងៗ ខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន។

### ខ.តំបន់ចែកចាយរបស់ក្រុមហ៊ុនឯកជនទាំង ២

ដូចបានជម្រាបជូនខាងលើ តាមផែនការរបស់រាជរដ្ឋាភិបាល អគ្គិសនីកម្ពុជានឹងរៀបចំការអភិវឌ្ឍន៍បណ្តាញបញ្ជូនរង ដើម្បីបញ្ជូនប្រភពអគ្គិសនីពីខេត្តបាត់ដំបង ទៅគ្របដណ្តប់តំបន់ចែកចាយរបស់សេវាករឯកជនទាំង ២ តំបន់នៅក្នុងខេត្តប៉ៃលិន ។ តំបន់ចែកចាយរបស់សេវាករឯកជនទាំង ២ តំបន់ ដែលនឹងទទួលប្រភពអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា នឹងមានផែនការបន្ថយថ្លៃ ដូចខាងក្រោម ៖

<u>**សម្រាប់ឧស្សាហកម្ម និងពាណិជ្ជកម្មធំៗ**</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ទិញMVពីខ្សែ MV របស់តំបន់ចែកចាយ | 0.165$/kWh | 0.164$/kWh | 0.163$/kWh | 0.162$/kWh |

<u>**កំណត់សំគាល់**</u> ៖ លើមូលដ្ឋាននៃផែនការនេះ អាជ្ញាធរអគ្គិសនីកម្ពុជាអាចកំណត់ថ្លៃទិញអគ្គិសនី ដែលទិញក្នុងលក្ខខណ្ឌផ្សេងៗខុសពីលក្ខខណ្ឌទូទៅបាន ប៉ុន្តែត្រូវយកអត្រាខាងលើជាមូលដ្ឋាន ។

<u>**សម្រាប់លំនៅដ្ឋានទូទៅ**</u>

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
|---|---|---|---|---|
| ទិញពីបណ្តាញសាធារណៈ | ៧៩០៛/kWh | ៧៧០៛/kWh | ៧៦០៛/kWh | ៧៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់លំនៅដ្ឋានក្រីក្រ ផ្ទះជួលតូចៗ ដែលមានចំណូលទាប ប្រើក្រោម១0kWh/ខែ

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

ថ្លៃអនុគ្រោះសម្រាប់ប្រើប្រាស់បូមទឹកធ្វើកសិកម្មដែលប្រើពីម៉ោង ៩ យប់ ដល់ម៉ោង ៧ ព្រឹក

| ប្រភេទនៃការទិញ | ឆ្នាំ ២០១៧ | ឆ្នាំ ២០១៨ | ឆ្នាំ ២០១៩ | ឆ្នាំ ២០២០ |
| --- | --- | --- | --- | --- |
| ទិញពីបណ្តាញសាធារណៈ | ៤៧៤៛/kWh | ៤៦២៛/kWh | ៤៥៦៛/kWh | ៤៥០៛/kWh |

* * * * * * * * *